កម្រងទស្សនៈ មាគ៌ាភ្លឺ

# ព្រះសាស្តា

## PREAH SASSDA



សច្ចៈធម៌ ពោធិញ្ញាណ ស្ថាបត្យកម្ម

Truth Enlightenment Architecture

ស្រាវជ្រាវ និងរៀបរៀង ប៊ុន ណ

គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ
Editions Angkor

ភ្នំពេញ

ព.ស. ២៥៥៤ គ.ស. ២០១០

ព្រះសាស្តា PREAH SASSDA
គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ

www.elibraryofcambodia.org

ទទួលការយល់ព្រមពីលោក ឡៅ ឈុនសុីវ៉ុន ដល់ការណាខ្មែរ
ដើម្បីទុកដាក់ក្នុង elibrary of Cambodia

៩ សកា ២០១៥

**កម្រងទស្សនៈ** **មាគ៌ាភ្លឺស្វាង**

**Braid of Viewpoint** **Lightened Path**

# ព្រះសាស្តា

# PREAH SASSDA

## Holy Logician

**សច្ចៈធម៌** **ពោធិញ្ញាណ** **ស្ថាបត្យកម្ម**

Truth Enlightenment Architecture


ស្រាវជ្រាវ និងរៀបរៀងដោយ **ប៊ុន ណារ៉ាវត្ត** នៅរដ្ឋ Massachusetts, U.S.A

ឧត្តមប្រឹក្សាកិត្តិយស **ព្រះគ្រូ សមុដ្ឋត្ថេរ ឯល ទ៊ា** ចៅអធិការវត្តត្រពាំងព្រះ ( កម្ពុជា )

ឧត្តមប្រឹក្សា **ព្រះគ្រូ ឥន្ទធីរោ ម៉ុម សារ៉េន** គ្រូសូត្រស្តាំវត្តត្រពាំងព្រះ ( កម្ពុជា )

ឧត្តមប្រឹក្សា **ព្រះគ្រូ ឥន្ទជោតិបញ្ញោ មាន ចន្ទ្រា** នៅសហរដ្ឋអាមេរិក

ឧត្តមប្រឹក្សា **ព្រះភិក្ខុ វិនយបញ្ញោ គ្រួច អ៊ឹម** នៅសហរដ្ឋអាមេរិក

ក្រាហ្វិក កំព្យូទ័រ ដោយ **រ័ត្ន ទារណ្ណា** នៅសហរដ្ឋអាមេរិក



បោះពុម្ពដោយ លោក **សៅ ម៉េងឡុង** បណ្ណាគារ **អង្គរ** ( **ភ្នំពេញ** )

បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

រៀបចំបោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ**

*Editions* Angkor

គ.ស ២០១០ ព.ស ២៥៥៤

ភ្នំពេញ



www.elibraryofcambodia.org

រក្សាសិទ្ធិ

**គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ**

*Editions* Angkor

ISBN : 13-99950-2-136-8

បោះនៅរោងពុម្ព **ម៉េង ហាន**

ភ្នំពេញ

www.elibraryofcambodia.org

# ព្រះពុទ្ធសមណគោត្តម



ថ្ងៃដែលព្រះអង្គត្រាស់ដឹង ក្នុងព្រះជន្ម ៣៥ ព្រះវស្សា គឺជាថ្ងៃដែលមានពន្លឺ ចែងចាំងដោយព្រះធម៌របស់ព្រះអង្គ បានដឹកនាំចម្លងមនុស្ស សត្វលោក អោយដើរលើផ្លូវ ភ្លឺថ្លា ស្រឡះនៃខ្សែជីវិត ចាកផុតពីពិភពអន្ធកាល ។

www.elibraryofcambodia.org

# មាតិកា (Contents)



| ជំពូក | វគ្គ | ចំណងជើង (Title) | ទំព័រ |
|---|---|---|---|
| | | អារម្ភកថា (Preface) | ៥ |
| | | ប្រារព្ធន័យ (Initiate Meaning) | ៧ |
| ជំពូក១ | ១ | ព្រះត្រៃបិតក (Tripitaka) | ១១ |
| | ២ | ព្រះពុទ្ធសាសនាមកកាន់ទូទាំងទ្វីបអាស៊ី (Transmission routes of Buddhism to Asia) | ១៥ |
| | ៣ | ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា (Buddhism History into the Khmer Kingdom) | ១៩ |
| | ៤ | ឧបទ្វីបឥណ្ឌាមុនសម័យពុទ្ធកាល (Ancient India before the time of the Buddha) | ២១ |
| | ៥ | សម័យអរិយក (Aryans Empire Time) | ២៤ |
| | ៦ | ព្រះពោធិសត្វ (Budhisattva) | ២៨ |
| ជំពូក២ | ១ | រឿង សុមេធបណ្ឌិត (Legendary Sumedhura) | ៣៣ |
| | ២ | ព្រះញ្ញាត្តិវង្សរបស់ព្រះសាស្តា (The Royal Familyof Preah Sassda) | ៤២ |
| | ៣ | ព្រះបាទសុទ្ធោទនៈ និងព្រះនាងមហាមាយា (King Sudhodana and his wife Mayamaya) | ៤៥ |
| | ៤ | ព្រះនាងបជាបតី (Princess Prajapati) | ៤៩ |
| | ៥ | ព្រះជាយាសុបិននិមិត្ត (Maya's dream that appears to have impact on reality) | ៥១ |
| | ៦ | ព្រះសាស្តាទ្រង់ប្រសូត្រ (Born Gautama Buddha) | ៥៤ |
| | ៧ | ការព្យាករណ៍ដល់រាជកុមារ (Prediction to Prince Siddhartha) | ៥៧ |
| | ៨ | រាជកុមារទាំង៣ | ៦១ |



www.elibraryofcambodia.org

| | | | |
|---|---|---|---|
| | | (Three young cousin brothers of Siddhartha) | |
| | ៩ | អភូតហេតុចំលែក (Strang miracle) | ៦៤ |
| | ១០ | គ្រូវិស្វាមិត្រ (Sage-Visvamitta) | ៦៦ |
| | ១១ | មហាប្រាសាទទាំង៣ (The three splendid palaces) | ៦៩ |
| | ១២ | រាជាភិសេកព្រះសិទ្ធត្ថ (Coronation to Prince Siddhartha) | ៧១ |
| | ១៣ | ទេវទូតទាំង៤ (Four divine messenger) | ៧៣ |
| | ១៤ | ទ្រង់ចេញសាងព្រះផ្នួស (Departure of Siddhartha to Priesthood) | ៧៧ |
| | ១៥ | ថ្ងៃព្រះសិទ្ធត្ថព្រះផ្នួស (Priesthood time of Siddhartha) | ៨១ |
| | ១៦ | បញ្ចវគ្គិយតាបស (Five Sramanas) | ៨៣ |
| | ១៧ | ព្រះបាទ ពិម្ពិសាររាជ (King Pimbisara) | ៨៥ |
| | ១៨ | សង្គ្រោះសត្វ (Rescue any kinds of creature in danger) | ៨៨ |
| | ១៩ | អាឡ្ឡាកាលោមគោត្រ និងឧទករាមបុត្រ (Sage-Alakalamkutra and Sage-Udraka Ramaputra) | ៩១ |
| | ២០ | ព្រះសាស្តាធ្វើទុក្កិរិយា (Practice asceticism of Siddhartha) | ៩៣ |
| | ២១ | នាងសុជាតា (Sujata) | ៩៨ |
| | ២២ | ទ្រង់ផ្ចាញ់មារ (Vanquish over the armed devil force) | ១០២ |
| | ២៣ | ថ្ងៃព្រះអង្គត្រាស់ដឹង (Attained day of the Enlightenment) | ១០៦ |
| | ២៤ | ទីបរិស្ថានដែលទ្រង់និមន្ត (Journey of Gautama toward the different places) | ១០៩ |
| | ២៥ | ធីតាមាររំខាន (Distraction of Princess Phantoms to Gautama) | ១១១ |


www.elibraryofcambodia.org

| | | | |
|---|---|---|---|
| | ២៦ | ព្រាហ្មណ៍ចិត្តបាប (Malevolent Brahmana) | ១១៣ |
| | ២៧ | ទ្រង់តាក់តែងព្រះត្រៃបិតក (Compose Tripitaka) | ១១៥ |
| | ២៨ | ប្រោសសហម្បតីព្រហ្ម (Majestic to Brahma Sahamapata) | ១១៨ |
| | ២៩ | ប្រោសបញ្ចវគ្គីយ (Majestic to five Sramanas) | ១២១ |
| | ៣០ | យសបព្វជា (Yasas to become Buddist Monk) | ១២៥ |
| | ៣១ | មិត្តរួមបព្វជា (Best friends of Yasathera) | ១២៨ |
| | ៣២ | ផ្សព្វផ្សាយព្រះពុទ្ធសាសនា (The declaration of the Buddhism) | ១៣១ |
| | ៣៣ | កស្សបសាវ័ក (Kasyapa disciple) | ១៣៣ |
| | ៣៤ | និមន្តចូលក្រុងរាជគ្រឹះ (Gautama goes to Ratnagiri) | ១៣៥ |
| | ៣៥ | កិច្ចប្រតិបត្តិ ៦ប្រការ (Six practices of the solute) | ១៣៧ |
| | ៣៦ | ព្រះសារីបុត្រ និងព្រះមោគ្គលាន (Sariputa and Maudgalyayana) | ១៤១ |
| | ៣៧ | ចតុរង្គសន្និបាត (Four-Principle Conference) | ១៤៦ |
| | ៣៨ | អង្គុលីមារ (Angulimala) | ១៤៨ |
| | ៣៩ | ទ្រង់និមន្តចូលមាតុភូមិ (Returning of Buddha to Kapilavastu) | ១៥១ |
| | ៤០ | ពិម្ពាពិលាប (Sobbing of Gautama's wife) | ១៥៦ |
| | ៤១ | ព្រះនន្ទ ព្រះរាហុល និងសក្យទ្រង់បព្វជា (Nanda, Rahula and Sakya princes to become disciples) | ១៥៩ |
| | ៤២ | ព្រះអនុរុទ្ធ និងមហាអានន្ទ (Anirudha and Maha Anada) | ១៦២ |
| | ៤៣ | ព្រះពុទ្ធបិតា ទ្រង់ប្រឈួន (Serious illness of Gautama's Father) | ១៦៤ |
| | ៤៤ | ព្រះមាតាចិញ្ចឹមសុំបព្វជា | ១៦៧ |


www.elibraryofcambodia.org

| | | | |
|---|---|---|---|
| | | (Nursed Maha Prajapati to become nun) | |
| | ៤៥ | ចិត្តទេវទត្ត មាត់ទេវត្តា (An angel's mouth but an evil heart) (Wolf in sheep's clothing) | ១៧១ |
| | ៤៦ | ព្រះគុណណូបការៈ (The goodness of Gautama Buddha, duration 45 years of his duties) | ១៧៩ |
| | ៤៧ | ដាក់ព្រះជន្មសង្ខា (Limit of Gautama Buddha's life) | ១៨៣ |
| | ៤៨ | ពុទ្ធឱវាទសំខាន់ៗដល់ភិក្ខុសង្ឃ (Important instruction of Gautama Buddha for the Buddhist Monks) | ១៨៨ |
| | ៤៩ | ក្រុងវេសាលីចុងក្រោយ (A final look at the the city of Vashali) | ១៩០ |
| | ៥០ | ព្រះសាស្តាទ្រង់ប្រឈួនជាទម្ងន់ (Gautama Buddha was in serious ill while traveling to Kushinagara) | ១៩២ |
| | ៥១ | បុកុសរាជទាយាទ (Prince Pukusa) | ១៩៤ |
| | ៥២ | អានន្ទវិយោគ (Sobbing of Ananda) | ១៩៦ |
| | ៥៣ | អានន្ទត្រូវបានលើកសរសើរ (Gautama praised Ananda) | ១៩៩ |
| | ៥៤ | សុភទ្ទបច្ឆិមភិក្ខុ (Subhadra last a Bhikkhu) | ២០២ |
| | ៥៥ | ទ្រង់សម្រេចបរិនិព្វាន (To achieve Nirvana) | ២០៥ |
| | ៥៦ | ពិធីថ្វាយព្រះភ្លើង (Cremation ceremony) | ២០៧ |
| | ៥៧ | ចែកព្រះសារីរិកធាតុ (To divide the Buddha's bone) | ២១០ |
| ជំពូក៣ | ១ | អំពីប្រភេទចេតិយនៃព្រះបរមគ្រូនៃយើង | ២១៣ |
| | ២ | អំពីការប្រព្រឹត្តព្រះធម៌វិន័យ (Buddhist council to discuse and verify the accuracy of the Dharma) | ២១៥ |
| | ៣ | ព្រះធម៌ជាទស្សនៈវិជ្ជា? (Is Dharma a Philosophy?) | ២១៩ |
| | | ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធ | ២២៦ |


www.elibraryofcambodia.org

# អារម្ភកថា
(Preface)

ក្នុងការជ្រួតជ្រាបនៃព្រះពុទ្ធសាសនា និងព្រះធម៌ឱវាទដ៏ឧត្តមពុទ្ធសាសនិកជនខ្មែរយើង គួរមើល គួរអានសៀវភៅដែលនិយាយពីរឿង **ព្រះសម្មាសម្ពុទ្ធ** ច្រើនកាលណា គង់មានការគាប់ប្រសើរជាក់ជាមិនខាន ទោះបីជាសៀវភៅប្រភេទណាក៏ដោយ អាចជាគំរូមេរៀនក្នុងការកសាងដំណើរជីវិតអោយស្ថិតនៅភាពរុងរឿងបាន ។

ខ្ញុំករុណា ខ្ញុំបាទមិនបានបួសរៀននៅសាលាវត្តណាមួយឡើយ តែខ្ញុំករុណា ខ្ញុំបាទធ្លាប់បានស្នាក់អាស្រ័យនៅវត្ត បំរើព្រះគ្រូចៅអធិការជាច្រើនអង្គ រយៈពេលទាំងនោះ ខ្ញុំករុណា ខ្ញុំបាទតែងបានអានសៀវភៅព្រះពុទ្ធសាសនា ដែលជាស្នាដៃព្រះគ្រូភិក្ខុជាច្រើនអង្គ និងអ្នកនិពន្ធរៀមច្បងជាច្រើននាក់ ធ្វើអោយខ្ញុំករុណា ខ្ញុំបាទចងចាំ និងមានគំនិតចងក្រង សៀវភៅពុទ្ធនិទាននេះឡើង ។

សៀវភៅមានចំណងជើង **ព្រះសាស្តា** នេះ បានចំណាយពេលអស់ជាច្រើនឆ្នាំ ទើបសម្រាប់បានជារូបរាង ហើយរៀបរៀងចែកចេញ ជា ៣ ជំពូក និងវគ្គជាច្រើនៈ

**ជំពូក ១៖ និយាយអំពីប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនា**

**ជំពូក ២៖ ជីវប្រវត្តិព្រះពុទ្ធបរមគ្រូ**

**ជំពូក ៣៖ ទស្សនៈពុទ្ធនិយម**

ក្នុងនេះទៀតសោត ជាសៀវភៅដែលខិតខំចងក្រងឡើង អោយទាន់បែបសម័យនិយម Computer ប្រមូលផ្តុំគ្រប់អត្ថន័យ ទស្សនៈប្រពៃៗ ជំនួយដល់ស្មារតី អស់លោកអ្នកអាន និងយុវវ័យ កុលបុត្រធម្មវិន័យ អោយកាន់តែយល់ដឹង

www.elibraryofcambodia.org

និងបន្ថែមសៀវភៅប្រភេទនេះ ដើម្បីទុកបំរើជាផលប្រយោជន៍ក្នុងព្រះពុទ្ធសាសនា និងរួមចំណែកលើកស្ទួយអក្សរសាស្ត្រជាតិខ្មែរយើង អោយនៅស្ថិតស្ថេរចិរកាល ។

ក្នុងសៀវភៅនេះ មានបញ្ចូលពាក្យអង់គ្លេសខ្លះៗ តាមវគ្គនិមួយៗ ដូចជា ឈ្មោះមនុស្ស ទីកន្លែងជាដើម ព្រោះតម្រូវការត្រូវតែមានបញ្ចូលបែបនេះ ។ ដូច្នេះបើមានខុសឆ្គងដោយប្រការណាជាយថាហេតុ (eventual) សូមមេត្តាខន្តីអភ័យទោសដោយចិត្តជាធម្មទាន សូមជៀសវាងអោយផុតពីអំពើហិង្សាផងទាំងពួង ដោយចិត្តអធ្យាស្រ័យគ្នាទៅវិញទៅមក រស់នៅក្នុងសុខសន្តិភាព ។

ធ្វើនៅថ្ងៃទី ៣០ ខែ ធ្នូ គ.ស ២០០៧
ត្រូវនឹងថ្ងៃ៦រោច ខែមិគសិរ ឆ្នាំកុរ ព.ស. ២៥៥១
នៅក្រុង Boston រដ្ឋ Massachussetts, សហរដ្ឋអាមេរិក

*អ្នកស្រាវជ្រាវ និង រៀបរៀង*
**ប៊ុន ណារ៉ាត្ន**
Email: narathresearcher@yahoo.com

www.elibraryofcambodia.org

# ប្រាជ្ញន័យ

(Initiate Meaning)

**ព្រះសាស្តា** Preah Sassda (Holy Philosopher) ជាព្រះបរមនាម នៃ **ព្រះសម្មាសម្ពុទ្ធ** ជាម្ចាស់ ដែលពួកអ្នកប្រាជ្ញបណ្ឌិត កវីទាំងឡាយបានហៅ ក្រោយពីពួកគេបានស្វែងយល់ច្បាស់ពីប្រវត្តិសាសនារបស់ព្រះអង្គ ក្នុងព្រះនាម នេះមានន័យថា: **ព្រះបរមសាស្ត្រាចារ្យ** (The Great Teacher) បើសម័យ នេះងាយហៅគឺសាស្ត្រាចារ្យ (Professor) ។ សាស្ត្រាចារ្យជាអ្នកមានចំណេះ ខាងបង្រៀន (ជាគ្រូ) បង្ហាត់បង្ហាញពីមុខវិជ្ជាផ្សេងៗ។

ក្នុងមុខវិជ្ជាព្រះពុទ្ធសាសនា មានមូលដ្ឋាន (Basic) ធំ ៣ គឺ: ១. **សីលសម្បត្តិ:** (ការប្រកាន់ភ្ជាប់នៅគុណធម៌ទាំងឡាយ) (Virtue Behavior) នាំមកនូវ ជីវិតទទួលបាននូវកិត្តិយសឈ្មោះប្រពៃ ដូចរស្មីព្រះអាទិត្យដែលផ្តល់ផលប្រ យោជន៍ដល់ធម្មជាតិផងទាំងពួង អោយរីកស្រស់បំព្រងបាន។ បើគ្មានគុណធម៌ ប្រៀបបានដូចគ្មានពន្លឺថ្ងៃ ជីវិតធម្មជាតិទាំងឡាយនឹងអួអាប់ ក្រឡាប់ចាក់ គ្មាន ទីស្រស់បំព្រងសោះឡើយ។ ២. **សម្មាបត្តិ:** (ការគ្រប់គ្រងផ្លូវចិត្ត) (Mental Concentration) ក្នុងជីវិតស្ថិតក្នុងទីស្ងប់ស្ងាត់ ធ្វើភាវនាកម្មដ្ឋាន ស្មឹងស្មាធិ៍ ប្រមូលអារម្មណ៍គ្រប់គ្រងផ្លូវចិត្ត រំងាប់ចោលចេញភាពមន្ទិលសង្ស័យទាំងពួង និង អពមង្គលទាំងឡាយបាន នោះជីវិតនឹងផ្តល់គ្រប់យ៉ាង នូវភាពសុខដុមរម្យនាជា ប្រាកដ។ ៣. **បញ្ញាបត្តិ:** (គតិបណ្ឌិត ភាពឆ្លាតវៃ រំពៃហេតុការណ៍សច្ចៈភាព) (Good deed highest consideration, wise) ការពិចារណារកហេតុផលវែង ឆ្ងាយ គឺជាគតិបណ្ឌិត ដែលជាមធ្យោបាយដោះស្រាយ គ្រប់ទំនាស់អវិជ្ជាផង រាំរះឡោយ ជ័យជំនះ និងក្តីរុងរឿង នឹងមានជាក់ក្នុងសច្ចៈធម៌នេះ។

www.elibraryofcambodia.org

ការប្រតិបត្តិទាំងអស់នេះ ជាមេរៀនគំរូ ក្នុងការស្កាប់នាកម្លាំងចិត្ត។ **ព្រះសម្មាសម្ពុទ្ធ** ជាសាស្ត្រាចារ្យបណ្តុះកម្លាំងចិត្តដល់សាវ័កព្រះអង្គ អោយចេះទីពឹងខ្លួនឯង (Self Dedendent) ដើម្បីរួចចាកភ័យខ្លួនឯង (Self rescue) ជាវិជ្ជាដាស់តឿនអោយយល់សច្ចៈភាព (True) បរិសុទ្ធ និងមិនបរិសុទ្ធ ស្រេចលើបុគ្គលម្នាក់ៗ។ ក្នុងគម្ពីធម្មបទ **ព្រះពុទ្ធ** ទ្រង់សម្តែងថាៈ បុគ្គលទាំងឡាយគួរធ្វើការអោយបានសម្រាប់ដោយខ្លួនឯង (Being should be done self work) តថាគតគ្រាន់តែបង្ហាញផ្លូវប៉ុណ្ណោះ។

www.elibraryofcambodia.org

# ព្រះរតនត្រ័យៈ

(The three most important:
1- The Buddha, 2- Holy law Dharma, 3- Buddhist monk)

<u>មានដូចខាងក្រោមនេះ:</u>


ព្រះពុទ្ធបដិមានៅតាមវត្តអារាមនៃប្រទេសកម្ពុជា
ជាកន្លែងគោរពបូជារបស់ប្រជាពលរដ្ឋខ្មែរ

**ព្រះពុទ្ធ:** ទ្រង់បានត្រាស់ដឹងពោធិញ្ញាណ និងផ្លូវសច្ចៈធម៌ (ធម៌បង្ហាញសេចក្តីពិត) ដោយបានប្រៀនប្រដៅសព្វសត្វលោកទៅរកផ្លូវល្អ ដើម្បីសេចក្តីសុខសាន្ត។

**ព្រះធម៌:** ជាក្បួនច្បាប់បង្ហាញពីផ្លូវត្រឹមត្រូវ ជាគុណធម៌ល្អបរិសុទ្ធ សម្រាប់អោយមនុស្សលោកទាំងពួងគោរព និងប្រតិបត្តិ។

**ព្រះសង្ឃ:** ជាអង្គសាវ័ក ជាអ្នកគោរពប្រតិបត្តិតាមព្រះធម៌តាមពុទ្ធឱវាទ និងធ្វើអោយមនុស្សទាំងឡាយ គោរពប្រតិបត្តិដូចព្រះអង្គសង្ឃសាវ័កដែរ។

សេចក្តីនមស្សការចំពោះព្រះរតនត្រ័យ មានន័យថាគោរពនូវអ្វី ដែលជាតំណាងព្រះពុទ្ធ (ព្រះបដិមា) (The Buddha's statue) ឯការបូជាទៀន ធូបផ្កាភ្ញី (Sacrifice for Buddha) ថ្វាយដល់ព្រះពុទ្ធរូប គឺជាការផ្សងឧទ្ទិស នូវភាពដឹងគុណ ចំពោះចិត្តមេត្តាករុណាបញ្ញាដ៏ឧត្តមរបស់ព្រះអង្គ ដែលបានធ្វើអោយមានប្រយោជន៍សម្រាប់មនុស្សលោកទាំងមូល។ ដូច្នេះទើបពុទ្ធសាសនិកជន តែងបំពេញតាវកិច្ចទាំងនេះដោយខានមិនបាន ការសំដែងនូវកតញ្ញូតាធម៌ (Gratitude) ក្នុងកិច្ចតបស្នងសងគុណចំពោះព្រះអង្គ។

www.elibraryofcambodia.org

ការគោរពបូជាខាងលើ ជាឆន្ទៈមួយដែលផុសចេញមកដោយសុទ្ធចិត្តឯកឯង ជាវិចារណញ្ញាណមួយ (Reasoning Power) ប្រកបដោយសម្មាទិដ្ឋិ (correct viewing) ដោយស្វ័យប្រវត្តិ គឺជាទឹកចិត្តជ្រះថ្លា ត្រូវបំពេញដោយខានមិនបាន ។

ចំពោះសៀវភៅ **ព្រះសារស្តារ** នៅពេលនេះ ក៏មានន័យទាក់ទងដូចការរៀបរាប់ខាងលើនេះដែរ គ្រាន់តែលក្ខណៈសៀវភៅនេះ ចង់បង្ហាញសុឆន្ទៈនៃទស្សនៈពុទ្ធនិយមមួយចំនួន និងប្រវត្តិសាស្ត្រនៃការវិវត្តន៍របស់ព្រះពុទ្ធសាសនានៃយើង និងរឿងរ៉ាវពុទ្ធនិទានរបស់ព្រះអង្គ ដែលខ្ញុំករុណាខ្ញុំបាទខិតខំស្រាវជ្រាវក្បួនខ្នាតខ្មែរយើងដែលបាននិទាន (Legend) ដោយបន្សល់ទុកតាមវត្តអារាម មានជាផ្ទាំងគំនូរ ជាសាស្ត្រាស្លឹករឹតជាដើម ថែមមានសាច់រឿងខ្លះរបស់ឥណ្ឌាផងដែរ ។ ទាំងនេះជាការរួមផ្សំដើម្បីអោយអ្នកអានជក់ចិត្តផ្ចិតអារម្មណ៍ យ៉ាងហោចណាស់ក៏ស្គាល់ពីគុណប្រយោជន៍នៃព្រះពុទ្ធសាសនា និងជាបទពិសោធន៍ក្នុងផ្លូវដ៏ត្រឹមត្រូវ សម្រាប់ជីវិតរស់នៅ ។

**ប៊ុន ណារ័ត្ន**



**ប៊ុន ណារ័ត្ន** ធ្វើជាងជាត់ពណ៌នៅវត្ត Stockton, CA (1995)

www.elibraryofcambodia.org

# ជំពូក ១

## វគ្គទី១

## ព្រះត្រៃបិតក[១] (Tripitaka)

## (Collecltions of Buddhist sacred writings)

ក្រោយពុទ្ធបរិនិព្វាន ព្រះអរិយសាវ័កជាច្រើនអង្គបានធ្វើកិច្ចសង្គាយនា[២] (Buddhist Monk Convention) ដើម្បីរក្សាព្រះធម៌ជាពុទ្ធវចនៈ (The words of the Buddha) តៗគ្នាពីជំនាន់មួយទៅជំនាន់មួយ រហូតដល់សព្វថ្ងៃ។ ក្រោយមកប្រមាណជាង ៥០០ ឆ្នាំ គេបានរកឃើញពុទ្ធវចនៈ ភាគច្រើននៅកោះស្រីលង្កា (Sri Lanka)។ **កោះស្រីលង្កា** ស្ថិតនៅទិសអាគ្នេយ៍ប្រទេសឥណ្ឌា ទីនោះគឺជាឃ្លាំងផ្ទុកគម្ពីដីកាជាច្រើន ដែលនិទានពីរឿងរ៉ាវ **ព្រះពុទ្ធ** ហើយជាទីកន្លែងដើម ដែលសាវ័កទាំងឡាយបានធ្វើ **កិច្ចសង្គាយនា**។

រឿងរ៉ាវ **ព្រះពុទ្ធបរមគ្រូ** នៃយើង ត្រូវបានប្រជាជាតិអាស៊ី ដែលជាពុទ្ធសាសនិកជន មានជាអាទិ៍បណ្ដាប្រទេសធំៗ ដូចជា ចិន ឥណ្ឌា ជប៉ុន កូរ៉េ ស្រីលង្កា។ល។ សុទ្ធតែយករឿងរ៉ាវព្រះអង្គមកចងក្រងជារឿង ជាសៀវភៅ ជាខ្សែភាពយន្តព្រោងព្រាតពេញទាំងទ្វីបអាស៊ី។ រឿងនិទានព្រះអង្គ ត្រូវបានគេស្រង់ចេញពីព្រះត្រៃបិតក។ **ព្រះត្រៃបិតក** ជាគម្ពីធំជាងគេ ក្នុងក្បួនព្រះពុទ្ធ

---

[១] ត្រៃបិតក = ត្រ័យបិដក. ត្រ័យ = ត្រៃ = ត្រី : បី។

[២] សូមអានទៅទំព័រចុងបញ្ចប់ មានការបង្ហាញពីកិច្ចសង្គាយនាធំទាំង៥។

www.elibraryofcambodia.org

សាសនា។ ប្រទេសខ្មែរយើងក៏បានសិក្សាស្រាវជ្រាវតាមគម្ពីព្រះត្រៃបិតកនេះដែរ ថែមទាំងគម្ពីរដីកាជាច្រើនផ្សំគ្នា គឺមានតំណាតតាំងពីយូរលង់ណាស់មកហើយ។

គម្ពីរ **ព្រះត្រៃបិតក** មានផ្ទុកឃ្លាំងធំ ៣ គឺ: ១. **គម្ពីរព្រះសូត្រ** ឬ **ព្រះសុត្តន្តបិតក** (The Sutra) មានចំនួន ២១000 ធម្មក្ខន្ធ(Dhammakhada)។ ២. **គម្ពីរព្រះវិន័យបិតក** (Vinaya Pitaka) មានចំនួន ២១000 ធម្មក្ខន្ធ។ ៣. **គម្ពីរព្រះអភិធម្មបិតក** (The Abhidhamma Pitaka) មានចំនួន ៤២000 ធម្មក្ខន្ធ សរុបទាំងអស់ក្នុងឃ្លាំងទាំង ៣ មានចំនួន ៨៤000 ធម្មក្ខន្ធ។ ឃ្លាំងនិមួយៗចែកចេញជាសៀវភៅមានចំនួនដូចតទៅ: **ព្រះសូត្រ** មានចំនួន ៦៣ សៀវភៅ។ **ព្រះវិន័យ** មានចំនួន ១៣ សៀវភៅ។ **ព្រះអភិធម្ម** មានចំនួន ៣៤ សៀវភៅ។ ចំណែកអត្ថន័យខ្លឹមសារនៅក្នុង **គម្ពីរបិតក** និមួយៗ មានលក្ខណៈផ្សេងៗដាច់ពីគ្នាគឺ:

**ព្រះសូត្រ:** ជាធម៌មានលក្ខណៈវោហាស័ព្ទ ដែលសម្តែងឡើងដូចជាធម្មទេសនាជាដើម ជាកិច្ចដែល **ព្រះពុទ្ធបរមគ្រូ** ទ្រង់សំដែងឡើង នៅទីកន្លែងផ្សេងៗ ក្នុងសម័យពុទ្ធកាលដែលព្រះអង្គគង់នៅ។ ធម៌ព្រះសូត្រ ឬសុត្តន្តបិតកនេះ មានរឿងរ៉ាវជាច្រើនរបស់ព្រះអគ្គសាវ័កព្រះអង្គដូចជា **ព្រះមោគ្គលាន ព្រះកស្សប ព្រះអនុរុទ្ធ មហាអានន្ទ** និងសាវ័កដ៏ទៃជាច្រើនអង្គ ព្រមទាំងរឿង **ជាតក** (Mativity) ផ្សេងៗ ដែលទាក់ទងនិងជាតិកំណើតនិមួយៗរបស់បុគ្គល ឧបនិស្ស័យកាលពីសម័យបុព្វេសន្និវាស (Conjugal relation which existed in a previous life)។

www.elibraryofcambodia.org

**ព្រះវិន័យបិតក:** ជាធម៌សម្តែងពីក្រិត្យក្រម ច្បាប់វិន័យផ្សេងៗ ដែលព្រះបរមគ្រូព្រះអង្គបានពាក់តែងឡើងជាបញ្ញត្តិទុកអនុវត្តន៍ និងប្រតិបត្តិក្នុងផ្លូវព្រះពុទ្ធសាសនារបស់ព្រះអង្គតរៀងមក។

**ព្រះអភិធម្មបិតក:** ជាធម៌សុខុមរមនាជ្រាលជ្រៅជាទីបំផុត ដែលទាក់ទងនឹងទស្សនវិជ្ជា គឺជាកំពូលធម៌ដែលអប់រំផ្លូវចិត្ត អោយស្ថិតក្នុងក្តីបរិសុទ្ធផូរផង់។



ទ្រង់ស្រង់ទឹក ( ស្រង់ចេញពីវត្តសំរោងអណ្តែត ក្រុងភ្នំពេញ ប្រទេសកម្ពុជា)

នៅក្នុងរាជ្យព្រះបាទ **ស៊ីសុវត្ថិមុនីវង្ស**[៣] ក្រុមជំនុំ **ប្រែព្រះត្រៃបិតក** ត្រូវបានបង្កើតឡើងនៅ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ១៩២៩ គម្ពីរបិតកធំ ទាំង៣ គឺព្រះវិន័យ ព្រះសុត្តន្ត ព្រះអភិធម្ម ត្រូវបានប្រែចប់សព្វ គ្រប់ ហើយទុកប្រើមកទល់សព្វថ្ងៃ សរុបសៀវភៅទាំងអស់មាន ១១០ ក្បាល។ ចំណែក **វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត** ក៏ត្រូវបានបង្កើតឡើងក្នុងរាជ្យព្រះអង្គដែរ គឺនៅឆ្នាំ ១៩៣០ ព្រមទាំងសាលាបាលីសម្រាប់ព្រះសង្ឃសិក្សាប្រកបដោយការបង្រៀនបែបសម័យទំនើបទៀតផង។

គ្រប់ប្រទេសដែលកាន់ព្រះពុទ្ធសាសនាបានចម្លងបកប្រែគម្ពីរ **ព្រះត្រៃបិតក** តាមភាសាអក្សរសាស្ត្ររបស់ជាតិខ្លួនឯងរៀងៗខ្លួន ហើយតម្កល់ទុកក្នុងមន្ទីរសាស្ត្រា បណ្ណាល័យ គម្ពីរដីកាផ្អែកព្រះពុទ្ធសាសនាប្រចាំប្រទេសរបស់ខ្លួន។ **ព្រះត្រៃបិតក** បានចូលមកស្រុកខ្មែរយើងក្នុង គ.ស. ៦៥៦ ព.ស. ១២០០ ក្នុងរជ្ជ

[៣] ពាក្យសៀវភៅ ប្រវត្តិសាស្ត្រខ្មែរភាគ ២ [illegible] ត្រីខ ១ [illegible] ១៩៧[illegible] ។

www.elibraryofcambodia.org

កាលព្រះបាទ **បទុមសុរិយវង្ស**[៤] ។ កាលនោះមានសំពៅមួយគ្រឿងត្រូវព្យុះបោកបក់បានរសាត់មកកៀងទើរនៅកោះ **ឫស្សីកែវ** ។ ក្នុងសំពៅនោះមាន គម្ពីរ **ព្រះត្រៃបិតក** (សុទ្ធតែជាភាសាបាលី) និងព្រះពុទ្ធរូបព្រះកែវមរកត ។ ព្រះបាទ **បទុមសុរិយវង្ស** ជាស្ដេចគោរពព្រះពុទ្ធសាសនាយ៉ាងខ្លាំង ព្រះអង្គបានទំនុកបម្រុងក្នុងកិច្ចកសាងប្រាសាទ វត្តអារាម និងព្រះពុទ្ធបដិមារជាច្រើន ទុកជាទីសក្ការៈគោរពបូជា និងផ្ដល់សេចក្ដីសុខសាន្តដល់ប្រជារាស្ត្រក្នុងនគរ ។

---

[៤] តាមសៀវភៅ **ប្រវត្តិសាស្ត្រខ្មែរភាគ ១** របស់លោក **រស់ ចន្ត្រាបុត្រ** ឆ្នាំ១៩៩៧ ។

www.elibraryofcambodia.org

# វគ្គទី២:
# ព្រះពុទ្ធសាសនាមកកាន់ទ្វីបអាស៊ី
# (Transmission routes of Buddhism to Asia)

ប្រមាណជាក្នុងគ.ស ៥៥០-៦០០ ពួកបុរាណវិទូ (Archeologist) បានធ្វើដំណើរទៅដល់ Mohenjo-Daro ព្រំប្រទល់ប្រទេស **ប៉ាគីស្ថាន-ឥណ្ឌា** (Pakistan-India) និងប្រទេស **នេប៉ាល** Nepal បានរកឃើញនៅទីនោះមានសំណល់ស្លាកស្នាមជាច្រើន ដែលជាទីស្ថានព្រះពុទ្ធបរមគ្រូទ្រង់បានប្រសូត និងបរិនិព្វាន។ នៅក្នុងសៀវភៅមួយឈ្មោះ Pioneers of Archaeology នៅទំព័រ ៥៦ បាននិយាយពីអ្នកបុរាណវិទូម្នាក់ឈ្មោះ John Marshall កើតនៅឆ្នាំ ១៨៧៦ បានធ្វើកិច្ចការស្រាវជ្រាវនៅក្នុងប្រទេសឥណ្ឌា អស់រយៈពេលជាង ២០ ឆ្នាំ បានរកឃើញសំណង់ក្រុងបុរាណមួយដែលត្រូវដីកប់ជិត រួចត្រូវគេជីកកកាយ



កំណោកកាយក្រុងបុរាណ នៅ Mohenjo-Daro ព្រំប្រទល់ប្រទេស ប៉ាគីស្ថាន និងឥណ្ឌា

www.elibraryofcambodia.org

ដោយចំណោយពេល ២៣ ឆ្នាំ ពីឆ្នាំ ១៩១៣ ដល់ ១៩៣៦ ទើបអាចកាយដីចេញអស់ សំអាតទីនោះ គឺស្ថិតនៅក្នុងរដ្ឋ Taxila ប្រទេសឥណ្ឌានាសម័យបុរាណ សព្វថ្ងៃស្ថិតនៅព្រំប្រទល់ដី **ឥណ្ឌា** និង **ប៉ាគីស្ថាន** ។ លោក Janet King និងលោក Petra Koppa បានសរសេរក្នុងសៀវភៅ World History នៅទំព័រ ៤៤ និង៤៦ ត្រង់វគ្គ The Birth of The World Religions បាននិយាយពីការកកើតឡើងនៅសករាជសាសនាក្នុងកំឡុងគ.ស ៣២០ ថា ព្រះពុទ្ធសាសនា (Buddhism) ត្រូវបានគេរកឃើញក្នុងចំណោមសាសនាធំៗ មានគ្រិស្តសាសនា (Christianity) ហិណ្ឌូសាសនា ឬព្រហ្មញ្ញសាសនា (Hinduism) អ៊ីស្លាមសាសនា (Islam) ។ល។ សៀវភៅដដែលនេះបានសរសេរនៅទំព័រ ៦២ និង ៦៣ ទៀតថា នៅក្នុងគ.ស ៦០០ មានពួកឈ្មួញសំពៅមួយក្រុម បានមកដល់កោះស្រីលង្កា (Sri Lanka) នៅជំនាន់ស្តេច **ដេវាណណភ្យាធី** (Devanampiya Tissa) បានឃើញរាជ្យបេសកកម្មរបស់ស្តេចឥណ្ឌា **ចាន់ត្រាមូរ៉ាយ៉ា** (Chandragupta Maurya) ជាចៅស្តេច **អសោករាជ** (Ashoka) នាំគម្ពីរពុទ្ធសាសនាមកថ្វាយស្តេច Piya Tissa **កោះលង្កា** ក្នុងចំណោងមិត្តភាពនគរទាំងពីរ ។ នៅគ.ស ៦០០ ដដែលមានពួកសំពៅមួយក្រុមទៀត នៅឆ្នេរសមុទ្រឥណ្ឌាឯណោះ បានធ្វើកំណត់ហេតុថា មានជាតិរ៉ូម៉ាំង (Roman) មួយក្រុម សំពៅដឹកនាំដោយលោក Alexzender បានមកដល់កំពង់ផែឥណ្ឌា បានឃើញការនាំគម្ពីរដីកាជាច្រើន ពីនគរឥណ្ឌាមកកាន់នគរផ្សេងៗ ។ ក្រុមអ្នកកំណត់ហេតុបានសន្និដ្ឋានថា ការនាំចេញគម្ពីរដីកាទាំងអស់នោះហើយ ដែលព្រះពុទ្ធសាសនាបុរាណបានកើតមានជាចំណារតរៀងមក ។

ចំណែកសៀវភៅដ៏ក្រាស់ខ្មឹកមួយឈ្មោះ Encyclopedia of World History មានជាង ៤០០ ទំព័រ បានសរសេរនៅទំព័រ ១៧៤-១៧៥ ថា មានអំបូរ

www.elibraryofcambodia.org

ស្តេចជាតិ **ឥណ្ឌូ-អរិយេក** (Indo-Aryans) មួយអង្គបានប្រសូតកាលពី ៥៦៣ មុន គ.ស នៅភាគខាងជើងឥណ្ឌា (Northeastern India) មានសាសនាដើ Hindu បានចេញបួសព្រះនាម Siddhathar as the holy man ទ្រង់បាន




សម្រេចត្រាស់ដឹង (Enlightened one) យល់ច្បាស់ពី Evolution of the life cycle turning round of birth and death ជីវិតវិលវល់ កើតស្លាប់លើវដ្តសង្សា ព្រះអង្គព្រះនាម **ព្រះពុទ្ធ** (Buddha)។ សៀវភៅឈ្មោះ Legends of The Ancient World បោះពុម្ពនៅប្រទេសចិន បានសរសេរពីពួកបុរាណវិទ្យាជាច្រើន បានធ្វើការស្រាវជ្រាវនៅក្នុងចន្លោះសតវត្សរ៍ទី ១០ និងទី ១៤ បានរកឃើញការហូរចូលនៃពុទ្ធសាសនាមកកាន់ទ្វីបអាស៊ី ពិសេសនៅចំណុចអាស៊ីបូព៌ា (Eastern Asia) មានចិនទីបេ ម៉ុងហ្គោ កូរ៉េខាងត្បូង និងតៃវ៉ាន់ និងនៅភូមិភាគអាស៊ីអាគ្នេយ៍ (Southeast Asia) ដែលខ្មែរយើងនៅក្នុងនោះដែរ ការហូរចូលទាំងនោះ គឺផ្តើមឡើងចាប់ពីសតវត្សរ៍ទី ១ ដល់ទី ៣។ ក្នុងរយៈពេល **៣**

www.elibraryofcambodia.org

សតវត្សរ៍ ពុទ្ធសាសនាបានរាយពាសពេញបណ្តាប្រទេស បណ្តានគរដូចបានរៀបរាប់មកនេះ។

ផ្នែកពុទ្ធសាសនា **មហាយាន** (Mahayana Buddhism) បានចេញពីឥណ្ឌាភាគខាងជើងតាមវាលរាប និងភ្នំហិមាល័យ ចូលទីបេ ម៉ុងហ្គោលី ចិន កូរ៉េជើងត្បូង ជប៉ុន ហើយហួសទៅតៃវ៉ាន់។ ផ្នែកពុទ្ធសាសនា **ថេរវាទ** (Theravada Buddhism) មកពីឥណ្ឌាភាគខាងជើង នេប៉ាល ស្រីលង្កា មកខ្មែរ ថៃ លាវ វៀតណាម ភូមា។




ការចូលនៃព្រះពុទ្ធសាសនាមកដល់ទ្វីបអាស៊ី នៅសតវត្សទី១២

www.elibraryofcambodia.org

# វគ្គទី៣

# ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា

## (Buddhism History into the Khmer Kingdom)

នៅប្រទេសខ្មែរមានរឿងមួយ[៥] ដែលចេញពីប្រភពកោះស្រីលង្កាថាៈ នៅ ព.ស. ២៣៤ មុនគ.ស. ៣០៩ ក្រោយបានធ្វើ **កិច្ចសង្គាយនា** រួចមកព្រះអរហន្តព្រះនាម **មោគ្គលីបុត្តតិស្ស** បានបញ្ជូនព្រះមហាថេរពីរអង្គព្រះនាម **សោណត្ថេរ** និង **ព្រះឧត្តរត្ថេរ** មកកាន់ទឹកដីសុវណ្ណភូមិ ដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនា គ្រាន់តែមិនបានបញ្ជាក់នគរឈ្មោះអ្វី នៅរជ្ជកាលណា ស្តេចអង្គណា ។ តាមគម្ពីរ **សមន្តប្បាសាទិកា** ត្រង់វគ្គ **ពាហិរនិទាន** បាននិយាយថា ព្រះមហាថេរទាំងពីរអង្គ ដែលបាននិមន្តមកផ្សាយព្រះពុទ្ធសាសនានៅទឹកដី **សុវណ្ណភូមិ** គ្រានោះ គឺជា **កោះគោកធ្លក** នគរខ្មែរនោះឯង ។ យោងតាមរឿងរ៉ាវទាំងនេះ គ្រាន់តែបញ្ជាក់ថាពុទ្ធសាសនាចូលនគរខ្មែរប្រហែលជាក្នុងបុរេប្រវត្តិ (Pre-history) បានជាគ្មានឯកសារណាអាចបញ្ជាក់ពីកាលវេលាច្បាស់លាស់យ៉ាងនេះ ។ លុះដល់សតវត្សរ៍ទី ១ ទើបមានឯកសារប្រវត្តិសាស្ត្របានប្រាប់ថា មានឥណ្ឌាចូលស្រុកខ្មែរ ពេលនេះវប្បធម៌ អរិយធម៌ និងសាសនាពិតជាមកជាមួយគ្នា ចំណុចនេះយើងពិតជាយល់ដូចគ្នា ។ នៅក្នុងឯកសារពង្សាវតារ និងប្រវត្តិសាស្ត្រខ្មែរបានបញ្ជាក់ពីការរីកចម្រើនយ៉ាងខ្លាំងនៃហិណ្ឌូសាសនា ឬព្រហ្មញ្ញសាសនា និងពុទ្ធសាសនាក្នុងសម័យនគរហ្វូណន (Funan) នាសតវត្សរ៍ទី ៥ ក្នុង រាជ្យស្តេច

---

[៥] សៀវភៅព្រះភិក្ខុ **ង៉ែត ឆាំង ខាត់** បោះពុម្ពនៅឆ្នាំ ១៩៦១ ។

www.elibraryofcambodia.org

**គោលនយោបាយជ័យវរ្ម័ន**[៨] ។ ឯកសារបញ្ជាក់កាន់តែច្បាស់ណាស់ទៅទៀត នៅក្នុងរាជ្យស្តេច **ជ័យវរ្ម័នទី ៧** គ.ស. ១១៨១ ព.ស. ១៧២៤ និយាយពីការរីកចម្រើននៃព្រះពុទ្ធសាសនា គឺមានមហាថេរបណ្ឌិត ១៨ អង្គ ព្រះថេរសាស្ត្រាចារ្យ ២៣៧០ អង្គ តែមិនមានប្រាប់ថាពុទ្ធសាសនា **មហាយាន** ឬ **ថេរវាទ** ឡើយ គ្រាន់តែដឹងថាព្រះពុទ្ធសាសនាប៉ុណ្ណោះ ។ លុះដល់គ.ស ១១៩៦ ព.ស ១៨៣៩ ក្នុងរាជ្យស្តេច **ស្រីឥន្ទ្រវរ្ម័ន** បានប្រកាសពុទ្ធសាសនា **ថេរវាទ** ដំបូងនៅក្រុងអង្គរធំ **ពុទ្ធសាសនាថេរវាទ** ជាមូលដ្ឋានទ្រឹស្តី និងទស្សនៈវិជ្ជា ដែលបានបង្ហាញពីគោលគំនិតប្រាប់អំពីសភាវៈ កម្មផល បុណ្យបាបដែលបុគ្គលបានកសាង គឺមានលក្ខណៈខុសពី **លទ្ធិទេវរាជ** ក្នុង **ព្រាហ្មណ្ឌសាសនា** (Brahmanism) ដូច្នេះហើយទើបព្រះបាទ **ស្រីឥន្ទ្រវរ្ម័ន** ទ្រង់បានលើកដំកើងជាសាសនារបស់រដ្ឋ **មហានគរ** ចាប់តាំងពីពេលនោះមក ។

---

[៨] សៀវភៅពុទ្ធសាសនា ឋិតវិទ្យាសាស្ត្ររបស់លោក សុង ស៊ីវ នៅទំព័រ៣៣ ៣៥ - ៥១ - ៥២ បោះពុម្ពឆ្នាំ ១៩៧១

www.elibraryofcambodia.org

# វគ្គទី៤

# ឧបទ្វីបឥណ្ឌាមុនសម័យពុទ្ធកាល

# (Ancient India before the time of the Buddha)

ប្រទេសចិនជាប្រទេសចំណាស់ជាងគេ ក្នុងចំណោមបុរាណប្រទេសនៅប៉ែកអាស៊ីបូព៌ា អ្នកប្រាជ្ញចិនចូលចិត្តតាមដាន កត់ត្រារឿងរ៉ាវប្រវត្តិសាស្ត្រពីប្រទេសជិតខាងខ្លួន ពិសេសគឺនៅប្រទេសឥណ្ឌា ដែលជាកន្លែងពុទ្ធស្ថាន ធ្វើអោយពួកគេចាប់អារម្មណ៍រឹតតែខ្លាំង។ ពួកអ្នកស្រាវជ្រាវចិនបានកត់ត្រារឿងរ៉ាវរបស់ព្រះពុទ្ធបានយ៉ាងក្បោះក្បាយជាងគេ ព្រោះចិន-ឥណ្ឌាមានទឹកដីឧបទ្វីបជាប់គ្នា ដូចនេះទើបមានរឿងនិទានចិនមួយដំណាលថា: កាលពីរាប់ពាន់ឆ្នាំមុន[៧] មានព្រះមហាថេរជាតិឥណ្ឌា ព្រះនាម **តាក់ម៉ារ** (Takamar) បានធ្វើដំណើរពីឥណ្ឌាមកចិនដោយនាំពុទ្ធសាសនាចូលមក ហើយពួកចិនក៏គោរពប្រតិបត្តិពុទ្ធសាសនាចាប់តាំងពីពេលនោះមកទាល់សព្វថ្ងៃតាមបែបពុទ្ធសាសនា **មហាយាន**។ មានពួកបុរាណវិទូ[៨] ខ្លះអោយដឹងថា មានចិនចូលឥណ្ឌាតាំងពីសតវត្សទី ៣ ដើម្បីទាក់ទងវិស័យព្រះពុទ្ធសាសនាជាមួយគ្នា កាលនោះនគរឥណ្ឌាគ្រងរាជដោយស្តេច **អសោក** (Ashoka)។ ក្រោយមកមានក្រុមអ្នកស្រាវជ្រាវពីប្រទេសផ្សេងៗមាន ជប៉ុន កូរ៉េទាំងពីរ ម៉ុងហ្គោ ទីបេ ពួកបណ្តាប្រទេសក្នុងអាស៊ីដូចគ្នា និងបណ្តាបស្ចិម

---

[៧] តាមសៀវភៅ World Religious របស់លោក Michael នៅទំព័រ ២០០ វគ្គទី ៦ ស្តីអំពី Chinese Tradition ថា ពុទ្ធសាសនាចូលនគរចិននៅព.ស ២០៦។

[៨] សៀវភៅដដែល ដែលនៅទំព័រ ២០១។

www.elibraryofcambodia.org

ប្រទេសខ្លះ បានធ្វើដំណើរទៅដល់ទីកន្លែង ក្នុងទីកដីប៉ាគីស្ថាន[៩] នេប៉ាល-ឥណ្ឌានិងស្រីលង្កាដោយផ្ទាល់តែម្តង។ ថ្វីបើឥណ្ឌាបានឆ្លងកាត់របបអាណានិគមអង់គ្លេសយ៉ាងយូរ (ពីឆ្នាំ ១៨០០ ដល់ ១៩៤៥)[១០]។ ក្រោយសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់នៅឆ្នាំនោះ (The end of world war II in 1945) ចក្រភពអង់គ្លេស (Great Britain) ក៏បានផ្តល់ឯករាជ្យដល់ប្រទេសឥណ្ឌានៅឆ្នាំនោះដែរ។ ២ ឆ្នាំក្រោយមក គឺនៅឆ្នាំ ១៩៤៧ ថ្នាក់ដឹកនាំឥណ្ឌា និងអង់គ្លេស ក៏សម្រេចចែកទឹកដីឥណ្ឌាជាពីរគឺ ឥណ្ឌា និងប៉ាគីស្ថានសព្វថ្ងៃ ចំណែកសាសនាធំ ២ ក៏ចែកគ្នាដែរ សាសនា Muslim អោយទៅប៉ាគីស្ថាន ឯ Hindus ទុកនៅក្នុងឥណ្ឌា។ សាសនាធំទាំងពីរត្រូវបានបំបែកទៅហើយ តែអ្នកកាន់ Muslim នៅតែមាន ១២% ក្នុងទឹកដីឥណ្ឌាសព្វថ្ងៃ ចំណែក Hindus មានដល់ទៅ ៨១% សព្វថ្ងៃ និងសាសនាផ្សេងៗជាច្រើន យ៉ាងណាក៏ដោយ ក៏ភាគតិចនៃអ្នកកាន់ព្រះពុទ្ធសាសនា នៅតែរក្សាកេរ្តិ៍ដំណែល និងទំនៀមទំម្លាប់បានយ៉ាងល្អប្រសើរ។

នៅក្នុងកំឡុងគ.ស ១៥០០ ក្រុមអ្នកស្រាវជ្រាវផ្នែកពុទ្ធសាសនា បានចាប់គូសផែនទីឡើង ការគូសវាសផែនទីនោះ គឺសំដៅបញ្ជាក់ពីតំបន់នានា ក្នុងសម័យពុទ្ធកាលដែលព្រះអង្គនៅមានព្រះជន្មគង់នៅឡើយ។ **ព្រះពុទ្ធបរមគ្រូ** ទ្រង់ខំនិមន្តធ្វើដំណើរត្រាច់ចរលើផែនដីសែនធំល្វឹងល្វើយ លាតសន្ធឹងបណ្តោយខ័ណ្ឌជួរភ្នំហិមាល័យ (Himalayas) ដែលជាព្រំប្រទល់អាណាចក្រទីបេ (Tibet) និងអាណាចក្រឥណ្ឌានាសម័យបុរាណ គឺស្ថិតនៅតាមបណ្តោយខ្សែស្របប្រទេសចិននាចំណុច Tropic of Cancer នៃផែនដី។ ផែនដីដ៏ធំល្វឹងល្វើយទាំងនេះ កាល

---

[៩] សម័យពុទ្ធកាល ប៉ាគីស្ថាន និងស្រីលង្កាជាទឹកដីឥណ្ឌា។
[១០] ត្រង់នេះពីជាប្រវត្តិសាស្ត្រខ្លះៗនៃប្រទេសឥណ្ឌា ។

www.elibraryofcambodia.org

សម័យមុនពុទ្ធកាលហៅថា **ជម្ពូទ្វីប**[១១] (Jambudvipa) បើគិតតាមផែនទីសព្វថ្ងៃ ភាគខាងកើតចាប់រាប់ពីទន្លេ Mohejo-Daro ប្រទេសប៉ាគីស្ថានសព្វថ្ងៃ។ ភាគកណ្ដាលកាត់តាមប្រទេសនេប៉ាល (Nepal) សព្វថ្ងៃទៅទល់ភាគខាងលិចជាប់ប្រទេសបង់ក្លាដេស (Bangladesh) និងឈូងសមុទ្របង់កាល (Bay of Bengal) ភាគខាងជើងជាប់បណ្ដោយជួរភ្នំហិមាល័យប្រទេសចិនសព្វថ្ងៃ។ ឯភាគខាងត្បូងទល់នឹងសមុទ្រកោះស្រីលង្កា (Srilanka) និងសមុទ្រអារ៉ាប់ (Arabian Sea) សព្វថ្ងៃ។




[១១] មហាទ្វីបទាំង ៤ មានឈ្មោះដូចតទៅនេះ ១-ឧត្តរកុរុទ្វីប, ២-អមរគោយានទ្វីប, ៣-បុព្វវិទេហទ្វីប, ៤-ជម្ពូទ្វីប ។

www.elibraryofcambodia.org

# វគ្គទី៥

# សម័យអរិយកៈ (Aryans Empire Time)



ជនជាតិមិលក្ខុសម័យបុរាណ

ក្នុងកំឡុងជាង ៣៥០ ឆ្នាំមុនព.ស. ជនជាតិ **អរិយកៈ** (Aryans) បាននាំទ័ពខ្លាំងពូកែមកពីភាគខាងជើង ឆ្លងកាត់ជួរភ្នំហិមាល័យ ចូលមកលុកលុយដេញជនជាតិ **មិលក្ខុ** (Barbarian) ដែលជាកុលសម្ព័ន្ធម្ចាស់ទឹកដីអោយមាននៅតែចំនួនតិចតួចប៉ុណ្ណោះ ដែលនៅសេសសល់លើទឹកដីចាស់ មកនៅភាគខាងកើតភូមិភាគ Pataliputra សព្វថ្ងៃស្ថិតក្នុងទឹកដី Bangladesh ។ ពេលធ្វើសង្គ្រាមលុកលុយបន្តិចម្តងៗ រហូតកាន់កាប់ទាំងស្រុងលើ **ជម្ពូទ្វីប** ទាំងមូល ជនជាតិ **អរិយកៈ** ក៏ប្រកាសខ្លួនជាម្ចាស់ដីរៀងរហូតមក[១២] ។ ជនជាតិ **អរិយកៈ** បានបង្កើតច្បាប់គ្រប់គ្រងទឹកដីសព្វបែបយ៉ាងដោយមាននគរតូចធំចំនួន **២១**[១៣] និងមានស្តេចគ្រប់គ្រង សូម្បីតែពួកកុលសម្ព័ន្ធក៏មានស្តេចកុលសម្ព័ន្ធ (Royal Tribes) គ្រប់គ្រងប្រចាំកុលសម្ព័ន្ធរបស់ខ្លួនដែរ ។ **ជម្ពូទ្វីប** សម័យនោះ នគរមួយភាគធំគ្រប់គ្រងដោយជនជាតិ **អរិយកៈ-ឥណ្ឌូ** (Aryans-Indo) ជាមនុស្សមានត្រកូលខ្ពង់ខ្ពស់ និងមានចំណេះវិជ្ជាគ្រប់គ្រាន់ ។ នគរមួយភាគតូចគ្រប់គ្រងដោយជនជាតិ **មិលក្ខុ** ជាមនុស្សមិនសូវមានចំណេះ

---

[១២] សៀវភៅឈ្មោះ Ancient India បោះពុម្ពនៅឆ្នាំ ១៩៨៥ ក្នុងរដ្ឋ Madhya Pradesh ប្រទេសឥណ្ឌា ។

[១៣] ក្នុងបាលី ឧបោសថសូត្រ តិកនិបាត អង្គុត្តរនិកាយ ។

www.elibraryofcambodia.org

ចេះដឹងអ្វីឡើយ ភាគច្រើនជារាជកុលសម្ព័ន្ធ។ **ជនមជ្ឈិម** ជាអាណាចក្រ អធិរាជ **អរិយក** ជាទីតាំងធំនៃអ្នកដឹកនាំ អ្នកមានអំណាច អ្នកប្រាជ្ញបណ្ឌិត ច្បាប់សម្រាប់នគរគឺចេញពីទីនេះ។ **ជនបុច្ចន** គឺនគរតូចតាច រស់នៅគ្រាន់តែជា ចំណោះគេ និងរណបគេប៉ុណ្ណោះ ជនជាតិ **មិលក្ខ** ភាគច្រើនស្ថិតនៅក្នុងនគរតូចៗ ទាំងនេះ។ លទ្ធិសាសនា ការគោរពជំនឿខុសៗគ្នា នគរខ្លះគោរពច្បាប់ **ជន មជ្ឈិម** គឺរូបសញ្ញា Indra-Aryans នគរខ្លះគោរពនិមិត្តសញ្ញាទេវលោក (The world of gods) មានរូប **ព្រះវិស្ណុ** (Vishnu) **ព្រះសិវា** (Shiva) **ព្រះម៉ែកាលី** (Kali-mother) **ព្រះសគ្គលី** (គ្រុឌ) (Bird-god Garuda) និងនិមិត្តសញ្ញាដទៃទៀត តាមតែស្រុកភូមិនិគមផ្សេងៗដែលជាការជឿរបស់អ្នកស្រុក។



១.ប្រាក់កាក់រូបព្រះម៉ែកាលី ដែលប្រើសម័យអរិយក

២.ព្រះឥន្ទ

៣.ព្រះវិស្ណុ

៤.ព្រះសិវា

៥.ព្រះព្រហ្ម

ព្រះដែលជនជាតិអរិយកគោរពបូជាពីសម័យបុរាណ

ចំពោះសិល្បៈវប្បធម៌ គេចូលចិត្តនិយមប្រគុំភ្លេងរបាំ ច្រៀង រាំថ្វាយដល់និមិត្តសញ្ញាជំនឿរបស់ខ្លួន។ មនុស្សជំនាន់នោះ រស់នៅស្ថិតក្នុងសង្គមបែងចែកវណ្ណៈ ៤ ប្រភេទគឺ: **ក្សត្រ ព្រាហ្មណ៍ វេស្ស សុទ្ទ**។ ក្នុងសៀវភៅ Ancient India ដែលបានបោះពុម្ពនៅក្នុងរដ្ឋ Madhaya Pradesh ប្រទេសឥណ្ឌាបានសរសេរថា រឿងរ៉ាវនៅសម័យ Indro-Aryans ថា: **វណ្ណៈស្តេច** (Monarch) ឬត្រកូលក្សត្រជាអ្នកកាន់កាប់ទឹកដី និងធ្វើសឹកសង្គ្រាមជ័យ មានសេនាមន្ត្រី ពលបរិវារ

www.elibraryofcambodia.org

ចាត់ចែងរាជកិច្ចព្រះនគរ គ្រប់គ្រងប្រជារាស្ត្រនៅក្នុងអាណាចក្រ។ ការសិក្សា របស់ក្សត្រគ្មានអ្វីក្រៅពីសិក្សាវិធីយុទ្ធសាស្ត្រ ដែលជាយុទ្ធវិធីខ្លាំងពូកែសម្រាប់ ការពារ និងពង្រីកទឹកដី។ **វណ្ណៈព្រាហ្មណ៍** (Brahmana) ជាត្រកូលអ្នក សិក្សារៀនសូត្រគ្រប់មុខវិជ្ជា (តែជំនាន់នោះមានតែលទ្ធិសាសនាទេដែលជាមុខ វិជ្ជា) ខ្លះមានវិជ្ជាខាងពេទ្យបុរាណ។ **វណ្ណៈព្រាហ្មណ៍** ត្រូវបានគេគោរព រហូត ធ្វើជាគ្រូអាចារ្យលើមនុស្សគ្រប់រូប ប្រដៅរាប់ទាំងត្រកូលក្សត្រទៀតផង។ **វណ្ណៈវេស្ស** (Vesha) ជាត្រកូលអ្នកធ្វើស្រែចំការច្បារដំណាំ និងប្រកបរបររក ស៊ី កិច្ចការជំនួញមានលក់ចេញទិញចូល។ **វណ្ណៈវេស្ស** នេះ ខ្លះជាអ្នកមាន ទ្រព្យសម្បត្តិច្រើន ខ្លះមធ្យមសមល្មមនឹងជីវភាពរបស់ខ្លួន។ **វណ្ណៈសុទ្ទ** (Sutta) ជាត្រកូលតូចទាបជាងគេ ដើរធ្វើគូលីកម្មករ និងជាទាសករ (Slave) អោយវណ្ណៈអ្នកមាន។ ការរកទទួលទាន គ្មានអ្វីក្រៅពីបញ្ចេញកម្លាំង ប្តូរយក ត្រឹមតែមួយចំអែតប៉ុណ្ណោះ វណ្ណៈនេះភាគច្រើនជាជនជាតិ **មិលក្ខ** ចេញពីជនបទ មកធ្វើការក្នុងទីក្រុង។ ក្នុងសៀវភៅអ្នកនិពន្ធបុរាណវិទ្យាម្នាក់ឈ្មោះ Stella Sand បានសរសេរក្នុងសៀវភៅ Discovery ពីដំណើរដើមទងពួកភ្នងក្នុងសម័យ បុរាណនៃជនជាតិនេះថា ជាដើមកំណើតកុលសម្ព័ន្ធម្ចាស់ទឹកដីព្រៃព្រឹក្សាដូនតាពួក គេមក ក្រោយពេលពួក **អរិយក** ចូលកាន់កាប់ទឹកដី **ជម្ពូទ្វីប** ហើយ គ្មានអ្នក ណាជួយអោយពួកគេ (**មិលក្ខ**) ក្លាយជាអ្នកចេះដឹងបានឡើយ។បើប្រៀបធៀប រឿងរ៉ាវក្នុងសៀវភៅ Voyages of Discovery របស់អាមេរិកដែលបាននិយាយ ពីរឿងពួកជនជាតិអេស្ប៉ាញ (Spanish) ដើរសំពៅមួយក្រុម ដឹកនាំដោយមេ បញ្ជាការឈ្មោះ Christopher Columbus ដែលជាអ្នកឯកទេសខាងធ្វើដំណើរ តាមសំពៅ បានមកឃើញទឹកដី Indians (កុលសម្ព័ន្ធភ្នង) ក្នុងឆ្នាំ ១៤៩២ នៅ

www.elibraryofcambodia.org

អាមេរិកខាងជើង (North America) ដែលសព្វថ្ងៃហៅថា សហរដ្ឋអាមេរិក (The United State of America) ហើយពួកគេបានចាត់ទុកថា បុព្វបុរសរបស់ពួកគេគឺភ្នងអាមេរិកាំង (American Indians) ព្រមទាំងបានបង្ហាត់បង្ហាញជនជាតិ Indians ទាំងនេះអោយចេះដឹង រស់នៅតាមបែបអ៊ឺរ៉ុប (Europe) ទៀតផង។ មានរឿងរ៉ាវប្រៀបធៀបដ៏អស្ចារ្យទៅទៀត គឺនៅពាក់កណ្ដាលសតវត្សរ៍ទី ១៩ ដែលពួកអាមេរិកកំពុងមមាញឹកក្នុងការកសាងទីក្រុងធំៗ មានអាគារខ្ពស់ៗ រោងចក្រជាច្រើន ដែលត្រូវការកម្មករចាំបាច់ និងចំនួនច្រើនមកធ្វើការ ពេលនោះពួកគេបានរកឃើញជនជាតិស្បែកខ្មៅរស់នៅអាមេរិកខាងត្បូង (South America) ដែលពួកស្បែកខ្មៅទាំងនោះមិនចេះអ្វីសោះ ពួកអាមេរិកក៏នាំពួកស្បែកខ្មៅទាំងនោះ នាំយកមកធ្វើជាទាសករដោយទិញពីមេដឹកនាំពួកស្បែកខ្មៅអោយមកធ្វើការយកតែបាយស៊ីប៉ុណ្ណោះ រហូតទាល់ឆ្នាំ ១៨៦០ ជំនាន់ប្រធានាធិបតី Abraham Lincoln បានប្រកាសចេញច្បាប់ឈប់មានទាសករតទៅទៀត ទើបពួកស្បែកខ្មៅទាំងនោះចាប់ផ្ដើមមានសិទ្ធិ មានសេរីភាព ដូចគេដូចឯងតរៀងមក។ ពួកជនជាតិស្បែកខ្មៅបានចាត់ទុកលោកប្រធានាធិបតី Abraham Lincoln ជាព្រះរបស់ពួកគេរហូតទល់សព្វថ្ងៃ មិនតែប៉ុណ្ណោះ តែមានសិទ្ធិចូលសាលារៀន ចូល College ខ្លះរៀនពូកែបានធ្វើការក្នុងជួររដ្ឋាភិបាល (Government Jobs) ពាសពេញផ្ទៃប្រទេសអាមេរិក ដោយមានលោក Borack Obama ជាប់ឆ្នោតជាប្រធានាធិបតីនៅឆ្នាំ ២០០៨ នេះថែមទៀត ផង។

រឿងរ៉ាវទាំងនេះ គ្រាន់ជាកាប្រៀបធៀបអោយដឹងថាកាលបើ **អរិយក** ចូលស្រុកពេញហើយ ពួក **មិលក្ខ** ជាម្ចាស់ស្រុកនៅតែល្ងិតល្ងង់ មិនបានរៀនសូត្ររហូត នៅតែធ្វើគូលីកម្មករតកូនតចៅរបស់គេដដែល។

www.elibraryofcambodia.org

# វគ្គទី៦

# ព្រះពោធិសត្វ (Budhisattva)

លិទ្ធិសាសនាជាច្រើន បានគ្រប់ដណ្តប់ប្រទេសឥណ្ឌាតាំងពីបុរាណកាលមក តែយ៉ាងណាក៏ដោយ ក៏ពុទ្ធសាសនិកជនឥណ្ឌានៅតែប្រកាន់ភ្ជាប់ ព្រមទាំងថែរក្សាសម្បត្តិមរតក (Heritage) នៃពុទ្ធសាសនាបានយ៉ាងគង់វង្សល្អប្រសើរដូចជាពុទ្ធស្ថាននៅឧទ្យាន **លុម្ពិនី** និងបង្គោលថ្មអនុស្សាវរីយ៍ដែល **ព្រះពុទ្ធ** ទ្រង់ប្រសូត្រនៅទីនោះ បង្គោលថ្មកសាងឡើងដោយស្តេច **អសោក** ក្នុងសតវត្សទី៣ សព្វថ្ងៃជាឈ្មោះស្រុកមួយ (Rummindei) ក្នុងប្រទេសនេប៉ាល់។ ដើមពោធិព្រឹក្សដែលហៅថា **ពុទ្ធគយា** ជាទីកន្លែងព្រះអង្គត្រាស់ដឹង និងបល្ល័ង្កពេជ្រនៅទីនោះ។ មហាចេតីយ៍ពុទ្ធគយាដែលបញ្ចុះសារីរិកធាតុ និងមហាចេតិយ៍ធម្មិកដ៏ធំបានកសាងក្នុងសតវត្សទី ៦។ តំបន់ព្រៃ **មិគទាយវ័ន** កន្លែង **ព្រះពុទ្ធ** និងបញ្ចវគ្គិតាបសគង់នៅ។ នគរ **កុសិនារា** កន្លែងព្រះអង្គបរិនិពាន្ទ សព្វថ្ងៃស្ថិតនៅខាងកើតទីក្រុងមួយឈ្មោះ Gorakpu ប្រទេសឥណ្ឌា និងចេតិយ៍បរិនិពាន្ទ។ល។ ព្រមទាំងពុទ្ធស្ថានដទៃជាច្រើនទៀត។ នៅរៀងរាល់ឆ្នាំតែងមានពុទ្ធសាសនិកយ៉ាងច្រើន ធ្វើធម្មយាត្រាទៅកាន់ទីពុទ្ធស្ថានទាំងនោះមិនដែលដាច់ នៅទីនោះយើងនឹងស្វែងយល់ពីរឿងរ៉ាវព្រះអង្គ និងអ្វីដែលហៅថា **ព្រះពោធិសត្វ**។ នៅក្នុងគម្ពីរ **ទិឃនិកាយ** -គម្ពី **សាមន្តប្បាសទិកា** ដែលអ្នកសិក្សាព្រះពុទ្ធសាសនារកឃើញនៅកោះស្រីលង្កានោះ ក៏មាននិទានពីរឿង **ព្រះពោធិសត្វ** នេះដែរ។ នៅប្រទេសចិនរឿងនិទាន **ព្រះពោធិសត្វ** គឺមានតាំងពីជំនាន់រាជវង្សថាំង

www.elibraryofcambodia.org

(Tang Dynasty) ក្នុងព.ស ៩០៧[១៤] ។ ក្នុងគ.ស ៥០០ នៅប្រទេសជប៉ុន កាល នោះជប៉ុន មាន Shinto ជាសាសនាក្នុងស្រុក ក្នុងអធិរាជស្តេច Yamoto ដល់ គ.ស ៦០០ ទើបមានភិក្ខុសង្ឃនិមន្តពីនគរចិន និងកូរ៉េ បានសំដែងធម៌ផ្សព្វផ្សាយ ពុទ្ធសាសនាបានយ៉ាងរហ័ស ជ្រួតជ្រាបពេញនគរជប៉ុន តែសាសនា Shinto មិន ទាន់បាត់បង់នៅឡើយទេ គឺនៅប្រតិបត្តិទាំងពីរ (Shinto-Buddhism) គេបាន ឃើញរឿង **ព្រះពោធិសត្វ** តាមរយៈស្នាដៃនិពន្ធរបស់អ្នកស្រី Marasaki Shikibu[១៥] នៅក្នុងវត្ត Nara ប្រទេសជប៉ុននៅគ.ស ៧១០ ។

នៅក្នុងគម្ពីរសុត្តន្តបិតក និងគម្ពីរដីកាផ្សេងៗរបស់ខ្មែរយើង សុទ្ធតែបង្ហាញ ពីតួអង្គ **ព្រះពោធិសត្វ** ជាម្ចាស់នៃយើងទាំងអស់គ្នា ព្រះអង្គខំបំពេញនូវទាន បារមី កុសលផលបុណ្យតាំងពីអតីតជាតិពីបុព្វេសន្និវាស (Previous life) ទាំង ៣០ ប្រការ ឥតមានសម្រាក ឬអាកខានអ្វីឡើយ រហូតអស់កាលបួនអសង្ខេយ្យ (Innumerable) និងមួយសែនកប្ប (100,000 years, age of the world) ដរាបបានដល់ **ភទ្ទកប្ប** (Fortunate time) ទាំងនេះជាគម្ពីរដីកាដែលព្រះពុទ្ធ **ឃោសាចារ្យ** (Preah Ghosa; Buddhist scholar who know the Tripitaka well) ដែលជាអ្នកដឹងនូវរឿងរ៉ាវរបស់ **ព្រះពុទ្ធសាសនា** ក្នុងព.ស ៨១០ ។

**ព្រះឃោសាចារ្យ** ជាបណ្ឌិតសង្ឃដែលបានសិក្សារៀនសូត្រ និងយល់ ច្បាស់ ចេះចាំនូវគម្ពីរ **ព្រះត្រៃបិតក** បានយ៉ាងស្ទាត់ជំនាញ ហើយព្រះអង្គបាន សរសេរទុកក្នុងតម្រាក្បួនច្បាប់ផ្សេងៗតមកក្នុងគម្ពីរព្រះពុទ្ធសាសនា បើតាម

---

[១៤] សៀវភៅ World Religions. វគ្គទី៦ Chinese Traditions ទំព័រ២០២ ។

[១៥] សៀវភៅ Encyclopedia of the world history ទំព័រ៨៧០ ។

www.elibraryofcambodia.org

សៀវភៅលោក Robert K. Headley បានសរសេរថា ឋានៈរបស់ព្រះឃោសាចារ្យនេះ គឺមហាក្សត្រខ្មែរក្នុងសតវត្សទី ៥ នោះប្រទានអោយដល់បណ្ឌិតសង្ឃអង្គនេះ ដែលជាអ្នកប្រាជ្ញពូកែខាងព្រះត្រៃបិតក និងខាងព្រះពុទ្ធសាសនា មិនតែប៉ុណ្ណោះ ព្រះអង្គជាអ្នកប្រាជ្ញ បានរកឃើញទ្រឹស្តីព្រះពុទ្ធសាសនាក្នុង ព.ស ៨១០ នេះបើយោងតាមពង្សាវតារខ្មែរ គឺស្ថិតនៅក្នុងចន្លោះរាជ្យស្តេច **កោណ្ឌញ្ញជ័យវរ្ម័ន** ទៅដល់ស្តេច **រុទ្រវរ្ម័ន**។ **ព្រះឃោសាចារ្យ** បានសម្តែងទុកក្នុងគម្ពីរពុទ្ធសាសនា[១៦] ថា: ព្រះពុទ្ធមួយអង្គៗ មានរយៈកាលប្រាំពាន់ឆ្នាំហៅថា **និតិកាលព្រះពុទ្ធសាសនា** ឬព្រះពុទ្ធមួយអាណត្តិៗ ដូចជានិតិកាលមុនព្រះពុទ្ធ **សមណគោត្តម** មានព្រះពុទ្ធ ៥ អង្គបានត្រាស់ រួចហើយបន្សល់ទុកនៅតែព្រះធម៌ គឺព្រះពុទ្ធសាសនានេះឯង។ ព្រះពុទ្ធទាំង ៥ អង្គនោះគឺ: ១-**ព្រះបដិសម្ភិទាញាណ**, ២-**ព្រះសុក្ខវិបស្សនៈ**, ៣-**ព្រះអនាគាមី**, ៤-**ព្រះសកទាគាមី**, ៥-**ព្រះសោតាបន្នៈ**។ ចំណែកនៅក្នុងគម្ពីរសាស្ត្រាក្បែកសនៃយើង ដែលមាននៅតាមវត្តអារាមនានា ក៏មាននិទានពីរឿងព្រះពុទ្ធទាំង ៥ អង្គ នៅក្នុងភទ្ទកប្បយើងនេះដែរ ដែលព្រះអង្គបានយោងព្រះពុទ្ធសាសនាលើលោកយើងនេះ កន្លងមកក្នុងមួយអាណត្តិៗព្រះអង្គគឺ ៥ ពាន់ឆ្នាំ ទ្រង់មានព្រះនាមដូចតទៅ: ១-**ព្រះកុក្កុសន្ធោ**, ២-**ព្រះកោនាគមនោ**, ៣-**ព្រះកស្សបោ**, ៤-**ព្រះគោតមោ** និងទី ៥-**ព្រះមេត្តេយ្យ**។

ដល់មកនិតិកាលព្រះ **សមណគោត្តម** ព្រះអង្គទ្រង់មានព្រះជន្មតែ ៨០ វស្សា ក៏ទ្រង់ទទួល **ព្រះបរិនិព្វាន** តែមិនមែនមានន័យថា អស់អាណត្តិរបស់ព្រះអង្គនោះទេ គឺសាសនាព្រះអង្គត្រូវបន្តរហូតគ្រប់ ៥០០០ ឆ្នាំដែរ ដល់គ្រប់

---

[១៦] សៀវភៅពុទ្ធសាសនា/វិទ្យាសាស្ត្ររបស់លោក **សុខ ស៊ីន** ឆ្នាំ ១៩៦៩។ គម្ពីរជិនមហានិទាន។

www.elibraryofcambodia.org

៥០០០ ឆ្នាំ ទើបអស់អាណត្តិរបស់ព្រះអង្គ រួចពីអាណត្តិព្រះ **សមណគោត្តម** ទើបមានព្រះពុទ្ធមួយអង្គទៀត ព្រះនាម **មេត្តេយ្យ** ដែលពុទ្ធសាសនិកជនយើងតែងហៅថាៈ **ព្រះសិអារ្យមេត្រីយ៍** ជាអរិយបុគ្គលដែលបានត្រាស់ដឹងក្រោយគេបង្អស់ចូលមកក្នុងលោកយើងនេះ។ សូមបញ្ជាក់ថា ព្រះពុទ្ធសាសនា **ព្រះសមណគោត្តម** នៃយើងឥឡូវទើបតែបានជាងពីរពាន់ឆ្នាំ (២៥៥៣) ប៉ុណ្ណោះ គឺមានរយៈពេលនៅសល់ប្រមាណជាង ២៤៤៧ ឆ្នាំទៀត ទើបគ្រប់ចំនួន ៥០០០ ឆ្នាំនៃអាណត្តិរបស់ព្រះអង្គ។

ដូចដែលមានចំណាររបស់ **ព្រះឃោសាចារ្យ** ក្តី **គម្ពីរសាស្ត្រាក្អែកស** ក្តី បានបញ្ជាក់អោយដឹងថា ព្រះពុទ្ធសាសនាមានរយៈកាលវែងឆ្ងាយណាស់ប្រៀបបានដូចគ្រាប់ខ្សាច់ស្ថិតក្នុងសមុទ្រខ្សាច់ មិនអាចរាប់បានឡើយ ដូច្នេះរឿងរ៉ាវ **ព្រះពោធិសត្វ** គឺមានទាក់ទងទៅនិងរឿងរ៉ាវព្រះពុទ្ធសាសនាខាងលើនេះដែរ។ **ព្រះពោធិសត្វ** ជាពូជអង្គបណ្តូលសារពេជ្រពោធិញ្ញាណ ដែលចាប់កំណើតជាច្រើនជាតិ ទ្រង់បានគោរពប្រតិបត្តិនូវសេចក្តីល្អគ្រប់ប្រការដូចជា ធ្វើទានសន្សំកុសល ជួយរំដោះទុក្ខសព្វសត្វអោយផុតចាកទុក្ខក្តីវេទនា ហើយបង្ហាញផ្លូវឆ្ពោះទៅកាន់ភាពសុខសាន្ត ក្នុងជាតិខ្លះរបស់ **ព្រះពោធិសត្វ** ព្រះអង្គក៏ជួបការលំបាករងទុក្ខវេទនា ពីកម្មផលនិស្ស័យដូចជារឿងនិទាន **សុវណ្ណសាម** រឿង **ព្រះវេស្សន្តរជាតក** របស់ខ្មែរយើង និងរឿងដ៏ទៃទៀតជាច្រើន សុទ្ធតែបង្ហាញពីផលបុណ្យទានកុសល ហើយដោយអំណាចផលបុណ្យ អភិញ្ញា ឧបនិស្ស័យ និងសមាបត្តិទាំងនេះហើយ ទើបព្រះអង្គបានយោងកំណើត និងការត្រាស់ដឹងជា **ព្រះពុទ្ធ**។

www.elibraryofcambodia.org

រឿងនិទាននៃជាតិចុងក្រោយមួយរបស់ **ព្រះពោធិសត្វ** មុនពេលដែលព្រះអង្គចាប់កំណើត ហើយបានត្រាស់ដឹងជា **ព្រះពុទ្ធ** នោះ សូមមេត្តាតាមដាននូវវគ្គជាបន្តបន្ទាប់ទៅនេះ ។



**ព្រះកុក្កុសន្ធោ** **ព្រះកោនាគមនោ** **ព្រះកស្សបោ** **ព្រះគោត្តមោ** **ព្រះមេត្តេយ្យ**

ព្រះពុទ្ធទាំង៥ព្រះអង្គ (ដកស្រង់ចេញពីវត្តសំរោងអណ្ដែត ក្រុងភ្នំពេញ ប្រទេសកម្ពុជា)

www.elibraryofcambodia.org

# ជំពូក ២

## វគ្គទី១

## រឿង សុមេធបណ្ឌិត[១៧]

## (Legendary Sumedhura)

កាលសម័យបុរាណព្រេងនាយ មានរឿងនិទានថា: **ព្រះភគវា** ជាអង្គ **ព្រះពោធិសត្វ** ទ្រង់យោងយកកំណើតនៅក្នុងត្រកូលព្រាហ្មណ៍មួយក្នុងស្រុក **អត្រាវាទី** (Attravatiya) មានឈ្មោះថា **សុមេធ** (Sumedhura)។ ឪពុកម្តាយ **សុមេធ** មានទ្រព្យសម្បត្តិជាអ្នកមានមធ្យម ពួកគាត់ចូលចិត្តស្រលាញ់ព្រះធម៌ មានជំនឿលើព្រះជាម្ចាស់ និងសេចក្តីល្អបរិសុទ្ធ មិនដែលមានធ្វើអំពើអាក្រក់អ្វីប្រចាំជីវិតពួកគាត់ឡើយ។ ពេលដែលចៅ **សុមេធ** មានវ័យបាន ១០ ឆ្នាំ ឪពុកម្តាយបាននាំទៅបួសកោរសក់ ហើយអោយស្នាក់អាស្រ័យ រស់នៅរៀនសូត្រជាមួយនឹងអាចារ្យព្រាហ្មណ៍ ដែលស្ថិតនៅក្នុងសំណាក់នោះ (ទីនោះជាវត្តអារាមមួយនៅសម័យនោះ)។ ចៅ **សុមេធ** ពេលបានបួសរស់នៅក្នុងសំណាក់វត្តហើយ ក៏ខំរៀនធម៌វិន័យគ្រប់យ៉ាង រហូតបានចេះដឹងសព្វគ្រប់ធម៌វិន័យទីនោះ។ ចៅ **សុមេធ** ត្រូវឡើងថ្នាក់សិក្សាមួយកម្រិតទៀត ដោយនៅក្នុងស្រុក **អាត្រា**

---

[១៧] រៀបរាងតាមភាពយន្តឥណ្ឌារឿង "**ព្រះពុទ្ធ**" មានចំនួន ២៥ ទើបចប់។

www.elibraryofcambodia.org

**ទាធី** អស់កន្លែងរៀនសូត្រ ហើយឪពុកម្ដាយ **សុមេធ** ក៏ពិគ្រោះគ្នា ត្រូវនាំចៅ **សុមេធ** ទៅរៀនបន្តនៅស្រុកផ្សេង ។

ក្នុងសម័យនោះ មានឥសីម្នាក់ឈ្មោះ **ឬទ្ធារាម៉ា** (Merit Brarma) ជាអ្នកមានកម្រិតវិជ្ជាល្បីល្បាញ មានអាស្រមធំទូលាយស្ថិតនៅជិតស្ទឹង **សារាវតី** (Sharavatti River) ក្នុងស្រុក **ឆន្ទនិគម** (Chhantaka) ឪពុកម្ដាយ **សុមេធ** សម្រេចគ្នាថា ត្រូវនាំចៅ **សុមេធ** ទៅសិក្សានៅទីនោះ ។ នៅក្នុងរាត្រីមុនថ្ងៃចេញដំណើរ ម្ដាយចៅ **សុមេធ** មានការនឹកស្រណោះអាឡោះអាល័យកូនសំណប់ក្រៃលែងថា នឹងត្រូវបែកគ្នានៅវេលាថ្ងៃស្អែក ។ ឪពុក **សុមេធ** ខំលួងលោមភរិយាអោយខំកាត់ចិត្តដោយស្រដីថា: "ចិត្តជាឪពុកម្ដាយ! គ្មានអ្នកណាចង់អោយកូនមានតែមួយបែកឃ្លាតឆ្ងាយនោះទេ! តែដើម្បីអោយកូនយើងស្វែងរកព្រះធម៌ និងសម្រេចបាននូវពោធិញ្ញាណ យើងត្រូវតែលះបង់ និងខំកាត់ចិត្តអោយបាន ដល់ពេលកូនសម្រេចព្រះធម៌ដ៏ឧត្តមហើយ គេនឹងមកជួយប្រោសសត្វលោកគ្រប់ទីកន្លែង ពេលនោះសេចក្ដីប្រាថ្នារបស់យើងក៏បានសម្រេច! ចៅ **សុមេធ** នឹងក្លាយជាបុគ្គលដ៏ប្រពៃ ជាក្ដីប្រាថ្នារបស់ព្រះជាម្ចាស់ផងដែរ!" ។ ម្ដាយចៅ **សុមេធ** ក្រោយពីបានស្ដាប់សម្ដីប្ដីសព្វបែបយ៉ាងហើយ ក៏ពិចារណា ខំកាត់ចិត្តពីកូនសំណប់ ហើយព្រមអោយប្ដីនាំកូនទៅរកឥសីល្បីឈ្មោះដូចចិត្តប្រាថ្នា ។ ព្រឹកព្រាងអរុណរះច្បាស់ពន្លឺ ឪពុកចៅ **សុមេធ** ក៏រៀបចំនាំកូនឡើងជិះលើខ្នងសេះយ៉ាងមាំមួយ រួចក៏ធ្វើដំណើរចាកចេញដោយមានអ្នកបម្រើជំនិតម្នាក់ទៅជាមួយផង ។

ការធ្វើដំណើរអស់ពេលជាច្រើនថ្ងៃ ក៏បានមកដល់អាស្រមឥសីដូចក្ដីប្រាថ្នា ។ នៅបរិវេណអាស្រមពោរពេញទៅដោយទីជម្រកជាច្រើន[១៨] ខ្លះស្ថិតនៅជាប់មាត់

[១៨] ផ្ទះខ្ទម១សំរាប់អ្នកមករៀនស្នាក់នៅ ។

www.elibraryofcambodia.org

ស៊ឹង **សាវាថតី** តែម្តង ដែលជាមជ្ឈមណ្ឌលបណ្តុះវិជ្ជាទូទៅ។ នៅទីនោះមានតាបសឈ្មោះ **វិស្វយៈ** (Vishavayaka) និងតាបស **អក្សលក្ខ** (Ashalaka) ជាបណ្ឌិតជំនួយក្នុងការបង្ហាត់បង្រៀន និងមានសមណព្រាហ្មណ៍ ព្រមទាំងសិស្សមកពីទីជិតឆ្ងាយ ស្នាក់បួសរៀននៅទីនោះផងដែរ។ អាស្រមមហាឥសីនេះ ជាទីតាំងគោរពជំនឿមាន **ព្រះសិវា** (Shiva) **ព្រះវិស្ណុ** (Vishnu) និង **ព្រះវិដា** (Vidas)[១៩] ជាអ្នកបង្កើតអោយមានត្រកូលព្រាហ្មណ៍ - ត្រកូលអ្នករៀនធម៌មកដល់ជំនាន់ពួកគាត់។ ក្រោយពេលជាង ១០ ឆ្នាំកន្លងផុតមក **សុមេធ** ខិតខំរៀនសូត្រចប់សព្វគ្រប់ បានត្រូវដល់ថ្នាក់បញ្ចប់បរិញ្ញា ក្នុងវស្សា ២៧ គ្រប់វិជ្ជាធម៌វិន័យទាំងឡាយ ព្រមទាំងគម្ពីរត្រៃឧបនិស្ស័យ ដែលជាក្បួនធំរបស់មហាឥសី និងតាបសទាំងអស់បានត្រូវសមណ **សុមេធ** ចេះចប់គ្មានសល់ ប្រកបដោយបញ្ញាលើសលប់ គ្មានសិស្សណាប្រៀបស្មើបានឡើយ។

ថ្ងៃប្រឡងយកសញ្ញាប័ត្របានមកដល់ ពេលនោះមានគ្រូៗជាព្រាហ្មណ៍មកពីទីឆ្ងាយជិត ធ្វើការចោទសួរនូវបញ្ហាជាច្រើនដល់សមណ **សុមេធ** ក្នុងសំណួរធំៗជាច្រើន មានសំណួរមួយត្រូវអោយសមណ **សុមេធ** ដោះស្រាយគឺៈ គតិបណ្ឌិតនិងគុណធម៌។ សមណ **សុមេធ** ក៏បានបកស្រាយឡើងថាៈ "ការគោរពប្រតិបត្តិសច្ចៈធម៌ដោយសមាបត្តិទាំងឡាយនោះហើយ ជាគតិបណ្ឌិតដ៏ត្រឹមត្រូវ ក្នុងចិត្តរាល់រូបានេះជាការជៀសមិនរួចឡើយ!"។ ការបកស្រាយហេតុផលទាំងនេះ ធ្វើអោយពួកបណ្ឌិតៗព្រាហ្មណ៍ទាំងឡាយមានការស្ញប់ស្ញែងក្រៃលែង។ ទីបញ្ចប់នៃកម្មវិធីប្រឡង សមណ **សុមេធ** ក៏បានទទួលឥស្សរយសជា **សុមេធបណ្ឌិត** ចាត់ទុកថា ជាកំពូលអ្នកប្រាជ្ញនៅសម័យនោះ។

---

[១៩] រូបសំពាក់ដូចព្រះនរាយ។

www.elibraryofcambodia.org

នៅថ្ងៃដែលបណ្ឌិត **សុមេធ** ទទួលបានឋានៈនោះ ស្រាប់តែមានអ្នករត់សំបុត្រ បាននាំសំបុត្រមកពីស្រុកកំណើតគាត់ប្រាប់ដំណើរថា ឪពុកបណ្ឌិត**សុមេធ** ត្រូវទទួលមរណៈកាលទៅហើយ ទុកចោលអោយម្តាយនៅកំសត់ម្នាក់ឯង។ បណ្ឌិត **សុមេធ** ក៏សម្រេចចិត្តវិលត្រឡប់ទៅស្រុកកំណើតវិញ ដើម្បីមើលថែទាំម្តាយមេម៉ាយ។ រយៈពេលក្រោយមកទៀត ម្តាយ **សុមេធ** ក៏ទទួលអនិច្ចកម្មចោលទៅទៀត ក្រោយពីមាតាបិតាទទួលមរណៈកាលអស់ទៅ បណ្ឌិត **សុមេធ** ក៏យកទ្រព្យសម្បត្តិទាំងអស់របស់គ្រួសារគាត់ ចែកទានដល់រាស្ត្រក្រីក្រក្នុងស្រុក **អមរាវតី**។ អ្នកស្រុកឃើញហើយរំភើបចិត្តគ្រប់ៗគ្នា ខ្លះក៏មានសំណួរសួរថា: "លោកម្ចាស់! បើលោកម្ចាស់ចែកទានទ្រព្យសម្បត្តិរបស់លោកអស់ទៅ! តើលោកម្ចាស់រស់នៅម្តេចបាន!"។ **សុមេធ** បណ្ឌិតបានតបវិញថា: "យើងមិនត្រូវការទ្រព្យសម្បត្តិទាំងអស់នេះទេ! យើងត្រូវការតែម្យ៉ាង គឺក្លាយជាបុព្វជិតដើម្បីរកព្រះធម៌តែប៉ុណ្ណោះ!"។ ថាហើយ **សុមេធ** បណ្ឌិតចែកទានបន្តលុះត្រាតែអស់ ពេលនោះអ្នកបម្រើជាច្រើន បានសម្រេចចិត្តសុំទៅបួសតាមបម្រើ **សុមេធ** បណ្ឌិត ដូចដែលអ្នកបម្រើនៅតាមបម្រើចៅហ្វាយនាយដូច្នោះដែរ តែ **សុមេធ** បណ្ឌិតមិនចាត់ទុកអ្នកទាំងនោះជាអ្នកបម្រើឡើយ គឺចាត់ទុកជាសិស្ស និងជួយបង្រៀនធម៌ទាំងឡាយដល់ពួកគេ។ ចាប់ពីពេលនោះមក **សុមេធ** បណ្ឌិតក៏ទៅបួសជាតាបស ហើយអ្នកដែលនៅជាមួយទាំងនោះ ក៏បួសជាសិស្សរបស់គាត់ដែរ ពួកគាត់បាននាំគ្នាធ្វើដំណើរទៅរកព្រៃភ្នំក្រំថ្ម ដើម្បីកសាងអាស្រមសំរេកធម៌នៅទីនោះ។ តាបស **សុមេធ** និងសិស្សបានទៅធ្វើអាស្រមស្នាក់នៅក្នុងជនបទស្ងប់ស្ងាត់ដាច់ស្រយាល ស្ថិតនៅក្នុងព្រៃជិតស្រុកមួយឈ្មោះថា **រ៉ាថ្ថណា** (Rathhana) ស្រុកនេះសំបូរទៅព្រៃភ្នំក្រំថ្ម។ តាបស **សុមេធ** ខំព្យាយាមភាវនា

www.elibraryofcambodia.org

ធមិ សន្សំកុសលសព្វគ្រប់ប្រការ រហូតដល់ឈានដល់ការសម្រេចចបាននូវ **អភិញ្ញាណសមាបត្តិ** (Get enlightenment of accurate) ដែលជាកំពូលធមិនៅជំនាន់នោះ។ នៅសម័យថ្ងៃមួយ ពួកអ្នកស្រុកនាំគ្នាផ្ញើលទៅមើល ទៅគោរពព្រះ**ឌិពុន្នករ**[២០] (Dipankar) ជាព្រះពុទ្ធជំនាន់នោះ បាននិមន្តមកដល់ស្រុក **រ៉ាម៉្វារណា** ដើម្បីអនុមោទនាដល់ប្រជារាស្ត្រទីនោះ អ្នកស្រុកនាំគ្នាមូលមីរដេសដាស ទៅសុំការថ្វាយព្រះពរពីព្រះអង្គ។

ក្នុងស្រុក **រ៉ាម៉្វារណា** មានធីតាគ្រប់លក្ខណ៍ម្នាក់ឈ្មោះ **យ៉ាស៊ូវត្តី** (Yashuvatti) នាងតែងចេញទៅគោរពបូជាក្នុងព្រះវិហារព្រះម៉ែ **ណារ៉ាវ៉ាទ្រី** (Naravatri) ជារៀងរាល់ថ្ងៃ ថែមទាំងសង្ហាតធ្វើបុណ្យទានជាប្រចាំ។ នាង **យ៉ាស៊ូ** តែងសុំសេចក្តីពីព្រះម៉ែ សុំអោយជាតិក្រោយនាងបានជួបបុគ្គលទេព (Highest deity) ជាគូរគាប់ភ្ជាប់និស្ស័យ គឺបំណងប្រាថ្នាតែមួយគត់សម្រាប់ជីវិតនាង។ ថ្ងៃងពីតាបស **សុមេធ** ក្រោយពីដឹងថាព្រះពុទ្ធ **ឌិពុន្នករ** ទ្រង់និមន្តមកដល់ស្រុកខ្លួនរស់នៅ ក៏នាំគ្នាជាអ្នកបួសទាំងអស់ចេញពីអាស្រមមកកាន់ប្រជុំជន **រ៉ាម៉្វារណា** ដើម្បីថ្វាយបង្គំព្រះពុទ្ធ **ឌិពុន្នករ** និងគេឯងដែរ។ ពេលដែលក្រុមតាបស **សុមេធ** មកដល់ប្រជុំជន អ្នកស្រុកទាំងអស់គ្នាគិតស្មានថាជាព្រះពុទ្ធ **ឌិពុន្នករ** ក៏នាំគ្នាថ្វាយបង្គំគ្រប់ៗគ្នា តែតាបស **សុមេធ** បានប្រាប់ទៅអ្នកស្រុកវិញថា: "អាត្មាមិនមែនជាព្រះពុទ្ធ **ឌិពុន្នករ** ទេ! អាត្មាក៏ជា **បុថុជ្ជន** (Ordinary Person) ដែលមកចង់ឃើញព្រះពុទ្ធ **ឌិពុន្នករ** ដូចអ្នករាល់គ្នាដែរ!"។ បន្តិចក្រោយមកព្រះពុទ្ធ **ឌិពុន្នករ** និងសង្ឃសាវ័កក៏និមន្តមកដល់ទីកន្លែងនោះ អ្នក

---

[២០] ដូចគ្នានិងពាក្យ **ព្រះពុទ្ធទីបង្ករ**

www.elibraryofcambodia.org



សុមេធតាបសដេកធ្វើជាស្ពាន
អោយព្រះពុទ្ធទិពង្គរៈឆ្លងកាត់ភក់

ស្រុកនាំគ្នាគោរពព្រះអង្គ តាបស **សុមេធ** និងក្រុមរបស់គាត់នាំគ្នាគោរព **ព្រះពុទ្ធ** ដូចអ្នកស្រុកដែរ។ នៅពេលនោះក្រុមព្រះពុទ្ធ **ទិពង្គរៈ** និងសាវ័កត្រូវនិមន្តឆ្លងកាត់កូនថ្លុកមួយ ដែលពោរពេញដោយភក់ជ្រាំ។ តាបស **សុមេធ** ក្រឡេកឃើញថ្លុកសុទ្ធតែភក់ គាត់ក៏មានចិត្តសទ្ធាលះបង់ ដើម្បីព្រះពុទ្ធ **ទិពង្គរៈ** ក៏ពោលឡើងទៅកាន់ព្រះពុទ្ធ និងសាវ័កព្រះអង្គថា: "ដើម្បីកុំអោយប្រឡាក់ព្រះបាទារបស់ ព្រះអង្គអាត្មាសុខចិត្តដេកធ្វើជាស្ពានអោយព្រះពុទ្ធនិងសាវ័កទាំងអស់ឆ្លងកាត់!"។ ថាហើយតាបសចិត្ត បុណ្យក៏ប្រះខ្លួនដេកធ្វើជាស្ពានអោយព្រះពុទ្ធ និងពួកសាវ័កឆ្លងលុះត្រាផុតអស់ នៅពេលនោះព្រះពុទ្ធ **ទិពង្គរៈ** និងសាវ័កបានឆ្លងផុតភក់ ហើយទ្រង់ប្រមើលដឹងថា: តាបសនេះជាអង្គព្រះពុទ្ធបណ្តូលសារពេជ្រកត្តាញ្ញូណ តំណទៅមុខនឹងបានត្រាស់ដឹងជាព្រះពុទ្ធព្រះនាម **សមណគោត្តម** នៅនិតិកាលអាណត្តិក្រោយនេះ។ ទ្រង់ដឹងដូច្នេះញញឹមហើយនិមន្តចេញទៅ ចំណែកអ្នកស្រុកឃើញការលះបង់របស់តាបសយ៉ាងនេះ នាំគ្នាស្ងើចសរសើរក្រៃលែងដោយលាន់មាត់ថា: "គ្មានបុគ្គលណាហ៊ានធ្វើដូចគាត់បានឡើយ"។ បន្ទាប់មកក្រុមព្រះពុទ្ធ **ទិពង្គរៈ** និងក្រុមតាបស **សុមេធ**នាំគ្នាទៅសម្រាកក្រោមដើមឈើធំមួយនៅជាយក្រុង ដើម្បីទុកឱកាសអោយពួកអ្នកស្រុកនាំគ្នាមកថ្វាយបង្គំសុំសេចក្តីបំណង ដែលខ្លួនប៉ងប្រាថ្នា។ គ្រានោះនាង **យ៉ាសូ** ក៏មកថ្វាយបង្គំព្រះពុទ្ធ **ទិពង្គរៈ** ក្រាបក្បាលដល់ព្រះបាទា ៨ ដង ហើយដាក់ផ្កាថ្វាយ ៨ ទងដែរ។ ព្រះពុទ្ធ **ទិពង្គរៈ** សួរទៅនាង **យ៉ាសូ** ថា: "នាងថ្វាយបង្គំយើង ៨ ដង! ព្រមទាំងប្រគេនផ្កា ៨ ទងទៀត!

www.elibraryofcambodia.org

តើនាងមានបំណងប្រាថ្នាអ្វីទៅ? - នាង **យ៉ាសូ** ឆ្លើយតបដោយប្រណមហត្ថាបង្គំទូលទៅព្រះអង្គវិញថា: "ចាំទាំង ៨ នេះជាតំណាងគុណធមិទាំង ៨ របស់ខ្ញុំករុណាដោយប្រាថ្នាសុំអោយបានធ្វើជាមហេសីនៃ **ព្រះអច្ឆរិយៈសុមេធ** គឺ **ព្រះបរមសាស្តា** ជំនាន់ក្រោយនេះ! សូមព្រះអង្គមេត្តាផងចុះ!"។ ព្រះពុទ្ធ **ទិពង្គរៈ** ទ្រង់ញញឹមពេញព្រះទ័យ ទ្រង់បានប្រទានពរតាមសេចក្តីប្រាថ្នារបស់នាង តែព្រះអង្គទ្រង់លួចក្រឡេកមើលទៅតាបស **សុមេធ** ឯណោះវិញ ក្នុងន័យបំពេញសេចក្តីប្រាថ្នារបស់នាង **យ៉ាសូ** តាបសក៏ញញឹមដោយយល់ព្រម សម្រាប់ជាតិខាងមុខគឺជាឧប្បនិស្ស័យ។ បន្ទាប់មកតាបស **សុមេធ** ក៏ថ្វាយបង្គំលាព្រះពុទ្ធ **ទិពង្គរៈ** ដើម្បីនាំសិស្សត្រឡប់ទៅអាស្រមវិញ។ នៅតាមផ្លូវពេលកំពុងធ្វើដំណើរ តាបស **សុមេធ** បានជួបនឹងមនុស្សខ្វាក់ភ្នែកម្នាក់ កំពុងធ្វើដំណើរត្រាច់ចរដោយមានបំណងប្រាថ្នាចង់ជួបតាបស **សុមេធ** ដែលល្បីឈ្មោះ និងចិត្តសប្បុរធមិសង្គ្រោះធ្វើទាន។ ពេលបានជួបតាបស **សុមេធ** ហើយ បុរសខ្វាក់ភ្នែកមិនស្គាល់តាបស ដែលខ្លួនកំពុងជួបនោះឡើយ គាត់សួរទៅតាបសថា: "តើផ្លូវណាទៅកាន់អាស្រមតាបស **សុមេធ** សូមមេត្តាជួយបង្ហាញផ្លូវផង!"។ - តាបស **សុមេធ** ក៏សួរទៅមនុស្សខ្វាក់នោះវិញថា: "តើអ្នករកគាត់មានការអ្វី?" បុរសខ្វាក់តបវិញដោយលើកដៃសំពះថា: "ឱ! លោកម្ចាស់អើយ! ខ្ញុំប្រាថ្នាជួបតាបសដោយក្តីសុទ្ធចិត្ត! ខ្ញុំឮល្បីថាគាត់មានចិត្តមេត្តាករុណាធមិសង្គ្រោះធ្វើទាន! បើមិនបានជួបជាតិនេះទេ! ខ្ញុំសូមប្រាថ្នាជាតិក្រោយសុំអោយជួបគាត់ដូចក្តីប្រាថ្នា"។ តាបស**សុមេធ** ឮហើយរំភើបចិត្ត ក៏ប្រញាប់ប្រាប់ទៅបុរសខ្វាក់វិញថា: "អ្នកមិនបាច់ជាតិក្រោយទេ! អ្នកនឹងឃើញនូវអ្វីដែលអ្នកប្រាថ្នានៅជាតិនេះតែម្តង អាត្មាគឺជាតាបសដែលអ្នកតាមរកនោះហើយ អាត្មានឹងអោយភ្នែកម្ខាងរបស់អាត្មាដល់អ្នក"។បុរសខ្វាក់

www.elibraryofcambodia.org

ភ្នែកបន្ទាប់ពីបានឮសម្ដីបែបនេះ គាត់មានចិត្តត្រេកអររំភើបញាប់ញ័រ លើកដៃសំពះតបទៅតាបសវិញដោយសំដីថា: "ឱ! លោកម្ចាស់អើយ! គឺលោកនេះហើយជាព្រះរបស់ខ្ញុំ"។ បន្ទាប់មកតាបស **សុមេធ** ក៏នាំបុរសខ្វាក់នោះទៅរកគ្រូពេទ្យដើម្បីធ្វើការវះកាត់ដោយធ្វើទានភ្នែក។ រយៈពេលមិនយូរប៉ុន្មាន គ្រូពេទ្យយ៉ាងចំណានម្នាក់ បានធ្វើការវះកាត់ដោយជោគជ័យ ដោយយកភ្នែករបស់តាបសម្ខាងទៅអោយបុរសខ្វាក់។ បុរសខ្វាក់ក៏បានភ្លឺភ្នែកម្ខាង ចំណែកឯតាបសក៏ពិការភ្នែកម្ខាងរបស់ខ្លួនទៅ។

ពេលវេលាកន្លងផុតទៅជាច្រើនឆ្នាំ វ័យចាស់ជរាក៏មកដល់ខ្លួនតាបស **សុមេធ** ក្រោយមកគាត់ក៏ទទួលមរណៈកាល ក្នុងភាពពិការភ្នែកម្ខាងនៃវ័យជរាព្យាធិនោះទៅ។តេជៈ ភាពនៃទាន (Acuity of Donate) របស់តាបស **សុមេធ** បានញ៉ាំងអោយមហាប្រថពីមានការរំជើបរំជួលញាប់ញ័រ តាបសចិត្តបុណ្យកាលអស់ព្រះជន្មហើយ ក៏បានទៅកើតនៅឋានត្រៃត្រឹង្ស (Realm of the gods) ដែលមាន **ព្រះសក្កទេវរាជ** (King of Angles) **ព្រះព្រហ្ម** (Brama) **ព្រះសិវា**(Shiva) **ព្រះវិស្ណុ** (Vishnu) ព្រមទាំងទេវតាទេពធីតារាប់ម៉ឺនស្ថិតនៅចក្រវាឡ បានរៀបចំពិធីយ៉ាងឱឡារិកទទួល **ព្រះសុមេធ** ទទួលតំណែងជាព្រះពុទ្ធអាណត្តិក្រោយនាចក្រវាឡ និងផែនដីមនុស្សលោក។ **ព្រះសក្កទេវរាជ** ជាប្រមុខទេវស្ថាន បានអារាធនាដោយព្រះបន្ទូលទៅកាន់ **ព្រះសុមេធ** ថា: "តើព្រះអង្គពេញព្រះទ័យបដិសន្ធិនៅវណ្ណៈណា? និងបដិដ្ឋាន (Place of birth) នៅទី


ព្រះទេវសុមេធបានកើតនៅឋានទេវលោក (ស្រង់ចេញពី Internet)

www.elibraryofcambodia.org

ណា? ដែលជាមាគ៌ាទ្រង់ត្រាស់ដឹងពោធិញ្ញាណ (Enlightenment) និងព្រះនិពាន្វ (Nirvana) ដើម្បីចំឡងសត្វលោក សត្វនិករអោយចាកទុក្ខសោកទាំងពួង ។

**ព្រះទេវសុមេធ** ទ្រង់សណ្តាប់ហើយក៏ប្រមើលនូវ **មហាវិលោកនៈ** (Great Perfect World) ទាំង ៥ ប្រការគឺៈ កាល ទីកន្លែង នគរ (ទ្វីប) ត្រកូល មាតាបិតា ទើបព្រះអង្គទ្រង់ផ្តល់បដិញ្ញាណដល់អស់ទេវទាំងឡាយថាៈ "មហាទ្វីប ទាំង ៣ អង្គ **ព្រះពោធិសត្វ** ដែលជា **ព្រះពុទ្ធ** ទ្រង់មិនដែលបដិសន្ធិនៅទីនោះ ឡើយ គឺមានតែនៅក្នុង **ជម្ពូទ្វីប** មួយប៉ុណ្ណោះ! ដែលជាបដិដ្ឋានសម្រាប់ ព្រះអង្គ"។ **ព្រះទេវសុមេធ** ទ្រង់បដិសញ្ញាបែបនេះហើយ ទ្រង់ក៏យកជាតិក្នុង **អរិយក** នៃត្រកូល **សក្យវង្ស** (Sakya) ក្នុងនគរ **កបិលព័ស្តុ**(Kapilavastu) ចំណែកព្រះមាតាទ្រង់ប្រមើលសំដៅពុទ្ធមាតា ដែលជារាជធីតាមានអភិនិហា កសាងតាំងពីបុរេសន្និវាស ប្រកបដោយបុណ្យបារមីធមិបំពេញគ្រប់មួយសែនកប្ប មកហើយ ។ **ព្រះសក្កទេវរាជ** ទ្រង់ក៏សម្រេចជាធរមានបញ្ហា **មហាវិលោ-កនៈ** អោយ **ព្រះទេវសុមេធ** យាងចុះច្យុតចាកទេវស្ថាន មកចាប់បដិសន្ធិក្នុង ផ្ទៃព្រះនាង **មហាមាយា** (Maha Maya) ដែលជាអគ្គមហេសីនៃព្រះបាទ **សុទ្ធោទនៈ**(Suddhodana) សោយរាជ្យសម្បត្តិក្នុងនគរ **កបិលព័ស្តុ** ។

(ចប់រឿងនិទាន **សុមេធ** បណ្ឌិត)

www.elibraryofcambodia.org

# វគ្គទី២

# ព្រះញាតិវង្សរបស់ព្រះសាស្តា

# (The Royal Family of Preah Sassda)

ក្នុងព្រះត្រៃបិដកមានតែគម្ពីរ **សុត្តន្តបិដក** ទេ ដែលមានចំនួនសៀវភៅច្រើនជាងគេ ហើយពោរពេញដោយរឿងរ៉ាវច្រើនឥតគណនា ចាប់តាំងពី **ធម្មបទ. សិគាលោវាទសូត្រ. ព្យគ្ឃបជ្ជសូត្រ. មង្គលសូត្រ. ករណីសូត្រ. បរាភវសូត្រ. វសលសូត្រ.** រហូតដល់ **ធម្មិកសូត្រ** មានប្រវត្តិសំខាន់ៗនៃអង្គសាវ័កទាំង ៥ អង្គ និងរឿងរ៉ាវជាច្រើនទៀត ដែលអ្នកប្រាជ្ញបណ្ឌិតពុទ្ធសាសនិកទាំងឡាយ បានខំធ្វើការគូសបញ្ជាក់ថា សូម្បីតែរឿងរ៉ាវ **ព្រះពុទ្ធ** ផ្ទាល់ ក៏មាននៅក្នុងគម្ពីរនេះដែរ ដូច្នេះហើយពួកកវីនិពន្ធ វិចិត្រករ បាននាំគ្នាយកមកចងក្រងតាំងពីបុរាណតរៀងមក ពិសេសនៅក្នុងរជ្ជកាលស្តេច **សោវម៌្មនទី១** ក្នុងគ.ស ៨៨៩ នៃព.ស ១៤៣២ កាលនោះគឺនៅរាជធានីអង្គរធំ ព្រះអង្គបានប្រកាសលើកព្រះពុទ្ធសាសនាជាផ្លូវការក្នុងផ្ទៃនគរ ពេលនោះហើយដែលមានស្នាដៃនិពន្ធជាច្រើនរបស់ពួកកវីមានឡើងដូចជា[២១] : កវី **សិវសោម** ( ជំនាន់ស្តេច **ឥន្ទ្រវម៌្មន** គ.ស ៨៧៧-៨៨៩ ) ។ កវី **យតិរមនភាវៈ** ( ជំនាន់ស្តេច **យសោវម៌្មន** គ.ស ៨៩៩-៩០៨ ) ។ កវី **ទិវាករ** ( ជំនាន់ស្តេច **រាជេន្ទ្រវម៌្មន** គ.ស ៩៤៤-៩៦៨ ) ។ កវី **ត្រូបន្រ្ទ** ( ជំនាន់ស្តេច **ជ័យវម៌្មន** ទី៧ គ.ស ១០៩០-១១០៩ ) ។ ព្រះនាង **ឥន្ទ្រទេវី** ( មហេសីស្តេច **ជ័យវម៌្មន** ទី៧ គ.ស ១០៩០-១១០៩ ) ដូចគ្នា។ ឈ្មោះទាំងនេះ គឺសំដៅ

---

[២១] ក្រុមអ្នកនិពន្ធខ្មែរសម័យអង្គរ សៀវភៅលោក **ឈី ធារមគេច** បោះពុម្ពឆ្នាំ គ.ស១៩៧២ ព.ស ២៥១៦ ។

www.elibraryofcambodia.org

តែអ្នកល្បីឈ្មោះប៉ុណ្ណោះទេ នៅមានអ្នកមិនល្បីជាច្រើនទៀត ទោះជាយើងមិនដឹងច្បាស់ថា ការនិពន្ធសម័យនោះមានលក្ខណៈបែបណាក៏ដោយ ក៏យើងដឹងថា អក្សរសិល្ប៍គឺចេញពីប្រភពទីវត្តអារាមទាំងអស់ ព្រោះសម័យនោះ មានតែវត្តព្រះពុទ្ធសាសនានេះឯង ដែលជាមជ្ឈមណ្ឌលបណ្តុះបណ្តាលអោយមានទូវចំណេះវិជ្ជាឈានដល់ការចេះដឹងតែងនិពន្ធបែបនេះឡើង ហើយក៏បានធ្វើអោយព្រះពុទ្ធសាសនា កាន់តែល្បីខ្ចរខ្ចារពេញដែនមហានគរ ហើយមានតែ **ព្រះពុទ្ធថេរវាទ** ទេ ដែលនៅគង់វង្សទល់សព្វថ្ងៃ។ តំណក្រោយៗមកទៀត ពួកជាងគំនូរ គូរឆ្លាក់រឿងនិទានព្រះពុទ្ធប្រវត្តិ (Biography of Buddha) តាមប្រាង្គប្រាសាទ ជញ្ជាំងព្រះវិហារនានាពាសពេញផ្ទៃប្រទេស។

ឯប្រទេសដែលកាន់ព្រះពុទ្ធសាសនា **មហាយាន** ក៏មានឆ្លាក់រឿងព្រះពុទ្ធនិទានតាមព្រះវិហាររបស់ខ្លួនផងដែរ មិនខុសពីខ្មែរយើងឡើយ។ យោងតាមរឿងរ៉ាវទាំងនេះហើយ ទើបខ្ញុំករុណា ខ្ញុំបាទរៀបរៀងឡើងតាមលក្ខណៈរឿងដោយ រៀបរាប់ពីព្រះញាតិវង្សព្រះបរមគ្រូនៃយើងនៅវគ្គនេះដូចទៅៈ

ក/ រាជវង្សខាងព្រះពុទ្ធបិតា ព្រះនាម **សក្យវង្ស** សោយរាជ្យនៅនគរ **កបិលព័ស្តុ**។

ខ/ រាជវង្សខាងព្រះពុទ្ធមាតា ព្រះនាម **កោលិយវង្ស** សោយរាជ្យនៅនគរ **ទេវទហៈ**។

www.elibraryofcambodia.org

គ/ ព្រះញាតិវង្សព្រះពុទ្ធបិតា

-ព្រះបាទ **សីហហនុ** (អ័យ្យកាលួតព្រះពុទ្ធ)

⇩

ព្រះបាទ **ជ័យសេន** (អ័យ្យកាទួតព្រះពុទ្ធ)

⇩

ឃ/ព្រះ **សីហហនុរាជ** មហេសីព្រះនាង **កច្ចានា**

(ជីតាព្រះពុទ្ធ) | (ជីដូនព្រះពុទ្ធ)

⇩ ⇩

មានរាជបុត្រា ៣ អង្គ— មានរាជបុត្រី២អង្គ

១-បុត្រាច្បង: ព្រះបាទ **សុទ្ធោទនៈ** (បិតាព្រះពុទ្ធ)

២-បុត្រាទី២: ព្រះបាទ **សុក្កោទនៈ** (ឪពុកមាទី១ព្រះពុទ្ធ)

៣-បុត្រាទី៣: ព្រះបាទ **អមិតោ្តទនៈ** (ឪពុកទី២មាព្រះពុទ្ធ)

៤-បុត្រីទី៤: ព្រះនាង **អមិត្តា** (ម្តាយមីងទី១ព្រះពុទ្ធ)

៥-បុត្រីទី៥: ព្រះនាង **បមិត្តា** (ម្តាយមីងទី២ព្រះពុទ្ធ)

ង/ ព្រះញាតិវង្សព្រះពុទ្ធមាតា

(គ្មានឯកសារបញ្ជាក់អំពីអ័យ្យកា និង

- អ័យ្យកោខាងព្រះពុទ្ធមាតាទេ)

ច/ ព្រះបាទ**អញ្ជនៈ** មហេសី **យសោធរា**

(ជីតាព្រះពុទ្ធ) | (ជីដូនព្រះពុទ្ធ)

⇩ ⇩

មានរាជបុត្រី២អង្គ — មានរាជបុត្រា២អង្គ

១-ព្រះនាង**មហាមាយា** (ព្រះមាតាព្រះពុទ្ធ)

២-ព្រះនាង**បជាបតី** (ម្តាយមីងទី១ព្រះពុទ្ធ)

៣-ព្រះបាទ **សុប្បពុទ្ធ** (ឪពុកមាទី១ព្រះពុទ្ធ)

៤-ព្រះបាទ**ទណ្ឌបាណិ** (ឪពុកមាទី២ព្រះពុទ្ធ)

www.elibraryofcambodia.org

# វគ្គទី៣
# ព្រះបាទសុទ្ធោទនៈ និងព្រះនាងមហាមាយា
# (King Suddhodana and his wife Mahamaya)



ព្រះបាទសុទ្ធោទនៈ និងព្រះនាងមហាមាយា
(ស្រង់ចេញពីវត្តសំរោងអណ្តែត)

មានពុទ្ធសាសនិកយើងខ្លះ បានដឹងរឿងពុទ្ធប្រវត្តិ ចាប់ផ្តើមត្រឹមតែព្រះអង្គចុះចាប់បដិសន្ធិក្នុងផ្ទៃមាតាប៉ុណ្ណោះ មិនសូវបានដឹងពីប្រវត្តិមាតាបិតារបស់ **ព្រះពុទ្ធបរមគ្រូ** នៃយើងឡើយ ដូច្នេះខ្ញុំករុណា ខ្ញុំបាទសូមរៀបរាប់នូវប្រវត្តិសង្ខេបខ្លះៗ នៃព្រះពុទ្ធបិតា និងព្រះពុទ្ធមាតាដូចតទៅៈ

នៅក្នុងរាជ្យព្រះបាទ **សីហហនុរាជ** (ជីតាព្រះពុទ្ធ) ដែលកំពុងគ្រងរាជ្យក្នុងនគរ **កបិលពស្តុ** នោះ ព្រះអង្គមានព្រះទ័យចង់រៀបចំអោយបុត្រាច្បងរបស់ព្រះអង្គ គឺព្រះបាទ **សុទ្ធោទនៈ** អោយមានមហេសី ប៉ុន្តែការជ្រើសរើសបវរកញ្ញា ដែលមានលក្ខណៈ **កបកល្យាណី** នោះជាការពិបាក ដូច្នេះទើបព្រះអង្គប្រទានរាជសម្បត្តិរាប់ពាន់កហាបណៈ (លុយសម័យបុរាណ) ដល់ក្រុមព្រាហ្មណ៍ដែលជំនាញខាងគន់គូររូបសម្បត្តិរាជធីតា អោយស្វែងរកព្រះនាងមកជាគូមហេសី។ ក្រុមព្រាហ្មណ៍បានទទួលរាជបញ្ជាធ្វើដំណើរដោយទាំងគ្រឿងអលង្ការ ប្រដាប់ប្រដាខ្លះជាភស្តុតាងនៃរាជបណ្ណាការទៅជាមួយផង។ នៅនគរ **ទេវទហៈ** (Devadarsi-

www.elibraryofcambodia.org

ta) មានរាជធីតាមួយអង្គព្រះនាម **មហាមាយា** ប្រកបដោយបណិធិកុសល (Possession of merit) បានកសាងតាំងពីអតីតជាតិពីជំនាន់ព្រះពុទ្ធ **វិបស្សី** មកម្ល៉េះ ព្រះនាងបានចាប់កំណើតក្នុងរាជវង្ស **កោលិយវង្ស** (Kauleyak) ជាបុត្រីច្បងរបស់ព្រះបាទ **អញ្ជនធិរាជ** និងអគ្គមហេសីព្រះនាង **យសោធរា**។ រាជធីតា **មហាមាយា** ជាកល្យាណីស្ថិតក្នុងវ័យវឌ្ឍនាការក្នុងព្រះជន្ម ១៦ វស្សា ជារាជធីតាមានសម្ផស្សល្អស្រស់លើសស្រីនានា នៅរដូវផ្ការីក ព្រះនាងយាងចេញកំសាន្តក្នុងសួនឧស្សាន ប្រកួតប្រជែងនឹងផ្កាចម្រុះពណ៌ ហែរហមដោយភីលៀងស្នំកា សេនាអាមាត្យជាច្រើន។ ផ្លែងពីក្រុមព្រាហ្មណ៍ដែលស្វែងរករាជធីតាកល្យាណីថ្វាយជាមហេសីព្រះរាជបុត្រា **សុទ្ធោទនៈ** នោះបានធ្វើដំណើរអស់ជាច្រើនថ្ងៃ មិនបានប្រទះសោះ លុះមកដល់នគរ **ទេវទហៈ** នៅសួន **ឧិត្យា** (Autaya park) ក៏ប្រទះឃើញរាជធីតា **មហាមាយា** ដ៏ល្អឆើត កំពុងក្រសាលលេងសប្បាយជាមួយពួកភីលៀង។ ក្រុមព្រាហ្មណ៍លួចមើលពីចម្ងាយ ហើយកេះតៗគ្នាប្រាប់ថា អោយជួយមើលគ្នា មើលហើយមើលទៀត ដោយពិនិត្យពិច័យ្យ និងការចាប់អារម្មណ៍ជាខ្លាំង ព្រោះហេតុថា ពួកគាត់មិនដែលជួបប្រទះទាល់តែសោះ។ មេក្រុមព្រាហ្មណ៍ម្នាក់ក្នុងចំណោមនោះបានពោលឡើងមុនគេថាៈ "នេះពិតជារាជធីតាបញ្ចពិធកល្យាណី (Five Beauties) គ្មានរាជធីតាណាប្រដូចបានឡើយ"។ ព្រាហ្មណ៍ម្នាក់ទៀតបន្ថែមថាៈ "ព្រះនាងជាកំពូលរាជធីតាដែលយើងកំពុងតាមរកនោះហើយ"។ ព្រាហ្មណ៍ម្នាក់ទៀតក៏បន្តថាៈ "ព្រះនាងប្រហែលជាគូព្រេងរបស់រាជកុមារយើងហើយ រាជបុត្រាពិតជាសព្វព្រះទ័យ!"។ ក្រោយពីការគិតគូរគ្នារួចហើយ ពួកគាត់ក៏នាំគ្នាចូលទៅថ្វាយបង្គំព្រះរាជធីតា ដើម្បីទូលថ្វាយពីបំណងរបស់ពួកគេ។ រាជធីតាយល់សេចក្តីរបស់ព្រាហ្មណ៍ ក៏គួរសមទៅវិញ

www.elibraryofcambodia.org

ដោយមានសុវណ្ណ (និយាយ) ប្រាប់អោយពួកគាត់ទៅគាល់ព្រះបិតា។ ក្រុមព្រាហ្មណ៏ក៏បង្គំលា ដើម្បីទៅចូលគាល់ព្រះបាទ **អញ្ជន**។ ក្រោយពីបានជួបព្រះបាទ **អញ្ជន** និងរ៉ាយរ៉ាប់តាមដំណើរពីកិច្ចចង ស្ពានមេត្រី។ ព្រះបាទ **អញ្ជន** មិនមានព្រះទ័យយល់ទោះអ្វីឡើយ ព្រះអង្គទ្រង់មានរាជឱង្ការ (និយាយ) ទៅកាន់ពួកព្រាហ្មណ៏ថា: "ចូរអស់លោកទាំងអស់គ្នា! ទៅទូលដំណឹងល្អដល់ព្រះរាជា **កបិលពស្តុ** វិញចុះ! យើងយល់ព្រមគ្រប់ប្រការហើយ! អ្វីៗស្រេចខាងព្រះអង្គទ្រង់ចាត់ចែងទៅចុះ!"។ ក្រុមព្រាហ្មណ៏ឮហើយ មានសេចក្តីត្រេកអរជាខ្លាំង បន្ទាប់មកក៏នាំគ្នាថ្វាយបង្គំលាព្រះរាជា **អញ្ជន** ត្រលប់ទៅនគរ **កបិលពស្តុ** វិញ។ លុះមកដល់បុរី ក្រុមព្រាហ្មណ៏ស្រដីទូលរ៉ាយរ៉ាប់ដល់ព្រះបាទ **សីហហនុរាជ** និងអគ្គមហេសីសព្វសេចក្តីទាំងអស់។ ក្នុងថ្ងៃដែលក្រុមព្រាហ្មណ៏នាំដំណឹងល្អមកថ្វាយ ក្នុងរាត្រីនោះ ព្រះអង្គទ្រង់សុបិន្តនិមិត្តឃើញថា ស្រាប់តែមានវិមានកែវមុនីរត្ន (Precious Stone Palace) ដ៏ខ្ពស់ស្កឹមស្កៃមួយមានជាច្រើនជាន់ បានផុសពីផ្ទៃប្រថពី ស្ថិតនៅចំពាក់កណ្តាលជម្ពូទ្វីប បន្ទាប់មកទ្រង់សុបិន្តបន្តទៀតថាឃើញសំពៅដ៏អស្ចារ្យមួយបើកកាត់មហាសមុទ្រ ដែលពោរពេញទៅដោយទឹករលកធំៗ នៅក្នុងសំពៅនោះមានរាជនីមួយអង្គ ជាអ្នកភេត្រា (Ship driver) ផងទ្រង់កាន់ពានទិព្វផង ដោយមានគ្រាប់ពេជ្រមួយ គ្រាប់មានពណ៌ឆព្វណ្ណរង្សី (Six colors of light) ចែងចាំងពេញផ្ទៃពានទិព្វ រហូតលេចចេញក្រៅនៃសំពៅ ស្របកាលវេលាយ៉ាងល្អប្រសើរ បានដំណឹងពីក្រុមព្រាហ្មណ៏ផង ធ្វើអោយព្រះអង្គ និងមហេសីមានព្រះទ័យសែនរីករាយឥតឧបមា ទ្រង់បានបញ្ជាដល់ពួកនាហ្មឺនមន្ត្រីសេនាបត្តីរៀបពិធីធ្វើដំណើរទៅកាន់នគរ **ទេវទហៈ** ដើម្បីអាស្រ័យទាក់ទងនឹង

www.elibraryofcambodia.org



ពិធីរៀបអភិសេក ( ស្រង់ចេញពី Internet )

ព្រះបាទ **អញ្ជន** ធ្វើកិច្ចពិភាក្សារឿងបញ្ហារាជមង្គលការបុត្រាបុត្រី។ មិនជាយូរប៉ុន្មានមហាក្សត្រនៃរាជវង្សទាំងពីរ ក៏បានជួបគ្នា ហើយមហារាជទាំងពីរ ទ្រង់នាំគ្នាមកកំសាន្តក្នុងសួន **ពិន្នីវ័ន** (Pinnivana Park) ក្នុងរាជធានី **ទេវទហៈ** ទ្រង់បានសន្ទនាគ្នាជាច្រើនប្រការ ដើម្បីរៀបចំពិធីបណ្ណាការអភិសេកបុត្រទាំងពីរ អោយសមតាមកិត្តិយសនាមនៃក្សត្រទាំងពីរ។ រាជានគរ **ទេវទហៈ** បានបញ្ជាអោយសេនាតាក់តែងមហាប្រាសាទមួយយ៉ាងប្រណិត ក្នុងរាជពិធីមង្គលការនោះ។ ថ្ងៃរាជមង្គលការបានមកដល់រាជបុត្រា **សុទ្ធោទនៈ** និងបុត្រី **មហាមាយា** បានទទួលសិរីមង្គលដ៏ល្អបវរ និងយ៉ាងមហាឱឡារិកដោយមានការបាចផ្កាជូនពរពីព្រះញ្ញាត្តិវង្សទាំងពីរនគរ ព្រមទាំងពីសំណាក់ទេវតាដែលរក្សាប្រាង្គប្រាសាទផងដែរ។ ចប់សព្វគ្រប់នូវពិធីមង្គលការនេះហើយ ព្រះញាត្តិវង្សខាងព្រះបាទ **សីហនុរាជ** ក៏បានលាព្រះញាតិវង្សខាងព្រះបាទ **អញ្ជន** ត្រឡប់ទៅនគរ **កបិលពស្តុ** វិញ ដោយនាំទាំងបុត្រាបុត្រី ទើបរៀបការហើយថ្មោងថ្មីទៅជាមួយផងដែរ។ ច្រើនឆ្នាំក្រោយមក ព្រះបាទ **សីហហនុរាជ** និងព្រះមហេសីក៏ទ្រង់សោយទិវង្គតដោយព្រះរោគាជរាព្យាធិ។ ពួកនាហ្មឺនមន្ត្រីក្នុងនគរក៏រៀបចំធ្វើឈាបនកិច្ច (cremation) បូជាព្រះភ្លើងថ្វាយព្រះសពចប់សព្វគ្រប់ប្រការ ហើយក៏មានពិធីឡើងសោយរាជសម្បត្តិស្នងពីព្រះបិតា។ ព្រះបាទ **សុទ្ធោទនៈ** ក៏បានគ្រងរាជ្យក្នុងនគរ **កបិលពស្តុ** ជាមួយអគ្គមហេសីព្រះនាង **មហាមាយា** សែនសុខសាន្តចាប់តាំងពីពេល នោះមក។

www.elibraryofcambodia.org

# វគ្គទី៤

# ព្រះនាងបជាបតី (Princess Prajapati)



ព្រះនាងបជាបតិ និងព្រះរាជកុមារសិទ្ធត្ថ
‹ ស្រង់ចេញពី Internet ›

ព្រះនាង **បជាបតី** ជាប្អូនស្រី បន្ទាប់ពីព្រះនាង **មហាមាយា** ជារាជធីតាគ្រប់វ័យការហើយ តែព្រះនាងមិនព្រមទទួលយកស្វាមីទាល់តែសោះ ព្រះនាងបានមករស់នៅជាមួយបងស្រី ក្នុងនគរ **កបិលពស្តុ** ដែរ ។ រាជធីតាទាំងពីរទៅណាមកណា មិនដែលចោលគ្នាឡើយ ប្រៀបដូចជាបក្សីមួយគូរ ។ ព្រះនាង **មហាមាយា** ជាបងស្រីតែងចំអន់លេងដោយសួរប្អូនស្រី តើពេលណាបានព្រះនាង **បជាបតី** ត្រូវមានស្វាមីនឹងគេ តែព្រះនាង **បជាបតី** មិនដែលស្រដីថា ខ្លួនព្រមយកស្វាមីនោះឡើយ ។ ថ្ងៃមួយនៅក្នុងសួនច្បារព្រះនាង **មហាមាយា** បានសួរទៅធីតា **បជាបតី** ជាប្អូនស្រីថាៈ "**បតី** ប្អូនស្រី! ប្អូនគួរតែគិតគូរ ល្មមបានព្រះស្វាមីហើយ! បងមើលទៅប្អូនអាយុកាន់តែច្រើន ពិចចាស់ហោ! ពិបាករកស្វាមីណាស់!"។ ព្រះនាង **បជាបតី** ក៏ស្រដីតបវិញថាៈ "សូមទ្រង់កុំមានសុរិយោដូច្នេះ! ខ្ញុំម្ចាស់មិនគិតទេ! បើសិនជាអាចមានមែន! គឺនៅថ្ងៃដែលខ្ញុំម្ចាស់ពោះក្មួយពរ គឺរាជបុត្រម្ចាស់បងនេះឯង"។ ព្រះនាង **មហាមាយា** បានឮហើយ ក៏មានតម្រិះវិញថាៈ "បើអញ្ចឹង! ប្អូនស្រីប្រាកដជាមានស្វាមីនៅថ្ងៃនោះមិនខាន"។

www.elibraryofcambodia.org

ពាក្យសុវណ្ណីឆ្លងឆ្លើយ គ្រាន់តែជាពាក្យលេងសើចប៉ុណ្ណោះ ប៉ុន្តែមានអត្ថន័យហាក់ដឹងជាមុននៅថ្ងៃអនាគត ជាកត្តាកំណត់ផលបុណ្យសាងពីអតីតជាតិ។ ព្រះនាង **បជាបតី** មានបុណ្យកុសលបារមីដូចព្រះនាង **មហាមាយា** ជាបងស្រីដែរ ដោយព្រះនាងបានបំពេញទានបារមីរាប់សែនកប្បកាលហោះ ព្រមទាំងសមាទានសីលគ្រប់យ៉ាង បានដល់នូវសេចក្តីសម្រេច ដូច្នេះហើយទើបព្រះនាង និងបងស្រីពែងបានរស់នៅជាមួយគ្នា ជិតស្និតតាំងពីវ័យកុមារភាពមក ព្រមទាំងមានព្រះទ័យយល់ចិត្តគ្នាទៅវិញទៅមក ជាឧបនិស្ស័យតាំងពីអតីតជាតិ។

www.elibraryofcambodia.org

# វគ្គទី៥

# ព្រះជាយាសុបិននិមិត្ត

## (Maya's dream that appears to have impact on reality)



សុបិន្តនិមិត្ត ៖ ស្រង់ចេញពីវត្តទឹកថ្លា ក្រុងភ្នំពេញ ប្រទេសកម្ពុជា ៖

កាលវេលាបានមកដល់ **ព្រះបរមសាស្តា** ទ្រង់ចុះចាកស្ថានទេវលោក មកចាប់បដិសន្ធិក្នុងផ្ទៃព្រះនាង **មហាមាយា** ក្នុងថ្ងៃព្រហស្បតិ៍ ១៥ កើត ខែ អាសាធ នាឆ្នាំរការ មុនព.ស ៨១ ឆ្នាំ។ នៅរាត្រីនោះ ព្រះជាយា **មហាមាយា** កំពុងផ្ទំលើទែនក្នុងព្រះរាជដំណាក់ ស្រាប់តែព្រះនាងទ្រង់សុបិននិមិត្តឃើញ "មានទេវមហារាជដែលថែរក្សាប្រាង្គប្រាសាទទាំងអស់ បានហោះចេញពីទិសទាំង ៤ មានទាំងរថទិព្វមកជាមួយ មកយាងព្រះនាង ឡើងគង់លើព្រះទីនាំង នាំហោះទៅកាន់ព្រៃ **ហិមវន្ត** (Himavana) ដែលស្ថិតនៅកណ្តាល **ជម្ពូទ្វីប** ក្នុងដែនគិរីបុព្វតា។ ទៅដល់ព្រៃនោះហើយ រាជរថទិព្វក៏បរសន្សឹមទៅឈប់ក្រោមដើមរាំងធំ មានផ្ទាំងសិលាដុះ ដូចមុនីកែវផុសឡើងអោយព្រះនាងគង់ ពេលនោះស្រាប់តែមានស្តេចដំរីសធំមួយ នៅប្រមោយមានកាន់ផ្កាឈូកទិព្វប្រកបដោយពន្លឺឆព្វណ្ណរង្សី (Six colors of light as diamond colors) ព័ទ្ធជុំវិញ។ មហាគុជសា (Large elephant) បានមកលុតជង្គង់ថ្វាយ

www.elibraryofcambodia.org

ផ្កាឈូកទិព្វនោះដល់ព្រះនាង ។ ព្រះនាងមានព្រះទ័យសែនរីករាយក្រៃ ទ្រង់អបអរ ផ្កាឈូកឆព័ណ្ណរង្សីពីប្រមោយដំរី អារម្មណ៍រីករាយក្នុងសុបិននោះ ធ្វើអោយ ព្រះនាងភ្ញាក់ដឹងព្រះកាយពេលដែលកំពុងផ្ទុំ ស្របនឹងកាលវេលាព្រះអាទិត្យរៀង រះច្បាស់ ពន្លឺចែងចាំងចេញពីទិសបូព៌ា ។ ពេលនោះព្រះបាទ **សុទ្ធោទនៈ** ក៏ទ្រង់ ភ្ញាក់ព្រះកាយផងដែរ នៅពេលឮសម្លេង និងព្រះកាយដឹងខ្លួនរបស់មហេសី ព្រះ រាជាទ្រង់មានបន្ទូលសួរព្រះនាងថា: "មហេសី! អូនសុបិនឃើញមានរឿងអ្វីកើត ឡើងមែនទេ? ព្រះនាងតបវិញថា: "ក្រាបទូលព្រះស្វាមី! ខ្ញុំម្ចាស់សុបិនឃើញ ហេតុការចម្លែកហើយអស្ចារ្យទៀតផង" ។ ព្រះនាងទូលថ្វាយរ៉ាយរ៉ាប់សព្វសេចក្តី តាមសុបិននិមិត្ត ព្រះរាជាឮហើយទ្រង់មានព្រះទ័យរីករាយ ដោយមានព្រះបន្ទូល ថា: "សុបិនទនេះល្អណាស់! បងនឹងអោយក្រុមព្រាហ្មណ៍បុរោហិតរាជវាំងយើង ទស្សន៍ទាយមើលទៀត" ។ បន្ទាប់មកព្រះអង្គក៏បង្គាប់អោយសេនាហៅពួកមន្ត្រី និងក្រុមព្រាហ្មណ៍ចូលរោងជំនុំ ដើម្បីពិភាក្សាបញ្ហាសុបិននិមិត្តរបស់ព្រះមហេសី ។ ក្រុមព្រាហ្មណ៍បុរោហិតក៏នាំគ្នាចាប់គន់គូរទស្សទាយតាមមុខជំនាញ បន្ទាប់មកក៏ ចេញលទ្ធផល ពួកគាត់ក៏ក្រាបទូលថ្វាយថា: "ព្រះនាងទ្រង់មានព្រះគតិហើយ ក្រាបទូល! គឺជារាជបុត្រាទៀតផង! ហើយរាជបុត្រា នោះគឺជាបុគ្គលទេព(deity) ដែលមកចាប់កំណើតនៅលើដែនដីយើងនេះ ក្រាបទូល!" ។ ព្រះបាទ **សុទ្ធោទនៈ** និងអគ្គមហេសីកាលបើសណ្តាប់ហើយ ទ្រង់មានព្រះទ័យសប្បាយរីករាយ ឯពួក នាហ្មឺនសព្វមុខមន្ត្រី ក៏នាំគ្នាសប្បាយចិត្តគ្រប់ៗគ្នាដែរ បន្ទាប់មកដោយទ្រង់សព្វ ព្រះទ័យខ្លាំងពេក ក៏មានចេញរាជអនុញ្ញាត្តិអោយធ្វើពិធីមួយ សប្បាយរីករាយ ទាំងរាស្ត្រ ទាំងមន្ត្រីផ្ទៃពេញនគរ ។

www.elibraryofcambodia.org



សម្តេចព្រះសង្ឃរាជ **ជួន ណាត** និងសម្តេច **ព្រះនរោត្តម សីហនុរាជ** នៅឆ្នាំ ១៩៦៧

www.elibraryofcambodia.org

# វគ្គទី៦
# ព្រះសាស្តាទ្រង់ប្រសូត្រ
# (Born Gautama Buddha)


ព្រះអង្គប្រសូត្រ ( ស្រង់ចេញពី Internet )

ដោយអំណាចបារមីផលបុណ្យកុសលតាំងពីបុព្វសន្និវាស បានបណ្តាលអោយមានហេតុភេទជាច្រើនដូចជា មានទេវតា ដែលនៅថែរក្សាទឹកដីព្រះនគរនាមហាចក្រវាឡចេញមក ជានិច្ចជាកាលតាមថែរក្សាព្រះគភ៌របូត ដល់គំរប់ ១០ ខែកំណត់ ចំណែក **ព្រះពោធិសត្វ** ដែលទ្រង់នៅក្នុងឧទរមាតា ព្រះអង្គទ្រង់គង់ពែនព្រះភ្នែន ព្រះភក្ត្របែរចំមុខផ្ទៃនៃព្រះមាតា ទ្រង់គង់មិនដូចសត្វលោកទាំងឡាយ ដែលផ្តេកខ្លួននោះឡើយ ទ្រង់គង់ភ្នែនរហូតទល់ប្រសូត្រ ។

បុព្វកាលសម័យនារដូវខែពិសាខ ព្រះនាង **មហាមាយា** ទ្រង់មានព្រះទ័យនឹករលឹកដល់ព្រះនគរកំណើត **ទេវទហៈ** ។ ព្រះនាងក៏សុំអនុញ្ញាតពីស្វាមីដើម្បីទៅលេងស្រុកកំណើត នៅពេលនោះព្រះបាទ **សុទ្ធោទនៈ** ទ្រង់បានអនុញ្ញាតតាមក្តីប្រាថ្នារបស់មហេសី ទ្រង់ត្រាស់បញ្ជាអស់ភីលៀងសេនា អាមាត្យជាច្រើនអោយរៀបចំក្បួនដង្ហែព្រះនាងទៅលេងនគរ **ទេវទហៈ** ។

ក្បួនដង្ហែបានមកដល់ព្រៃ **សាលវ័ន្ត** មួយឈ្មោះ **លុម្ពិនី** (Ancient Nepal, Lumbini) ស្ថិតនៅចន្លោះនគរ **កបិលពស្តុ** និង **ទេវទហៈ** ។ **លុម្ពិនី** មិនមែនជាព្រៃស្មសានស្ងាត់នោះទេ គឺជាសាលវ័ន្តព្រឹក្សាដែលមានទេសភាពស្រស់

www.elibraryofcambodia.org

ត្រកាល មានមនុស្សម្នាតែងមកកំសាន្តរាល់រដូវក្តៅ។ មកដល់ទីនេះព្រះនាង **មហាមាយា** មានព្រះទ័យអោយក្បួនឈប់សម្រាក ហើយយាងព្រះនាងចុះពី ព្រះទីនាំង ទ្រង់យាងទៅកាន់ដើមឈើសាលព្រឹក្សដ៏ត្រឈឹងត្រឈៃមួយ ប្រាថ្នា សម្រាកនៅទីនោះ នៅខណៈនោះព្រះនាងក៏ទ្រង់ឈឺផ្ទៃ **កម្មជវាត** (The force which expels a new born child from the mother's womb) ក៏ ចាប់ផ្តើមមានចលនាបញ្ជាក់ប្រាប់ថា ព្រះនាងជិតប្រសូត្ររាជបុត្រហើយ ពេល នោះហេតុអស្ចារ្យមួយ គឺមែកសាលព្រឹក្សស្រាប់តែទោទន់មកអោយព្រះនាង តោងកាន់យ៉ាងស្រួល ដើម្បីទប់ព្រះកាយអោយបានរឹងមាំ រួចមកព្រះនាងទ្រង់ក៏ ប្រសូតបុត្រទាំងជំហរ ដោយដៃព្រះនាងម្ខាងតោងកាន់សាលព្រឹក្សនោះ។ ក្រុម ភីលៀង សេនាអាមាត្យបានស្ទុះស្ទាយកផ្ទាំងក្រណាត់និងស្បៃសន្ទិយា (The thin cloths) ទៅហ៊ុំព័ទ្ធជុំវិញក្រោមដើមសាលព្រឹក្ស ព្រមទាំងមានប្រដាប់ប្រដារ សម្រាប់សម្រាលបុត្រផង។ ភ្លាមនោះរុក្ខទេវតាដើមសាលព្រឹក្ស និងទេវតារក្សា ដែនបព្វតាបានហោះចេញមកព្រោងព្រាត អបអរសាទរ និងប្រោះព្រំសព្វយ៉ាង ដល់ថ្ងៃបដិសន្ធិនៃ **ព្រះសាស្តា** ដែលទ្រង់ប្រសូតចាកឧទរព្រះមាតា ប្រកបដោយ ព្រះកាយស្អាតល្អបវរ គ្មានប្រឡាក់មន្ទិលអ្វីបន្តិចឡើយ ពេលនោះគឺចំថ្ងៃសុក្រ ១៥ កើត ខែពិសាខ ឆ្នាំចរ មុន ព.ស ៨០ ឆ្នាំ។ ខណៈពេល **ព្រះពោធិសត្វ** ទ្រង់ ប្រសូត ស្រាប់តែមានទទិព្វលេចចេញពីលំហរអាកាស បង្ហូរចេញកម្តៅ គឺទឹកក្តៅ អ៊ុនៗ (warm water) មកលាងព្រះមន្ទិលគភ៌គ្រប់យ៉ាង បានយ៉ាងស្អាតប្រសើរ។ នៅឯលំហរអាកាសស្តេច **សក្កទេវរាជ** និង ព្រះមហាទេពទាំង ៤ ព្រះអង្គក៏ពុះ បាចផ្កាជូនពរនៅថ្ងៃដែល **ព្រះសាស្តា** ទ្រង់ឃើញភពផែនដីជាលើកដំបូងនៃជីវិត ព្រះអង្គ។ ទេពទារកដ៏អស្ចារ្យគ្រាន់តែប្រសូតមកភ្លាម ចេះដើរបានភ្លាមៗ

www.elibraryofcambodia.org

ជំហានចេញ ស្រាប់តែមានផ្កាឈូកផុសចេញដូចទេពនិមិត្តមកទ្រព្រះបាទ ទ្រង់ឈានបាន ៧ ជំហានផ្កាឈូកក៏ផុសចេញ ៧ ដងដែរ។ ភាពចម្លែកអស្ចារ្យបន្តទៀត ទ្រង់ព្រះកាយបិទបាំងដោយក្រណាត់ស្បៃរុំព័ទ្ធដងខ្លួន និងមានរិជ្ឈមាត្រ (body) ប្រៀបដូចជាអង្គកុមារមានវ័យ ២ វស្សាទៅ ៣ វស្សាដូច្នេះដែរ។ ព្រះរាជជាយាទ្រង់ប្រសូតបុត្រកណ្ដាលផ្លូវដូច្នេះ ការធ្វើដំណើរទៅលេងនគរកំណើតត្រូវផ្អាក ហើយក្រុមសេនាហែរហមបានយាង ព្រះនាងត្រឡប់វិលចូលនគរ **កបិលពស្តុ** មិនបានទៅកាន់នគរ **ទេវទហៈ** ឡើយ។



www.elibraryofcambodia.org

# វគ្គទី៧
# ការព្យាករណ៍ដល់រាជកុមារ
# (Prediction to Prince Siddhartha)


ព្យាករណ៍រាជកុមារ ( ស្រង់ចេញពីវត្តត្រពាំងព្រះ ខេត្តកំពង់ចាម ប្រទេសកម្ពុជា)

ព្រះញាតិវង្សទាំងពីរបានមកជួបជុំគ្នានៅនគរ **កបិលព័ស្តុ** ពេលដែលព្រះរាជានគរ **ទេវទហៈ** យាងមកសួរសុខទុក្ខបុត្រី ដែលទើបប្រសូតបុត្រាដ៏អស្ចារ្យ ផ្អើលអស់មនុស្សម្នា ទេវតានាផែនដី និងចក្រវាលទាំងមូល។ ភាពល្បីរន្ទឺបានឮដល់ព្រះមហាឥសី **កាឡទេ-វិល៍** (Hermit Kalatavita) ដែលកំពុងភាវនាធម៌នៅភ្នំហេមពាន្ត។ ឥសី **កាឡទេវិល៍** ជាឥសីដែលមានវិជ្ជាគ្រប់បែប ពេលដែលគាត់កំពុងតាំងសមាធិ (concentration) ស្រាប់តែគាត់បើកភ្នែក ហើយលាន់មាត់ថាៈ "ឱ! ព្រះភគវាទ្រង់ប្រសូតហើយ! អាត្មាត្រូវតែទៅជួបព្រះអង្គ"។ រួចហើយគាត់ក៏រៀបចំខ្លួនចុះពីភ្នំទៅកាន់នគរ **កបិលព័ស្តុ** ជាបន្ទាន់។ នៅក្នុងរាជវាំងឯណោះ មានទុក្ខក្រៀមក្រម្តៅយព្រះជាយា Maya ក្រោយពីប្រសូតបុត្រាបាន ៧ ថ្ងៃ ក៏ទ្រង់សោយទីវង្គត់ (pass away) ទៅទុកសល់នៅក្រុមរាជវង្សយំសោកស្រណោះ ជាសង្ខារកំណត់ព្រះនាងត្រឹមប៉ុណ្ណោះ។ ព្រះនាង **មហាមាយា** ពេលផុតសង្ខារទៅ ទ្រង់ក៏បានទៅកើតឯស្ថានត្រៃត្រឹង្ស ជាទេពធីតាមួយអង្គ សោយបរមសុខ ផុតកម្មជាមនុស្សលោកនា ស្ថានកណ្តាលទៀតហើយ។ ក្រោយពីរៀបចំឈាបនកិច្ចថ្វាយព្រះនាងរួចហើយ ក្រុមប្រឹក្សារាជវង្សក៏តែងតាំង

www.elibraryofcambodia.org

ព្រះនាង **បជាបតី** ដែលជាប្អូនស្រីឡើងជាព្រះ ជាយាទី២ ហើយព្រះនាងត្រូវមើលថែរាជទារក និងក្លាយជាព្រះមាតាចិញ្ចឹមចាប់ ពីពេលនោះមក។

នៅក្នុងសាលប្រជុំនៃរាជវាំង ព្រះបាទ **សុទ្ធោទនៈ** និងព្រះជាយាថ្មី ព្រះនាង **បជាបតី** បាននាំរាជទារកយកមក ដើម្បីអោយពួកព្រាហ្មណ៍បុរោហិតទស្សទាយ និងថ្វាយព្រះនាម។ ពួកមន្ត្រីរាជវាំង និងព្រះរាជាកំពុងរង់ចាំលទ្ធផលនៃការទស្សទាយពីក្រុមព្រាហ្មណ៍ទាំង ៨ ដែលមានឈ្មោះ:

១-ព្រាហ្មណ៍ **រាមា**
(Brahmana-Rama)
២-ព្រាហ្មណ៍ **លក្ខៈ**
(Brahmana-Laka)
៣-ព្រាហ្មណ៍ **យញ្ញ**
(Brahmana-Yayaha)
៤-ព្រាហ្មណ៍ **មជៈ**
(Brahmana-Makcha)
៥-ព្រាហ្មណ៍ **កោជៈ**
(Brahmana-Kauya)
៦-ព្រាហ្មណ៍ **សុទត្ត**
(Brahmana-Soddha)
៧-ព្រាហ្មណ៍ **សុយាមៈ**
(Brahmana-Soyama)
៨-ព្រាហ្មណ៍ **កោណ្ឌិញ្ញ**
(Brahmana-Kaudiny

កំពុងធ្វើការព្យាករណ៍យ៉ាងញាប់ដៃ ដើម្បីឆាប់បានលទ្ធផលថ្វាយព្រះរាជា។ មិនជាយូរប៉ុន្មានក្រុមព្រាហ្មណ៍បានឃើញលទ្ធផល ក៏ប្រញាប់ទូលថ្វាយដល់ព្រះមហាក្សត្រពីជោគរាសី (destiny) រាជបុត្រថា: "បរពិតមហារាជ! ដ៏ចម្រើន! តាមក្បួនតម្រាទស្សទាយរបស់ពួកព្រាហ្មណ៍គឺដូចគ្នាទាំងអស់! រាជកុមារទ្រង់មានបុណ្យបារមីខ្ពស់ក្រៃលែង! បើទ្រង់បានសោយរាជ្យនឹងក្លាយទៅជាមហាអធិរាជ (Emperor) គ្មានក្សត្រណាប្រៀបស្មើព្រះអង្គបានឡើយ! បើទ្រង់ចេញជាបុព្វជិតនឹងបានត្រាស់ជា **ព្រះពុទ្ធ**"។ ពេលនោះមានព្រាហ្មណ៍ក្មេងម្នាក់ឈ្មោះ

www.elibraryofcambodia.org

**កោណ្ឌិញ្ញ** បាននិយាយអះអាងថា: "បពិត្រក្រាបទូល! ក្បួនតម្រាទូលបង្គំបាន បញ្ជាក់ច្បាស់ណាស់ថា រាជកុមារនឹងក្លាយខ្លួនជាអ្នកបួស ហើយទ្រង់ត្រាស់ជា **ព្រះពុទ្ធ** ជាក់ជាប្រាកដក្រាបទូល!"។ បន្ទាប់មកក្រុមព្រាហ្មណ៍ក៏ថ្វាយព្រះនាម ដល់រាជកុមារផងដែរ ដោយយល់ទៅតាមអច្ឆរិយៈទាំងឡាយ ដែលបានឧប្បហេតុ ឡើងទាំងប៉ុន្មានលើរាជកុមារ តាំងពីមាតាសុបិននិមិត្ត រហូតដល់ថ្ងៃប្រសូត មាន ផ្កាឈូកដុះទ្រព្រះបាទ ដូច្នេះពួកគាត់ក៏ថ្វាយព្រះនាមថា **សិទ្ធត្ថ** (Siddhartha) មានន័យថា: "អ្នកធ្វើអោយសេចក្តីប្រាថ្នាទាំងឡាយបានសម្រេច" (Accomplish ment of all aspiration) តែមហាជនក្នុងជម្ពូទ្វីបចូលចិត្តហៅព្រះនាមថា **គោត្តម** (Gautama) ដោយយល់ថា ព្រះអង្គនឹងក្លាយជា **ព្រះពុទ្ធ** ពិតប្រាកដ ដូច្នេះហើយទើបព្រះនាមព្រះអង្គហៅភ្ជាប់គ្នាគឺ **ព្រះពុទ្ធគោត្តម** (Gautama Buddha) នៅថ្ងៃដែលពីធីព្យាករណ៍ និងថ្វាយព្រះនាមកំពុងប្រព្រឹត្ត ស្រាប់តែ លេចមហាឥសី **កាឡទេវិល៍** ចេញមកដូចទេពនិមិត្ត។ ព្រះរាជាឃើញមហា ឥសីល្បីឈ្មោះផុសនៅចំពោះព្រះភក្ត្រដូច្នេះ ព្រះអង្គទ្រង់គោរពរាក់ទាក់ ដោយ មានបន្ទូលថា: "ឱ! មហាឥសីដ៏អស្ចារ្យ! តើ ព្រះអង្គមានឱវាទអ្វីដែរ សូមមានព្រះដីកា មកចុះ"។ — មហាឥសីតបដោយលើកដៃ ចង្អុលឡើងលើ បង្ហាញម្រាមតែមួយតត់ថា: "ព្រះរាជាដ៏ចម្រើន! អាត្មាមកនេះ សូមជួយ ត្រេកអរដល់រាជវង្សព្រះអង្គ ទ្រង់ដែលក្លាយ ជា **ព្រះពុទ្ធ** ជួយសត្វលោកយើងនៅថ្ងៃ អនាគត"។ ព្រះបាទ **សុទ្ធោទនៈ** ឮហើយ



មហាឥសី កាឡទេវិល៍ (ស្រង់ចេញពី Internet)

www.elibraryofcambodia.org

មានព្រះទ័យសោមនស្ស តែព្រះអង្គមានបំណងផ្សេង ទ្រង់សំពះទៅមហាឥសី ដោយមានបន្ទូលថាៈ "ខ្ញុំករុណាសូមអរព្រះគុណព្រះមហាឥសីជាអនេករកអ្វីប្រៀបមិនបានឡើយ! តែខ្ញុំករុណាប្រាថ្នាចង់អោយបុត្រាបានឡើងគ្រងរាជសម្បត្តិសិន! តើបានទេព្រះមហាឥសី? សូមក្តីមេត្តាផងចុះ"។ - ឥសីសណ្តាប់ហើយ ក៏តបទៅវិញថាៈ "បើទ្រង់មានបំណងបែបនេះ! ចាំអាត្មាប្រមើមើលសិន"។ ថាហើយមហាឥសីធ្មេចភ្នែក ដៃរាប់គ្រាប់អង្កាំចង្រ្កមម្តងមួយៗ បានមួយសន្ទុះក៏បើកភ្នែក ហើយតបទៅព្រះរាជាវិញថាៈ "នេះជាឧប្បនិស្ស័យ! មិនអាចកែប្រែបានឡើយ! ណើ្អយ..! ល្មមសមពេលវេលា អាត្មាសូមចម្រើនពរព្រះមហារាជសិនហើយ! បើព្រះអង្គមិនអស់ព្រះទ័យ ទ្រង់អាចសាកល្បងមើលបាន"។ ថាហើយមហាឥសីក៏ចម្រើនពរលាព្រះអង្គចេញទៅ ហើយក៏បាត់ដោយបំបាំងកាយទាំងអស់គ្នាក្នុងព្រះរាជវាំងបានត្រាន់តែត្រឹមសម្លឹង មុខគ្នាទៅវិញទៅមកប៉ុណ្ណោះ ហើយនឹកស្ងើចដល់ភាពអស្ចារ្យរបស់មហាឥសី។



សៀវភៅប្រវត្តិសាស្ត្រខ្មែរ នឹងត្រូវចេញបន្ទាប់ពីសៀវភៅព្រះសាស្តា

www.elibraryofcambodia.org

# វគ្គទី៨

# រាជកុមារទាំង៣

## (Three young cousin brothers of Siddhartha)



ព្រះអង្គទ្រង់សង្គ្រោះសត្វក្ងាន ពីទេវទត
( ស្រង់ចេញពី Internet )

ព្រះអង្គ **សុក្កោទនៈ** (Shukaudana) ដែលត្រូវជាអនុជបន្ទាប់ព្រះបាទ **សុទ្ធោទនៈ** ទ្រង់មានរាជបុត្រាមួយព្រះអង្គ ព្រះនាម **អានន្ទកុមារ** (Ananda) ត្រូវជាអនុជជីដូនមួយរាជកុមារ **សិទ្ធត្ថ**។ **អានន្ទ** កុមារទ្រង់ប្រសូតក្រោយរាជកុមារ **សិទ្ធត្ថ** ជាងមួយសប្តាហ៍ប៉ុណ្ណោះ។

ព្រះអង្គ **អមិតោ្តទនៈ** (Amittaudana) ដែលជាអនុជទី ២ ព្រះបាទ **សុទ្ធោទនៈ** ដែរ ទ្រង់ក៏មានបុត្រាមួយអង្គដែរ ព្រះនាម **អនុរុទ្ធ** (Aniruddha) និងបុត្រីមួយអង្គទៀត ព្រះនាម **រោហិនី** (Rauhini) ទាំងពីរ ព្រះអង្គជាបងប្អូនជីដូនមួយ និងរាជកុមារ **សិទ្ធត្ថ** ដែរ។

ចំណែកព្រះនាង **អមិត្តះ** (Amitta) ដែលជាប្អូនស្រីព្រះបាទ **សុទ្ធោទនៈ** បានរៀបមង្គលការនឹងព្រះអង្គ **សុប្បពុទ្ធ** (Suppabuddha) ជាប្អូនទី ៣ នៃព្រះមាតា **មហាមាយា** ក៏មានបុត្រាមួយអង្គព្រះនាមទេវទត្ត[២២] (Devadatta)

---

[២២] ទេវទត្តត្រូវជាបងថ្លៃរបស់ព្រះពុទ្ធ។

www.elibraryofcambodia.org

និងបុត្រីមួយអង្គទៀត ព្រះនាម **ពិម្ពាសោធរា** (Pimpie Sodhara) ហៅព្រះនាមក្រៅថា ព្រះនាង **ពិម្ពា**[២៣] ។

៧ ឆ្នាំក្រោយមក រាជកុមារ **សិទ្ធត្ថ** មានវ័យវឌ្ឍនាកាល (Gradually grew up) ក្លាយជាកុមារល្អគ្រប់ប្រការ (Gentle and polite, good moral character) ចរិយាសម្បត្តិ និងរូបសម្បត្តិ ថែមទាំងមានបញ្ញាខុសប្លែកពីក្មេងផងទាំងពួង ពិសេសក្នុងចំណោមកុមារទាំង ៣ អង្គ ដែលជាជីដូនមួយគឺ **អានន្ទកុមារ អនុរុទ្ធកុមារ** និង **ទេវទត្តកុមារ**។ រាជកុមារទាំង ៤ តែងរត់លេងកំសាន្តជាមួយគ្នា តែកុមារ **ទេវទត្ត** មានចរិតខុសគេ តែងមានចិត្តកាចចចែសមិនសូវមានចិត្តអាណិតអាសូរដល់មនុស្សសត្វអ្វីឡើយ ។ ដូចជានៅសម័យថ្ងៃមួយពេលក្រុមកុមារទាំង ៤ កំពុងរត់លេង កុមារ **ទេវទត្ត** បានទាញព្រួញបាញ់ចំសត្វក្ងានព្រៃមួយមានរបួស - **រាជកុមារសិទ្ធត្ថ** ឃើញក៏ស្ទុះទៅដណ្តើម ក្នុងបំណងដោះលែងក្ងានព្រៃអោយមានជីវិតត្រឡប់ទៅព្រៃវិញ។ ចំណែកកុមារ **ទេវទត្ត** មានចិត្តកើតជាគំនុំទុកក្នុងចិត្ត ឯរាជកុមារ **អានន្ទ** និង **កុមារអនុរុទ្ធ** គឺមានចិត្តដូចកុមារ **សិទ្ធត្ថ** ដែរ អ្វីដែលកុមារ **សិទ្ធត្ថ** ធ្វើ និងចូលចិត្ត កុមារទាំងពីរតែងមានដូចគ្នា ថែមទាំងស្តាប់បង្គាប់ និងគោរពស្រឡាញ់ ធ្វើតាមគ្រប់ពេលទាំងអស់ ទង្វើកុមារទាំងពីរបានធ្វើអោយកុមារ **ទេវទត្ត** មិនពេញចិត្តសោះ។ ថ្ងៃបន្ទាប់មកទៀត ពេលក្រុមកុមារទាំង ៣ កំពុងរត់លេងក្នុងសួនកុមាររាជកុមារ **សិទ្ធត្ថ** ទ្រង់ទតឃើញសត្វបង្កួយមួយកំពុងដេញស៊ីស្រមោច រួចក៏មានសត្វពស់មួយចេញមកស៊ីសត្វបង្កួយនោះបាត់ទៅ ស្រាប់តែបន្ទាប់មកមានសត្វខ្លែងធំមួយ

[២៣] ព្រះនាង **ពិម្ពា** ត្រូវជាពេសិរបស់ព្រះពុទ្ធ។ ( ទំព័រ ៨០ )

www.elibraryofcambodia.org

ហើរមកចឹកសត្វពស់ស៊ីបន្ត។ សកម្មភាពសត្វទាំងនេះបានធ្វើអោយទឹកព្រះទ័យរាជកុមារ **សិទ្ធត្ថ** ទ្រង់ពិចារណាឃើញភាពកាចសាហាវនៅពីក្រោយអំពើល្អ។



ហេតុការណ៍អំពីភាពកាចសាហាវរបស់សត្វដែលព្រះអង្គបានទតឃើញ
( ស្រង់ចេញពីសៀវភៅ Sakymuni Buddha )

www.elibraryofcambodia.org

# វគ្គទី៩

# អព្ភូតហេតុចម្លែក

## (Strange miracle)



អព្ភូតហេតុចម្លែក
( ស្រង់ចេញពី Internet )

ព្រះបាទ **សុទ្ធោទនៈ** ព្រមទាំងមន្ត្រីមួយចំនួន ចង់អោយរាជកុមារ **សិទ្ធត្ថ** នៅសោយរាជ្យសម្បត្តិ បន្តរាជវង្ស ដូច្នេះទើបចាត់វិធានការកុំអោយបុត្រា បានឃើញភាពបព្វជិតទាំងឡាយ ហើយទ្រង់បង្វែង ដានដូចជា នាំបុត្រអោយចេញកំសាន្តជាមួយពួក ព្រះអង្គតាមកន្លែងផ្សេងៗ ។ នៅសម័យថ្ងៃមួយចំរដូវ វស្សា (rainy season) ជារដូវភ្ជួររាស់ ព្រះមហាក្សត្រ ទ្រង់ចេញធ្វើពិធីច្រត់ព្រះនង្គ័ល (ceremony of the sacred furrow) ជាគម្រូ ដើម្បីអោយប្រជារាស្ត្រប្រឹងធ្វើស្រែទទួលទាន ភោគផលសម្រាប់ជីវភាពរស់នៅ ។ ក្រុមសេនា អាមាត្យបានហែរហមព្រះរាជា និងរាជបុត្រាទៅកាន់កន្លែង ដែលត្រូវធ្វើរាជពិធីច្រត់ព្រះនង្គ័ល ។ ជួនជានៅពេល នោះ ថ្ងៃចែងចាំងខ្លាំង ព្រះរាជាបានបង្គាប់អោយសេនារៀបកន្លែងមួយនៅក្រោម ដើមព្រីងយ៉ាងធំ ដើម្បីអោយបុត្រផ្ទំនៅទីនោះ រួចព្រះអង្គក៏នាំសេនាទៅកន្លែងធ្វើ ពិធីនោះ ។ នៅពេលដែលរាជកុមារបានដឹងខ្លួនឡើង នៅជុំវិញព្រះអង្គឃើញមាន ភាពស្ងប់ស្ងាត់ល្អ ក៏ទ្រង់ពែនព្រះភ្នែនតាំងសមាធិ បន្ទូរខ្យល់ដកដង្ហើមចេញចូល ទ្រង់មានឧប្បនិស្ស័យលើការសមាធិកម្មដ្ឋាន ទ្រង់ចម្រើនអារម្មណ៍អានាបាស្សតិ កម្មដ្ឋាន (meditation consisting of counting breaths) ដែលចាប់ផ្តើម

www.elibraryofcambodia.org

សម្រាប់បឋមជ្ឈាន (first dhyana) ដល់អភិសម្ពោធិនិមិត្ត (Prefix intelligen-ce) នៅគ្រានោះ។ នៅពេលដែលរាជកុមារកំពុងធ្វើសមាធិកម្មដ្ឋាន រសៀលក៏ជ្រេ (The afternoon around 2 to 3 P.M) ព្រះទិនករជះចេញផុតកម្ដៅថ្ងៃក៏មកដល់ តែម្លប់គ្របពីលើព្រះអង្គនៅដដែល ធ្វើអោយពន្លឺពុំអាចប៉ះព្រះកាយព្រះអង្គបានឡើយ ជួនជាពេលនោះស្រាប់តែមានអាមាត្យបានមកដល់ ឃើញហេតុភេទដូច្នេះ ក៏រត់ទៅទូលព្រះរាជា។ ព្រះបាទ **សុទ្ធោទនៈ** ក៏យាងពីកន្លែងច្រត់ព្រះនង្គ័លមកដល់ ទតឃើញដូចសំដីអាមាត្យទូលថ្វាយមែន ព្រះអង្គទ្រង់នឹកគិតស្ញប់ស្ញែងក្រៃលែង ទ្រង់ត្រិះរិះក្នុងព្រះទ័យថា រាជបុត្រារបស់ព្រះអង្គពិតជាអំបូរបុគ្គលទេវមានបុណ្យបារមីពិតប្រាកដមែន។

www.elibraryofcambodia.org

# វគ្គទី១០

# គ្រូវិស្វាមិត្រ (Sage-Visvamitta)


គ្រូវិស្វាមិត្រ (ដកស្រង់ចេញពីវត្តសំរោងអណ្តែត ក្រុងភ្នំពេញ) ប្រទេសកម្ពុជា

ភាពដ៏អស្ចារ្យនៃជីវិតរបស់រាជកុមារ **សិទ្ធត្ថ** កាន់តែធ្វើអោយព្រះបាទ **សុទ្ធោទនៈ** មានព្រះទ័យយកចិត្តទុកដាក់ កាន់តែខ្លាំងឡើង១។ នៅពេលរាជកុមារមានព្រះជន្ម ៨ វស្សា ព្រះរាជាទ្រង់បង្គាប់អោយសេនាជីកស្រះ **បោក្ខរណី** (Pond with lotus flowers) ប្រកបដោយបុប្ផារីកចំរុះពណ៌ ផ្កាឈូកក្រហម សរីកស្គុះស្គាយណាយផ្កាពេញគង្គា។ លុះដល់រាជកុមារបានព្រះជន្ម ១៥ វស្សា ទៅ ១៦ វស្សា បានត្រូវព្រះបិតាបញ្ជូនទៅអោយសិក្សាជាមួយគ្រូ **វិស្វាមិត្រ** ជាកំពូលបណ្ឌិតព្រាហ្មណ៍ ដែលមានវិជ្ជាសព្វបែបយ៉ាងនៅសម័យនោះ។ នៅអាស្រមគ្រូ **វិស្វាមិត្រ** ជាកន្លែងប្រកបដោយជំនឿ ៣ យ៉ាងគឺៈ ព្រះអាទិទេព មនុស្សលោក និងឥសី ដែលនៅជិតដាមដល់សព្វថ្ងៃក្នុងផ្នត់គំនិតប្រជារាស្ត្រឥណ្ឌា[២៤]។ **គ្រូវិស្វាមិត្រ** បានបង្ហាត់បង្រៀនសព្វមុខវិជ្ជា ដែលខ្លួនមានទាំងប៉ុន្មានដល់ព្រះអង្គ **សិទ្ធត្ថ**។ពេលវេលាសិក្សាបានកន្លងទៅយ៉ាងឆាប់រហ័ស គ្រប់មុខវិជ្ជាព្រះអង្គចេះចាំគ្មានសល់ ទាំងអក្សរសាស្ត្រ និងយុទ្ធ

[២៤] ក្នុងសៀវភៅ Ancient India: គ្រប់វគ្គ Belief and Society ទំព័រ ១២ (ដូចនេះហើយ គ្រូ **វិស្វាមិត្រ** ការគោរពទេវតា ៣ ពួកគឺ : -ព្រះជួក -មនុស្សធ្វើ -ឥសីមានឫទ្ធិ ដូច្នេះនេះឯង។

www.elibraryofcambodia.org

សាស្ត្រ ថែមទាំងទ្រង់មានបញ្ញាឈ្លាសវៃលើសគ្រូ **វិស្វាមិត្រ** ទៅទៀត។ ការសិក្សាចប់កាលណា ទ្រង់ក៏យាងត្រឡប់មកព្រះនគរវិញដោយមានគ្រូ **វិស្វាមិត្រ** ដង្ហែមកជាមួយផង។ ពេលចូលដល់ទីបុរីព្រះបិតា និងសេនាអាមាត្យ មន្ត្រីបានរៀបចំទទួលព្រះអង្គយ៉ាងអឹកធឹក (tremendous) ជាទីបំផុត។

នៅមុខពិធីទទួលគ្រូ **វិស្វាមិត្រ** បានប្រគល់រាជបុត្រា **សិទ្ធត្ថ** ទៅព្រះរាជាវិញ ដោយបន្ទីពាក្យរីករាយថា: "បពិត្រមហារាជដ៏ចម្រើន! ព្រះរាជបុត្រាទ្រង់មានបារមី និងប្រាជ្ញាវាងវៃណាស់ ចំណេះវិជ្ជាទាំងប៉ុន្មាន ទ្រង់ចេះចាំយ៉ាងស្ទាត់ជំនាញលើសគ្រូដើមទៅទៀត! តំណទៅគ្មានក្សត្រណាប្រៀបស្មើព្រះអង្គបានឡើយ"។ ព្រះបាទ **សុទ្ធោទនៈ** ទ្រង់មានព្រះទ័យសោមនស្សរីករាយ តែព្រះអង្គធ្វើជាមានបន្ទូលថា: "ដល់ប៉ុណ្ណឹងផង! តើធ្វើដូចម្ដេចអោយយើងឃើញបាន"។ គ្រូ **វិស្វាមិត្រ** ទូលតបទៅព្រះអង្គភ្លាមថា: "សូមព្រះអង្គបើកពិធីសាកល្បងទៅក្រាបទូល! ទ្រង់នឹងទតឃើញច្បាស់ជាមិនខាន"។ ដោយចង់ទតឃើញផ្ទាល់ នូវចំណេះវិជ្ជារបស់រាជបុត្រាដល់កម្រិតណា ទ្រង់ក៏ចេញបញ្ជាអោយបើកពិធីប្រឡងយុទ្ធសាស្ត្រផ្សេងៗ ដោយមានកំពូលអ្នកខ្លាំងពូកែជាច្រើនចូលរួមដើម្បីមកប្រកួតប្រជែង និងរាជបុត្រ **សិទ្ធត្ថ**។ ពិធីប្រយុទ្ធក៏ចាប់ផ្ដើម មានយុទ្ធជនជាច្រើន គូរប្រកួតសុទ្ធតែចាញ់ព្រះរាជបុត្រទាំងអស់។ ចប់ការប្រយុទ្ធដោយប្រើដាវ (sword) ហើយចូលដល់ប្រកួតផ្នែកទស្សនបញ្ញា (Intelligent viewpoint) ម្ដងវិញ។ ពេលនោះមានអ្នកបណ្ឌិតល្បីៗ និងរាជបុត្រាមកពីនគរផ្សេងៗ បានចូលរួមជាច្រើនអង្គ ទីបំផុតអង្គទាំងអស់នោះសុទ្ធតែចាញ់ព្រះអង្គ **សិទ្ធត្ថ** ទាំងអស់ ពួកគេនាំគ្នាសរសើរនូវសមត្ថភាពរបស់ព្រះអង្គថា: "យើងទាំង

www.elibraryofcambodia.org

អស់! សូមសរសើរដល់ព្រះអង្គ **សិទ្ធត្ថ** ហើយ! ទ្រង់ជាកំពូលតក្កបណ្ឌិតដ៏អស្ចារ្យ ព្រមទាំងយុទ្ធវិជ្ជាខ្លាំងពូកែគ្មានគូប្រៀបសោះឡើយ" ។

ពិធីប្រកួតត្រូវបានបញ្ចប់ក្រោមភាពជោគជ័យ និងក្តីរីករាយរបស់មហាក្សត្រ និងអ្នកមុខអ្នកការទូទាំងរាជធានី ។



ប្រកួតវិជ្ជាគុណ ‹ ស្រង់ចេញពីវត្តព្រះពុទ្ធឃោសាចារ្យ ក្រុងភ្នំពេញ›

www.elibraryofcambodia.org

# វគ្គទី១១

# មហាប្រាសាទទាំង៣

## (The three splendid palaces)



ប្រាសាទទាំង៣ (ស្រង់ចេញពី Internet)

ព្រះបាទ **សុទ្ធោទនៈ** ទ្រង់មានព្រះទ័យព្រួយបារម្ភ ខ្លាចក្រែងរាជបុត្រា លុះដល់សច្ចធម៌ស្វែងយល់នូវភាពបព្វជិត ដូចដែលមហាឥសី **កាឡទេវិល** បាននិយាយហើយចាកចេញនៅពេលអនាគត ទ្រង់បានរកមធ្យោបាយផ្សេងៗ ទាក់ទាញអារម្មណ៍បុត្រា ដើម្បីអោយជីវិតទ្រង់យល់ថា ជីវិតជាមហាក្សត្រគឺសប្បាយរីករាយ មានអ្វីៗសព្វបែបយ៉ាង មិនខ្វះចន្លោះឡើយ ដូច្នេះព្រះបិតា ក៏មានតម្រិះបញ្ជាអោយកសាងមហាប្រាសាទដ៏ស្កឹមស្កៃចំនួន ៣ ថ្វាយដល់រាជបុត្រា សម្រាប់អោយទ្រង់គង់នៅនារដូវទាំង ៣ ដែរ ។ ប្រាសាទនីមួយៗមានឈ្មោះផ្សេងពីគ្នា និងមានក្បាច់រចនាប្លែកៗ ដើម្បីអោយទ្រង់មានក្ដីរីករាយក្នុងជីវិតរស់នៅ ។ ១-**ប្រាសាទចន្ទៈ** ខាងក្នុងមានកម្ដៅស្រួល សាងឡើងសម្រាប់អោយព្រះអង្គគង់នៅរដូវរងា។ ២-**ប្រាសាទកោកនទៈ** ខាងក្នុងត្រជាក់ស្រួល សាងឡើងសម្រាប់ព្រះអង្គនៅរដូវក្ដៅ។ ៣-**ប្រាសាទកោញ្ចៈ** ខាងក្នុងមិនក្ដៅមិនត្រជាក់ សាងឡើងសម្រាប់អោយព្រះអង្គគង់នៅរដូវភ្លៀង ឬរដូវវស្សា។ គ្រប់ប្រាសាទទាំង ៣ នេះ ពោរពេញទៅដោយភីលៀងស្នំក្រមការ សេនាអាមាត្យ និងសម្ភារៈប្រើប្រាស់គ្មានខ្វះចន្លោះឡើយ។ **ព្រះសិទ្ធត្ថ** ទ្រង់គង់នៅក្នុងប្រាសាទទាំង ៣ នេះ ដោយសុះ

www.elibraryofcambodia.org

សាន្តគ្រប់ប្រការអស់កាលដ៏យូរឆ្នាំ នៅពេលខ្លះបានជួបជុំព្រះញាតិវង្សម្តងៗ ទ្រង់តែងបានសាកល្បងវិជ្ជាផ្សេងៗ មានបាញ់ព្រួញជាដើម អោយព្រះញាតិវង្សទតសូរស័ព្ទនៃធ្នូជ័យល្បីឮកក្រើកប្រថពី ធ្វើអោយសព្វសត្វនិករ (All living creatures) ទាំងឡាយខ្លបខ្លាចឥតគណនា។



ព្រះអង្គទ្រង់សំដែងគុណវិជ្ជា ( ស្រង់ចេញពីវត្តទឹកថ្លា ក្រុងភ្នំពេញ)

# វគ្គទី១២

# រាជាភិសេកព្រះសិទ្ធត្ថ

## (Coronation to Prince Siddhartha)



ព្រះអង្គទ្រង់រៀបអភិសេក ‹ ស្រង់ចេញពី វត្តព្រះពុទ្ធឃោសាចារ្យ ក្រុងភ្នំពេញ ប្រទេសកម្ពុជា›

ជាច្រើនឆ្នាំក្រោយមកអ្វីៗសព្វយ៉ាង ដែលព្រះបាទ **សុទ្ធោទនៈ** បានរៀបចំអោយបុត្រាបានយល់សេចក្តីសុខក្នុងជីវិត តែហាក់បីដូចជា មានប្រសិទ្ធភាពបានត្រឹមតែមួយរយៈប៉ុណ្ណោះ ទ្រង់ជាបិតានៅតែខ្លាចក្រែងរាជបុត្រចាកចេញ ដោយប្រការណាមួយ ទើបទ្រង់បានជួបពិគ្រោះជាមួយទីប្រឹក្សា មន្ត្រី ព្រមទាំងព្រះជាយា ដើម្បីទទួលយោបល់ពីពួកគេ។ ទីបំផុតកិច្ចសន្ទនា បានសម្រេចត្រូវជ្រើសរើសរាជធីតាណាមួយអោយរៀបមង្គលការនឹងទ្រង់ កាលបើទ្រង់មានព្រះមហេសីហើយ ប្រហែលជាអាចធ្វើអោយព្រះអង្គបំភ្លេចបាននូវរឿងរ៉ាវចាកចេញពីនគរ ដូច្នេះការជ្រើសរើសបវរកញ្ញាអនាគតកូនប្រសាស្តេច ក៏ចាប់ផ្តើមប្រព្រឹត្ត ប៉ុន្តែនៅពេលនោះ ព្រះអង្គគ្មានព្រះទ័យពេញចិត្តលើរាជធីតាណោឡើយ ចុងបញ្ចប់នៃកម្មវិធីជ្រើសរើសស្រាប់តែមានរាជធីតាមួយអង្គព្រះនាម **ពិម្ពាសោធរា** ជារាជបុត្រីនៃព្រះបាទ **សុប្បពុទ្ធ** ដែលជាព្រះបិតុលាខាងព្រះមាតា **មហាមាយា** ហេតុតែជាឧបនិស្ស័យពីបុព្វេ បណ្តាលអោយព្រះទ័យព្រះអង្គបំពាក់ទំរង់ (ចិញ្ចៀន) ដល់ព្រះនាង ពិធីជ្រើសរើសបានសម្រេចយករាជធីតា **ពិម្ពា** ជាមហេសីអោយព្រះអង្គតែម្តង។ នៅឆ្នាំឆ្លូវនារដូវកាលដ៏ប្រសើរ ព្រឹក្សាបុប្ផជាតិទាំងពួងខរីកប្រណាំងគ្នា

www.elibraryofcambodia.org

ប្រឡងនឹងទិវាភិសេកមង្គលការដ៏មហាឱឡារិក រវាំងព្រះអង្គ និងរាជបុត្រី **ពិម្ពា** នាគ្រានោះទៅ។ ក្រោយពីពិធីរាជមង្គលការបានចប់សព្វគ្រប់កន្លងមក ព្រះបាទ **សុទ្ធោទនៈ** ទ្រង់បានផុតពីទុក្ខកង្វល់រឿងបុត្រាចាកចេញ ដោយយល់ថា រាជបុត្រាបានជាប់ចំណងត្រឹមហ្នឹងហើយ ច្បាស់ជាមិនមានបំណងចាកចេញចោលនគរទៀតឡើយ។ **ព្រះសិទ្ធត្ថ** ទ្រង់គង់នៅក្នុងនគរដ៏សុខសាន្តរហូតបានរាជបុត្រាមួយអង្គព្រះនាម **រាហ៊ុលកុមារ** (Rahula)។ ជីវិតព្រះអង្គពោរពេញទៅដោយសេចក្ដីសុខ ជួបជុំមហេសី និងបុត្រាស្ងួន គួរតែធ្វើអោយព្រះអង្គសប្បាយព្រះហឫទ័យ តែបែរត្រឡប់ជាធ្វើអោយទ្រង់ចេះតែមិនសប្បាយក្នុងព្រះទ័យទៅវិញ ហើយបណ្ដាលចិត្តអោយចង់ចេញក្រៅរាជវាំងកំសាន្ត និងបានរួចពីទុក្ខកង្វល់ទាំងឡាយ ដែលមាននៅក្នុងអារម្មណ៍របស់ព្រះអង្គ។

www.elibraryofcambodia.org

# វគ្គទី១៣

## ទេវទូតទាំង៤ (Four divine messenger)



ព្រះអង្គទតឃើញហេតុទាំង ៤ បែប
(ស្រង់ចេញពី Internet)

កាលសម័យនាអារុណោទ័យ (dawn) កំពុងជះពន្លឺបំភ្លឺភពផែនដី ពេលដែលព្រះអង្គ **សិទ្ធត្ថ** កំពុងគង់ប្រថាប់ក្នុង **ប្រាសាទគោនទះ** ទ្រង់ភ្ញាក់ឡើង ព្រះទ័យកង្វល់ ចង់យាងចេញក្រៅរាជវាំងជាបន្ទាន់ ដោយព្រះទ័យហាក់ចង់ដឹងរឿងរ៉ាវនៅខាងក្រៅជាពន់ពេក ក៏បង្គាប់អោយសេនាហៅនាយសារថី[២៥] រៀបចំរទេះសាលីយាងព្រះអង្គចេញក្រៅ។ មិនយូរប៉ុន្មាននាយសារថី (Horse cart driver) បានចូលបង្ហាញខ្លួនចំពោះព្រះអង្គដើម្បីរង់ចាំទទួលបញ្ជា។ ព្រះអង្គទ្រង់បង្គាប់ទៅនាយសារថីថា: "ម្នាល! នាយសារថីចូរអ្នករៀបរទេះសាលីទៅ យើងត្រូវចេញទៅក្រសាលក្រៅរាជវាំងថ្ងៃនេះ!"។ នាយសារថីក្រាបថ្វាយបង្គំទៅព្រះអង្គទូលតបថា: "តើគួរទូលព្រះរាជា! អោយទ្រង់ជ្រាបទេ ព្រះអង្គ?"។ - **ព្រះសិទ្ធត្ថ** គ្រាន់តែមានបន្ទូលថា: "មិនបាច់ទេ!"។ នាយសារថីក៏ស្ទុះស្ទារៀបចំទីមរាជរថមួយយ៉ាងប្រណិត រួចមកទទួលព្រះអង្គយាងចេញក្រៅរាជវាំង។ ពេលដែលព្រះអង្គចេញដល់ក្រៅ ទិដ្ឋភាពជាច្រើនដែលទ្រង់បានទតឃើញ មានការចាប់អារម្មណ៍

[២៥] អ្នកបររទេះសេះប្រចាំការសំរាប់ព្រះអង្គ។ ភាពយន្ត ឥណ្ឌាបានបង្ហាញថា តួនាយសារថីគឺជាទេវតានិមិត្តខ្លួន។

www.elibraryofcambodia.org

ចំពោះប្រជារាស្ត្រ ខ្លះមាន ខ្លះក្រ ខ្លះខំធ្វើការដោយកម្លាំងគ្មានឈប់សម្រាក ខ្លះមានទុក្ខលំបាក ធ្វើអោយទ្រង់ភ្ញាក់ព្រះទ័យ នឹកអាណិតដល់រាស្ត្រប្រជាទាំងនោះជាពន់ពេក។ ពេលដែលព្រះអង្គយាងដល់ជាយក្រុងបន្តិចក៏ប្រទះឃើញហេតុ ៤ បែប ដែលធ្វើអោយព្រះអង្គចាប់ចិត្តចម្ងល់ក្នុងព្រះទ័យជាខ្លាំង កើតក្តីពិចារណា។

ព្រាដំបូង ព្រះអង្គទតឃើញមនុស្សចាស់ជរាម្នាក់កំពុងធ្វើដំណើររញ៊ីររញ៉ូរ ដើរកាត់រាជរថព្រះអង្គ ទ្រង់អោយនាយសារថីឈប់ រទេះ ដោយខ្លាចប៉ះត្រូវគាត់ ទ្រង់មានហឫទ័យ ងឿងឆ្ងល់ ដោយមិនធ្លាប់ឃើញបែបនេះពីមុនមក ក៏ត្រាស់សួរទៅនាយសារថីថា: "តើគាត់យ៉ាងម៉េចហ្នឹង! ម្តេចបានជាគាត់ធ្វើដំណើររញ៊ីររញ៉ូរបែបដូច្នេះ?" - នាយសារថីទូលតបវិញថា: "ក្រាបទូល! ព្រះអង្គនេះហៅថា មនុស្សចាស់ជរា មនុស្សយើងតែដល់ពេលចាស់ទៅគឺមានសភាពបែបនេះហើយក្រាបទូល!"។ ព្រះអង្គទតហើយមានហឫទ័យកណ្តោចកណ្តែង អាណិតដល់ជនចាស់ជរានោះជាពន់ពេក តែទ្រង់មិនចេញបន្ទូលឡើយ គ្រាន់តែបង្គាប់ជាថ្មីដល់នាយសារថីអោយធ្វើដំណើរទៅមុខទៀត។ ឯជនចាស់ជរានោះក៏បាត់ចេញពីក្រុមមហាជនដែលកំពុងធ្វើដំណើរក្នុងទីក្រុងនោះទៅ។ ចេញពីទីនោះបន្តិចទៀតមក ទ្រង់ក៏ទតឃើញមនុស្សម្នាក់កំពុងឈឺស្តមរីងរៃ ដេកយ៉ាងកំសត់ព្រះអង្គទតហើយ ក៏ត្រាស់សួរទៅនាយសារថីថា: "តើពួកគាត់កំពុងធ្វើអ្វី? ហេតុដូចម្តេចបានជាមនុស្សដេកមានសភាពបែបដូច្នេះអញ្ចឹង?"។ នាយសារថីក៏ទូលតបទៅវិញថា: "ក្រាបទូល! នេះហៅថាមនុស្សពពឹក្រាបទូល! មនុស្សយើងកាលណាតែមានជំងឺ



ហេតុភេទទាំង៤ស្ថិតក្នុងព្រះទ័យព្រះអង្គ
(ស្រង់ចេញពី Internet)

www.elibraryofcambodia.org

ហើយ គឺដេកដូច្នេះឯង ក្រោកទៅណាពុំរួចឡើយក្រាបទូល!"។ ព្រះអង្គទតហើយ ទ្រង់មានក្ដីអាណិតអាសូរ និងរន្ធត់ក្នុងព្រះហឫទ័យ ហើយទ្រង់ក៏ត្រិះរិះថា "ជីវិតដែលកំពុងឈឺគឺពិតជាពិបាកជាងអ្វីៗទាំងអស់ ទតទៅវេទនាណាស់" ទ្រង់ដកដង្ហើមធំបន្តិចដោយមិនមានបន្ទូលអ្វីឡើយ គ្រាន់តែបង្គាប់អោយនាយសារថីអោយបន្តដំណើរទៅមុខទៀត។ រាជរថបរត្រីកៗបានបន្តិចក៏ទុចង៉ក់ ដោយព្រះអង្គបានឃើញមនុស្សដេកស្លាប់ ទ្រង់មានហឫទ័យចម្ងល់ ក៏ត្រាស់សួរទៅនាយសារថី គាត់ក៏ទូលថ្វាយដោយរៀបរាប់ថា: "ក្រាបទូល! នោះគេហៅថា បុគ្គលមរណៈ! មនុស្សយើងកាលណាចាស់ហើយត្រូវតែស្លាប់! ហើយសេចក្ដីស្លាប់ គ្មានអ្នកណាគេចរួចទេ! ក្រាបទូល!"។ ទ្រង់ទតឃើញហើយ និងស្ដាប់ពាក្យរៀបរាប់របស់នាយសារថី ព្រះអង្គសែនសង្វេគ នឹកអនិច្ចាក្នុងព្រះទ័យពន់ពេកក្រៃ តែព្រះអង្គនៅតែមិនមានបន្ទូលអ្វី គ្រាន់តែធ្វើសញ្ញាអោយនាយសារថីបន្តរាជរថទៅមុខទៀតប៉ុណ្ណោះ។ នាយសារថីដែលជាទេវតានិមិត្តកាយនោះ ទ្រង់លួចញញឹមប៉ប្រាយក្នុងហឫទ័យដោយថ្លែងយល់ថា: **ព្រះសិទ្ធត្ថ** កំពុងលង់ក្នុងទេវទូតនិមិត្តរបស់ខ្លួនហើយ ឥឡូវនៅសល់តែទេវនិមិត្តចុងក្រោយបង្អស់ ដែលធ្វើអោយទ្រង់សម្រេចព្រះទ័យ។ នៅជាយក្រុងចុងភូមិបង្អស់នៃរាជធានី នៅពេលដែលរាជរថកំពុងតែបរសន្សឹមៗទៅមុខ ស្រាប់តែត្រូវឈប់នៅក្រោមដើមព្រឹក្សាដ៏ធំមួយពេលនោះព្រះអង្គទ្រង់ទតឃើញបុព្វជិតមួយអង្គ កំពុងសមាធិនៅក្រោមដើមឈើនោះដោយធ្មេចព្រះនេត្រ។ **ព្រះសិទ្ធត្ថ** ទ្រង់មានព្រះទ័យចាប់អារម្មណ៍លើសទេវទូតទាំង ៣ ដែលទ្រង់បានទតឃើញពីមុន ពេលនោះទ្រង់ប្រញាប់ត្រាស់សួរទៅនាយសារថីភ្លាមៗដោយមិនបង្អង់យូរ នាយសារថីក៏រហ័សឆ្លើយទូលទៅព្រះអង្គវិញថា: "ក្រាបទូលព្រះអង្គ! នេះហៅថា **សមណៈបុព្វជិត** គឺអ្នកបួស

www.elibraryofcambodia.org

កាន់សីល សន្សំសីល រមែងសង្វាតព្យាយាមកសាងកុសល ធ្វើភាវនាកម្មដ្ឋាន សម្មាធិធម៌ សម្អាតចិត្តដោយក្តីផូរផង់ ព្រមទាំងមានចិត្តជាទាន គឺមានសភាពដូច្នេះ ហើយក្រាបទូល!"។ ព្រះអង្គជ្រាបហើយ ទ្រង់ហាក់សព្វព្រះទ័យក្រៃលែង ទ្រង់មានចំណូលព្រះទ័យចុះចាករាជរថ មកក្រាបបង្គំអង្គបុព្វជិតនោះ ទ្រង់បានបន្លឺបន្ទូលតិចៗមកថាៈ "ខ្ញុំករុណាសូមផ្សងក្នុង ពះទ័យសុំអោយក្តីប្រាថ្នាសាមាធិកម្មបែបនេះ ចូរមានដល់រូបខ្ញុំករុណាកុំបីអាក់ខានឡើយ"។ រួចព្រះអង្គបង្គំលាសមណៈអង្គនោះឡើងរាជរថត្រឡប់វិលចូលព្រះនគរវិញ ដោយនាំនូវព្រឹត្តិការណ៍ ដែលព្រះអង្គបានទតឃើញទាំងប៉ុន្មានទៅជាមួយផងដែរ។



ព្រះអង្គទ្រង់ពិចារណាពីអភូតហេតុទាំង៤
(ស្រង់ចេញពី Internet)



ប្រាសាទបុរាណនៅរដ្ឋ Madhya Pradesh ប្រទេសឥណ្ឌា

www.elibraryofcambodia.org

# វគ្គទី១៤

# ទ្រង់ចេញសាងព្រះផ្នួស

# (Departure of Siddhartha to Priesthood)

ក្រោយពីត្រឡប់ពីយាងកំសាន្តនូវទិដ្ឋភាពក្រៅវាំង ព្រមទាំងទតឃើញនូវហេតុការណ៍នៃទេវទូតទាំង ៤ មក ធ្វើអោយ **ព្រះសិទ្ធត្ថ** មិនស្ងប់ព្រះហឫទ័យ ទ្រង់ផ្ទុំមិនសូវ បានរាល់ពេលរាត្រី ពេលថ្ងៃព្រះអង្គតែងនៅស្រងូតស្រងាត់ (sad facial expression) តែអង្គឯង ទ្រង់ចេះតែសញ្ជប់សញ្ជឹងវង្វេងឆ្ងាយក្នុងព្រះទ័យ ទ្រង់ត្រិះរិះពិចារណានូវហេតុការណ៍មនុស្ស ចាស់ ឈឺ ស្លាប់ ក្នុងជីវិតស្ថិតក្នុងស្ថតរន្ធត់ គឺជាការគៀបសង្កត់សត្វលោកក្នុងវដ្តសង្សារ (evolution of the life cycle) ដោយជៀសមិនរួច ជីវិតមិនបានទទួល ឬជួបអ្នកប្រាជ្ញណាមួយ ដើម្បីប្រៀនប្រដៅ ឬបង្ហាញទិសដៅដោយប្រការណាមួយ ជីវិតត្រូវទទួលការងុបងុលក្នុងផ្លូវដែលខ្លួនមិនដឹង ភ្លេចខ្លួនក្នុងវ័យវង្វាទាការ ដែលចេះតែរំកិលតាមពេលវេលា។ ចំណែកខាងផ្លូវបុព្វជិត ទ្រង់បានពិចារណាថា រាល់រូបាគង់នឹងវិវត្តន៍មិនឈប់ឈរទៅកាន់ក្តីមរណា ដូច្នេះគប្បីជីវិតត្រូវស្វែងរកប្រយោជន៍សម្រាប់សង្គ្រោះនូវក្តីទុក្ខផងទាំងពួង ទ្រង់យល់ថាមានតែបុព្វជិតនេះទេ ដែលអាចរកឃើញធម៌ដំណោះស្រាយ រំដោះទុក្ខទាំងនោះបាន ត្រិះរិះពិចារណាដូចនេះហើយ ទើបព្រះអង្គសម្រេចព្រះទ័យត្រូវតែចេញទៅបួស។



ទ្រង់ទតឃើញភាពគ្មានរបៀបរបស់ពួកភីលៀង ( ស្រង់ចេញពី Internet )

www.elibraryofcambodia.org



ទ្រង់យាងចេញពីព្រះរាជដំណាក់
(ស្រង់ចេញពី Internet)

នៅក្នុងរាត្រីខែអាសាឍ ឆ្នាំថោះ ក្នុងព្រះជន្ម ២៩ វស្សា **ព្រះសិទ្ធត្ថ** ទ្រង់យាងលបៗចាកចេញពីរាជដំណាក់ យាងមកកាត់បន្ទប់ភិលៀង ឃើញមីនំមីនាងដេកគ្មានរបៀប ខ្លះច្រងាងកណ្ដាលវាល រឹតតែបង្ហាញអោយព្រះអង្គមិនចូលចិត្ត ខ្ពើមរអើមចំពោះសភាពនៃពួកភិលៀងទាំងនោះ ឆ្លងផុតពីបន្ទប់ពួកភិលៀង ក៏មកដល់ដំណាក់មហេសី **ពិម្ពា** ឃើញព្រះនាងទ្រង់ផ្ទំលក់យ៉ាងស្កប់ស្កល់ ឱបរាជបុត្រាកុមារ **រាហ៊ុល**។ ព្រះអង្គមានព្រះទ័យនឹកអាណិតបុត្រាស្ងួនភ្ងារ ចង់ដកដៃមហេសីចេញ តែខ្លាចព្រះនាងភ្ញាក់ នាំអោយខកដំណើរព្រះអង្គ ទ្រង់ក៏កាត់ចិត្តថា មានតែពេលនេះទេ ដែលជាឱកាសអាចស្រាយចំណងចេញបាន ដើម្បីសម្មាសម្ពោធិញ្ញាណរំដោះទុក្ខមនុស្សសត្វ ទើបទ្រង់សម្រេចដាច់ព្រះទ័យចាកចេញទាំងពាក់កណ្ដាលរាត្រី។ នៅពេលនោះដែរ នាយ **ឆន្នអាមាត្យ** (King's confidant-Chhana) (អ្នកបម្រើជំនិត) បាននាំសេះ **កណ្ឋក** (horse Kanthaka) យ៉ាងមាំមួយ ចេញមកទទួលព្រះអង្គ ទ្រង់ឡើងលើខ្នងពាជីនោះ រួចបំផាយចេញដោយនាយ **ឆន្នអាមាត្យ** រត់តាមពីក្រោយទៅជាមួយ។ ពេលចេញដល់ក្រៅវិមានរាជវាំង ទ្រង់ងាកព្រះភក្ត្រសម្លឹងទឹកដីរាជនគរ ដែលព្រះអង្គធ្លាប់ រស់នៅតាំងពី



ចេញសាងព្រះផ្នួស
(ស្រង់ចេញពី Internet)

www.elibraryofcambodia.org



មហាគម្ព័ន្ធឃាត់ព្រះអង្គ ( ស្រង់ចេញពីវត្តសំរោងអណ្ដែត ក្រុងភ្នំពេញ ប្រទេសកម្ពុជា)

តួចមក ទ្រង់ពោរពេញដោយក្ដីអាល័យ រកអ្វីប្រៀបពុំបាន តែព្រះអង្គខំកាត់ព្រះទ័យ ងាកព្រះភក្ត្រមកវិញ រួចបំផាយសេះចេញទៅ ។

រាជដំណើរបានមកឆ្ងាយបន្តិចពីនគរ ស្រាប់តែមានបដិហារ (magical creation) មួយ បាននិមិត្តចេញឡើងនាកណ្ដាលអាកាសវេហាស៍នោះ គឺជា **មហាគម្ព័ន្ធមារ** (great devil Kaumpontha) ស្រែកឡើងឃាត់ដំណើរព្រះអង្គថា: "នែ៎! **សិទ្ធត្ថ**! ចូរអ្នកកុំចេញទៅបួសអី! នៅតែ ៧ ថ្ងៃទៀត សម្បត្តិចក្រពត្តិមហាធិរាជនឹងមកដល់រូបអ្នកហើយ! "**ព្រះសិទ្ធត្ថ** ទ្រង់សណ្ដាប់តែមិនឈប់បំផាយសេះឡើយ ទ្រង់តបទៅ **មហាគម្ព័ន្ធ** មារវិញថា: "មហាមារ! យើងដឹងហើយ តែយើងមិនត្រូវការសម្បត្តិចក្រពត្តិ (empire wealth) អីទេ! ឆាប់ថយចេញទៅ!" ។ មហាមារឮហើយអស់ពាក្យនិយាយ ធ្វើទឹកមុខហួសចិត្ត រួចក៏ហោះគេចចេញបាត់ទៅ។ ចំណែករាជដំណើរ **ព្រះសិទ្ធត្ថ**ចេះតែទៅមុខមិនឈប់ឈរឡើយ ទ្រង់បានធ្វើដំណើរឆ្លងកាត់នគរ **សាវត្ថី** (Shavasti) នគរ **វេសាលី** (Vaishali) ចម្ងាយផ្លូវ ៣០ យោជន៍[២៦] (ancient measurement, 1 Yojana = 16 Kilometers = 9.94 miles) ព្រះអង្គបានទៅដល់ស្ទឹងមួយឈ្មោះ **អនោមា** (Anoma river) ជាស្ទឹងដែលមានទឹករាក់អាចធ្វើដំណើរឆ្លងបាន ព្រះអង្គក៏ជិះសេះឆ្លងស្ទឹងនោះទៅកាន់ត្រើយម្ខាង ឯនាយ **ឆន្នអាមាត្យ** ក៏តាមពីក្រោយព្រះអង្គជាប់មិនបែកគ្នាឡើយ ។ ពេលទ្រង់ឆ្លងដល់ត្រើយម្ខាងស្រួលបួលហើយ ព្រះអង្គក៏ចុះចាកខុរ

[២៦] ៣០ យោជន៍ = ៤៨០ គីឡូម៉ែត្រ = ២៩៨ miles ។

www.elibraryofcambodia.org

សេះ ហើយដោះគ្រឿងពស្ត្រា (decoration of the King) ដែលជាក្សត្រចេញ ហើយមានរបស់ផ្សេងៗ អោយទៅនាយ **ឆន្នអាមាត្យ** នាំយកត្រលប់ទៅអោយព្រះបិតាឯរាជសីមាវិញ ដើម្បីថ្វាយដំណឹងដល់រាជវង្សទាំងអស់បានជ្រាបផង។ នាយ **ឆន្នអាមាត្យ** ទទួល គ្រឿងសព្វយ៉ាងពីព្រះអង្គ ហើយក៏ក្រាបបង្គំលានាំសេះចាកចេញពីនោះ។ មកដល់ពាក់កណ្តាលផ្លូវ កណ្ឋកសេះក៏ដាច់ខ្យល់ស្លាប់ដោយអាការៈនឿយហត់ក្នុងពេលធ្វើដំណើរទៅមក។ កណ្ឋកសេះកាលបើស្លាប់ទៅ ហើយក៏បានទៅកើតជាអង្គទេវបុត្រនៅស្ថានទេវលោក មានព្រះនាមថា **កណ្ឋកទេវបុត្រ** (male divinity) ចំណែក **នាយឆន្នអាមាត្យ** មានទុក្ខសោកក្រៃលែង ដោយអាណិតកណ្ឋកសេះដែលបានស្លាប់ទៅ។ ក្រោយមកគាត់ក៏រៀបចំបង្វិច ដែលជាគ្រឿងពស្ត្រាព្រះអង្គ ស្ពាយចេញដំណើរថ្មើជើងបន្តលុះត្រារហូតដល់រាជនគរ។

**នាយឆន្ន** ចូលក្រាបបង្គំព្រះបាទ **សុទ្ធោទនៈ** ដោយរ៉ាយរ៉ាប់សព្វប្រការ និងថ្វាយគ្រឿងពស្ត្រាទាំងនោះដល់ព្រះអង្គជ្រាប។ មហារាជ និងព្រះញាតិវង្សក៏មានហប្ញទ័យក្តុកក្តួលគ្រប់ៗគ្នា អាណិតដល់រាជបុត្រពន់ពេកដោយយល់ថា មិនគួរឡើយណាព្រះអង្គលះបង់រាជនគរដែលធ្លាប់គង់ដ៏សែនសុខ ឥឡូវប្រែក្លាយជាបព្វជិតរស់នៅតាមដងព្រៃភ្នំ ជំរំទីស្ងាប់ស្ងាត់ទៅវិញ។ ព្រះបាទ **សុទ្ធោទនៈ** ទ្រង់មានព្រះតម្រិះដោយបន្លឺព្រះបន្ទូលថាៈ "បើពេលវេលាឧប្បនិស្ស័យបានកំណត់ដូច្នេះទៅហើយ! អ្វីៗអោយទៅតាមដំណើរចុះ"។ ទ្រង់មានតែបួងសួងអនុមោ-ទនា (receive consequently) បន្ថែមថាៈ "សូមអោយក្តីប្រាថ្នារបស់រាជបុត្របានសម្រាប់គ្រប់បែបយ៉ាងដែលទ្រង់ចង់បាន"។

www.elibraryofcambodia.org

# វគ្គទី១៥
# ថ្ងៃព្រះសិទ្ធត្ថព្រះផ្នួស
# (Priesthood time of Siddhartha)

នៅសម័យថ្ងៃព្រហស្បតិ៍ ១៥ កើត ខែអាសាធ ឆ្នាំថោះ នៅលើពំនូកខ្សាច់ជិតកូនស្ទឹង **អនោមា** មានទឹកហូររីម១ ថ្លាយង់យល់បាតដី ព្រះសូរ្យសែងចាំងក្តៅហែង តែប្លែកត្រង់កន្លែង **ព្រះសិទ្ធត្ថ** គង់ព្រះផ្នួស បែរជាមានម្លប់ត្រជាក់រហើមគួរជាទីមនោរម្យ ដោយអំណាចផលបុណ្យបារមីព្រះអង្គ ដែលមានតាំងពីបុព្វេសន្និវាសមក បណ្តាលអោយមានហេតុកើតឡើងនូវគ្រឿងបរិក្ខាទិព្វ (celestial equiqment) បាននិមិត្តគ្រប់យ៉ាងចេញមក សម្រាប់អោយព្រះអង្គទ្រង់ព្រះផ្នួស ។ បរិក្ខារទាំងនោះមានៈ ព្រះខ័នជ័យសម្រាប់កាត់កេសា (hair) មានត្រៃចីវរ បាត្រ កាំបិតកោរវត្តពន្ធ (គ្រឿងដេរ ម្ជុលអំបោះ) បំពង់ទឹក ជើងពានសព្វសារពើដើម្បីសម្រេចកិច្ចក្នុងពេលសាងផ្នួស ។ បបំមព្រះអង្គទ្រង់អញ្ជលីប្រណម (placing of the two hands with palms together and fingers up taken reverence) ថ្វាយបង្គំអធិដ្ឋានក្នុងព្រះទ័យ (pray to the gods) ឧទ្ទិសដល់ទីកន្លែងសក្តិសិទ្ធដែលព្រះអង្គកំពុងស្ថិតនៅ រំលឹកដល់គុណឧបេ្បនិស្ស័យនាទិសស្ថានទេវលោក ដែលមានស្តេចសកទេវរាជព្រះមហាទេពទាំង ៤ (ព្រះព្រហ្មណ៏ ព្រះសិវា ព្រះវិស្ណុ ព្រះនរាយណ៏) និងអស់ពួកទេវត្តា ទេពនិករនាចក្រវាឡទាំងមូល ។ ទ្រង់ឧទ្ទិសសព្វកិច្ចគ្រប់បែបយ៉ាងដូច្នេះ គឺចង់បញ្ជាក់ប្រាប់ពិភពលោកថា ចាប់ពីថ្ងៃដែលព្រះអង្គទ្រង់ព្រះផ្នួសនេះទៅ ព្រះអង្គនឹងខំធ្វើឡើងដើម្បីសម្រេចព្រះធម៌ និងជួយដល់សត្វលោកអោយមានសេចក្តីសុខ ដែលជីវិតគ្រប់រូប

www.elibraryofcambodia.org

តែងប្រាថ្នាចង់បាន។ ពេលបញ្ចប់កិច្ចទាំងនោះហើយ ព្រះអង្គក៏ចាប់ព្រះខ័នជ័យ កាត់កេសាអោយសល់ប្រវែង ២ ធ្នាប់ប៉ុណ្ណោះ ហើយបោះទៅលើអាកាស ពេលនោះទេពនិករក៏ហោះព្រោងព្រាតចេញមកទទួល ដាក់ទុកក្នុងប្រអប់កែវ ហើយយកទៅដំកល់ទុកក្នុង **ចូឡាមណីចេតិយ៍** (Chaulamana Stupa of the gods) នាស្ថាន **តាវតឹង្ស**។ បន្ទាប់ពីកាត់កេសារួចមក ទ្រង់បន្តព្រះមោលី (បួងសក់) (tie hair) ឡើងលើព្រះអង្គធ្វើដូច្នេះព្រោះមិនចង់អោយដុះវែងទៅទៀត (ដូចរូបដំកល់សល់សព្វថ្ងៃ) (as Buddha statue until now) ទាល់ថ្ងៃបរិនិពាន្ទ ឯសំពត់កាសាយ (សំពត់ក្រង) មានពណ៌លឿងទុំដូចដែលបុព្វ-ជិតទាំងឡាយបានប្រើ តែសម័យនោះមានប្រើតែ ២ ទេ គឺសំពត់ដណ្តប់ និងសំពត់ស្បៀកប៉ុណ្ណោះ ចំណែកសង្ឃាដី (multi-layered cloth used by monks to wrap around the body) ទើបនឹងមាននៅគ្រាក្រោយបន្តមកទៀត ព្រះអង្គបានក្លាយខ្លួនជាបុព្វជិតតាំងពីពេលនោះមក គឺ **ព្រះសាស្នា** នេះឯង។



ព្រះអង្គទ្រង់កាត់ព្រះកេសា
(ស្រង់ចេញពី Internet)



ព្រះអង្គទ្រង់សម្មាធិកម្មដ្ឋាន
(ស្រង់ចេញពី Internet)

www.elibraryofcambodia.org

# វគ្គទី១៦

# បញ្ចវគ្គីយតាបស (Five Sramanas)

ក្រុមបណ្ឌិតព្រាហ្មណ៍នៅក្នុងរាជវាំង ដែលជាអ្នកធ្លាប់បានទស្សទាយ និងផ្តល់ព្រះនាមថ្វាយ **ព្រះសាស្តា** ពីមុននោះ ក្រោយមកពួកគាត់បានដំណឹងថា **ព្រះសិទ្ធត្ថ** ទ្រង់បានចេញបួសហើយ ពួកគាត់ក៏មានចិត្តចង់អោយកូនប្រុសរៀងៗខ្លួនចេញទៅបួសតាម **ព្រះសិទ្ធត្ថ** ដែរ ពួកគាត់បានជួបប្រជុំគ្នា ដើម្បីពិភាក្សាពីរឿងអោយកូនចេញបួស។ **រាមព្រាហ្មណ៍** បានចេញយោបល់មុនគេថា: "**ព្រះសិទ្ធត្ថ** ព្រះអង្គបានចេញសាងព្រះផ្នួសហើយ! តើពួកយើងគួរធ្វើដូចម្តេច! ដើម្បីតាមបំរើព្រះធម៌ជាមួយព្រះអង្គបាន?"។ **លក្ខណព្រាហ្មណ៍** ដែលចំណាស់ជាងគេក្នុងចំណោមនោះពោលឡើយថា: "ហ៊ឺ! ពួកយើងកាន់ចាស់អស់ហើយ! តើធ្វើម្តេចទៅកើត"។ **វប្បៈសុទត្ត** ព្រាហ្មណ៍ជាឪពុករបស់ **វប្បៈ** (Baspa) ក៏ពោលដែរថា: "យើងចាស់ៗមែនហើយ! តែកូនរបស់យើងរាល់គ្នា! ពួកគេអាចទៅបាន យើងអោយពួកគេទៅបួសតាមបំរើព្រះអង្គទៅ វាជាការល្អណាស់ទៅហើយ"។ **កោណ្ឌញ្ញព្រាហ្មណ៍** ដែលមានវ័យក្មេងជាងគេ ហើយធ្លាប់បានទស្សទាយអះអាងថា **ព្រះសិទ្ធត្ថ** នឹងក្លាយជា **ព្រះពុទ្ធ** តែមួយគត់ក្នុងលោក បានពោលឡើងថា: "អស់លោកព្រឹទ្ធាចារ្យព្រាហ្មណ៍ចាស់មែនហើយ! តែខ្ញុំនៅក្មេងអាចទៅបួសនៅពេលនេះបាន! ហើយអាចជួយមើលខុស ត្រូវដល់កូនព្រាហ្មណ៍ទាំង ៤ ផងដែរ!"។ **រាមព្រាហ្មណ៍** ដែលផ្តើមមុនគេឮហើយ ក៏និយាយដោយក្តីរីករាយឡើងដែរថា: "ល្អណាស់! បើអញ្ចឹងព្រាហ្មណ៍ **កោណ្ឌញ្ញ** ឯងទៅបួស

www.elibraryofcambodia.org

ជាមួយកូនពួកយើងចុះ ហើយជួយមើលពួកគេផងណា!"។ **កោណ្ឌិញ្ញ** ព្រាហ្មណ៍ តបវិញដោយញញឹមថា: "បាទ! សូមព្រឹទ្ធាចារ្យទាំងអស់ទុកចិត្តចុះ! សព្វបែប យ៉ាងនឹងល្អប្រសើរជាក់ជាមិនខាន!"។ ក្រុមព្រាហ្មណ៍ក៏សម្រេចអោយកូនប្រុស ទាំង ៤ នាក់ដែលមានឈ្មោះ : ១-**វប្បៈ** (Baspa) ២-**ភទ្ទិយ** (Bhadrika) ៣-**មហានាម** (Mahanama) ៤-**អស្សជិ** (Asvajit) រួមនិងព្រាហ្មណ៍ **កោណ្ឌិញ្ញ** (Kaundinya) ផង សរុបមានគ្នាទាំងអស់ ៥ នាក់ ដូច្នេះទើបគេ អោយឈ្មោះពួកគាត់ថា: **បញ្ចវគ្គីយ**។

**បញ្ចវគ្គីយ** បានទៅបួសជាតាបសហើយទៅរៀនធម៌ និងស្នាក់នៅ អាស្រមរបស់ **អាឡារគោត្រ** តាបស នាព្រៃ **មិគទាយវ័ន** (Deer Park) ជិតក្រុង **ពារាណសី** (City of Baranasi)។ ចាប់តាំងពីពេលនោះ **បញ្ចវគ្គីយ** បានក្លាយជាតាបសទាំង ៥ ហើយក្រោយមកតាមរក **ព្រះសិទ្ធត្ថ** ដែលទ្រង់ ចេញសាងផ្នួសដើម្បីបម្រើព្រះអង្គ។



បញ្ចវគ្គីយតាបសនៅបំរើព្រះអង្គ ( ស្រង់ចេញពី Internet )

www.elibraryofcambodia.org

# វគ្គទី១៧
# ព្រះបាទ ពិម្ពិសាររាជ (King Pimbisara)


ព្រះអង្គសោយចង្ហាន់ ( ស្រង់ចេញពីវត្ត សំរោងអណ្តែតក្រុងភ្នំពេញ

**ព្រះសាស្តា** ទ្រង់គង់នៅមាត់ស្ទឹង **អនោមា** បានព្រះផ្នួសហើយ ព្រះអង្គទ្រង់ព្រះតម្រិះធ្វើសមាធិកម្មដ្ឋាន ដើម្បីស្រាវជ្រាវរកពោធិញ្ញាណវិធី (Way of Enlightenment) ក្នុងកំឡុងពេលខ្លី តែមិនមានលទ្ធផលឡើយ។ ព្រះអង្គទ្រង់ក៏និមន្តទៅគង់នៅតំបន់ **អនុបិយម្ពវ័ន** (Anupiya) បាន ៧ ថ្ងៃ ក៏ទ្រង់និមន្តបន្តទៅកាន់និគមជនបទមួយទៀត ឈ្មោះ **មគធះ** (Magadha) ទ្រង់គង់ប្រថាប់នៅទីនោះបានមួយរយៈពេល។

កាលបន្ទាប់មក ព្រះអង្គទ្រង់ប្រដាប់ចីវរ (the outer robe)និងបាត្រដើម្បីនិមន្តបិណ្ឌបាត្រ (food quest) ឆ្ពោះទៅកាន់ទីប្រជុំជននៃរាជធានីក្រុង **រាជគ្រឹះ** (Ratnagiri) ។ មហាជនក្នុងក្រុងបានចេញមក ប្រគេនចង្ហាន់ និងរាប់បាត្រ(food offering) ថ្វាយព្រះអង្គគ្រប់ជនានុជន។ ពេលជាមួយគ្នានោះ ក៏មានអភិជន (nobility) ម្នាក់ដែលជាជំនិតក្នុងរាជវាំងបានឃើញ **ព្រះសាស្តា** និមន្តបិណ្ឌបាត្រដូច្នេះ ក៏នាំដំណឹងទៅប្រាប់ព្រះរាជាគឺព្រះបាទ **ពិម្ពិសារ**។ ស្តេច **ពិម្ពិសារ** ទ្រង់សណ្តាប់ហើយដឹងថា មានបុព្វជិតនិមន្តបិណ្ឌបាត្រក្នុងនគររបស់ខ្លួន ព្រះអង្គមានការចាប់អារម្មណ៍យ៉ាងខ្លាំង ទ្រង់ក៏ចាត់អោយសេនាទៅពិនិត្យតាមដានមើល ចង់

www.elibraryofcambodia.org

ដឹងថាតើព្រះសាមណៈអង្គនេះ គង់នៅកន្លែងណា? ហើយនិមន្តមកពីទីណា? អង្គសេនាទទួលបញ្ជាក៏ចេញទៅពិនិត្យសកម្មភាព ដែល **ព្រះសាស្តា** និមន្តចេញចូលក្នុងរាជនគរតាមបញ្ជាស្តេច។ ចំណែក **ព្រះសាស្តា** ទ្រង់បំពេញកិច្ចបិណ្ឌបាត្រចប់ហើយ ព្រះអង្គមិននិមន្តទៅ **មគធៈ** វិញទេ ទ្រង់និមន្តបង្ហួសទៅកាន់ភ្នំ **បណ្ឌវៈ** (Pandava) ដែលជាដងព្រឹក្សា ស្ថិតនៅជាប់ជ្រលងកូនភ្នំ ពោរពេញទៅដោយទេសភាពដ៏ស្រស់ត្រកាល ទ្រង់គង់ទីនោះដើម្បីសោយចង្ហាន់។ ឯសេនាដែលតាមដានបានតាមរហូតស្គាល់ទីកន្លែងដែល **ព្រះសាស្តា** គង់នៅហើយ ក៏ត្រឡប់នាំដំណឹងទៅរាយការណ៍ថ្វាយព្រះបាទ **ពិម្ពិសារ** ឯរាជវាំងវិញ។ ស្តេច **ពិម្ពិសារ** ទ្រង់ជ្រាបហើយ ក៏រៀបដំណើរយាងទៅកាន់កន្លែង **ព្រះសាស្តា** គង់នៅ ក្នុងបំណងនឹងសាកសួរញាត្តិត្រកូលរបស់ព្រះសាមណៈអង្គនេះ។ កាលបើបានជួបហើយ ព្រះបាទ **ពិម្ពិសារ** ទ្រង់ថ្វាយបង្គំ រួចសាកសួរនូវជីវប្រវត្តិ **ព្រះសាស្តា**។ **ព្រះសាស្តា** ក៏ថ្វាយជីវប្រវត្តិរបស់ព្រះ អង្គដល់មហារាជវិញដោយសព្វប្រការ។ ស្តេច **ពិម្ពិសារ** មានបំណងចង់អោយ **ព្រះសាស្តា** ទ្រង់នៅគ្រងរាជជាមួយខ្លួននឹងចែករាជសម្បត្តិថ្វាយអោយពាក់ កណ្តាលទៀតផង តែ **ព្រះសាស្តា** ទ្រង់បដិសេធមិនទទួលយកឡើយ ហេតុនេះហើយស្តេច **ពិម្ពិសារ** ក៏មានព្រះទ័យផ្សេងដោយសុំពរពី **ព្រះសាស្តា** វិញថាៈ "បពិត្រព្រះមហាសមណៈដ៏អស្ចារ្យ! បើទ្រង់មិនព្រមគង់នៅសោយរាជ្យសម្បត្តិជាមួយខ្ញុំព្រះករុណាទេ! ខ្ញុំព្រះករុណាសុំការប្រោសប្រទានម្យ៉ាងពីព្រះអង្គ គឺនៅពេលដែលព្រះអង្គបានត្រាស់ដឹងនូវសាម្មាសម្ពោធិញ្ញាណហើយ! សូមមេត្តានិមន្តមកប្រោសខ្ញុំព្រះករុណាជាមុនផងព្រះអង្គ!"។ **ព្រះសាស្តា** ញញឹមតបទៅស្តេច **ពិម្ពិសារ** វិញដោយបញ្ជាក់ន័យថា ព្រះអង្គនឹងនិមន្តមកប្រោសស្តេចតាមសំណូមពររបស់ទ្រង់ដែលបានស្នើសុំ។

www.elibraryofcambodia.org

ក្រោយពីបានទទួលរាជប្រទានពី **ព្រះសាស្តា** សមតាមព្រះទ័យហើយ ស្តេច **ពិម្ពិសារ** រីករាយ ហើយថ្វាយបង្គំលាត្រឡប់ចូលរាជវាំងវិញ ដោយពាំនាំនូវក្តីសង្ឃឹមក្នុងព្រះទ័យទៅជាមួយផង ។



ព្រះបាទ **ពិម្ពិសាររាជ** និមន្តព្រះអង្គអោយឡើងសោយរាជ្យ
( ស្រង់ចេញពីវត្តសំរោងអណ្តែត ក្រុងភ្នំពេញ ប្រទេសកម្ពុជា )

www.elibraryofcambodia.org

# វគ្គទី១៨

# សង្គ្រោះសត្វ

# (Rescue anykind of creature in danger)



ព្រះអង្គសង្គ្រោះសត្វ
( ស្រង់ចេញពី Internet )

**ព្រះសាស្តា** ទ្រង់ថ្វាយក្តីប្រាថ្នាដល់ព្រះបាទ **ពិម្ពិសារ** រួចហើយ ព្រះអង្គក៏ទ្រង់ចាកចេញពីភ្នំ **បណ្ឌវៈ** ទៅកាន់តំបន់ **និរាវត្ថី** (Nirauvasti) ទ្រង់និមន្តដោយផ្ទាល់ព្រះបាទាមកដល់និគមជនបទមួយទៀត ដែលភាគច្រើនជាប្រជាជនកុលសម្ព័ន្ធរស់នៅ។ នៅពេលនោះព្រះអង្គបានប្រទះឃើញអ្នកស្រុកនៅទីនោះ កំពុងធ្វើពិធីបូជាយញ្ញ (fire-worship) ដោយប្រជាជនទាំងនោះស្ថិតនៅក្នុងជំនឿបែបនោះនៅឡើយ។ ការបូជាយញ្ញរបស់ពួកគេ គឺយកសត្វពពែ ឬចៀម មកកាត់ក្បាលថ្វាយដល់ព្រះអគ្គី។ នៅពេលដំបូង ពេលព្រះអង្គនិមន្តទៅដល់ទីនោះ ព្រះអង្គបានសាកសួរទៅអ្នកស្រុកម្នាក់ថា: "តើស្រុកនេះ គេនាំគ្នាធ្វើអ្វី? ម្តេចបានជាអ៊ូអរម្ល៉េះ"។ អ្នកស្រុកនោះសំពះព្រះអង្គ ហើយទូលឆ្លើយតបវិញថា: "បពិត្រព្រះមហាសាមណៈ! ថ្ងៃលោកមេស្រុកកុលសម្ព័ន្ធបានរៀបចំពីធីបូជាយញ្ញ សូមព្រះអង្គទតមើល (អ្នកស្រុកនោះចង្អុលប្រាប់ព្រះអង្គកន្លែងពីធីបូជាយញ្ញ)។ **ព្រះសាស្តា** ទតឃើញហើយ ព្រះអង្គក៏និមន្តយ៉ាងលឿនទៅជួបមេស្រុក និងប្រជាជនទីនោះដោយមានព្រះដិកាឃាត់ទៅពេជឃាត (executioner)ដែលកំពុងរៀបចំពិធីបូជានោះថា: "ម្នាលបុគ្គលទាំងឡាយអើយ! មានលោកមេស្រុកជាប្រមុខ! សូម

www.elibraryofcambodia.org

បញ្ឈប់ពិធីរបៀបនេះទៅ! ពួកអ្នកមិនត្រូវយកជីវិតសត្វនេះមកសម្លាប់ ព្រោះតែ ចង់បានសេចក្ដីសុខរបស់ខ្លួននោះទេ! អ្នកដឹងទេ! រាល់រូបកាយ សត្វកើតមក ស្រឡាញ់ជីវិតដូចមនុស្សយើងដែរ!"។ ព្រះអង្គទ្រង់និមន្តឈរចំកណ្ដាលចំពោះ មនុស្សទាំងនោះ ហើយមានព្រះដិកាបន្តទៀតថា: "យើងជាមនុស្សត្រូវមានចិត្ត មេត្តា (compassion) ករុណា (grace) ខន្តី (tolerance) ដល់ពពួកសត្វដែលជា មិត្តរបស់យើង! មិនត្រូវបៀតបៀនជីវិតពួកគេទេ! បើយើងធ្វើអំពើបែបនេះ យើងនឹងទទួលនូវផលកម្ម ដូចដែលយើងធ្វើទៅលើពួកគេដូច្នេះដែរ" (Every existence is inconceivably precious, mankind have to mercy and compassion of any animal, we must do not harm as sows the seeds of sorrow and agony will doubtedly reap the same fruits) ប្រជារាស្ត្រទាំងអស់ ព្រមទាំងអ្នកចាត់ចែងពិធីនាំគ្នាឈរស្រឡាំងកាំង ខំប្រឹង ស្ដាប់នូវធម៌ដ៏បូន្មានទាំងអស់ដែលព្រះអង្គសំដែង។ បន្ទាប់មកទៀត **ព្រះសាស្ដា** ទ្រង់សំដែងធម៌ប្រោសដល់អ្នកទាំងអស់ដោយគាថា "ជីវិតមានតម្លៃមិនអាចកាត់ ថ្លៃស្មើបាន! ដូច្នេះមនុស្សយើង ចូរកុំប្រើអំពើដ៏ព្រៃផ្សៃ (cruel killing) ទៅលើ ពពួកសត្វដែលជាមិត្តរបស់យើងឡើយ ចំណែកភាពទុក្ខសោក ឈឺ ចាស់ កើត ស្លាប់ជាសភាវៈធម្មតាប្រចាំអោយសង្ខា រាល់រូបមិនអាចជៀសរួច មិនមែន បណ្ដាលមកពីអ្វីនោះទេ! (Physical existence is truly impermanent and once it is created it will ordinarily perish) ។ ចៅហ្វាយស្រុក និងប្រជាជន ស្ដាប់ហើយ ទ្រង់ភ្ញាក់ខ្លួន ហើយពេញចិត្តនឹងព្រះដិកាធម៌ដ៏ឧត្ដុងឧត្ដម ប្រកប ដោយចរិយាមេត្តាធម៌ (good moral with full compassion) របស់ព្រះអង្គ ពន់ពេកក្រៃ។ ចៅហ្វាយស្រុកតំណាងប្រជារាស្ត្រក្នុងតំបន់ បានលុតជង្គង់ក្រាប បង្គំថ្លែងអំណរគុណចំពោះ **ព្រះសាស្ដា** ដែលធ្វើអោយពួកគាត់បានភ្លឺស្វាងពីយុគ អន្ធការកាល (epoch of darkness) ដែលមានជាយូរមកហើយ វិលមករកសេចក្ដី

www.elibraryofcambodia.org

អាណិតមេត្តាដូចព្រះជិកាបានសំដែង ។ បន្ទាប់ពីដោះស្រាយជួយសង្គ្រោះសត្វបានឆ្លងផុតពីក្តីអន្តរាយរួចមក ព្រះអង្គក៏និមន្តចេញឆ្ពោះសំដៅទៅកាន់តំបន់ **និរាចត្តី** ជាបន្តទៀត ។




សៀវភៅប្រលោមលោក កម្រងជីវិតពិតនៃជនភៀសខ្លួនខ្មែរ នឹងចេញនៅពេលខាងមុខ

www.elibraryofcambodia.org

# វគ្គទី១៩

# អាឡារកាលាមគោត្រ និងឧទកៈរាមបុត្រ

## (Sage-Alakalamkutra and Sage-Udraka Ramaputra)


តាបសអាឡារកាលោម ‹ ស្រង់ចេញពីវត្តសំរោងអណ្ដែត ក្រុងភ្នំពេញ ប្រទេសកម្ពុជា›

ព្រះសាស្ដាបាននិមន្តមកដល់ **និរាវត្តី** ជាកន្លែងអាស្រមតាបសដែលមានឈ្មោះល្បី ចេះទាំងផ្លូវលោក ទាំងផ្លូវធម៌ គឺតាបស **អាឡារកាលាមគោត្រ** និង **ឧទកៈរាមបុត្រ**។ តាបសទាំងពីរនេះមិនត្រឹមតែចេះប៉ុណ្ណឹងទេ ពួកគាត់ចេះទាំងអរូបសមាបត្តិវិទ្យា (abstruct science meditation) ថែមទៀតផង។ ជាដំបូងព្រះអង្គទ្រង់ គង់ស្នាក់នៅជាមួយ **អាឡារកាលាម** តាបសសិក្សារៀនសូត្រ ព្រមទាំងព្យាយាមប្រតិបត្តិតាមតាបសជាគ្រូ មិនយូរប៉ុន្មាន ព្រះអង្គក៏ចេះអស់នូវធម៌ទាំងអស់ ព្រមទាំងធម៌សមាបត្តិទាំង ៨[២៧] និងវិធីសាស្ត្រដទៃ គឺមានតម្រិះស្មើនឹងតាបសជាគ្រូទី ១ ទ្រង់ក៏ចាកចេញនិមន្តបន្តទៅកាន់ អាស្រមតាបស **ឧទកៈរាម** ជាគ្រូទី ២ ទៀត។

---

[២៧] សមាបត្តិទាំង ៨ : ១- សម្មាទិដ្ឋិ (Correct understanding), ២-សម្មាសង្កប្ប (Correct thought), ៣-សម្មាវាចា (Correct speech), ៤-សម្មាកម្មន្តៈ (Correct profession), ៥-សម្មាអាជីវៈ (Correct way of living), ៦-សម្មាវាយាម (Correct effort), ៧-សម្មាសតិ (Correct memory), ៨-សម្មាសមាធិ (Correct mental concentration)។

www.elibraryofcambodia.org



តាបសឧទកៈរាមបុត្រ ‹ ស្រង់ចេញពីវត្តសំរោងអណ្តែត ក្រុងភ្នំពេញប្រទេសកម្ពុជា›

នៅទីនោះ ព្រះអង្គក៏ខំសិក្សាប្រតិបត្តិនូវធម៌ដែលតាបសជាគ្រូបង្ហាត់បង្ហាញ ទីបំផុតក្បួនទាំងប៉ុន្មានរបស់តាបស **ឧទកៈរាម** ក៏ទ្រង់ចេះអស់គ្មានសល់ គឺមានតម្រិះស្មើនឹងគ្រូនេះទៀតផងដែរ តែទ្រង់នៅតែរកមិនឃើញពីវិធីទៅរក ផ្លូវពោធិញ្ញាណដែលព្រះអង្គចង់បាន។ ទ្រង់បានត្រាស់សួរទៅគ្រូទាំងពីរដើម្បីស្វែងយល់ពីវិធីដែលព្រះអង្គត្រូវការ តែតាបសទាំងពីរបានទូលទៅព្រះអង្គដោយអះអាងថា: "គ្មានធម៌អ្វីដែលខ្លាំងជាង **សមាបត្តិ** ដែលព្រះអង្គទ្រង់ចេះចាំនេះទេ! នេះជាកំពូលធម៌រកអ្វីប្រៀបគ្មានឡើយ សូម្បីតែលោកីយ៍ដែលជាសភាវៈពិត ក៏ស្ថិតនៅក្នុងធម៌នេះដែរព្រះអង្គ!"។

សំដីអះអាងរបស់តាបសទាំងពីរ គួរតែធ្វើអោយ **ព្រះសាស្តា** ទ្រង់រីករាយ ប៉ុន្តែព្រះអង្គបែរ ជាមិនចាប់អារម្មណ៍បន្តិចសោះឡើយ ទ្រង់ត្រិះរិះយល់ថា វិជ្ជាទាំងឡាយដែលព្រះអង្គចេះមកនេះ គ្រាន់តែជាវិជ្ជាបង្ហាញយល់នូវ ការប្រតិបត្តិធម៌ប៉ុណ្ណោះ មិនមែនជាផ្លូវទៅកាន់បដិសញ្ញានៃពោធិញ្ញាណនោះទេ ដូច្នេះព្រះអង្គត្រូវស្វែងរកបន្តនូវសច្ចៈធម៌នោះ ដោយមធ្យោបាយរបស់ព្រះអង្គផ្ទាល់តែម្តង ទ្រង់ក៏បង្គំលាគ្រូទាំងពីរ ហើយធ្វើដំណើរទៅកាន់ **ឧរុវេល** និគម (uruvilva) ព្រោះព្រះអង្គយល់ថា នៅទីនោះប្រាកដជាទីមនោរម្យ និងផ្តល់នូវសេចក្តីព្យាយាមទាំងប៉ុន្មាន ដែលទ្រង់ចង់បាន។



ទ្រង់និមន្តចេញពីអាស្រមតាបស ឆ្ពោះទៅកាន់តំបន់ឧរុវេល

www.elibraryofcambodia.org

# វគ្គទី២០

# ព្រះសាស្តាធ្វើទុក្ករកិរិយា

## (Practice asceticism of Siddhartha)



ព្រះអង្គធ្វើទុក្ករកិរិយា
( ស្រង់ចេញពី Internet )

នៅឥណ្ឌាជំនាន់បុរាណកាល បុគ្គលដែលមាន ជំនឿខ្លាំងលើសាសនាផ្សេងៗ និងអរូបិយបញ្ញា (abstruct intellingent) ទោះជាបុព្វជិត ឬជាព្រាហ្មណ៍ក៏ដោយ តែងបានធ្វើការលះបង់កម្មសិទ្ធ ផ្សេងៗ មានទ្រព្យសម្បត្តិ និងក្រុមគ្រួសារជាដើម ចូលក្នុងព្រៃដើម្បីធ្វើទុក្ករកិរិយា គឺបង្អត់អាហារខ្លួនឯង ឬធ្វើទារុណកម្មលើខ្លួនឯង (self torture) ក្នុងប្រការផ្សេងៗ ដើម្បីចង់អោយខ្លួនបានបដិបញ្ញា ក្លាយជាឧត្តមបុគ្គល ប៉ុន្តែលទ្ធផលចុងក្រោយ បានត្រឹមតែទទួលការលំបាកវេទនារាងកាយតែប៉ុណ្ណោះ។ ក្នុងចំណោមនោះ **ព្រះសាស្តា** ក៏ជាទុក្ករបុគ្គល (ascetic person) មួយអង្គដែរ ដែលទ្រង់បានពិចារណា ត្រូវតែទទួលការរងលំបាក ទើបឈានទៅដល់ទិសដៅទេពបញ្ញា (divine intelligent) នៃពោធិញ្ញាណបាន។

នៅរដ្ឋ **ឧរុវេល** ជារដ្ឋមួយនៃប្រទេសឥណ្ឌានាសម័យបុរាណ ជារដ្ឋចុងកាត់មាត់ញកស្ថិតនៅដាច់ស្រយាល តែពោរពេញដោយទេសភាពស្រស់ត្រកាល ព្រឹក្សាខៀវស្រស់បំព្រងអមដោយស្ទឹងមួយឈ្មោះ **នេរញ្ជរា** (Atranjikhera river) ប្រកបដោយទឹកថ្លាហូរ ខ្ទបប្រាំងខ្ទបវស្សាររដូវណាក៏ដូចរដូវណា លំអរ

www.elibraryofcambodia.org

ដោយផ្ទាំងសិលាតម្រៀបគ្នាជាជួរ ហែរហមសងខាងដូចប្រាង្គទ្វារប្រាសាទចូលទៅកាន់វិមាននៃមហារាជានាស្ថានសុបិន ចំណែកបុប្ផាផ្កាព្រៃវិញ ដុះលាយចម្រុះពណ៌បណ្ដាក់គ្នា ខ្លះព័ទ្ធសិលា ខ្លះព័ទ្ធព្រឹក្សារយីងរយោង គួរអោយជាទីរម្យនា (pleasant place) ដូចជារមណីយដ្ឋានមួយដែលបង្កើតឡើងសម្រាប់ព្រះបរមពោធិសត្វ អោយព្រះអង្គគង់ប្រថាប់នៅទីនោះ។ នៅក្រោមដើមសាលព្រឹក្ស (banyan tree) ដ៏ធំមួយ **ព្រះសាស្ដា** ទ្រង់គង់ភ្នែន ដាក់ព្រះហត្ថទាំងទ្វេខ្ទប់លើព្រះបាទ ទ្រង់បិទព្រះនេត្រទាំងសងខាង ខំប្រមូលអារម្មណ៍អោយបានមូល ដើម្បីសំដែងរកផ្លូវត្រាស់ដឹង នូវព្រះអនុត្តរសាម្មាសម្ពោធិញ្ញាណ (incomparable correct enlightenment) ទ្រង់មិនរួញរា ចាប់ផ្ដើមបំពេញសេចក្ដីលំបាកក្រៃលែង ដែលមនុស្សធម្មតាមិនអាចធ្វើបានដូចព្រះអង្គឡើយ បន្ទាប់មកទ្រង់ខំសង្កត់ព្រះទន្ត (ធ្មេញ) ដោយសន្សឹម១ទាល់តែព្រះទន្តបានប៉ះគ្នា យកអណ្ដាតខ្ទប់ជាប់នឹងពិតាន (ក្រឡើត) យ៉ាងណែន ទាល់តែហូរញើសចេញតាមព្រះកច្ឆ (ក្លៀក) ទាំងសងខាង ខណៈនោះហើយដែលព្រះអង្គទទួលអារម្មណ៍ហឹងព្រះកាពិ (ត្រចៀក) ទាំងសងខាងសែនលំបាក នៅពេលដែលខ្យល់ធ្វើដំណើរមិនស្រួល វត់បញ្ច្រាស់រកផ្លូវចេញ បន្ទាប់មកទ្រង់ក៏ចាប់ឈឺពេញព្រះសិរសាសៀតចុកចាប់ ក្ដៅក្នុងព្រះកាយជាខ្លាំង វារៈកាលចុងក្រោយទ្រង់បានកាត់បន្ថយព្រះក្រយាហារ (food) ទាំងអស់ គឺសោយតែបន្តិចបន្តួចប៉ុណ្ណោះក្នុងមួយថ្ងៃ បណ្ដាលហេតុធ្វើអោយព្រះកាយស្គាំងស្គមនៅតែស្បែកដណ្ដប់ឆ្អឹង ដរាបដល់មហាជនមកឃើញមើលមិនស្គាល់ថាជាព្រះអង្គ អ្នកទាំងអស់នោះបានត្រឹមតែអនិច្ចាអាណិតដល់ព្រះអង្គប៉ុណ្ណោះ មិនមានពាក្យអ្វីស្រដីថ្លាថ្លែងសោះឡើយ។ កាលព្រះអង្គទ្រង់ពិសោធន៍ទុក្ខកិរិយាអស់រយៈវារៈ ៣ ដងកន្លងមកហើយ ទ្រង់ក៏នៅមិនសម្រេច

www.elibraryofcambodia.org

សាម្ភាសម្តោធិញ្ញាណដដែល ។ កាលនោះមានសមណៈព្រាហ្មណ៍ដទៃជាច្រើនដែល និមន្តមកពីឆ្ងាយជិតកាត់ទីនោះ បានឃើញហេតុភេទដែលព្រះអង្គធ្វើទុក្ករកិរិយា វេទនាខ្លួនបែបនោះ គ្រាន់តែពិគ្រោះគ្នានឹងពាក្យសំដីថា: "មិនគាំទ្រព្រះអង្គឡើយ បានត្រឹមតែសោយទុក្ខវេទនា ប្រៀបដូចជាដើមឈើ មែកឈើដែលត្រាំទឹកហើយ មិនអាចបង្កាត់ភ្លើងអោយឆេះបាននោះទេ គឺជាការឥតប្រយោជន៍សោះ។ គ្រា ដែលព្រះអង្គកំពុងរងកិច្ចទុក្ករកិរិយានោះ ពួកបញ្ចវគ្គិយតាបសក៏មករកព្រះអង្គ ឃើញ ហើយនាំគ្នាស្ថិតនៅបំរើព្រះអង្គ។ អស់រយៈ ៦ វស្សាកន្លងផុតទៅ កិច្ច ព្យាយាមធ្វើបធានកិរិយា (premble of behavior) របស់**ព្រះសាស្តា** ដើម្បីរក ផ្លូវត្រាស់ដឹងទាំងប៉ុន្មាន តែមិនសម្រេច បែរជារងទុក្ខ ដេកដួលស្តូកលើព្រះធរណី ទៅវិញ ពេលនោះមានមារ **គាយិកា** (devil Kauyaka) និងបក្សពួកមារមើលពី លើអាកាស ឃើញព្រះអង្គដេកដួល គិតស្មានថាព្រះអង្គសុគតហើយ ក៏ហោះទៅ ទូលព្រះបាទ **សុទ្ធោទនៈ** ជាបិតា តែព្រះអង្គមិនជឿពួកមារអបលក្ខណ៍ (in-humanity) ទាំងនោះឡើយ ។ ពួកមារអស់ប្រាជ្ញនឹងថ្លែង ក៏តែចចេញពីកន្លែង ស្តេចជាបិតា នាំគ្នាហោះត្រឡប់ទៅកន្លែង **ព្រះសាស្តា** គង់នៅម្តង ពេលទៅដល់ ក្រុមមារក៏ពោល ពាក្យចំអកផ្សេងៗដល់ព្រះអង្គ រួចក៏ហោះចេញទៅវិញបាត់ ។ វាជាការឥតប្រយោជន៍ ទោះបីសំដីមារ បែបណាក៏ដោយ ក៏ **ព្រះសាស្តា** ទ្រង់មិន ដឹងមិនឮអ្វីដែរ ព្រោះពេលនោះព្រះអង្គកំពុងសន្លប់ មិនដឹងព្រះកាយទាល់តែ សោះ។ ភាពទុក្ខលំបាករបស់ព្រះពោធិសត្វ ធ្វើអោយកក្រើកដល់ស្ថានទេវតា ស្តេចសក្កទេវរាជទ្រង់ទតពីស្ថានទេវលោកឃើញភាពបែបនោះ ព្រះអង្គក៏ស្រែះ យាងចុះ ហើយប្រែក្រឡាជនសមញ្ញមកលេងពិណ (musical instrument that is played plucking the strings, the Indian lute as mandolin) ថ្វាយ

www.elibraryofcambodia.org



ទ្រង់ពិចារណានូវសំលេងពិណ
( ស្រង់ចេញពីវត្តទឹកថ្លា
ក្រុងភ្នំពេញ ប្រទេសកម្ពុជា)

ព្រះអង្គស្តាប់ សំលេងពិណបានបញ្ជាក់ន័យដូចតទៅ: "ខ្សែដែលតឹងខ្លាំង នឹងត្រូវដាច់ បើធូរពេកពិតជាមិនពិរោះ! ដូច្នេះត្រូវរឹតអោយស្ថិតនៅកណ្តាល នោះនឹងមានសម្លេងពិរោះរណ្តំជាក់ជាមិនខាន"។ ដោយអំណាចបារមីពិណទិព្វបានដាស់អង្រួន **ព្រះសាស្តា** ដែលទ្រង់កំពុងសន្លប់ អោយបានដឹងព្រះកាយឡើងវិញ ហើយព្រះអង្គចាប់មានស្មារតីរឹងមាំ ចងចាំជាក់បទភ្លេងអត្ថន័យនៃសំលេងតន្ត្រីពិណ ព្រះអង្គប្រឹងងើបឡើងគង់សារជាថ្មី ដោយត្រិះរិះពិចារណាថា: "ឱ! នេះជាអំពើតឹងប្រាកដណាស់! ដូច្នេះអាត្មាអញគួរតែរក្សាសុខភាពឡើងវិញ និងរិះរកសារជាថ្មី"។ ក្រោយពីទ្រង់បានពិចារណាសព្វប្រការ ក៏សម្រេចព្រះទ័យ ចេញនិមន្តបិណ្ឌបាត្រឆាន់អាហារតាមប្រក្រតីឡើងវិញ លក្ខណៈសម្បត្តិក៏មាន ពេញព្រះកាយល្អដូចដើម ដោយអាការៈប្រតិបត្តិតាមគន្លងកណ្តាល ដូចដែលពិណទិព្វបានសម្តែងមក។ ចំណែកពួក **បញ្ចវគ្គីយ** តាបស កាលបើបានឃើញ **ព្រះសាស្តា** សម្រួលឥរិយាបទ និងឆាន់អាហារតាមធម្មតាវិញដូច្នេះ បែរជាមានគំនិតយល់ឃើញផ្សេងវិញថា: "**ព្រះសិទ្ធត្ថ** នេះ ខំធ្វើទុក្ករកិរិយាអស់ ៦ វស្សាមក ហើយមិនបានត្រាស់ឥឡូវបែរជាឆាន់អាហារទៅវិញ! តើពេលណាទើបព្រះអង្គ ត្រូវបានត្រាស់ដឹង គ្មានប្រយោជន៍អ្វីដែលអោយពួកយើងទ្រាំនៅបំរើព្រះអង្គបានទៀតទេ!"។ គិតដូច្នេះហើយ តាបសទាំង ៥ ក៏នាំគ្នាយកបាត្រ ត្រៃចីវរ នាំគ្នាចាក ចេញពីទីនោះ ហើយបបួលគ្នាធ្វើដំណើរទៅកាន់ព្រៃ **មិគទាយវ័ន** ហើយ ក្រោយមកហៅថា **សារនាថ** (Sarnath) ស្ថិតនៅជិតក្រុង **ពារាណសី** ក្រោយមកក្រុងនេះ ក៏

www.elibraryofcambodia.org

ប្រែឈ្មោះហៅថា **បេនរេស** (Benares) វិញ ។ **បញ្ចវគ្គីយ** តាបសមានគំនិតចាកចេញ លែងគិតទឹកនាដល់ **ព្រះសាស្តា** ទុកចោលអោយ ព្រះអង្គទ្រង់គង់នៅ **ឧរុវេលនិគម** នាស្ទឹង **នេរញ្ជរា** តែអង្គឯង ។

www.elibraryofcambodia.org

# វគ្គទី២១

# នាងសុជាតា (Sujata)

**សេនានិគម** (Senakuma) ជាស្រុកមួយស្ថិតនៅក្នុងរដ្ឋ **ឧរុវេល** ។ ក្នុងស្រុកនោះមានសេដ្ឋីម្នាក់ មានកូនស្រីមួយឈ្មោះនាង **សុជាតា** ។ **នាងសុជាតា** ជានារីពេញវ័យ មានចិត្តសុទ្ធាជ្រះថ្លា ក្នុងការធ្វើបរិច្ចាគទ្រព្យធនរបស់ខ្លួន នាងតែងមានសេចក្តីប្រាថ្នាមួយក្នុងឆាកជីវិត ដោយចង់បានគូរគាប់មានជាតិវង្សត្រកូលស្មើនឹងវង្សរបស់នាងដែរ ដូច្នេះហើយនាង **សុជាតា** តែងតែទៅបន់ស្រន់សុំក្តីប្រាថ្នានោះនៅក្រោមដើមជ្រៃមួយជិតស្ទឹង **នេរញ្ជរា** ដែរ តែមិនឆ្ងាយពីកន្លែង **ព្រះសាស្តា** ធ្វើទុក្ករកិរិយាប៉ុន្មានទេ គ្រាន់តែបាំងព្រៃ មើលគ្នាមិនឃើញប៉ុណ្ណោះ ។

ក្រោយពី **ព្រះសាស្តា** ធ្វើទុក្ខកិរិយាអស់ ៦ វស្សា ហើយមិនបានត្រាស់ក៏ទ្រង់រិះរកវិធីថ្មីៗ និងនិមន្តជាប្រក្រតី ។ ថ្ងៃមួយព្រះអង្គបាននិមន្តមកគង់នៅក្រោមដើមជ្រៃ ដែលនាង **សុជាតា** តែងមកបន់ស្រន់ គាប់ជួនពេលនោះចំរដូវចូលវស្សា **ព្រះសាស្តា** ក៏ទ្រង់គង់ចាំវស្សានៅទីនោះ តែម្តងទៅ ។

នៅសម័យថ្ងៃមួយនាង **បុណ្ណាទាសី** (Buddnasa) ជាអ្នកបម្រើផ្ទាល់របស់នាង **សុជាតា** ដើរទៅបានប្រទះឃើញ **ព្រះសាស្តា** គង់នៅក្រោមដើមជ្រៃនោះ ទ្រង់មានលោកធាតុនាចក្រវាឡបែរ ព្រះភក្ត្រទៅទិសបូព៌ា មានរស្មីឆព្វណ្ណរស្សីចែងចាំងដូចមាស ។ នាង **បុណ្ណាទាសី** កាត់យល់វាគឺជាទេវរុក្ខា (guardian angle) នៅថែរក្សាដើមជ្រៃនោះប្រាកដណាស់ នាងគិតថាការ បន់ស្រន់

www.elibraryofcambodia.org



នាងសុជាតាថ្វាយចង្ហាន់ដល់ព្រះអង្គ
(ស្រង់ចេញពី Internet)

របស់ចៅហ្វាយស្រីខ្លួនពិតជាស័ក្តសិទ្ធ ឥឡូវមានរូបទេវតាបង្ហាញខ្លួនមែន នាងទាសីត្រេកអរក៏រត់ត្រលប់ទៅផ្ទះ ប្រាប់ហេតុការណ៍ដល់ម្ចាស់ស្រីខ្លួនអោយដឹងផង។ នាង **សុជាតា** កាលបើបានដឹងតាមការប្រាប់របស់ទាសីហើយ នាងក៏ត្រេកអរជាខ្លាំង ក៏រៀបចំភោជនាហារមានមធុបាយាស (rice cooked with milk) គឺជាបាយដាំដោយទឹកដោះគោ មានក្លិនឈ្ងុយឆ្ងាញ់ ដាក់ក្នុងថាសមាសដោយមានជើងពាន ហើយគ្របក្រណាត់ស្បែសដ៏ល្អស្អាតជិតជុំ រួចនារីទាំងពីរក៏នាំគ្នាយាត្រាឆ្ពោះទៅដើមរុក្ខា ដែលពួកនាងយល់ថា គឺជាទេវតានិមិត្តបង្ហាញខ្លួន។ នៅពេលដែលនាង **សុជាតា** ទៅដល់ទីនោះ គឺចំពេល **ព្រះសាស្តា** កំពុងបិទព្រះនេត្រតាំងសមាធិ។ នាង **សុជាតា** ស្វែងយល់ជាក់ថា គឺជា **ព្រះបរមពោធិសត្វ** ទ្រង់កំពុងតាំងសមាធិធមិ ស្វែងរកផ្លូវត្រាស់ដឹងគឺជា **ព្រះពុទ្ធ** អង្គពិតៗ មិនមែនជាទេវព្រឹក្សាអ្វីឡើយ នាងក៏ក្រាបថ្វាយបង្គំ ៣ ដង រួចថ្វាយចង្ហាន់ដាក់ពីមុខព្រះអង្គដោយពន្លឺវាចាតិចៗថា: "សេចក្តីប្រាថ្នារបស់នាងខ្ញុំព្រះករុណា! បានសម្រេច ហើយនាងខ្ញុំករុណាសូមថ្វាយមធុបាយាស និងភោជនៈមាស[២៨] ដល់ព្រះអង្គ សូមទ្រង់ទទួលយកដោយក្តីសុទ្ធចិត្តពីនាង ខ្ញុំព្រះករុណាផងចុះ"។ រួចពួកនាងក៏ក្រាបថ្វាយបង្គំ ៣ ដងទៀត លាព្រះអង្គទៅវិញ។ ពេល **ព្រះសាស្តា** ទ្រង់ចប់សមាធិ ព្រះអង្គបើកព្រះនេត្រឡើង ឃើញមធុបាយាសដាក់លើថាសមាស ទ្រង់ពេញព្រះទ័យនឹងក្តីជ្រះថ្លា ដែលធីតាចិត្តបុណ្យ បានថ្វាយចង្ហាន់

---

[២៨] ថាសមាស និងទ្រដោយជើងពាន។

www.elibraryofcambodia.org

បែបនេះដល់ព្រះអង្គ ទ្រង់ក្រោកឡើងនិមន្តពីដើមជ្រៃ ហើយនិមន្តប្រទក្សិណ ៣ ជុំនៅក្រោមជ្រៃនោះ រួចព្រះអង្គកាន់យកថាសមាស ដែលមានចង្ហាន់នោះទៅកាន់មាត់ស្ទឹង **នេរញ្ជរា**។ ដល់មាត់ស្ទឹង ទ្រង់ដាក់ចង្ហាន់ថាសមាសនោះនៅលើផ្ទាំងថ្មមួយ ហើយទ្រង់និមន្តចុះស្រង់ទឹកដ៏ថ្លាយង់។ បន្តិចក្រោយមក ក៏ទ្រង់និមន្តឡើងគោកវិញ ទ្រង់គ្រងដណ្តប់ត្រៃចីវរ គង់បែរព្រះភក្ត្រទៅទិសបស្ចឹម[២៩] (west) ហើយទ្រង់ពូតបាយពំនូក៧ (ប៉ុនគ្រាប់ត្នោត) ជាច្រើនដុំ រួចព្រះអង្គឆាន់ត្រាអស់គ្មានសល់នៅសល់តែថាសមាស ព្រះអង្គក៏កាន់ថាសមាសទៅមាត់ស្ទឹងដោយអធិដ្ឋាន (to wish) ថា: "បើអាត្មាអញពិតជាបានត្រាស់ជា **ព្រះពុទ្ធ** មែន សូមអោយសុវណ្ណភាជនៈនេះ (golden tray) អណ្តែតបញ្ច្រាសទឹកឡើងទៅលើ"។ អធិដ្ឋានរួចព្រះអង្គក៏ដាក់ថាសមាសនោះទៅក្នុងស្ទឹង ថាសមាសក៏អណ្តែតបញ្ច្រាស់ទឹកមែន ទៅបានចម្ងាយប្រមាណ ៨០ ហត្ថ (ancient measure) ថាសមាសក៏លិចបាត់ទៅ ទ្រង់ទតឃើញហេតុភេទដូច្នេះ ព្រះអង្គទ្រង់មានព្រះទ័យរីករាយជាខ្លាំង ព្រោះសេចក្តីប្រាថ្នារបស់ព្រះអង្គនឹងបានសម្រេច។ ទ្រង់និមន្តត្រឡប់ទៅគង់នៅក្រោមដើមសាលព្រឹក្សមួយ ដែលស្ថិតនៅក្បែរនោះ



ទ្រង់ស្រង់ទឹក
(ស្រង់ចេញពីវត្តសំរោងអណ្តែត)



ទ្រង់ផ្សងសុវណ្ណភាជនៈ
(ស្រង់ចេញពីវត្តសំរោងអណ្តែត)

---

[២៩] ទិសធំទាំង ៤ គឺ: -បូព៌ា (East), -បស្ចឹម (West), -ឧត្តរ (North) -ទក្សិណ (South)។ ទិសតូចទាំង ៤ គឺ: -ឦសាន្ត (Northeast), -ពាយ័ព្យ (Northwest), -អគ្នេយ៍ (Southeast), -និរតី (Southwest)។ (ទំព័រ ៦៧)

www.elibraryofcambodia.org

នៅថ្ងៃនោះដែរ ស្រាប់តែមានអ្នក ច្រូតស្បូវស្មា (straw-peddler) ម្នាក់ឈ្មោះថា **សោត្ថិយៈ** (Sothiya) បានរែកស្បូវមកដល់ឃើញ **ព្រះសាស្តា** គាត់ក៏មានចិត្តជ្រះថ្លា ចូលទៅប្រគេនស្បូវមួយបាច់ធំៗ រួចក្រាបថ្វាយព្រះអង្គ គង់ **ព្រះសាស្តា** ទ្រង់ទៅគង់លើស្បូវនោះ រួចប្រទានសព្ទសារធុការដល់នាយ **សោត្ថិយៈ** ចប់សព្វប្រការនាយ **សោត្ថិយៈ** ក៏ក្រាបថ្វាយបង្គំលាព្រះអង្គបន្តដំណើរចេញទៅ។



នាយសោត្ថិយៈប្រគេនស្បូវដល់ព្រះអង្គ (ស្រង់ចេញពីវត្តសំរោងអណ្តែត ក្រុងភ្នំពេញ ប្រទេសកម្ពុជា)

www.elibraryofcambodia.org

# វគ្គទី២២
# ទ្រង់ផ្ចាញ់មារ
## (Vanquish over the armed devilforce)


ព្រះអង្គផ្ចាញ់មារ
(ស្រង់ចេញពី Internet)

**ព្រះបរមសាស្តា** មហាបុរសទ្រង់ខំព្យាយាមផ្លូវកាយ ផ្លូវចិត្តទាំងយប់ទាំងថ្ងៃ មិនគិតពីការនឿយហត់លំបាកព្រះកាយ តាំងពីព្រះអង្គក្លាយខ្លួនជាបុព្វជិតមក មានរយៈពេល ៦ វស្សា ទីបំផុតព្រះអង្គបានដល់នូវក្តីសម្រេច ប៉ុន្តែមុននឹងទ្រង់សម្រេចការត្រាស់ដឹង ពេលនោះស្រាប់តែមានរឿងមួយអស្ចារ្យកើតឡើង។ គ្រានោះមាន **រតនបល្ល័ង្ក** (throne decorated with precious stones) បាននិមិត្តផុសចេញដោយអំណាចបារមី ១០ ប្រការ សម្រាប់អោយព្រះអង្គគង់ប្រថាប់ធ្វើសមាធិកម្មដ្ឋាន រតនបល្ល័ង្កនោះមានកំពស់ ១៤ ហត្ថ (ជិត ៧ ម៉ែត្រ) យ៉ាងអស្ចារ្យ ពេលជាមួយនោះដែរ ស្រាប់តែមានស្តេចយក្ខឈ្មោះ **មារវិជ័យ** (devilVicto) បានកេណ្ឌពលសេនា យ៉ាងច្រើនសន្ធឹកងងឹតមេឃងងឹតដី មានទាំងទ័ពអាកាស (air force) ទ័ពថ្មើរជើង ទ័ពជើងទឹក (infantry with navy troops) ផង ខាងលើក៏មាន ខាងក្រោមក៏មាន ឡើងក៏ក្រេកផែនប្រថពីទាំងមូល។ ស្តេចយក្ខ **មារវិជ័យ** ជិះដំរី **គិរី មេខុល** (Kirimakala) មានកំពស់ដល់ទៅ ១៥០ យោជន៍ និមិត្តដៃចេញមករាប់រយ កាន់គ្រឿងអាវុធគ្រប់ធុន។ ចំណែករបរពលសេនាយក្ខ

www.elibraryofcambodia.org

(devil army) មានរូបរាងកាយផ្សេងៗ ខ្លះមានក្បាលជាយក្ខ ខ្លះមានក្បាលជាសត្វមានពណ៌លឿង ខៀវ ក្រហម កាន់អាវុធផ្សេងៗខុសៗគ្នា នាំគ្នាព័ទ្ធជុំវិញមណ្ឌលសមាធិស្ថាននៃ **ព្រះបរមពោធិសត្វ**។ ដោយអំណាចបុណ្យបារមីនៃ **ព្រះពោធិសត្វ** ទេវតា ទាំងហ្វូនក្នុងចក្រវាឡចាំការពារព្រះអង្គ ចំណែក **ព្រះបរមសាស្ដា** ទ្រង់គង់ ភាវនាធ្វើមិនដឹងមិនឮ នៅហ្នឹងថ្កល់ដោយមិនអើពើ មិនខ្វាយចំពោះហេតុការណ៍គគ្រឹកគគ្រេងរបស់ទ័ពយក្ខទាំងនោះឡើយ ។ ទ័ពយក្ខនាំគ្នាសម្រុកចូលតាមទិសផ្សេងៗ ប៉ុន្តែចូលមិនចុះទាល់តែសោះ ដោយមានទ័ពទេវតារារាំងយ៉ាងខ្លាំងក្លា ដោយប្រើអភិនិហារផ្សេងៗ ទ័ពយក្ខក៏រាថយ ចំពោះហេតុការណ៍នេះគ្រប់ៗគ្នា មានទិសខ្លះទ័ពយក្ខអាចចូលបាន ដោយគ្មានទ័ពទេវតាស្ថិតនៅ ប៉ុន្តែតែមិនអាចធ្វើអ្វីដល់ **ព្រះបរមសាស្ដា** បានឡើយ ។ ស្ដេចយក្ខ **មារវិជ័យ** ឈរបង់ជំទែងលើ មហាគុជសាបោះសំដីផ្ដាញ់ផ្ដាល **ព្រះសាស្ដា** ថា: "នែ៎! **សិទ្ធត្ថ** យើងនឹងអោយមហាព្យុះ **វិជ្ជវាន** (powerful hurrican) របស់យើងបោកបក់ដល់អ្នកឯង កម្ទេចក្នុងពេលនេះមិនខាន! អ្នកត្រូវដឹងសូម្បីតែកំពូលភ្នំដ៏អស្ចារ្យ ក៏មិនអាចទប់នឹងព្យុះរបស់យើងបានដែរ! ឥឡូវចាំទទួលយកទៅ!"។ ស្ដេចយក្ខក៏ប្រើវេទមន្តបណ្ដើរ បន្ថែមសំដីបណ្ដើរទៀតថា: "អ្នកត្រូវតែចុះចេញពីបល្ល័ង្កនេះភ្លាម ព្រោះបល្ល័ង្កនេះត្រូវបានមកយើងទេ!"។ **ព្រះសាស្ដា** នៅតែគង់ធ្វើព្រងើយ មិនបើកព្រះនេត្រឡើយ ព្រះអង្គតបទៅស្ដេចយក្ខដោយពុទ្ធដិការផ្អែមល្ហែមថា: "ម្នាលស្ដេចមារអើយ! អ្នកមិនបានបំពេញបារមី ៣០ ប្រការ! មហាបរិច្ចាគ ៥ ចរិយា! ឯ ៣ ប្រការនោះទៀតសោត អ្នកក៏គ្មានបន្តិចដែរ! ដូច្នេះរតនបល្ល័ង្កនេះមិនមែនសម្រាប់អ្នកឡើយ"។ ស្ដេចយក្ខឮហើយ មានចិត្តក្រេវក្រោធ (mad) យ៉ាងខ្លាំង បានលើកកងចក្រដ៏មុតស្រួចចោលតម្រង់ទៅ

www.elibraryofcambodia.org

**ព្រះសាស្តា** ឯពលយក្ខដ៏ទៃទៀត ក៏នាំគ្នាគប់អាវុធគ្រប់គ្នា ខ្លះលើកភ្នំត្រវែងទៅរកព្រះអង្គដែរ ប៉ុន្តែអាវុធទាំងនោះបានប្រែក្លាយជាផ្កាចំរុះពណ៌ ស្រោចស្រពលើព្រះអង្គទៅវិញ ស្តេចយក្ខឃើញ ដូច្នេះក៏ស្រងាកចិត្ត (deceive) ស្លុតកាយា មិនអាចធ្វើអ្វីដល់ **ព្រះសាស្តា** បាន ដោយអំណាចទានបារមីសព្វប្រការ បានបណ្តាលអោយចិត្តទាហានមារទាំងនោះទោទន់ ចុះចាញ់ឥទ្ធិពលទានបារមីរបស់ព្រះអង្គយ៉ាងស័ក្តសិទ្ធ វរហ៏ពលយក្ខទាំងអស់ ព្រមទាំងដំរីសាដឹមហាធំក្រៃ ក៏លុតជង្គង់ចុះសំដែងការគោរពកោតខ្លាចពី ចេស្តារបស់ **ព្រះសាស្តា**។ ស្តេច **មារវិជ័យ** យល់ជាក់នូវបុណ្យបារមីព្រះមហាបុរសអស្ចារ្យយ៉ាងនេះ ដោយផ្ទុំនឹងទិដ្ឋភាពនៃការបរាជ័យរបស់ខ្លួនផង ក៏សម្រេចចិត្តចុះចាញ់ដោយ លើកហត្ថទាំងវយដាក់ប្រណមលើសិរសាពោលដោយគាថាឡើងថា: "ឱ! មហាអគ្គបុរសដ៏មានបុណ្យ! ព្រះអង្គពិតជាបុគ្គលទេពដ៏ពិតមែន! ទ្រង់ពោរពេញដោយបញ្ញាញាណ និងបុណ្យបារមីអស្ចារ្យក្រៃ! វរហ៏ពលមារយើង សុំចុះចាញ់ដោយអស់ចិត្តហើយ! សូមទ្រង់ប្រោសប្រណីដល់ពួកយើងផង"។ បន្ទាប់មកពន្លឺឆព័ណ្ណរង្សីចែងចាំងចេញពីព្រះអង្គ ហើយជះទៅលើពួកពលមារ ព្រះអង្គបានសម្តែងធម៌គាថា: "ម្នាល! ពលមារទាំងអស់គ្នា! អ្វីដែលពួកអ្នកបានស្ងប់ចិត្តនៅពេលនេះ! នឹងនាំមកនូវសុខសន្តិភាពគ្រប់ទីកន្លែង! ចូរចម្រើន១! ។ ក្រុងមារ និងបរិវារនមស្សការហើយ ក៏នាំគ្នាហោះចាកចេញអស់ទៅ។ ឯទ័ពទេវតាឃើញមាររត់ខ្ចាត់ខ្ចាយចេញអស់ដូច្នេះ ក៏រីករាយព្រះទ័យគ្រប់អង្គ ព្រមទាំងស្រែកជ័យឃោសពីលើអាកាសថា: "ព្រះអង្គទ្រង់ឈ្នះពួកមារហើយ"។



ទ័ពទេវតាសម្តែងការអបអរពេលដែលព្រះអង្គ ឈ្នះមារ ( ស្រង់ចេញពី Internet )

www.elibraryofcambodia.org

មានរឿងមួយទៀតត្រង់វគ្គៈ "ព្រះអង្គផ្ចាញ់មារនេះ" បាននិទានថាៈ កាលេ ពលមារមករំខានព្រះអង្គ ពេលនោះពួកមារបានប្រើសិល្ប៍ធ្វើព្យុះ ធ្វើភ្លៀងយ៉ាង ខ្លាំងកើតចេញជាមហាសាគរ តែមិនអាចធ្វើអ្វីដល់ព្រះអង្គបានឡើយ សូម្បីតែ គ្រាប់ភ្លៀងក៏មិនបានប៉ះដល់រាងកាយព្រះអង្គដែរ ខណៈនោះស្រាប់តែផុស **ព្រះនាងគង្ហីង** (earth goddess) ចេញមកពីក្នុងទឹកនៅចំមុខរតនបល្ល័ងនៃ ព្រះមហាបុរស គ្រាន់តែ **ព្រះនាងគង្ហីង** ចេញផុត ព្យុះភ្លៀងក៏រាំង ព្រះនាងបាន បូតសក់ដ៏វែងអន្លាយរបស់ខ្លួន បង្កើតជាសត្វក្រពើធំៗ ត្រឹឆ្លាមមកខាំហែកហួរ ពួកពលយក្សស្លាប់អស់ ស្ដេចមារឃើញដូច្នេះ ក៏សុខចិត្តចុះចាញ់ ហើយលើកទ័ព ដែលសេសសល់ពីស្លាប់ត្រឡប់ទៅវិញអស់គ្មានសល់ ចប់ភារកិច្ច **ព្រះនាងគង្ហីង** ក៏លេចចុះទៅក្នុងទឹកវិញ ហើយមហាសាគរក៏រីងស្ងួតអស់ដែរ។ (រឿងនិទានទាំង នេះ ក៏បានបន្សល់ទុកដូចជា មានគំនូរតាមជញ្ជាំងព្រះវិហារ វត្តអារាមនានានៅ ទល់សព្វថ្ងៃនេះដែរ)។



www.elibraryofcambodia.org

# វគ្គទី២៣
# ថ្ងៃព្រះអង្គត្រាស់ដឹង
# (Attained day of the Enlightement)

ក្រោយពីទ័ពមារចាកចេញទៅ បរិយាកាសអាប់អួរដោយព្យុះភ្លៀងសង្គ្រាម ដែលបង្កឡើងដោយពលយក្ខ បានត្រូវប្រែក្លាយជា ផ្ទៃមេឃមានពពកស្រឡះល្អ ព្រះអាទិត្យចេញចរ ជាប្រក្រតី អ្វីៗបានល្អគ្រប់យ៉ាងឡើងវិញ។

**ព្រះសាស្តា** ខំប្រមូលអារម្មណ៍ដើម្បីលប់បំបាត់ស្នាមអប្រិយ៍ (repulsion) ទាំងឡាយ ដែលប៉ុនប៉ងរារាំងបំណងព្រះអង្គទៅរកពោធិញ្ញាណ។ ថ្វីត្បិតតែអ្វីៗ បានល្អប្រសើរមែន តែរឿងរ៉ាវលោកិយ៍តាំងពីទ្រង់ពេញវ័យ រហូតទាល់ថ្ងៃព្រះ អង្គគង់សមាធិកម្មដ្ឋាន ហើយថ្មីៗមានព្រឹត្តការណ៍ទ័ពយក្ខទៀត ធ្វើអោយព្រះ អង្គច្របូកច្របល់មួយរយៈដែរ តែទ្រង់អត់ទ្រាំខំព្យាយាមរក្សាព្រះទ័យ ដោយ ប្តេជ្ញាចាកចេញពីរឿងហេតុទាំងនោះអោយបាន។ ប៉ុន្មានថ្ងៃក្រោយមក ក្នុង អារម្មណ៍ព្រះអង្គក៏បានជ្រះស្រឡះអស់រលីងគ្មានសេសសល់ ហាក់បីដូចជាផ្ទាំង ក្រណាត់ទេសឯកពណ៌សក្បុស ស្រាយចេញពីកីលាតត្រដាង រង់ចាំទទួលការកែ ឆ្នៃ ធ្វើតាមតម្រូវការ **ព្រះបរមសាស្តា** មហាបុរសនៃយើង ទ្រង់មានហឫទ័យ ជ្រះថ្លាផូរផង់ ទ្រង់ចាំយកតែម្យ៉ាង គឺសាម្មាសម្ពោធិញ្ញាណនោះ ដែរ។

ក្នុងពេលដ៏ស្ងប់ស្ងាត់ លុះក្នុងសមាធិកម្មដ្ឋានឈានដល់ទីជម្រៅមែនទែន លុះដល់បឋមយាម ព្រះញ្ញាណព្រះអង្គស្រាប់តែកើតឡើងដោយអច្ឆរិយក្នុង អារម្មណ៍ (marvelous attracts) ហាក់បីដូចជាគ្រឿងចក្រស្វ័យប្រវត្ត (automatic) ចាប់កន្ទ្រាក់ដំណើរការដូច្នេះដែរ បដិបញ្ញាដ៏វិសេសនោះ ធ្វើអោយ

www.elibraryofcambodia.org

ព្រះអង្គទ្រង់ប្រមើមើលដឹង (ចក្ខុទិព្វ) (divine vision) ហេតុការណ៍សព្វយ៉ាងពីបុព្វសន្និវាស (សំវដ្ដកប្ប និងវិវដ្ដកប្ប) (Age of the world to fortunate time) រហូតមកទល់បច្ចុប្បន្នជាតិ ដែលព្រះអង្គកំពុងស្ថិតនៅបដិញ្ញាណ បានដឹងបន្តទៀតពីរឿងរ៉ាវសត្វលោកទាំងឡាយ វិលវល់កើតស្លាប់តាមកងចក្រនៃវាលវដ្ដសង្សា (evolution of the lifecycle turning round of birth and death) មិនចេះឈប់ឈរ ក្លាយជាកំណត់ច្បាប់សម្រាប់ធម្មជាតិក្នុងលោកទាំងមូល មិនអាចកែប្រែបាន។ ព្រះញាណទិព្វបានទតដឹងពីកម្ម និងផលនៃអតីតជាតិ និងបច្ចុប្បន្នជាតិរបស់សត្វលោកគ្រប់ៗរូប[៣០] មិនតែប៉ុណ្ណោះទិព្វញាណបានឆ្លុះបញ្ចាំងឃើញពីជីវិតសត្វលោក ដែលបានបំពេញទាន-សីល-សាងកុសល ដឹងគុណមាតាបិតា ឧបជ្ឈាយាចារ្យ ឧបាសក-ឧបាសិកា គោរពដល់អ្នកកាន់សីល ប្រព្រឹត្តតែសុច្ចរិត ជាបុគ្គល **សាម្មាទិដ្ឋិ** (យល់ត្រូវ) កាលបើស្លាប់បែកធ្លាយទៅ មានផលបុណ្យបានកើតនៅសុគតិសួគ៌ាដែលមានស្ថានលើដល់ទៅ ៩ ជាន់។ ឯបុគ្គល **មិច្ឆាទិដ្ឋិ** (យល់ខុស) អាក្រក់ថោកទាប មើលងាយប្រមាទអ្នកមានគុណ មានមាតាបិតាជាដើម ប្រមាទដល់អ្នកកាន់សីល ប្រព្រឹត្តតែអំពើទុច្ចរិត កាលបើស្លាប់ បែកធ្លាយទៅ បានទៅកើតនៅវិនិបាតនរកអវចីយ៍ ដែលមានចុះទៅក្រោមរហូត ១៨ ជាន់។

រឿងរ៉ាវលោកីយ៍មានបន្តទៀតមិនថាជាតិណា ឬជាតិណាឡើយ ភាពជរាព្យាធិ គឺជាទុក្ខលំបាកខ្លាំងបំផុត ជាបំណុលជីវិតដែលស្ពាយជាប់រហូតដល់ថ្ងៃផុត

---

[៣០] ដូច្នេះហើយទើបព្រះអង្គដឹងរឿងអតីតជាតិរបស់ព្រះសាវ័កព្រះអង្គ។

www.elibraryofcambodia.org

រលត់ ព្រះអង្គបានស្វែងយល់ឃើញនូវ **អរិយសច្ចៈ** ទាំង ៤[៣១] (supreme thruths) យ៉ាងពិស្តារ ឯផ្នែកព្រះធម៌ ព្រះអង្គបានដឹងសព្វធម៌ទាំងអស់ មាន អនុត្តរធម៌ (incomparable dharma) ជាដើម សុទ្ធតែប្រាប់ពីហេតុ និងបច្ច័យ (motive) និមួយៗបានយ៉ាងច្បាស់លាស់ ហើយធម៌ទាំងឡាយនោះបានប្រាកដ ដល់ **ខីណាសវា** ដែលដឹងច្បាស់នូវផ្លូវនិព្វាន (nirvana) ជាទីបញ្ចប់នូវហេតុ និង បច្ច័យ ។ "**ខីណាសវា**" មិនត្រឹមតែកំណត់ទីបញ្ចប់នូវហេតុ និងបច្ច័យទាំងប៉ុន្មាន នោះទេ ថែមទាំងបង្ហាញនូវការកំចាត់បង់នូវកិលេសលោកីយ៍មិនអោយមានក្នុង សន្តានចិត្តបុគ្គលឡើយ ។

នៅថ្ងៃពុធ ១៥ កើត (full moon) ខែវិសាខ (Viskha month) ឆ្នាំរកា (year of cock) ពេលទៀបភ្លឺ (befor dawn) ក្រោមដើមមហាសាលព្រឹក្សក្បែរ មាត់ស្ទឹង **នេរញ្ជរា ព្រះសិទ្ធត្ថ** នៃត្រកូល **សក្យវង្ស** ទ្រង់បានសម្រេចត្រាស់ ជា **ព្រះពុទ្ធ** ព្រះនាម **សមណគោត្តម** (Gautama) ក្នុងព្រះជន្ម ៣៥ព្រះវស្សា ព្រះអង្គជាអរិយបុគ្គល (civilized person) ត្រាស់ដឹងនូវ **បដិវេធធម៌** ( ធម៌ ដែលផ្តើមឡើងដោយបញ្ញាធិញ្ញាណ មិនរៀន សូត្រពីអ្នកណាឡើយ) ចាប់តាំងពីថ្ងៃនោះមក ពិភពលោកក៏ចាប់មានពន្លឺចែងចាំង ដោយព្រះធម៌ របស់ព្រះអង្គបានដឹកនាំចម្លងមនុស្ស សត្វលោក អោយដើរលើផ្លូវភ្លឺថ្លា ស្រឡះនៃខ្សែជីវិត ចាកផុត ពីពិភពអន្ធកាល (darkness) ។



ព្រះអង្គសំរេចបាននូវការត្រាស់ដឹង
( ស្រង់ចេញពី Internet )

---

[៣១] ១. ទុក្ខសច្ចៈ ( ស្គាល់ភាពពិតនៃសេចក្តីទុក្ខ ) (Suffering). ២.សមុទយៈសច្ចៈ ( ស្គាល់ហេតុនៃទុក្ខ ) (Origin of suffering) ៣.និរោធសច្ចៈ ( ស្គាល់ភាពពិតនៃការរលត់ទុក្ខ ) (Preventability of suffering). ៤.ស្គាល់ន័យ នៃការរលត់នៃទុក្ខ ) (Means for the elimination of suffering)

www.elibraryofcambodia.org

# វគ្គទី២៤

# ទីបរិស្ថានដែលទ្រង់និមន្ត

## (Journey of Gautama toward the different places)



នាគមុច្ចលិន្ទ ចេញមកការពារ ព្រះអង្គ ( ស្រង់ចេញពី Internet )

ក្រោយពីបានត្រាស់ដឹងជា **ព្រះពុទ្ធ** បាន ៧ ថ្ងៃនៅក្រោមដើមសាលព្រឹក្ស នាមាត់ស្ទឹង **នេរញ្ជរា** មក ព្រះអង្គក៏ទ្រង់និមន្តបន្តបន្ទាប់ ទៅគង់ទីស្ថានផ្សេងៗ ដើម្បីបន្តការសមាធិធម៌ ព្រះញាណនៅទីកន្លែងដទៃទៀត មានកន្លែងខ្លះ ព្រះអង្គ ត្រូវបរិច្ចាគធម៌ប្រោស សត្វដែលមាន ទុក្ខទោសផងដែរ ។

ព្រះអង្គនិមន្តចាកចេញពីដើមសាលព្រឹក្ស ទៅគង់នៅដើមជ្រៃមួយស្ថិតនៅទិសបូព៌ (East) កន្លែងនោះមានឈ្មោះថា **អជបាលនិគ្រោធ** ។ ដើមជ្រៃនោះមានម្លប់ធំ រយើងរយោងដោយវល្លិជ្រៃធ្លាក់ចុះ ជាកន្លែងសម្រាប់ពួកអ្នកឃ្វាលពពែតែងតែមកឈប់សម្រាក ប៉ុន្តែថ្ងៃដែល **ព្រះសាស្ដា** ទ្រង់មកគង់ទីនោះ ស្រាប់តែមិនឃើញមានអ្នកគង្វាលពោសូម្បីម្នាក់ឡើយ ។ ព្រះអង្គទ្រង់គង់នៅដើមជ្រៃ **អជបាលនិគ្រោធ** អស់រយៈ ៧ ថ្ងៃ ក៏ទ្រង់និមន្តបន្តទៅកាន់ដើមរាំងមួយធំ ស្ថិតនៅទិសអគ្នេយ៍ពីដើមសាលព្រឹក្ស ដែលព្រះអង្គត្រាស់ដឹងទីនោះ ស្ថិតនៅជិតមហាសាគរ

www.elibraryofcambodia.org



នាគមុច្ចលិន ចេញមកការពារ
ព្រះអង្គ ( ស្រង់ចេញពី Internet )

មួយ (sea) ឈ្មោះ **មុច្ចលិន**[៣២] បានគង់នៅទីនោះ ធ្វើសាមាធិអស់រយៈ ៧ ថ្ងៃដែរ ក្នុងកំឡុងពេល ៧ ថ្ងៃនោះ មានព្យុះភ្លៀងព្រិល (snow) ធ្លាក់យ៉ាងខ្លាំង ពេលព្រះអង្គកំពុងគង់សាមាធិ ពេលនោះដែរស្រាប់តែមាននាគមួយឈ្មោះ **មុច្ចលិន** ជាអ្នកថែរក្សាទឹកដីនៅទីនោះ បានផុសចេញពីសមុទ្រ ហើយវារទៅថ្វាយរង្វេល ៧ ជុំនៅក្បែរ ព្រះអង្គ ហើយបើកពពារប្រក់ពីលើបាំងការពារព្រះអង្គ កុំអោយត្រូវព្យុះភ្លៀងប៉ះពាល់ដល់រាងកាយ រហូតទាល់តែភ្លៀងរាំងស្ងប់ដូចប្រក្រតី ទើបនាគនោះប្រែក្រឡាជាមាណពម្នាក់យ៉ាងស្អាត ចូលទៅក្រាបថ្វាយបង្គំ **ព្រះបរមសាស្តា** ដោយសុំប្រាថ្នាអោយមានសេចក្តីសុខដល់ទីស្ថានដែលខ្លួនរស់នៅ **ព្រះសាស្តា** ទ្រង់បើកព្រះនេត្រ ចៅមាណពប្រែកាយដោយព្រះទ័យសោមនស្ស សរសើរពីទឹកចិត្តរបស់នាគជាសត្វតិរច្ឆានសោះ តែមានចិត្តជាបុណ្យបានចេញមកជួយការពារទ្រង់អោយផុតពីគ្រោះព្យុះភ្លៀងទាំងឡាយ ។

ព្រះអង្គទ្រង់សម្តែងធម៌ដោយគាថាថា: "អ្នកមានធម៌ដោយប្រាកដជាគុណអោយកើតសេចក្តីសុខ! សេចក្តីមិនព្យាបាទ និងបៀតបៀនសត្វទាំងឡាយ ជាគុណដ៏ប្រសើរក្នុងលោក! អ្នកមានសន្តានចិត្តល្អប្រពៃ គង់ជួបផលបុណ្យនិស្ស័យមិនខាន! ចូរអ្នកសម្រេចនូវអំពើល្អ!"។ ចៅនាគមាណពក្រោយពីស្តាប់ព្រះធម៌ដែលព្រះសម្តែងដល់ខ្លួន មានចិត្តត្រេកអរណាស់ រួចក្រាបថ្វាយបង្គំលាព្រះទ្រង់ញាណត្រឡប់ទៅកាន់មហាសាគររបស់ខ្លួនវិញទៅ ។

---

[៣២] ដោយហេតុនាគមុចលិនរស់នៅតំបន់សាគរនោះ ទើបកន្លែងនោះគឺសំដៅទៅលើឈ្មោះនាគនោះតែម្តងទៅ ។

www.elibraryofcambodia.org

# វគ្គទី២៥

# ធីតាមាររំខាន

## (Distraction of Princess Phantoms to Gautama)

ក្រោយពីបានគង់សាមាធិកម្មដ្ឋាននៅតំបន់ **មុច្ចលិន** អស់ ៧ ថ្ងៃក្រោយមក ព្រះអង្គក៏ទ្រង់និមន្តត្រឡប់ទៅគង់នៅក្រោមដើម ជ្រៃនៅ **អជបាលនិគ្រោធ** វិញ។ កាលបើទ្រង់គង់នៅទីនោះវិញហើយ ព្រះអង្គមានការពិចារណានូវធម៌ទាំងឡាយ ដែលព្រះអង្គបានត្រាស់ដឹងទាំងប៉ុន្មាន ដើម្បីប្រារព្ធវិភាគឡើងវិញ ដោយប្រការដ៏ច្រើនមានជាអាទិ៍គឺ **សាមានាន** ចំពោះបុគ្គលទាំងឡាយដែលព្រះអង្គគប្បីត្រូវទូន្មានបាន និងបុគ្គលដែលទូន្មានមិនបាន។ ប្រភេទលក្ខណៈដែលគប្បីត្រូវទូន្មានបាននោះ គឺបុគ្គលដែលមានលក្ខណៈសម្បត្តិស្លូតបូត សុចរិតទៀងត្រង់ ស្គាល់គុណស្គាល់ទោស មានកតញ្ញូតាធម៌ (gratitude) និងអកតញ្ញូតាធម៌ (ingratitude) ដែលចែងក្នុងបាលីមាន ៣ យ៉ាង **១-ឧគ្ឃដិតញ្ញូបុគ្គល** **២-វិបចិតញ្ញូបុគ្គល** **៣-នេយ្យបុគ្គល** នៅខណៈដែលព្រះអង្គកំពុងត្រិះរិះពីការតាក់តែងនូវធម៌ទាំង ៣ នេះ ស្រាប់តែមានទេវមារដែលជាអ្នកនាំមកនូវភាពកង្វល់ បានចូលមកក្រាបបង្គំទូលសុំព្រះអង្គអោយធ្វើបរិនិព្វាន ព្រោះជាការកង្វល់ក្នុងចិត្តមារដោយខ្លួនឯង។ **ព្រះបរមសាស្ដា** ទ្រង់មានពុទ្ធដិកាតបទៅកាន់មារនោះវិញថា: "ម្នាលមារអើយ! បំណង



ទេវមារសុំអោយព្រះអង្គបរិនិព្វាន ‹ ស្រង់ចេញពីវត្តសំរោងអណ្ដែត ›

www.elibraryofcambodia.org

ប្រាថ្នារបស់អ្នក តថាគតយល់ច្បាស់ណាស់! ប៉ុន្តែតថាគតមិនទាន់មានភិក្ខុជាសាវ័កនៅឡើយ! បើសិនជាសាវ័កតថាគតមានហើយមែន តែមិនបានប្រព្រឹត្តគ្រប់គន្លងព្រហ្មចរិយា ធម៌ដោយបរិបូរណ៍នោះទេ **តថាគត** ក៏មិនទាន់បរិនិព្វានបានដែរ" ។ ទេវមារដែលមានចិត្តប្រាថ្នាចង់អោយ **ព្រះសាស្តា** ធ្វើបរិនិព្វាននោះពេលបានសណ្តាប់ហើយ ក៏មានការខកចិត្តយ៉ាងខ្លាំង មារកើតការគិតក្នុងចិត្តថាត្រូវតែចាកចេញដោយក្តីអាម៉ាស់មួយរយៈសិន ចាំគិតរកវិធីថ្មីទៀតនៅពេលក្រោយ គិតហើយក៏ហោះចាកចេញបាត់មួយរំពេច ។ បន្ទាប់មកទៀត ក៏មានធីតាមារ ៣ អង្គទៀតគឺ នាង **តណ្ហា** (Tanaha) នាង **អរតី** (Atita) និងនាង **រាគា** (Riekie) ដែលហោះចុះពីស្ថានអរូបភព (non-world) បានប្រើល្បិចប្រែកាឡាខ្លួនជាច្រើនរូបភាព រូបចុងក្រោយបង្អស់របស់ពួកនាង គឺជាកញ្ញាយ៉ាងល្អឆើតបញ្ចេញភាពត្រេកត្រអាល លួងលោមទន់ភ្លន់មកច្រៀងរាំ សុំសេចក្តីស្នេហាពីព្រះអង្គ និងចង់អោយព្រះអង្គនឹកឃើញរឿងដើមកាលនៅក្នុងរាជវាំង ចង់អោយព្រះអង្គវិលវល់ ភ្លេចអារម្មណ៍ពីការសាម្មាធិ ប៉ុន្តែជាការឥតប្រយោជន៍ ព្រះអង្គមិនត្រឹមតែមិនភ្លេចការសម្មាធិរបស់ព្រះអង្គប៉ុណ្ណោះទេ ថែមទាំងធ្វើអោយទ្រង់រឹតតែខំប្តេជ្ញាព្រះទ័យ លប់បំបាត់ចោលភាពរំខានទាំងនោះបានយ៉ាងជ្រះស្រឡះទៀតផង ។ ធីតាមារទាំង ៣ ប្រាណ ប្រើអស់ល្បិចហើយ នៅតែមិនអាចបំបែកការសម្មាធិរបស់ព្រះអង្គបាន ក៏អស់តម្រិះសម្រេចចិត្តប្រែកាយដូចដើម ហើយនាំគ្នាហោះចាកចេញវេវិញ ទាំងក្តីអាម៉ាស់ ។


ធីតាមាររំខានព្រះអង្គ
(ស្រង់ចេញពី Internet)

www.elibraryofcambodia.org

# វគ្គទី២៦
# ព្រាហ្មណ៍ចិត្តបាប
# (Malevolent Brahmana)


ព្រាហ្មណ៍ចិត្តសួរចង់ដឹងតិរះព្រះអង្គ
( ស្រង់ចេញពីសៀវភៅ
Sakymuni Buddha )

**ព្រះសាស្តា** ទ្រង់បន្តការពិចារណាព្រះធម៌ជាបន្តទៀត តាមសម្រួលអស់រយៈពេល ៧ ថ្ងៃ គង់ស៊ប់ក្នុងសម្មាធិកម្មដ្ឋាន ទ្រង់គង់ប្រថាប់ធ្វើអភិធម្មបិដក (Abhidhamma Pitaka) ជាន័យសារវ័ន្ត (essential meaning) នៅគ្រានោះ ស្រាប់តែមានព្រាហ្មណ៍ម្នាក់ឈ្មោះ **កជាតិកៈ** (Kachaka) ដែលមានចិត្តបាបក្នុងខ្លួនបានចូលមក គ្រាន់តែសម្តែងការគួរសមបន្តិចក៏សួរ ក្នុងបំណងចង់ដឹងតម្រិះ ព្រះអង្គដែលត្រាស់ដឹងនោះ ចេះដល់កំរិតណាដោយមានសំនួរថា: "**ព្រះគោត្តម** តើធម៌អ្វីទៅដែលអាចបានក្លាយជាព្រាហ្មណ៍ពិតប្រាកដ? និងអ្វីទៅដែលហៅថា អរិយបុគ្គលនោះ?"។

**ព្រះបរមសាស្តា** ទ្រង់សណ្តាប់ហើយ ព្រះអង្គមិនមានព្រះទ័យអាក់អន់ស្រពន់ព្រះទ័យព្រោះតែសំដីដែលព្រាហ្មណ៍ពោលឡើង មិនមានពាក្យហៅព្រះអង្គថា **ព្រះពុទ្ធ** ឬ **ព្រះភគវា** បែរជាហៅចំឈ្មោះព្រះអង្គទៅវិញ ម្យ៉ាងសំដីព្រាហ្មណ៍ជាន័យមូសា។ ព្រះអង្គទ្រង់តបដោយត្រង់ៗ ក្នុងន័យគុណធម៌ទៅវិញថា: "ម្នាលព្រាហ្មណ៍អើយ! ការលះបង់ចោលនូវចិត្តបាបទាំងឡាយ! ការខំរក្សាចិត្តប្រកបដោយគុណធម៌ មិនមានអំណួតអួតអាង តាំងចិត្តដោយជ្រះថ្លា ស្វែងរក

www.elibraryofcambodia.org

ផ្លូវសិក្សា រក្សាភាពសុច្ចរិត នោះហើយជាព្រាហ្មណ៍ពិត និងជាអរិយបុគ្គល ដែលមានកិត្តិយសថ្លៃថ្នូរ មិនដូចជាបុគ្គលធម្មតាអាចធ្វើបាននោះឡើយ!"។ ព្រាហ្មណ៍ **ភរទ្វាជគោត្រ** ស្តាប់ហើយសែនខ្មាស់ខ្លួនក្រៃ គិតថា **ព្រះសាស្តា** ទ្រង់ដឹងពីបំណងរបស់ខ្លួន ដែលមកចង់ផ្ចាញ់ដល់ព្រះអង្គ គិតហើយព្រាហ្មណ៍ក៏គេចចេញពីព្រះភក្ត្រព្រះអង្គវិញយ៉ាងរហ័សពីទីនោះភ្លាមទៅ។

www.elibraryofcambodia.org

# វគ្គទី២៧
# ទ្រង់តាក់តែងព្រះត្រៃបិតក
# (Compose Tripitaka)



ព្រះអង្គនៅព្រៃអនិមិស្សកិ ( ស្រង់ចេញពី Internet )

កាលសម័យព្រះអង្គគង់នៅ **អនិមិស្សក** ស្ថិតនៅទិសឥសាន្តពីដើមសាលព្រឹក្ស ពេលដែលព្រះអង្គស្វាងពីការភាវនាធមិហើយ ព្រះអង្គនឹកឃើញអនុស្សាវរីយ៍ទីដើមសាល ព្រឹក្ស និងរតនបល្ល័ងពេជ្រដែលបានផ្តល់បុព្វនិស្ស័យសម្មាសម្ពោធិញ្ញាណ ជាជីវិតដ៏អស្ចារ្យសម្រាប់ព្រះអង្គ ដែលបានត្រាស់ដឹងជា **ព្រះពុទ្ធ** ទ្រង់គង់សម្លឹងពីព្រៃ **អនិមិស្សក** ទៅកាន់ដើមសាលព្រឹក្ស ដែលឃើញនៅឆ្ងាយសន្លឹមពីទីនោះ មានរយៈពេល ៧ ថ្ងៃ ដូច្នេះទើបព្រះអង្គនិមន្តទៅគង់នៅ **រតនចេតិយ** ស្ថិតនៅព្រៃនាទិសពាយព្យ ពីដើមសាលព្រឹក្ស ព្រះអង្គគង់នៅទីនោះ រួចក៏ចងក្រងព្រះ **អភិធម្មបិតក** ដោយត្រិះរិះពីច្បាប់ធមិនៃព្រះពុទ្ធសាសនា ក្នុងរយៈពេលនោះក៏មានព្រះភិក្ខុជាច្រើនមកចូលរួម ព្រមទាំងតាំទ្រព្រះអភិធម្មដែលព្រះអង្គបានសំដែង និងតាក់តែងជា **៨ សមាបត្តិ** ព្រមទាំងត្រិះរិះពិចារណានូវព្រះបិតកទាំង ៣ ប្រការ ដោយនិកាយអង្គ ៩ យ៉ាងនៃ **ធម្មក្ខន្ធ** ទាំង ៨៤០០០។ ទ្រង់ពិចារណាសាចុះសាឡើងនូវ **ព្រះវិន័យបិតក សុត្តន្តបិតក** និង **អភិធម្មបិតក** ដោយព្រះពោធិញ្ញាណ។ ក្នុង

www.elibraryofcambodia.org

កំឡុងពេលដែលទ្រង់ពិចារណាទូវធម្មគុណទាំងនោះ ព្រះអង្គក៏បានផ្លាស់ប្តូរកន្លែងមួយទៅកាន់កន្លែងមួយ លុះត្រាបានចប់សព្វគ្រប់ពី **ព្រះបិតក** ទាំង ៣ នៅក្រោមដើមកែស (Pipala tree) មួយ សរុបថ្ងៃនៃទីកន្លែងទាំងនោះមានរយៈពេល ៤៩ ថ្ងៃគត់។

ក្នុងរយៈពេល ៤៩ ថ្ងៃ ដែលព្រះអង្គខំពាក់តែង **ព្រះបិតក** ទាំង ៣ ទាំងយប់ទាំងថ្ងៃត្រាបានសម្រេច ដោយមិនគិតពីព្រះរាជសុខភាព និងការនឿយហត់សូម្បីបន្តិចសោះឡើយ សេចក្តីព្យាយាមរបស់ព្រះអង្គធ្វើអោយទស្សនបណ្ឌិតសម័យថ្មី មានក្តីកោតព្រះអង្គក្រៃលែង។ នៅកំឡុងពេលនោះដែរ ព្រះអង្គមិនត្រឹមតែសម្រេច **ព្រះបិតក** ទាំង ៣ នោះទេ ថែមទាំងស្រាវជ្រាវរាវរកនូវវិជ្ជាលោកិយ៍ដទៃទៀត គឺ **ចរិយាធម៌** និង **គុណធម៌** ដែលជាសច្ចៈភាពនៃជីវិតវិវត្តន៍នាភពផែនដីនេះ ដូចដែលធម្មបាលីបានពោលថាៈ "ព្រះអង្គជា **តក្កវិទូ** (Holy logician) **អនុត្តរោ** (incomparable) ដែលរកឃើញ **តក្កវិជ្ជា**(logic) និង **អរិយសច្ចៈ** (Supreme thuths) ប្រាកដដោយអង្គឯង មិនមានគ្រូអាចារ្យណាមកបង្ហាត់បង្ហាញដល់ព្រះអង្គឡើយ"។ នៅសម័យថ្ងៃដែលទ្រង់គង់នៅក្រោមដើមកែសនោះ ស្រាប់តែមានឈ្មួញពីរនាក់បងប្អូន បានធ្វើដំណើរត្រាច់ចរ ជួញដូរនូវគ្រឿងទេសរបស់ខ្លួន បានមកដល់ក្រោមដើមកែសដែល **ព្រះបរមសាស្តា** ទ្រង់កំពុងសមាធិ។ ឈ្មួញពីរនាក់បងប្អូនដែលមានឈ្មោះ **តបុស្សៈ** (Phabusha) និង **ភល្លិកា** (Phalyka) ឃើញព្រះអង្គទ្រង់គង់តែអង្គឯង គ្មានញាតិមិត្តយ៉ាងដូច្នេះ ក៏កើតមានចិត្តជ្រះថ្លា ក៏នាំគ្នាយកស្បៀងអាហារពិសេសដែលដាក់ជាប់ដំណើរខ្លួនចេញមកយកទៅប្រគេនដល់ព្រះអង្គ។ **តបុស្សៈ** និង **ភល្លិកា** ក្រាបថ្វាយបង្គំព្រះអង្គរួចដាក់អាហារដែលពួកគាត់រៀបចំយ៉ាងសមរម្យ

www.elibraryofcambodia.org



តបុស្សៈ និងភល្លិកាប្រគេនចង្ហាន់ដល់ព្រះអង្គ
(ស្រង់ចេញពីវត្តសំរោងអណ្តែត)

ប្រគេនព្រះអង្គដោយពោលថាៈ "បពិត្រព្រះអង្គដ៏ចម្រើន! សូមទ្រង់ទទួលនូវភោជនាហារទាំងនេះអំពីពួកខ្ញុំព្រះករុណា ទាំងពីរនាក់បងប្អូន! ដើម្បីទ្រទ្រង់ព្រះសុខភាពព្រះអង្គអោយបានល្អប្រសើរ និងជាប្រយោជន៍ដល់សត្វលោកផងដែរ!"។**ព្រះបរមសាស្តា** ទ្រង់ទទួលអាហារ ហើយសម្តែងពុទ្ធដិកាថាៈ "ចូរចម្រើន១! ការមានសទ្ធាជ្រះថ្លាបែបនេះ គឺជាកុសលផលបុណ្យយ៉ាងល្អបំផុត! ប្រៀបដូចជាទឹកថ្លាយង់ គ្មានល្អកកករធូលីឡើយ! អ្នកនឹងជួបសេចក្តីល្អមិនខាន!"។ ព្រះអង្គទ្រង់មានពុទ្ធដិកាជាច្រើនទៀតធ្វើអោយនាយទាំងពីរនាក់បងប្អូនមានចិត្តចង់ប្រតិបត្តិតាមព្រះឱវាទព្រះអង្គ នៅខណៈនោះហើយដែលអ្នកទាំងពីរបានស្រុះស្រួលគំនិតគ្នា សុំក្លាយខ្លួនជាសាវ័កក្នុងវិស័យពុទ្ធសាសនាព្រះអង្គ ដូចនេះហើយ **តបុស្សៈ** និង **ភល្លិកា** ក៏ក្លាយជាសាវ័កព្រះអង្គចាប់ពីពេលនោះមក រួចហើយពីរនាក់បងប្អូនក៏ក្រាបថ្វាយ បង្គំលាព្រះអង្គទៅស្រុករបស់ពួកគាត់វិញ ដើម្បីប្រតិបត្តិតាមគន្លងព្រះធម៌របស់ព្រះអង្គ។

www.elibraryofcambodia.org

# វគ្គទី២៨

# ប្រោសសហម្បតីព្រហ្ម

# (Majestic to Brahma Sahamapata)



ព្រះអង្គប្រោសសហម្បតិព្រហ្ម
( ស្រង់ចេញពី វគ្គសំរោងអណ្តែត )

ព្រឹត្តការណ៍ដែល **ព្រះបរមសាស្តា** បានតាក់តែង **ព្រះត្រៃបិតក** បានចប់សព្វប្រការហើយ បានធ្វើអោយមានភាពរន្ធឹសុះសាយ គ្រប់ទីស្ថានមនុស្ស និងទេវត្តា ចំណែក **សហម្បតីព្រហ្ម** ដែលគង់នៅស្ថាន **ព្រហ្ម** បានដឹងថា **ព្រះសិទ្ធត្ថ** ទ្រង់បានត្រាស់ជា **ព្រះពុទ្ធ** ហើយបែរជាគង់នៅស្ងៀមស្ងាត់ មិនចេញប្រោសសត្វលោក ពួក **ព្រហ្ម** ក៏បានជំនុំគ្នាដើម្បីសុំយោបល់ពី **សហម្បតីព្រហ្ម** ជាមេ។ **សហម្បតីព្រហ្ម** មិនអស់ចិត្ត ក៏នាំពួក **ព្រហ្ម** គ្រប់អង្គហោះចុះមកស្ថានកណ្តាល ហើយទៅកាន់កន្លែង **ព្រះសាស្តា** គង់សម្មាធិ ។ ដល់កន្លែង **ព្រះពុទ្ធ** គង់សម្មាធិហើយ ពួក **ព្រហ្ម** ក៏នាំគ្នាថ្វាយបង្គំ **ព្រះពោធិសត្វ** ។ **ព្រះពុទ្ធ** ជាម្ចាស់ទ្រង់បានដឹងពីបំណងពួក **ព្រហ្ម** មកថ្វាយបង្គំព្រះអង្គរួចជាស្រេចហើយ ទើបពេលដែលពួក **ព្រហ្ម** មកដល់ ទ្រង់ក៏មានពុទ្ធដិកាថា: "ម្នាល! **សហម្បតីព្រហ្ម! តថាគត** យល់ពីបំណងនៃ **ព្រហ្ម** គ្រប់អង្គហើយ! ប៉ុន្តែពេលវេលាមិនទាន់ដល់នៅឡើយ! ព្រោះពពួកសត្វទាំងឡាយនោះ ស្ថិតនៅដោយក្តីត្រេកអរនៃតណ្ហាជាខ្លាំង! **បដិបទា** ជាធម៌នៃសេចក្តីស្ងប់ មិនអាចបញ្ជាក់អោយពួកគេដឹងច្បាស់នូវទីបំផុតនៃទុក្ខ គឺព្រះនិព្វាននោះបានទេ! ការប្រព្រឹត្តនូវធម៌ស្ងប់រំលត់ទុក្ខ ទាល់តែកិរិយារំងាប់

www.elibraryofcambodia.org

អោយបានទាំងស្រុង នូវកិលេសចោលចេញ ហើយស្វែងយល់អោយច្បាស់តែមួយ គត់នូវន័យព្រះនិព្វាន ទោះបីពេលនេះ **តថាគត** ខំសំដែងនូវធម៌ទាំងប៉ុន្មានយ៉ាង ណាក៏ដោយ! ក៏សត្វលោកទាំងឡាយនោះគេនៅតែមិនជឿដែរ មានតែនាំសេចក្តី ព្រួយមានដល់ **តថាគត** ប៉ុណ្ណោះ! តែពេលវេលា និងបង្ហាញលទ្ធផលល្អឧត្តម នៅពេលក្រោយជាក់ជាមិនខាន!"។

**សហម្បតីព្រហ្ម** សណ្តាប់ហើយ ទ្រង់ពេញព្រះទ័យអស់ក្តីសង្ស័យអ្វីទៀត ឡើយ **ព្រះបរមសាស្តា** ទ្រង់ប្រមើមើលដោយទិព្វញ្ញាណដឹងថា ត្រូវសំដែងធម៌ ប្រោសដល់ពពួកទេវតាទាំងនេះជាមុនសិន ដូច្នេះហើយព្រះអង្គក៏សម្តែងធម៌ ប្រោសដល់ពួក **ព្រហ្ម** នៅពេលនោះ។ អត្ថន័យទាំងឡាយនៃព្រះធម៌របស់ព្រះ អង្គ បានចូលជ្រួតជ្រាបក្នុងដួងចិត្តដួងវិញ្ញាណ **ទេវព្រហ្ម** គ្រប់ៗអង្គ ធ្វើអោយ រាល់អង្គស្ងប់ចិត្ត ស្ងប់ព្រះកាយដោយហឫទ័យរីករាយគ្រប់ៗអង្គ។ **សហម្បតី ព្រហ្ម** និង **ព្រហ្ម** បរិវារបានស្តាប់ពុទ្ធដិកាធម៌ ដោយឱកាសដ៏ល្អប្រសើរគ្រប់ ប្រការ កងបរិវារ **ព្រហ្ម** ក៏ក្រាបថ្វាយបង្គំលា **ព្រះបរមសាស្តា** ត្រឡប់ទៅកាន់ ស្ថាន **ព្រហ្ម** វិញអស់ទៅ។ ចំណែក **ព្រះសាស្តា** ពេលដែលព្រះអង្គបានបញ្ចប់ ធម៌ប្រោសដល់ពួកទេវព្រហ្មរួចមក ក៏ស្រាប់តែព្រះអង្គទ្រង់នឹករលឹកដល់ **អាឡារកាលាមតាបស** និង **ឧទករាមបុត្រតាបស** ដែលព្រះអង្គធ្លាប់បាន គង់ស្នាក់អាស្រ័យនៅសិក្សាជាមួយលោកទាំងពីរ ព្រះអង្គបានឆ្វេងយល់ថា លោក តាបសទាំងពីរនេះ ឧបនិស្ស័យត្រូវទទួលយកព្រះធម៌ដំបូងពីព្រះអង្គ ព្រោះលោក ទាំងពីរជាបុគ្គលគ្មានកិលេសលោកីយ៍ អាចឆាប់ទទួលយកបាននូវមគ្គផលជា ប្រាកដ ប៉ុន្តែក្រោយមក **ព្រះបរមសាស្តា** ទ្រង់ជ្រាបដំណឹងថា តាបសទាំងពីរ ទទួលមរណៈកាលអស់ទៅហើយ ទ្រង់មានព្រះទ័យអាឡោះអាល័យលោកទាំង

www.elibraryofcambodia.org

ពីរនោះក្រៃលែង តែទ្រង់ខំកាត់ព្រះទ័យ ពីក្តីស្រណោះទាំងអស់នោះដែរ ដោយយល់ថា នេះជាច្បាប់ធម្មជាតិដែលជៀសមិនរួច។ បន្ទាប់មកព្រះអង្គក៏នឹកបន្តដល់ពួក **បញ្ចវគ្គីយ** ទាំង ៥ អ្នកដែលធ្លាប់បាននៅបំរើព្រះអង្គថា ជាអ្នកមាននិស្ស័យត្រូវប្រោសមុនគេដែរ ក៏សម្រេចព្រះទ័យនិមន្តចេញពីរដ្ឋ **ឧរុវេល** ទៅកាន់កន្លែងពួកគាត់រស់នៅគឺ **មិគទាយវ័ន** ជិតនគរនៃក្រុង **ពារាណសី**។



www.elibraryofcambodia.org

# វគ្គទី២៩
# ប្រោសបញ្ចវគ្គីយ
# (Majestic to five Sramanas)



ព្រះអង្គប្រោសបញ្ចវគ្គីយទាំង៥
(ស្រង់ចេញពីវត្តសំរោងអណ្តែត)

កាលវេលាក្រោយបន្ទាប់មក **ព្រះបរមសាស្ដា** ក៏ទ្រង់និមន្ដទៅដល់ទីកន្លែងដែល **បញ្ចវគ្គីយ** គាបសរស់នៅដូចក្ដីបំណង។ ចំណែក **បញ្ចវគ្គីយ** ទាំង ៥ កាលបើបានឃើញ **ព្រះសាស្ដា** កំពុងនិមន្ដមកពីចម្ងាយដូច្នេះ ក៏នាំគ្នាជំនុំគិតគ្រោងក្នុងចិត្តថា: "នែ៎គ្នាយើងចូរមើលន៎! **ព្រះសមណះគោត្តម** កំពុងនិមន្តតម្រង់មករកពួកយើងហើយ! យើងកុំនិយាយអ្វីជាមួយព្រះអង្គអោយសោះ កុំធ្វើបដិកិច្ចគោរពថ្វាយបង្គំអី! ហើយក៏កុំទទួលបាត្រចីវរពីព្រះអង្គដែរ!"។ មួយអង្គទៀតបន្ថែមពាក្យថា: "ឬពួកយើងគ្រាន់តែក្រាលអសនៈទុកចោលទីនេះបានហើយ! កុំរវល់អីជាមួយព្រះអង្គទុកអោយទ្រង់គង់តែអង្គឯងចុះ! បើអញ្ជើងអោយព្រះអង្គឃេរក៏បានដែរ កុំនាំគ្នាខ្វល់អោយសោះ"។ ជំនុំគ្នាហើយ **បញ្ចវគ្គីយ** សម្រេចថាមិនរវល់នឹងព្រះអង្គទេ តែខណៈដែល **ព្រះបរមសាស្ដា** និមន្ដទៅជិតអ្នកទាំង ៥ ស្រាប់តែភ្លេចនូវគម្រោងចិត្តដែលគ្រោងទុកពីមុន ព្រោះឃើញព្រះអង្គនៅពេលនោះមិនមែនដូចមនុស្សធម្មតា ព្រះភក្ត្រពោរពេញដោយរស្មីចែងចាំងប្រកដដោយពោធិញ្ញាណ និងបារមីអស្ចារ្យក្រៃ ជាបុគ្គទេពដែល **បញ្ចវគ្គីយ** ពួកគាត់មិនដែលឃើញពីមុន

www.elibraryofcambodia.org

មកទាល់តែសោះ។ ដោយអំណាចបារមីដូច្នេះហើយ ទើបបណ្ដាលចិត្តអ្នកទាំង ៥ ត្រឡប់ជាមានចិត្តត្រេកអរទទួលរាក់ទាក់ ភ្លេចអស់គំនិតព្រោងទុកពីមុននោះ ភ្លាមនោះដែរ **បញ្ចវគ្គីយ** ក៏នាំគ្នាស្ទុះស្ទាទៅថ្វាយបង្គំ ខ្លះទទួលបាត្រ ចីវរ ខ្លះ រៀបចំក្រាលអសនៈដោយគោរពជាទីបំផុត។

ក្រោយពី **ព្រះសាស្ដា** និមន្តគង់លើអសនៈដែលពួក **បញ្ចវគ្គីយ** បាន រៀបចំថ្វាយរួចស្រួលបួលហើយ ព្រះអង្គក៏ទ្រង់មានពុទ្ធដីកាឡើងថាៈ "ម្នាល សមណៈទាំងឡាយ! **តថាគត** បានសម្រេចការត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ហើយ ដោយយល់ច្បាស់ពី **សច្ចៈ** នៃ **ព្រះនិព្វាន** ដែលមិនមានកើតស្លាប់ក្នុងវដ្ដ សង្សារយើងនេះទៀតទេ រីឯ **ព្រះអមតៈធម៌** វិញ **តថាគត** នឹងសម្ដែងអោយ អ្នកទាំងឡាយបានដឹងបានយល់ និងប្រតិបត្តិអោយបានត្រាស់ដឹងនាបច្ចុប្បន្នជាតិ នេះតែម្ដង! ឥឡូវនេះ ជាបឋម **តថាគត** ត្រូវសម្ដែងព្រះ **ធម៌អមតៈ** នេះដល់ ពួកអ្នកទាំងអស់គ្នានៅទីនេះសិន! ចូរគ្រប់គ្នាផ្ដោតអារម្មណ៍ ចាំស្ដាប់នូវព្រះធម៌ ទាំងនេះដូចតទៅ!"។ រួចហើយ **ព្រះពុទ្ធ** ជាម្ចាស់ក៏ទ្រង់សំដែងធម៌ជាបន្តបន្ទាប់ ធ្វើអោយ **បញ្ចវគ្គីយ** តាបសទាំង ៥ មានការភ្ញាក់ផ្អើល និងចាប់អារម្មណ៍ជា ខ្លាំង។ ពេលដំបូងក្នុងចិត្តតាបសទាំង ៥ ហាក់មិនអស់ចិត្ត ព្រោះពួកគាត់គិតយល់ ថាៈ "ការព្យាយាមប្ដូរផ្ដាច់របស់ព្រះអង្គ ក្នុងការស្វែងរកភាពពិតនៃ **សម្ពោធិ ញ្ញាណ** ដូចជាការលះបង់ព្រះទ័យ ធ្វើទុក្ខកិរិយាជាដើម តែក្រោយមកទ្រង់បាន លះបង់ចោលទៅវិញ តើធ្វើម្ដេចព្រះអង្គអាចសម្រាប់ពោធិញ្ញាណបាន? ឥឡូវនេះ បែរជាមិនគួរអោយជឿដល់ថា ព្រះអង្គអាចចេះចាំធម៌បានយ៉ាងស្ទាត់ជំនាញ ហើយសំដែងបានយ៉ាងក្បោះក្បាយទៀតផង ព្រមទាំងទ្រង់បកស្រាយពី **សច្ចៈ** នៃ **ព្រះនិព្វាន** បានយ៉ាងជាក់ច្បាស់ទៀត!"។ ដូច្នេះហើយដែលធ្វើអោយ

www.elibraryofcambodia.org

**បញ្ចវគ្គីយ** ខ្លួនឯង មានចម្ងល់ជាច្រើន ទើបពួកគាត់ពោលពាក្យឡើងដោយមិនដឹងខ្លួនថាៈ "មែនកាលពីមុនពេលយើងធ្លាប់រស់នៅជាមួយព្រះអង្គ! យើងមិនដែលឃើញទ្រង់ចេះសំដែងធម៌ដ៏អស្ចារ្យបែបនេះសោះ ឥឡូវនេះស្រាប់តែឃើញព្រះអង្គចេះចាំព្រះធម៌ទាំងនេះបានយ៉ាងស្ទាត់ជំនាញ ព្រះអង្គពិតជាទ្រង់សម្រេចនូវការត្រាស់ដឹង **សម្មាសម្ពោធិញ្ញាណ** ពិតប្រាកដណាស់ ព្រោះថា ព្រះធម៌ **បរមសច្ចៈ** នេះមិនងាយបុគ្គលណាចេះចាំបានឡើយ! ដូចនេះពួកយើងត្រូវគោរពព្រះអង្គជាព្រះបរមគ្រូនៃយើងចាប់តាំងពីពេលនេះតទៅ ហើយត្រូវទទួលយកការប្រៀនប្រដៅសព្វបែបយ៉ាងពីព្រះអង្គ មិនត្រូវធ្វេសប្រហែសទេ"។

ក្រោយមកនៅថ្ងៃ ១៥ កើត ខែអាសាឍ ឆ្នាំរកា **ព្រះបរមសាស្តា** ទ្រង់សម្តែង **ព្រះបឋមទេសនា** ប្រោសដល់ **បញ្ចវគ្គីយ** (ដែលកាលមិនទាន់ក្លាយខ្លួនជាព្រះសាវ័កនៅឡើយ)។ **ព្រះធម្មទេសនា** (preaching the dharma) នាគ្រានេះ ពោរពេញដោយអត្ថន័យក្បោះក្បាយ បានលើកឡើងពន្យល់ពី **ហេតុ** និង **ផល** ដែលបច្ច័យនៃ **អរិយសច្ចៈ** ទាំង៤ (supreme truths) ដែលជាទង្វើទុក្ខប្រចាំកាយ មិនអាចជៀសរួចពីសេចក្តីលះបង់នៃអំពើស្មោគគ្រោកទាំងឡាយដែលនាំមកនៅការភ្លេចភ្លាំង គិតតែពី **លោភៈ** (ambition) **ទោសៈ** (violent) **មោហៈ** (anger) ចង់បំពេញដល់នូវក្តីកាមារម្មណ៍ (sensual pleasure) ជាអំពើចំពោះតែ **បុថុជ្ជន** ប៉ុណ្ណោះ មិនមែនជា **អរិយបុគ្គល** ឡើយ។ ធម៌ដែលគួរប្រព្រឹត្ត គួរប្រតិបត្តិទៅរកសេចក្តីស្ងប់ យល់ជាក់ច្បាស់ពី **អរិយសច្ចៈ** ទាំង ៤ប្រការនោះហើយជាផ្លូវត្រាស់ដឹង និងជា **អរិយបុគ្គល** ពិតប្រាកដ។ **បញ្ចវគ្គិយ** ទ្រង់ពិចារណាទៅតាមធម្មទេសនាគ្រប់ប្រការ ពេលនោះមានតែ **ព្រាហ្មកោ-ណ្ឌិញ្ញ** ទេ ដែលទ្រង់យល់ច្បាស់ជាងគេ **ព្រាហ្មកោណ្ឌិញ្ញ** បានប្រាកដនូវធម៌

www.elibraryofcambodia.org

ចក្ខុ (Dharma vision) (ទតឃើញព្រះធម៌ស្ថិតនៅនឹងភ្នែក គ្រប់ធម៌សព្វយ៉ាង ដែល **ព្រះបរមសាស្តា** បានទេសនា)។ ចំណែក **ព្រះពុទ្ធបរមគ្រូ** ពេលព្រះអង្គ ទ្រង់សំដែងធម្មទេសនា ទ្រង់បានដឹងនៅពេលនោះដែរថា **ព្រាហ្មណ៍កោណ្ឌិញ្ញ** បាន យល់ច្បាស់ព្រះធម៌របស់ព្រះអង្គជាងគេ និងត្រូវបានបំបួសមុនគេ ទើបព្រះអង្គ ត្រាស់ដល់ **ព្រាហ្មណ៍កោណ្ឌិញ្ញ** អោយក្លាយជាព្រះភិក្ខុភាវៈនាម **អញ្ញាកោណ្ឌ-ញ្ញៈ** (Ayakaundinya) ជាព្រះសាវ័កមុនគេក្នុងព្រះពុទ្ធសាសានានៅគ្រានោះ ឯង។

ក្រោយមក **ព្រះពុទ្ធ** ជាម្ចាស់ទ្រង់គង់នៅព្រៃ **មិគទាយវ័ន** ជាមួយ **បញ្ចវគ្គិយ** ទ្រង់បានព្យាយាមសំដែង **ធម្មទេសនា** ដល់ **បញ្ចវគ្គិយ** លុះត្រា វហូតដល់ពួកគាត់បានក្លាយជាសាវ័ក និងបានត្រាស់គ្រប់ៗអង្គ។ ព្រះភិក្ខុទាំង ៥ អង្គបាននិមន្តចេញបិណ្ឌបាត្រជាប្រក្រតីផ្លាស់ប្តូរវេន បើ ២ អង្គចេញ ៣ អង្គនៅ បម្រើ **ព្រះពុទ្ធ** ហើយរមែងស្តាប់ធម៌សំដែងដែលព្រះអង្គផ្តល់អោយ។ តែបើ ៣ អង្គនិមន្តចេញម្តង ២ អង្គដែលនៅត្រូវបានព្រះអង្គផ្តល់អោយនូវព្រះធម៌ដូចគ្នា ដែរ។ មិនយូរប៉ុន្មាន ដោយការគោរពប្រតិបត្តិ យកចិត្តទុកដាក់ និងការសង្វាតព្យាយាមផង ដែរនោះ ព្រះភិក្ខុទាំង ៥ ក៏បានសម្រេចត្រាស់ ដឹងក្លាយជា **ព្រះអរហន្ត** (Arahantship disciples) ទាំង ៥ ជាដំបូងឡើង ក្នុងលោក ចាប់ពីពេលនោះមក។



បញ្ចវគ្គិយទាំង៥ បានក្លាយជាព្រះអរហន្ត
(ស្រង់ចេញពី Internet)

www.elibraryofcambodia.org

# វគ្គទី៣០

# យសបព្វជា

# (Yasas to become Buddist Monk)



ព្រះអង្គប្រោសយសត្ថេរ (ស្រង់ចេញ ពីវត្តសំរោងអណ្តែត ក្រុងភ្នំពេញ)

ក្នុងសម័យដែល **ព្រះពុទ្ធ** កំពុងគង់ **វិបស្សនា** (Clear sightedness) នៅក្នុងព្រៃ **មិគទាយវ័ន** មានកូនសេដ្ឋីម្នាក់ (Son of millionaire) ឈ្មោះ **យស** (Yasas) រស់នៅក្នុងវិមានស្កឹមស្កៃនៃក្រុង **ពារាណសី** មានទ្រព្យសម្បត្តិ និងអ្វីៗសព្វយ៉ាងមិនខ្វះចន្លោះឡើយ តែសេចក្តីត្រេកត្រអាល និងការឈ្លក់វង្វេងដោយតណ្ហា និងការសប្បាយដោយមានអ្នកបំរើស្រីៗច្រើនពេក គ្មានបានគិតគូរអ្វីជាគុណប្រយោជន៍សោះ ធ្វើអោយសេដ្ឋីបុត្រ **យស** មានការធុញទ្រាន់ក្នុងជីវិតបែបនោះទៅវិញ គាត់ក៏មានចិត្តចង់គេចវេសចេញពីទីកន្លែងដែលខ្លួន (សេដ្ឋីបុត្រ **យស**) យល់ថាជាអំពើមិនគប្បី ។ សម្រេចចិត្តរួចនិងយល់ឱកាសមានល្អប្រសើរហើយ សេដ្ឋីបុត្រ **យស** ក៏លួចរត់ចេញពីវិមានស្តុកស្តម្ភ ដោយមិនមានអ្នកណាបានដឹងឡើយ ។ **យស** ខំធ្វើដំណើរយាត្រាយ៉ាងវែងឆ្ងាយ គេចពីបណ្តាមហាជន ក៏បានទៅដល់កន្លែងដែល **ព្រះពុទ្ធ** គង់នៅព្រៃ **មិគទាយវ័ន** ។ **ព្រះបរមសាស្តា** ទតឃើញ **យស** មកដល់ ទ្រង់ក៏មានព្រះនិស្ស័យស្វែងយល់ថា បុគ្គលនេះនឹងត្រូវបានត្រាស់ក្នុងព្រះពុទ្ធសាសនាពុំខាន

www.elibraryofcambodia.org

ព្រះអង្គ។ - ទ្រង់ក៏មានពុទ្ធដិកាឡើងថាៈ "ម្នាល! អ្នកដ៏ចម្រើន! អ្នកមាននិស្ស័យណាស់ បានមកជួប **តថាគត** ចូរអ្នកត្រងត្រាប់ស្តាប់នូវព្រះធម៌ ដែល **តថាគត** នឹងផ្តល់អោយ"។ **យស** ឮហើយក៏ចូលទៅក្រាបថ្វាយបង្គំព្រះអង្គ រួចអង្គុយក្នុងទីដ៏សមរម្យ ត្រងត្រាប់ស្តាប់នូវព្រះធម៌ដែល **ព្រះពុទ្ធ** ទ្រង់សម្តែងទៅ គ្រានោះ **ព្រះពុទ្ធ** ជាម្ចាស់ទ្រង់សម្តែងធម៌ **អនុបុព្វិកថា** (sub-portion) ស្តីអំពីទាន (donation) សីល (morality) សួគ៌ា (angel's world) និងអានិសង្ស (good results) ដែលលះបង់ចាកចេញពីចំណងកាមគុណ។ ចប់អនុបុព្វិកថាហើយ ទ្រង់ក៏សម្តែងពន្យល់អំពី **អរិយសច្ចៈ** ទាំង ៤ ជាបន្តបន្ទាប់ទៀត។ **យស** ព្យាយាម ស្តាប់នូវព្រះធម៌ដែល **ព្រះពុទ្ធ** សម្តែង គាត់បានពិចារណាយល់ច្បាស់លាស់ ពីព្រះធម៌ដ៏ឧត្តុងឧត្តមទាំងនេះ គាត់កើតចិត្តរីករាយជ្រះថ្លា ក្រាបបង្គំសុំសាងផ្នួស ប្រតិបត្តិធម៌ និងសុំបម្រើ **ព្រះបរមសាស្តា** ជាគ្រូតទៅ។ ចំណែកឯក្រុមគ្រួសារសេដ្ឋីជាមាតាបិតារបស់ **យស** ក្រោយពីដឹងបាត់កូនប្រុសហើយ ក៏ចាត់ចែងអោយទាសាទាសីតាមរកគ្រប់ច្រកល្ហក។ ក្រោយមកលោកសេដ្ឋីជាបិតានិង បរិវារបានមកដល់ទីកន្លែង **ព្រះពុទ្ធ** គង់នៅ ក៏បានសាកសួរព្រះអង្គអំពីដំណើងកូនប្រុសដែលបាត់ចេញពីវិមានសេដ្ឋី នៃក្រុង **ពារាណសី** ដោយគាត់ទួញសោកយ៉ាងខ្លាំងពីទុក្ខព្រួយបាត់កូនស្ងួនភ្ងារ។ **ព្រះបរមសាស្តា** ទ្រង់ជ្រាបនូវរឿងទាំងនេះ ហើយព្រះអង្គក៏មានពុទ្ធដិកាលួងលោមទៅលោកសេដ្ឋីវិញ ព្រមទាំងសម្តែងព្រះធម៌ប្រោសដល់ក្រុមគ្រួសារសេដ្ឋីដោយប្រការថាៈ "ម្នាលលោកសេដ្ឋីដ៏ឧត្តម! សូមលោកកុំព្រួយបារម្ភចំពោះកូនប្រុសអី! បុត្រាលោកសេដ្ឋីបានមករកឃើញសេចក្តីស្ងប់រំងាប់ លះបង់ចាកចេញពីតណ្ហាលោកីយ៍ ហើយបានស្វែងយល់ដល់ព្រះធម៌ ដោយការពិចារណាដ៏ត្រឹមត្រូវរបស់គេ ដោយការរិះរកនេះក្រុំពុំអាចទៅ

www.elibraryofcambodia.org

អ្វីឡើយ"។ រួចហើយព្រះអង្គទ្រង់សំដែង **ធម្មទេសនា** ដល់សេដ្ឋី និងបរិវាររនៅគ្រានោះដែរ។ ក្រោយពីបានស្តាប់ **ធម្មទេសនា** ដែលប្រកបដោយអត្ថន័យ **ព្រហ្មវិហារធម៌ ចរិយាធម៌ គុណធម៌** យ៉ាងល្អប្រពៃ ធ្វើអោយពួកសេដ្ឋីមានចិត្តជ្រះថ្លា ព្រមលះបង់អោយបុត្រាបួសជាសាមណេរ រស់នៅប្រតិបត្តិធម៌ជាមួយ **ព្រះពុទ្ធ** ជាម្ចាស់នាពេលនោះទៅ។ លោកសេដ្ឋីអស់ចិត្ត លែងអាល័យកូន ព្រោះគាត់ពេញចិត្តចំពោះកូនប្រុសដែលរស់ក្រោមម្លប់ព្រះពុទ្ធសាសនា លែងខ្វល់ខ្វាយនូវរឿងលោកីយ៍ទាំងឡាយ ពួកគាត់ក៏ក្រាបបង្គំលា **ព្រះពុទ្ធ** ត្រឡប់ទៅវិមានរបស់ខ្លួនវិញ។ ដល់វិមាន លោកសេដ្ឋីព្យាយាមនិយាយពន្យល់ដល់ភរិយាដោយសព្វប្រការ សេដ្ឋីនីជាភរិយាកាលបើបានស្តាប់ហើយ ក៏មានសេចក្តីជ្រះថ្លាយល់ថាមានកូនបានបួសរស់ក្នុងផ្លូវធម៌គឺជាការប្រពៃ សេចក្តីល្អគ្រប់យ៉ាងនឹងមានជាប្រាកដលើគ្រួសាររបស់គាត់។ សេដ្ឋីនីក៏ឈប់មានក្តីទុក្ខព្រួយ ថែមទាំងបួងសួងសុំអោយបុត្រាសម្រេចជាព្រះសាវ័ករបស់ **ព្រះពុទ្ធ** ជាម្ចាស់ដូចក្តីបំណង។

ចំណែកឯភិក្ខុ **យស** ខិតខំសិក្សាប្រតិបត្តិធម៌ ក្រោយមកត្រូវ **ព្រះពុទ្ធ** ជាម្ចាស់ប្រទានបព្វជាដល់ព្រះភិក្ខុ **យស** ជា **ឧបសម្បទា** (observing the eight precepts) ហើយមិនយូរប៉ុន្មាន **ព្រះយស** ក៏បានត្រាស់ជាព្រះអរហន្ត **យសត្ថេរ** (Yasathera)។ ចាប់ពីពេលនោះមក ក៏កើតមានព្រះអរហន្ត ៧ អង្គក្នុងលោកគឺ **ព្រះពុទ្ធ**១អង្គ **បញ្ចវគ្គិយ**៥អង្គ **យសត្ថេរ** ១អង្គ។

www.elibraryofcambodia.org

# វគ្គទី៣១

# មិត្តរួមបព្វជា

# (Best friends of Yasathera)



សេដ្ឋីបិតាមាតាព្រះយសប្រគេន ចង្ហាន់ព្រះអង្គ
(ស្រង់ចេញពីវត្តសំរោងអណ្ដែត)

សម័យថ្ងៃមួយ ពេលព្រឹកព្រាងពេញពន្លឺ **ព្រះពុទ្ធ** ទ្រង់ប្រដាប់ត្រៃចីវរ និងបាត្រនិមន្តជាមួយ **ព្រះយស** ទៅកាន់វិមានសេដ្ឋីនាក្រុង **ពារាណសី** ជាទីកន្លែងរបស់សេដ្ឋីជាបិតា **ព្រះយស** ។ ពេលមកដល់វិមានលោកសេដ្ឋី និងសេដ្ឋីនី បានមកនិមន្តព្រះពុទ្ធគង់លើអាសនៈ ដែលបានរៀបចំថ្វាយព្រះអង្គ ចំណែក **ព្រះយស** ក៏គង់ទៅជិតអាសនៈនោះដែរ ។ ក្រុមញាតិមិត្តលោកសេដ្ឋីបានមកថ្វាយបង្គំព្រះអង្គគ្រប់ៗគ្នា ។ ពេលជាមួយគ្នានោះ សេដ្ឋីនី និងភរិយារបស់ **ព្រះយស** បានស្ម័គ្រចិត្តសុំក្លាយខ្លួនជាឧបាសិកាក្នុងម្លប់ព្រះពុទ្ធសាសនាព្រះអង្គមុនស្ត្រីក្នុងលោក ។ លោកសេដ្ឋីជីតារបស់ **ព្រះយស** បានចេញមកថ្វាយបង្គំ ប្រគេនចង្ហាន់ដែលគាត់បានរៀបចំដោយផ្ទាល់ដៃរបស់គាត់ ថ្វាយដល់ **ព្រះពុទ្ធ** និងព្រះភិក្ខុ **យសត្ថេរ** ជាចៅរបស់គាត់ ។ **ព្រះពុទ្ធ** និង **យសត្ថេរ** ក៏បានឆាន់ចង្ហាន់ទាំងនោះបានយ៉ាងសព្វព្រះទ័យរួចរាល់ហើយ **ព្រះពុទ្ធ** ក៏ទ្រង់សម្ដែងធម៌ **ធម្មិក** (ideally good, Dhamimika) ទូន្មានបណ្ដាជនទាំងឡាយដែលកំពុងស្ថិតនៅទីនោះ ។ កាលបើបានស្ដាប់ព្រះធម៌ **ធម្មិក** ដោយយកចិត្តទុកដាក់មក គ្រប់ៗគ្នាក៏មានចិត្តរីករាយ

www.elibraryofcambodia.org

និងទុកចិត្ត យល់ច្បាស់ពីព្រះធម៌ជាទីពឹង ទីអាស្រ័យសម្រាប់ជីវិតរបស់ពួកគេ នូវសេចក្តីរុងរឿងតទៅ។ ការសម្តែងធម៌អប់រំផ្លូវចិត្តបានចប់សព្វប្រការហើយ **ព្រះបរមសាស្តា** និង **យសត្ថេរ** ក៏និមន្តត្រឡប់ទៅកាន់អាស្រមនៅព្រៃ **មិគទាយវ័ន** វិញ។ ក្រោយបន្ទាប់មក មិនយូរប៉ុន្មានក៏មានមិត្តសំឡាញ់របស់ **ព្រះយស** ៤ នាក់ទៀត គឺឈ្មោះ **វិមល** (Vimala) **សុពាហុ** (Subala) **បុណ្ណជី** (Ponnaci) **គវំបតិ** (Keavapaty) សុទ្ធតែជាកូនសេដ្ឋីដូចគ្នានៅក្នុងក្រុង **ពារាណសី** ដែរ។ សេដ្ឋីបុត្រទាំង ៤ បានដឹងដំណឹងថា **ព្រះយស** ដែលជាកល្យាណមិត្តរបស់ពួកខ្លួន បានចេញបួសជាសាវ័ក **ព្រះពុទ្ធ** ហើយមិត្តទាំង ៤ ដែលជាសម្លាញ់ចិត្តមួយថ្លើមមួយនឹងគ្នានោះ ក៏ជាអ្នកគោរពព្រះពុទ្ធ ព្រះធម៌ដូចគ្នា ក៏ស្ម័គ្រចិត្តបបួលគ្នាទៅបួសប្រតិបត្តិធម៌ជាមួយ **ព្រះយស** ដែរ។

មិត្តទាំង ៤ បានធ្វើដំណើរទៅកាន់កន្លែង **ព្រះពុទ្ធ** គង់នៅ ហើយក៏បានជួបនិងភិក្ខុ **យសត្ថេរ** ដូចបំណង។ **ព្រះយសត្ថេរ** បាននាំមិត្តទាំង ៤ ទៅក្រាបបង្គំ **ព្រះពុទ្ធ** ជាម្ចាស់ ហើយទូលតាមដំណើរការនៃបំណងពួកគេទាំង៤។ **ព្រះពុទ្ធ** ទ្រង់ពេញព្រះទ័យនូវសទ្ធានចិត្តពួកគេទាំង ៤ នាក់ ដែលស្ម័គ្រស្មោះជាមួយគ្នាចេះគោរពស្រលាញ់ព្រះធម៌ដូចគ្នា ដូច្នេះព្រះអង្គក៏អនុញ្ញាតិបំបួសពួកគេទាំង ៤ បន្ទាប់មកមិត្តទាំង ៤ ក៏ក្លាយជាភិក្ខុទាំង ៤ ស្តាប់ធម៌ឱវាទសព្វយ៉ាងពី **ព្រះពុទ្ធ**។


មិត្តទាំង ៤ របស់ព្រះយសសុំការបំបួសពីព្រះអង្គ
( ស្រង់ចេញពី Internet )

**ព្រះពុទ្ធបរមគ្រូ** ទ្រង់សម្តែងព្រះធម៌ជាច្រើន ទូន្មានអប់រំគ្រប់គ្រងផ្លូវចិត្តទាំង **ចរិយាធម៌** និង **គុណធម៌** សព្វយ៉ាងដល់ភិក្ខុទាំង ៤ មិនយូរប៉ុន្មាន ដោយចិត្តផ្តេកផ្តួលទាំង

www.elibraryofcambodia.org

ស្រុងលើព្រះធម៌ និងការពិចារណាដ៏ប្រពៃ ភិក្ខុក្រោយទាំង ៤ អង្គក៏ត្រាស់ដឹងដូចជា **ព្រះយសត្ថេរ** ដែរ ហើយ **ព្រះពុទ្ធបរមគ្រូ** ក៏ប្រទានបព្វជា **ឧបសម្បទា** ដូចជា **ព្រះយស** ដែរ ។ ចាប់ពីពេលនោះមក **ព្រះអរហន្ត** ក៏កើតមានចំនួន ១១ អង្គ។ ក្រោយពី **ព្រះអរហន្ត** ១១ អង្គមក ដំណឹងនេះបានលេចឮដល់មិត្តដ៏ទៃរបស់ **ព្រះយស** និងភិក្ខុទាំង ៤ ដែលធ្លាប់ជាមិត្តរួមរស់ស្គាល់ចិត្តគ្នា ឥឡូវបានក្លាយជាសាវ័កនៅបំរើ **ព្រះពុទ្ធ** ហើយមិត្តភ័ក្រទាំងនោះសរុបមានគ្នាចំនួន ៥០ នាក់ ក៏ស្ម័គ្រចិត្តបបួលគ្នាទៅបួសរៀនធម៌ដូច **ព្រះយស** និងភិក្ខុទាំង ៤ ដែរ ។ **ព្រះពុទ្ធ** ជាម្ចាស់ទ្រង់សព្វព្រះទ័យនឹងទឹកចិត្តពួកគេរាល់គ្នា ដែលស្មោះស្ម័គ្រក្លាយខ្លួនជាបព្វជិត គោរពប្រតិបត្តិព្រះធម៌ជាមួយព្រះអង្គ ទ្រង់ក៏បានបំបួសមិត្តទាំង ៥០ នាក់នោះជាសមណសង្ឃ សិក្សាប្រតិបត្តិព្រះធម៌ជារៀងមក ដោយការខំសង្វាតព្យាយាមយកចិត្តទុកដាក់ មិនយូរប៉ុន្មានភិក្ខុទាំង ៥០ នោះ ក៏បានសម្រេចការត្រាស់ដឹងជាព្រះអរហន្តគ្រប់ៗ អង្គដូច្នេះនៅពេលនោះហើយព្រះអរហន្តក៏កើតមានបន្តចំនួន ៦១ អង្គចាប់ពីពេលនោះមក ។

www.elibraryofcambodia.org

# វគ្គទី៣២

# ផ្សព្វផ្សាយព្រះពុទ្ធសាសនា

# (The declaration of the Buddhism)



ព្រះអង្គចាត់ចែងអោយភិក្ខុចេញផ្សាយព្រះធម៌
(ស្រង់ចេញពី Internet)

កាលបើបានព្រះសាវ័កដ៏ច្រើនដូច្នេះហើយ **ព្រះពុទ្ធ** ក៏ទ្រង់ធ្វើកិច្ចប្រជុំ និងចាត់ចែងបញ្ជូនព្រះសាវ័កទាំង ៦០ អង្គនោះអោយនិមន្តទៅផ្សព្វផ្សាយព្រះធម៌ នៅទីកន្លែងផ្សេងៗ ដោយទ្រង់មានពុទ្ធដីកាឡើងថា: "ម្នាលភិក្ខុទាំងឡាយ! **តថាគត** បានរំដោះទាំងស្រុងហើយ ពីចំណងទាំងអស់របស់មនុស្ស និងទេវត្តា រីឯភិក្ខុទាំងឡាយក៏ដូច្នេះដែរ! ឥឡូវនេះ ចូរភិក្ខុទាំងអស់គ្នានិមន្តទៅផ្សព្វផ្សាយព្រះធម៌តាមទីនិគមជនបទ និងទីក្រុងនានា ដើម្បីអោយមហាជនគ្រប់រូបបានយល់ជ្រួតជ្រាបពីព្រះធម៌ដែលជាគុណប្រយោជន៍ និងផ្តល់សេចក្តីសុខដល់មនុស្សគ្រប់រូប! ចូរអ្នកព្យាយាមពន្យល់អោយបានច្បាស់ពីគុណសម្បត្តិ នៃព្រះធម៌ដ៏ជាទីបរិសុទ្ធនេះដល់ពួកគេ (ពួកគេនឹងមានប្រយោជន៍ធំធេង នឹងអាចក្លាយជា **ព្រះអរហន្ត** បាន)! រីឯមនុស្សមួយចំនួនដែលស្ថិតនៅដោយកិលេសលោកីយ៍នៅឡើយ មិនថាតិច ឬច្រើនក្តី បើសិនជាពួកគេមិនបានស្តាប់ មិនបានដឹងពីព្រះធម៌ទេនោះ ពួកគេទាំងនោះនឹងខាតបង់ប្រយោជន៍ធំ នឹងអស់មគ្គផលជាច្រើនប្រការសម្រាប់ពួកគេ!" ចូរអ្នកទៅបំពេញតាមទីកន្លែងផ្សេងៗ តាមកាលកំណត់ចុះ! ចំណែកនៅប៉ែក

www.elibraryofcambodia.org

**ឱរុវេល** ប្រទេស ជាកន្លែងស្អុគស្មាញជាងគេនោះ ទុកអោយ **តថាគត** និមន្ត ទៅដោយផ្ទាល់នៅទីនោះតែម្តង!" ។

ដូចព្រះអង្គមានពុទ្ធដិកា នៅរដ្ឋ **ឱរុវេល** ក្នុងប្រទេសឥណ្ឌានាសម័យបុរាណ រដ្ឋនេះមិនដូចជារដ្ឋដទៃដែលលូតលាស់នោះឡើយ ។ **ឱរុវេល** ជារដ្ឋស្ថិតនៅចុងកាត់មាត់ញក ពោរពេញដោយជំនឿទំនៀមទំលាប់ចាស់ៗជាច្រើន ។ ក្នុងពុទ្ធកាលសម័យដែល **ព្រះពុទ្ធ** គង់នៅ ទ្រង់ឆ្វេងយល់ថា តំបន់នេះមានការលំបាកក្នុងការកែទំរង់ ទើបព្រះអង្គសម្រាប់ព្រះទ័យនិមន្តទៅសំដែងធម៌នៅទីនោះ ដោយផ្ទាល់ព្រះអង្គ ។

www.elibraryofcambodia.org

# វគ្គទី៣៣

# **កស្សបសាវ័ក** (Kasyapa disciple)



ព្រះអង្គប្រោសឧរុវេឡកស្សប
( ស្រង់ចេញពីវត្តសំរោងអណ្តែត )

បន្ទាប់មកព្រះសាវ័កទាំង ៦០ អង្គ ក៏និមន្តទៅសម្តែងធម៌តាមទីកន្លែងរៀងៗខ្លួនតាមពុទ្ធឱវាទ រីឯ **ព្រះពុទ្ធ** ទ្រង់ក៏និមន្តទៅកាន់រដ្ឋ **ឧរុវេល** ហើយទ្រង់ទៅគង់នៅទិសប៉ែកនិរតី ក្នុងតំបន់មួយឈ្មោះ **ឧរុវេលកស្សប**។ **ឧរុវេលកស្សប** គ្រប់គ្រងដោយព្រាហ្មណ៍ត្រកូល **កស្សប** ទើបតំបន់នេះហៅឈ្មោះបែបនេះ ។ ត្រកូលព្រាហ្មណ៍ **កស្សប** មានបងប្អូន ៣ នាក់ (Kasyapa 3 brothers) ព្រាហ្មណ៍បងបង្អស់ឈ្មោះ **ឧរុវេកស្សប** (Uruvlva Kasyapa) មានសិស្សសមាជិក ៥០០ នាក់ ព្រាហ្មណ៍ទី ២ ឈ្មោះ **នទិកស្សប** (Natika Kasyapa) មានសិស្សសមាជិក ៣០០ នាក់ និងព្រាហ្មណ៍ប្អូនទី ៣ ឈ្មោះ **គយាកស្សប** (Kaya Kasyapa) មានសិស្ស ២០០ នាក់ ។

ក្នុងសម័យ **ព្រះពុទ្ធ** ទ្រង់និមន្តទៅដល់តំបន់នោះ ជាដំបូង ព្រាហ្មណ៍ **កស្សប** ជាបងគេ និងជាប្រធានធំ បានអោយព្រះអង្គទៅគង់នៅក្នុងរោងមួយជាកន្លែងសម្រាប់បូជាភ្លើង ។ **ព្រះមុនីសាស្តា** ទ្រង់មិនប្រកាន់ ព្រះអង្គក៏ទ្រង់គង់នៅទីនោះដោយព្រះទ័យស្ងប់ស្ងាត់ ។ ពេលវេលាដែលព្រះអង្គគង់នៅក្នុងរោងបូជាភ្លើងនោះ ព្រះអង្គខំសម្តែងធម៌ជាច្រើនប្រការ ព្យាយាមពន្យល់អប់រំផ្លូវចិត្តដល់

www.elibraryofcambodia.org

មេព្រាហ្មណ៍ទាំង ៣ ព្រមទាំងបរិវាររបស់ពួកគាត់។ ព្រះធម៌ដែលព្រះអង្គសម្តែងពន្យល់ដល់ពួកគេនៅពេលនោះ ជាធម៌មានលក្ខណៈវិសេសវិសាល គឺប្រើចិត្តវិធីបន្ទាបចិត្តគំនិតនៃជំនឿអកុសលដែលធ្លាប់មានពីមុនមក ដោយងាកមករកផ្លូវថ្មីនៃ **សច្ចៈធម៌ គុណធម៌** និង **ព្រហ្មវិហារធម៌** ទាំងសព្វប្រការ លុះត្រាតែពួកព្រាហ្មណ៍ទាំងនោះស្ថិតក្នុងការពិចារណាល្អិតល្អន់ ពួកគេក៏យល់ច្បាស់ដូចព្រះធម៌ដែលព្រះអង្គទ្រង់សម្តែងមែនថា: មនុស្សត្រូវមានភារកិច្ចជាសារៈសំខាន់ ដើម្បីជួយមនុស្សដូចគ្នា និងជួយដល់ពពួកសព្វសត្វផងដែរ អោយរួចចាកទុក្ខលំបាកដោយអត្ថន័យសង្កត់ធ្ងន់លើការប្រព្រឹត្តល្អ រមែងទទួលផលល្អ ការប្រព្រឹត្តខុសសាងអំពើអាក្រក់ រមែងទទួលកម្មផលអាក្រក់ មានការរងទុក្ខទោស ធ្លាក់ទៅនរកអវចីយ៍ជាដើម។ ព្រាហ្មណ៍ **កស្សប** ប្រកបដោយសតិសម្បជញ្ញៈលើសប្អូនទាំងពីរ បានយល់ច្បាស់តាមគន្លងព្រះធម៌ ដែល **ព្រះពុទ្ធ** សម្តែង ចំណែក **នទិក** និង **គយា** ជាប្អូនៗដំបូងហាក់មិនព្រមជឿ នៅមានមន្ទិលជាប់ប្រាណ តែក្រោយមកដោយការពិចារណាលើខ្លឹមសារនៃព្រះធម៌ ក៏ឯកភាពតាមបងដែរ រួចបន្ទាប់មកមានបរិវារព្រាហ្មណ៍ទាំង ១០០០ នាក់ ក៏លុះតាមទាំងអស់គ្នាដោយបិតិរីករាយ ហើយក៏នាំគ្នាក្រាបបង្គំសុំ បួសជាភិក្ខុប្រតិបត្តិព្រះធម៌ក្នុងព្រះពុទ្ធសាសនា មិនយូរប៉ុន្មាន **សមណៈកស្សប** បីនាក់បងប្អូន ព្រមទាំងភិក្ខុទាំង ១០០០ អង្គ ក៏សម្រេចធម៌ជា **ព្រះអរហន្ត** ទាំងអស់គ្រប់ៗអង្គ។



សមណៈកស្សប និងភិក្ខុទាំង ១០០០ អង្គ
( ស្រង់ចេញពី Internet )

www.elibraryofcambodia.org

# វគ្គទី៣៤

# និមន្តចូលក្រុងរាជគ្រឹះ

# (Gautama goes to Ratnagiri)



ព្រះអង្គនិមន្តចូលក្រុងរាជគ្រឹះ
( ស្រង់ចេញពី Internet )

**ព្រះបរមសាស្តា** ទ្រង់សម្រេចកិច្ចនៅរដ្ឋ **ឧរុវេល** ជាស្ថាពរ ក្នុងការផ្សព្វផ្សាយព្រះធម៌របស់ព្រះអង្គ ព្រមទាំងបានសាវ័ករាប់ពាន់អង្គថែមទៀត ដើម្បីបំពេញដល់ការសន្យារបស់ព្រះអង្គ ចំពោះស្តេច **ពិម្ពិសារ** និងផ្សព្វផ្សាយការប្រៀនប្រដៅដល់ប្រជារាស្ត្រក្នុង នគរនោះផង។ ព្រះអង្គក៏ទ្រង់និមន្តចូលក្រុង **រាជគ្រឹះ** មានទាំងសាវ័ករាប់ពាន់អង្គ និមន្តហែរហមទៅជាមួយ។ ពេលនិមន្តដល់ក្រុង **រាជគ្រឹះ** ហើយ **ព្រះពុទ្ធ** ព្រមទាំងសាវ័កព្រះអង្គទាំងអស់គង់នៅក្នុងសួន **តាលវ័ន** (Palm garden) ជាតំបន់មួយសំបូរដើមត្នោត។ **ព្រះពុទ្ធ** បានបំពេញការសម្តែងធម៌ជាច្រើននៅទីនោះ ព្រះបា **ពិម្ពិសាររាជ** ព្រមទាំងប្រជារាស្ត្រព្រះអង្គបាននាំគ្នាមូលមីរដេរដាស ទៅក្រា បង្គំស្តាប់ព្រះធម៌ដែលទ្រង់សម្តែង ដោយនាំគ្នាខំយកចិត្តទុកដាក់ជាទីបំផុត។ ក្រោយពីបានស្តាប់ដល់នូវការជ្រួតជ្រាប ប្រជារាស្ត្រជាច្រើនបានសុខចិត្តថ្វាយខ្លួនសុំធ្វើជាពុទ្ធបរិស័ទរបស់សាសនាព្រះអង្គគ្រប់ៗគ្នារៀងមក។ រំលឹកឡើងនូវសេចក្តីប្រាថ្នារបស់ស្តេច **ពិម្ពិសារ** កាលព្រះអង្គបានជួបជាមួយ **ព្រះពុទ្ធ** គ្រាដំបូងស្តេច **ពិម្ពិសារ** បានធ្លាប់ទូលថ្វាយព្រះពុទ្ធជាម្ចាស់ថាៈ "ក្រៅពីទ្រង់ជាមហាក្សត្រ

www.elibraryofcambodia.org

ព្រះអង្គបានប៉ងប្រាថ្នាស្ដាប់ព្រះធម៌របស់ **ព្រះពុទ្ធ** ដែលជា **អនុត្តរៈ** ( ព្រះសាម្មាសម្ពោធិញ្ញាណ ) អោយបានមុនគេបង្អស់ក្នុងចំណោមស្ដេចទាំងឡាយ ដែលគ្រងរាជនាដែនប្រថពីទាំងមូលនេះ ពេលនេះសេចក្ដីប្រាថ្នារបស់ទ្រង់បានសម្រេចហើយ ដោយបានស្ដាប់ធម៌ដ៏បវរឱវាទរបស់ **ព្រះបរមសាស្ដា** និងសាវ័កសង្ឃទាំងឡាយ ធ្វើអោយព្រះអង្គរីករាយព្រះទ័យត្រេងត្រាប់ស្ដាប់ឱវាទគ្រប់ប្រការ ដើម្បីអោយខ្លួនទ្រង់ក្លាយជាមហាក្សត្រប្រកបដោយ **ទសពិធរាជធម៌**[៣៣] ដល់រាស្ត្ររបស់ព្រះអង្គក្នុងព្រះនគរ ។

ជាកិច្ចតបស្នងសងគុណ ចំពោះព្រះពុទ្ធសាសនា ព្រះបាទ **ពិម្ពិសារ** សព្វព្រះទ័យប្រគេនដីមួយកន្លែងឈ្មោះ **វេឡុវ័ន**[៣៤] (Venuvana) ដល់ **ព្រះពុទ្ធ** ដើម្បីកសាងធ្វើជាវត្ត សម្រាប់អោយភិក្ខុសង្ឃទាំងឡាយ គង់ស្នាក់អាស្រ័យនៅ ។ មិនយូរប៉ុន្មាន វត្ត **វេឡុវ័ន** ដែលពីមុនជាដីឬស្សីនោះ (bamboo garden) បានប្រែក្លាយទៅជាវត្តអារាម ជាទីសក្ការៈគោរពបូជាមុនគេបង្អស់ក្នុងព្រះពុទ្ធសាសនានៃយើង ។



ចំការឫស្សីដែលព្រះបាទពិម្ពិសារប្រគេនព្រះអង្គសំរាប់កសាងវត្តវេឡុវ័ន
( ស្រង់ចេញពី Internet )

---

[៣៣] រឿងព្រះបាទពិម្ពិសារមានចែងយ៉ាងពិស្ដារក្នុងត្រៃសរណធម៌ ។

[៣៤] ទីនោះកាលពីមុនជាចំការឫស្សី ( ឫស្សីស្រុក ) ត្រូវបានកាប់គាស់យ៉ាងស្អាត ដើម្បីកសាងជាវត្តថ្វាយដល់ព្រះពុទ្ធសាសនា ។

www.elibraryofcambodia.org

# វគ្គទី៣៥
# កិច្ចប្រតិបត្តិ ៦ប្រការ
# (Six practices of the solute)



ព្រះអង្គទូន្មានចៅមាណពពីកិច្ច
ប្រតិបត្តិ៦ ប្រការ
(ស្រង់ចេញពី Internet)

នៅក្នុងសម័យ ដែលព្រះពុទ្ធគង់នៅវត្ត **វេឡុវ័ន** នាព្រឹកថ្ងៃមួយនោះ ដែលព្រះអង្គទ្រង់និមន្តបិណ្ឌបាត្រនៅជាយក្រុង **រាជគ្រឹះ** ព្រះអង្គបានទតឃើញចៅមាណពម្នាក់ ដែលមានខ្លួនទទឹកជោកពេញសំលៀកបំពាក់ទាំងព្រលឹម ហាក់បីដូចជាទើបងើបចេញពីមុជទឹកស្ទឹងទន្លេ។ ចៅមាណពនោះស្ថិតនៅចំពាក់កណ្តាលផ្លូវមួយ នៃជាយក្រុងក្នុងវិថីដែល **ព្រះពុទ្ធ** និមន្តបិណ្ឌបាត្រ។ ចៅមាណពនោះបានធ្វើកិច្ចប្រតិបត្តិ គឺក្រាបថ្វាយបង្គំទិសទាំង ៤។ ដំបូង នាយសំពះទៅទិសខាងកើត បន្ទាប់មកទិសខាងត្បូង រួចខាងលិច និងខាងជើង រួចរាល់ហើយក៏ងើបសំពះឡើងទៅលើបញ្ចប់ សំពះចុះមកក្រោម រួចក៏យកគ្រាប់ធញ្ញជាតិបាចទៅគ្រប់ទិសទាំងប៉ុន្មាន ដែលខ្លួនបានសំពះគោរព។ **ព្រះពុទ្ធ** ទ្រង់សម្លឹងទៅចៅមាណពនោះ នូវសកម្មភាពរបស់គាត់ដែលបានធ្វើ ព្រះអង្គទ្រង់ចម្លែក ទ្រង់គិតថាជាប្រពៃណីអ្វីទៅ បានជាអោយគាត់ធ្វើបែបនេះ រួចក៏ទ្រង់និមន្តទៅជិតហើយសួរទៅចៅមាណពនោះថា: "ម្នាលចៅមាណព! អ្នកធ្វើកិច្ចដូច្នេះ តើមានន័យយ៉ាងដូចម្តេច?"។ - ចៅមាណពនោះឮហើយ ក៏ក្រាបថ្វាយបង្គំ **ព្រះពុទ្ធ** រួចឆ្លើយតបដោយគោរពទៅព្រះអង្គវិញថា: "បពិត្រព្រះសមណៈដ៏ឧត្តម! បានជាខ្ញុំព្រះករុណា

www.elibraryofcambodia.org

ប្រតិបត្តិយ៉ាងដូច្នេះ គឺធ្វើតាមបណ្តាំឪពុកដែលមុនពេលគាត់ធ្វើមរណៈកាលទៅ គាត់បានប្រាប់ខ្ញុំករុណាថា រាល់ពេលព្រឹក អោយខ្ញុំករុណាត្រូវធ្វើកិច្ចគោរពទៅទិសទាំង ៦ រួចបាចគ្រាប់ធញ្ញជាតិទៅកាន់ទិសទាំងនោះ ដើម្បីរំដោះគ្រោះចង្រៃផងទាំងពួង កុំអោយញាំញី និងបៀតបៀនបាន"។ **ព្រះសាស្តា** ក្រោយពីស្តាប់សំដីរបស់ចៅមាណពហើយ ព្រះអង្គទ្រង់មានព្រះទ័យសោមនស្សចំពោះនាយមាណពនេះណាស់ ទ្រង់មានពុទ្ធដីកាទៅចៅមាណពវិញថា: "ម្នាលចៅមាណពអើយ! នេះជាការប្រពៃណាស់ ចំពោះកូនដែលត្រង់ត្រាប់ស្តាប់បង្គាប់ឪពុកដោយចិត្តស្មោះបែបនេះ តែអត្ថន័យនៃបណ្តាំនោះគឺ មានន័យធំធេងជាងអ្វីដែលចៅមាណពបានយល់ ហើយបានធ្វើកន្លងមកនេះ"។ **ព្រះពុទ្ធ** ទ្រង់លើកហត្ថឡើងត្រាស់បង្ហាញបន្ថែមទៅចៅមាណពនោះទៀតថា: "ម្នាលចៅមាណពដ៏ប្រពៃ! អ្វីដែលឪពុកអ្នកបានទុកជាបណ្តាំនោះគឺ: **កិច្ចប្រតិបត្តិទាំង ៦ ប្រការ** ចូរអ្នកចាំស្តាប់: ១-ការគោរពទៅទិស **ខាងកើត** មានន័យថា ចង់អោយអ្នកប្រតិបត្តិចំពោះបុគ្គលណាដែលមានមេត្តាករុណា ចេះស្រលាញ់អាណិតអ្នក គឺចង់អោយអ្នកត្រូវគោរពពួកគាត់ទុកដូចជាឪពុកម្តាយបង្កើតអ្នកដែរ។ ២-ការគោរពទិស **ខាងត្បូង** គឺមានន័យថា គាត់ចង់អោយអ្នកគោរពបំរើគ្រូបាអាចារ្យដោយចិត្តស្មោះដែលគាត់បានបង្ហាត់បង្រៀនអោយអ្នកមានចំណេះចេះដឹងក្នុងខ្លួន។ ៣-ការគោរពទិស **ខាងលិច** មានន័យថា គាត់ចង់អោយអ្នកចេះស្រលាញ់ មើលថែភរិយា និងបុត្រភ្វារបស់ខ្លួនផ្ទាល់អោយបានល្អប្រសើរ។ ៤-ការគោរពទិស **ខាងជើង** មានន័យថា អ្នកគួររាប់អានសណ្តានញាត្តិមិត្ត ដែលជាសាច់សារលោហិតទាំងឡាយរបស់អ្នក កុំអោយបែកបាក់អោយសោះ។ ៥-ការគោរពទៅ **ខាងលើ** មានន័យថា ឪពុកអ្នកចង់អោយអ្នកគោរព ប្រតិបត្តិអ្នកកាន់សីលទាំងឡាយដូច

www.elibraryofcambodia.org

ជា សមណៈសង្ឃ យាយជី តាជី ពួកព្រាហ្មណ៍ ព្រមទាំង **ព្រះអរហន្ត** គ្រប់ៗអង្គ ទុកដូចជាព្រះសម្រាប់អ្នក ។ ៦-ការគោរពមក **ក្រោម** មានន័យថាអោយរូបអ្នក មានចិត្តមេត្តាគ្រប់យ៉ាងនៅក្នុងជីវិត មិនថាចំពោះមនុស្សឬសត្វតូចធំណាឡើយ ។ រីឯការបាចគ្រាប់ធញ្ញជាតិគឺជាភារៈកិច្ច ដែលអ្នកត្រូវតែធ្វើការប្រតិបត្តិលើប្រការ ទាំង ៦ នេះឯង ។ ឪពុកអ្នកប្រកបដោយឆន្ទៈចិត្តធម៌ ទើបគាត់មានពាក្យផ្តាំផ្ញើ បែបនេះ តែអត្ថន័យនោះវែងឆ្ងាយពេក គាត់អាចផ្តាំតែប៉ុន្មានម៉ាត់ប៉ុណ្ណឹង អ្នក អាចធ្វើការត្រិះរិះពិចារណាបាន ដើម្បីរារាំងអំពើបាបទាំងឡាយ មិនអោយបៀត បៀនដល់រូបអ្នកនាពេលអនាគត!" ។ ចៅមាណពក្រោយពីបានស្តាប់ហើយ មាន ចិត្តរំភើបរីករាយណាស់ នាយក្រាបសំពះគោរពដឹងគុណដោយស្មោះអស់ពីដួងចិត្ត ចំពោះ **ព្រះពុទ្ធ** ជាម្ចាស់ដែលទ្រង់បានបង្ហាញនូវការ **ប្រតិបត្តិទាំង ៦** យ៉ាង ប្រពៃដល់ខ្លួន ។ បន្ទាប់មក **ព្រះពុទ្ធ** ទ្រង់សម្តែងធម៌ប្រោសចៅមាណពនោះ ដោយប្រទាននាមថា **សុជាត** (Sujata) ក្នុងន័យអោយស្វែងយល់នូវប្រការ ដែលបុគ្គលនិមួយៗរមែងប្រព្រឹត្តដោយខ្លួនឯង និងប្រព្រឹត្តទៅអ្នកដ៏ទៃ គប្បី អោយមានសេចក្តីសុខ សេចក្តីចម្រើនល្អប្រសើរ ដល់ជនទាំងឡាយផងទាំងពួង ។ ទ្រង់បានបង្ហាញនូវប្រការជាច្រើនទៀតដូចជា: ត្រូវជៀសវាងអោយបាននូវអំពើ ទុច្ចរិតទាំងឡាយ មិនអោយលួច ឆក់ ប្លន់ទ្រព្យសម្បត្តិគេ កុំសម្លាប់ជីវិតអ្នកដ៏ទៃ និងកុំគប្បីប្រព្រឹត្តនូវគ្រឿងញៀន គ្រឿងស្រវឹងជាដើម ចុងបញ្ចប់ព្រះអង្គទ្រង់ អោយដំបូន្មានអំពី <u>**អាជីពចិញ្ចឹមជីវិត**</u> ការរកទទួលទានដោយកម្លាំងកាយសុច្ចរិត យុត្តិធម៌ទៀងត្រង់ បើមានទ្រព្យធនសមប្រកបហើយ ត្រូវចេះថែទាំទុកដាក់ អោយបានល្អ គឺទុកខ្លះសម្រាប់ចិញ្ចឹមគ្រួសារ ទុកខ្លះធ្វើជាទុនបន្ត ទុកខ្លះជាជំនួយ ជួយដល់ជនក្រីក្រកំសត់ទុរគតិ ហើយចុងក្រោយ ត្រូវមានបម្រុងទុកសម្រាប់

www.elibraryofcambodia.org

ពេលមានអាសន្នយប់ថ្ងៃដោយប្រការណាមួយ ។ ចៅ **សុជាត** ត្រងត្រាប់ស្តាប់ដំបូន្មានប្រៀនប្រដៅដោយមេត្តាធម៌ពី **ព្រះពុទ្ធ** ជាម្ចាស់ដោយយកចិត្តទុកដាក់និងដោយក្តីរីករាយឥតឧបមា ដោយប្តេជ្ញាក្នុងចិត្តថា ត្រូវតែប្រតិបត្តិគ្រប់ឱវាទទាំងអស់ គ្មានអោយចន្លោះមួយណាឡើយ ហើយក៏សុំខ្លួនជាឧបាសករបស់ព្រះពុទ្ធសាសនាចាប់តាំងពីពេលនោះមក ។

www.elibraryofcambodia.org

# វគ្គទី៣៦

# ព្រះសារីបុត្រ និងព្រះមោគ្គលាន

# (Sariputa and Maudgalyayana)



(ស្រង់ចេញពីវត្តសំរោងអណ្ដែត)

**ព្រះសារីបុត្រ** និង **ព្រះមោគ្គលាន** ជាអគ្គសាវ័ក (Senior Disciples) ឆ្វេងស្ដាំរបស់ **ព្រះពុទ្ធ** ជាម្ចាស់។បើក្នុងសម័យនេះ គេហៅថា គ្រូសូត្រឆ្វេង គ្រូសូត្រស្ដាំរបស់ចៅអធិការវត្ត។ **ព្រះសារីបុត្រ** (Sariputa) ជាអគ្គសាវ័កស្ដាំ ចំណែកឯ **ព្រះមោគ្គលាន** (Maudgalyayana) ជាអគ្គសាវ័កឆ្វេង។ នៅក្នុងគម្ពីរ **សុត្តន្តបិដក** (the Sutre) មានសរសេររឿងនិទានពីប្រវត្តិអគ្គ សាវ័កទាំងពីរនេះដូចតទៅៈ **ព្រះសារីបុត្រ** កាល មិនទាន់បួសមានឈ្មោះថា **ឧបតិស្សៈ** (Upatisya) ឯ **ព្រះមោគ្គលាន** កាលមិនទាន់បួសឈ្មោះ **កោលិតៈ** (Kolita)។ កាលក្នុងសម័យនោះ លោកទាំងពីរជាមិត្តសម្លាញ់នឹងគ្នា បានមកចូលសិក្សាក្នុងសាលារៀនមួយក្នុង **ក្រុងរាជគ្រឹះ** ដោយមានគ្រូយ៉ាងល្បីម្នាក់ឈ្មោះ **សញ្ជយ** (Samjayan) ជាអ្នកបង្រៀននៅទីនោះ។ (បើតាមសៀវភៅ Ancient India ដែលមាននៅក្នុងក្រុង Madhya Pradesh ប្រទេសឥណ្ឌានោះ បានសរសេររឿងនិទាន **ព្រះពុទ្ធ** ថា សាលារៀននៅទីនោះគឺជាមហាវិទ្យាល័យក្នុងរាជធានី **រាជគ្រឹះ** ឯគ្រូ **សញ្ជាយ** មានកម្រិត

www.elibraryofcambodia.org

វិជ្ជាខ្ពង់ខ្ពស់ តែមុខវិជ្ជាភាគច្រើន ច្រើនតែលិទ្ធិសាសនា **ធម្មបទ** មិនមានមុខវិជ្ជាឯកទេសឡើយ ។

**ឧបតិស្សៈ** និង **កោលិតៈ** ជាសិស្សរៀនពូកែជាងគេបង្អស់ ក្នុងចំណោមសិស្សជាង ២០០ នាក់នៅក្នុងសាលារៀននោះ តែសេចក្ដីត្រូវការលើមុខវិជ្ជាសិក្សាមិនគ្រប់គ្រាន់ចំពោះសិស្សទាំងពីរនេះឡើយ ដូច្នេះសិស្សទាំងពីរតែងព្យាយាមស្វែងរក **ឧត្តរៈធម៌** (Super Dharma) និង **សច្ចៈធម៌** (Truth) ដែលជាមាគ៌ាភ្លឺថ្លា (Lightened path) ឆ្លុះបញ្ចាំងចូលដល់ផ្លូវចិត្តបែបនេះហើយ ដែលធ្វើអោយមិត្តទាំងពីរបានសន្យាព្រមព្រៀងគ្នាថា ក្នុងចំណោមពួកគេទាំងពីរនាក់ទោះជាអ្នកណាមួយក៏ដោយ អោយតែរកឃើញមុននូវធម៌វិសេសទាំងពីរ ត្រូវតែអោយដំណឹងគ្នាទៅវិញទៅមក រីឯការស្វែងរកអាស្រ័យដោយផលបុណ្យនិស្ស័យរៀងៗខ្លួន ។

នៅថ្ងៃមួយ ពេលព្រឹកព្រាងពេញពន្លឺ សព្វសត្វនិករចេញចរឆ្វេចឆ្វាចមនុស្សម្នាចាកចេញពីជម្រកទៅប្រកបកិច្ចការតាមមុខរបររៀងៗខ្លួន ធ្វើអោយបរិយាកាសមានភាពអ៊ូអរពេញក្រុង **រាជគ្រឹះ** ។ នៅតាមដងវិថីមួយនៃជាយក្រុង **ឧបតិស្សៈ** ពេលដែលកំពុងធ្វើដំណើរ ក៏ប្រទះឃើញសាមណេរមួយអង្គដែលកំពុងនិមន្តបិណ្ឌបាត្រ ព្រះសង្ឃអង្គនោះមានលក្ខណៈសម្បត្តិចរិយាស្រគត់ស្រគំរាបសា ដំណើរមួយៗ សមប្រកបដោយសីល និងកិរិយាយ៉ាងប្រពៃ លក្ខណៈទាំងនេះហើយដែលធ្វើអោយ **ឧបតិស្សៈ** មានការចាប់អារម្មណ៍យ៉ាងខ្លាំង ដោយគិតថាសង្ឃអង្គនេះប្រាកដជាចេះ **ឧត្តរៈធម៌** និង **សច្ចៈធម៌** ដែលខ្លួនកំពុងតាមរកនោះហើយ គិតដូច្នេះ **ឧបតិស្សៈ** ក៏លបធ្វើដំណើរតាមពីក្រោយសង្ឃអង្គនោះ ជាបរិវេណព្រះសង្ឃអង្គនោះក៏ចេះតែនិមន្តបិណ្ឌបាត្រពីកន្លែងមួយទៅកន្លែងមួយទៀត រហូត

www.elibraryofcambodia.org

លុះត្រាតែចប់ការបិណ្ឌបាត្រ ត្រូវត្រលប់ទៅវត្តវិញ ទើប **ឧបតិស្សៈ** ក៏ដើរតំរង់ចូលទៅគោរព ព្រមទាំងសាកសួរទៅព្រះសង្ឃអង្គនោះតាមដំណើរថា: "ខ្ញុំព្រះករុណាសូមក្រាបប្រតិបត្តិ! សុំសួរដល់ព្រះថេរផង តាមលក្ខណៈសម្បត្តិព្រះអង្គពោរពេញដោយចរិយាប្រពៃណាស់! តើព្រះអង្គបានត្រងត្រាប់ស្តាប់តាមគ្រូអាចារ្យណា? ហើយព្រះគ្រូព្រះអង្គបានបង្រៀនអ្វីខ្លះ? តើព្រះធម៌អ្វីទៅដែលប្រកប ដូចដែលព្រះថេរទ្រង់បានបង្ហាញនូវចរិយាប្រពៃនេះ! ខ្ញុំករុណាចង់ដឹងបន្ថែមណាស់ សូមព្រះថេរមេត្តាប្រាប់ផង!"។ ព្រះសង្ឃអង្គនោះ កាលបើបានសណ្តាប់ហើយ ក៏មានចិត្តសទ្ធាមិនលាក់លៀមអ្វីឡើយ ទ្រង់បានបរិយាយដោយព្រះទ័យសោមនស្សតបទៅវិញថា: "ម្នាលឧបាសកដ៏ប្រពៃ! អ្នកចង់ដឹងនេះជាការប្រសើរហើយ ចាំអាត្មានឹងរ៉ាយរាប់អោយបានដឹងដូចតទៅ: ព្រះបរមគ្រូរបស់អាត្មា ទ្រង់ព្រះនាម **សមណគោត្តម** (Gautama Buddha) ព្រះអង្គជា **ព្រះបរមគ្រូ** ដ៏អស្ចារ្យដែលយាងមកពីត្រកូល **សក្យ** (Sakya) បានលះបង់រាជ្យទ្រព្យក្នុងនគរមកប្រតិបត្តិធម៌ជាគោលដៅនៃជីវិតព្រះអង្គ! អាត្មាភាពព្រះនាម **អស្សជិ** (Asvajit) ជាសិស្សក្នុងចំណោមសិស្សរាប់ពាន់របស់ព្រះអង្គ!"។ ចំណុចរ៉ាយរ៉ាប់ទាំងនេះមិនបានធ្វើអោយ **ឧបតិស្សៈ** អស់ចិត្តឡើយ គាត់ចង់ដឹងនូវលក្ខណៈធម៌ដែលភិក្ខុ **អស្សជិ** បានរៀនចេះដឹងសមប្រកបដោយចរិយាធម៌បែបនេះ ទើបគាត់សួរបន្តទៀតទៅព្រះភិក្ខុ **អស្សជិ** ជាថ្មីថា: "បពិត្រព្រះថេរដ៏ឧត្តម! បើព្រះអង្គមិនយល់ទាស់ទេ សូមព្រះអង្គជួយបកស្រាយបន្ថែមនូវធម៌ ដែលព្រះអង្គបានសិក្សាពីព្រះបរមគ្រូរបស់ព្រះអង្គ! តើមានន័យយ៉ាងដូចម្តេចទៅ? ខ្ញុំករុណាចង់ដឹងចំណុចនោះណាស់"។ ភិក្ខុ **អស្សជិ** នៅតែស្ថិតក្នុងព្រះទ័យសោមនស្សដដែលបានតបសំនួរបញ្ជាក់ចម្លល់ជាថ្មីថា: "ម្នាលឧបាសកដ៏ប្រពៃ! ព្រះធម៌ដែល**ព្រះពុទ្ធ**

www.elibraryofcambodia.org

**បរមគ្រូ** ទ្រង់ប្រៀនប្រដៅនោះគឺជា **អមតធម៌** (Immortal Dharma) ធម៌មិនចេះសាបសូន្យ ពេលដែលព្រះអង្គបានត្រាស់ដឹងនូវសាម្មាសម្ពោធិញ្ញាណដោយព្រះអង្គឯង ធម៌នេះក៏បានបង្ហាញដល់សត្វលោកនូវ **ទុក្ខមហាវិសាល** គឺជាការ **កើត ស្លាប់** ក្នុងវាលវដ្តសង្សា មានតែ **ផ្លូវនិព្វាន** ទើបបំបាត់ទុក្ខទាំងហ្នឹងបាន! ហើយដើម្បីដល់ **ព្រះនិព្វាន** បុគ្គលត្រូវស្វែងយល់អោយច្បាស់នូវ **ចរិយាធម៌ គុណធម៌ សច្ចៈធម៌** ដែលជាសភាវៈកើតឡើងពីហេតុ និងបច្ច័យ (motive) ហើយត្រូវជៀសអោយបាននូវកម្មលោកិយ៍ ដែលនាំមកមិនអោយសម្រេចនូវហេតុផលទាំងឡាយ! អាត្មាចាកចេញពីមាតុភូមិមកសិក្សាប្រតិបត្តិធម៌នឹង **ព្រះពុទ្ធ** ប៉ុន្តែព្រះធម៌ព្រះអង្គមានច្រើនអនេក អាត្មាសិក្សាមិនទាន់បានជ្រៅជ្រះនៅឡើយទេ បើឧបាសកចង់ច្បាស់ទៅទៀត សូមទៅជួបនឹង **ព្រះបរមគ្រូ** ជាម្ចាស់ចុះ!"។ ការរៀបរាប់មកទាំងនេះ ធ្វើអោយ **ឧបតិស្សៈ** ភ្លឺច្បាស់យ៉ាងច្រើនចំណែកភិក្ខុ **អស្សជី** ក៏បង្ហាញផ្លូវទៅកាន់វត្ត **វេឡុវ័ន** ដែលជាកន្លែង **ព្រះបរមសាស្តា** គង់នៅ រួចក៏ចម្រើនពរលា **ឧបតិស្សៈ** និមន្តចេញទៅ។

**ឧបតិស្សៈ** ក្រោយពីដឹងបែបនេះហើយក៏រូតរះម្នីម្នា ស្កាត់ទៅជួបមិត្ត **កោលិតៈ** ដើម្បីប្រាប់នូវរឿងទាំងប៉ុន្មាន អោយមិត្តសំឡាញ់បានដឹង។ ក្រោយពីអ្នកទាំងពីរបានជួបគ្នាហើយ **កោលិតៈ** ក៏មានចិត្តត្រេកអរ និងអន្ទះសាជាខ្លាំង បន្ទាប់មកអ្នកទាំងពីរក៏នាំគ្នារូតរះធ្វើដំណើរទៅកាន់វត្ត **វេឡុវ័ន** ដើម្បីបានជួប **ព្រះពុទ្ធ** ជាម្ចាស់ អាលនឹងស្រាយពីបំណងដែលពួកខ្លួនចង់បានជាយូរមកហើយ។ ក្រោយបន្ទាប់មក ពួកគាត់ក៏បានជួបនិង **ព្រះពុទ្ធ** ជាម្ចាស់សមដូចបំណង។ **ព្រះបរមសាស្តា** ទ្រង់ស្វែងយល់ពីឧបនិស្ស័យនៃអ្នកទាំងពីរ នឹងត្រូវបានត្រាស់ដឹងជាអគ្គសាវ័កនៅថ្ងៃអនាគតជាមិនខាន ព្រះអង្គទ្រង់ក៏អនុញ្ញាតិអោយអ្នកទាំង

www.elibraryofcambodia.org

ពីរបួសជាសាមណេរ: ហើយនៅសិក្សាប្រតិបត្តិធម៌ជាមួយព្រះអង្គតរៀងមក។ ដោយសេចក្តីព្យាយាមត្រងត្រាប់ប្រតិបត្តិធម៌បានគ្រប់ប្រការ និងដោយការសង្វាតរៀនសូត្រ មិនយូរប៉ុន្មានភិក្ខុ **ឧបតិស្ស:** និងភិក្ខុ **កោលិត:** ក៏បានស្វែងយល់ និងជ្រួតជ្រាបគ្រប់ព្រះធម៌ពី **ព្រះពុទ្ធ** ជាម្ចាស់ ហើយបានត្រាស់ដឹងជាព្រះអរហន្ត និងក្លាយជាព្រះអគ្គសាវ័កឆ្វេងស្តាំរបស់ **ព្រះពុទ្ធ** ហើយប្រែព្រះនាមថា **ព្រះសារីបុត្រ** និង **ព្រះមោគ្គលាន**។

**ព្រះសារីបុត្រ** ទ្រង់មានបញ្ញា ជាជំនួយ ការផ្នែកផ្លូវលោក និងផ្លូវធម៌ ឯ **ព្រះមោគ្គលាន** ទ្រង់មានបញ្ញារកឃើញផ្លូវធម៌ បែកចេញជាវិជ្ជាត្រៃវេទ Magical formulas តាមរឿង និទានខ្លះ ព្រះអង្គអាចនិមន្តទៅដល់ស្ថានត្រៃភព (the three domains of existence) គឺជាស្ថានទាំង ៣។ ព្រះនាមនៃព្រះអគ្គសាវ័កទាំង ពីរ បានលេចឮល្បីល្បាញគ្រប់ទិសទីនៅក្នុងសម័យពុទ្ធកាល។



ព្រះមោគ្គលាន និងព្រះសារីបុត្រ ( ស្រង់ចេញពី Internet )

www.elibraryofcambodia.org

# វគ្គទី៣៧
# ចតុរង្គសន្និបាត
# (Four-Principle Conference)



មហាចតុរង្គសន្និបាត ព្រះសង្ឃទាំង១២៥០អង្គ
( ស្រង់ចេញពី Internet )

ក្នុងសម័យដែល **ព្រះពុទ្ធ** ទ្រង់គង់នៅវត្ត **វេឡុវ័ន** នោះ ក្រោយពីព្រះអង្គបានសាវ័កយ៉ាងច្រើនរាប់ពាន់អង្គ ហើយមហាសន្និបាតសង្ឃមួយ បានត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃ ១៥ កើត ខែមាឃ ឆ្នាំរកា គឺជាថ្ងៃឧបទ្ទហេតុដ៏អស្ចារ្យមួយកើតឡើង គឺនៅថ្ងៃនោះស្រាប់តែមានភិក្ខុចំនួន **១២៥០** អង្គដែលគង់ផ្សព្វផ្សាយធម៌នៅកន្លែងផ្សេងៗពីគ្នា បាននិមន្តមកចូលរួមព្រមគ្នាទាំងអស់នៅចំថ្ងៃតែមួយ ដោយមិនបានកំណត់ ឬណាត់គ្នាជាមុនឡើយ ដោយហេតុនេះហើយទើបគេអោយឈ្មោះ **មហាសន្និបាត** នោះថា **<u>ចតុរង្គសន្និបាត</u>** គឺសំដៅលើចំណុចសំខាន់ ៤ យ៉ាង: ១-ភិក្ខុគ្រប់អង្គដែលនិមន្តមកសុទ្ធតែជាព្រះអរហន្ត ២-ព្រះសាវ័កទាំងនោះសុទ្ធតែបានបំបួសផ្ទាល់ដោយ **ព្រះពុទ្ធបរមគ្រូ** ៣-ការនិមន្តមកដល់នៃព្រះសង្ឃសាវ័កទាំង ១២៥០ អង្គ គឺចំថ្ងៃតែមួយព្រមៗគ្នា ៤-ជាថ្ងៃដែល **ព្រះពុទ្ធ** ជាម្ចាស់ទ្រង់សម្តែងធម៌ឱវាទ **បាតិមោក្ខ** (Priciple precepts) គឺជាគោលធម៌យ៉ាងសំខាន់ៗដល់ព្រះសង្ឃសាវ័កទាំងអស់ ដែលមកចូលរួមដូចជា ធម៌បង្ហាញនូវការទូន្មានកិរិយា មិនត្រូវធ្វើអំពើបាបផងទាំងពួង (Not to do any evils) កិរិយាត្រូវបំពេញកុសលគ្រប់ប្រការ (to cultivate good) កិរិយាធ្វើចិត្តអោយផូរផង់ (to

www.elibraryofcambodia.org

purify one's mind) ដោយប្រកាន់នូវ **សុក្រិត្យធម៌** (perfectionment) **ព្រហ្មវិហារធម៌** (Sympathetic) **ចរិយាធម៌** (Attitude Dharma) និងសេចក្តីអត់ឱនទាំងពួង (noble clemencies) ហើយទ្រង់សម្តែងព្រះធម៌ឱវាទជាច្រើនប្រការទៀត ដូចជាធម៌សម្រាប់អប់រំផ្លូវ **កាយ វាចា ចិត្ត** គឺៈ **ដោយផ្លូវកាយ** កុំមានចេតនាបៀតបៀនជីវិតមនុស្សសត្វផងទាំងពួង កុំលួចប្លន់ទ្រព្យសម្បត្តិអ្នកដ៏ទៃ កុំប្រព្រឹត្តខុសក្នុងកាមលោកីយ៍ទាំងឡាយ។ **ដោយផ្លូវវាចា** កុំមានចេតនាពោលពាក្យកុហក ញុះញង់ប្រមាទមើលងាយ ប្រើសំដីអសប្បុរស ឬសំដីមុសាផងទាំងឡាយ។ **ឯដោយផ្លូវចិត្ត** គឺកុំមានចិត្តចេតនាកេងប្រវ័ញ្ចពីទ្រព្យអ្នកដ៏ទៃមកធ្វើជារបស់ខ្លួន ហើយកុំមានចិត្តគុំគួនពួនក្នុងផ្លូវយល់ខុស។ ព្រមទាំងធម៌ឱវាទជាច្រើនទៀត ដែលព្រះអង្គបកស្រាយបំភ្លឺទៅកាន់អំពើសេចក្តីល្អគ្រប់យ៉ាង។ ដើម្បីរំលឹកឡើងនូវព្រឹត្តការណ៍ថ្ងៃ **ចតុរង្គសន្និបាត** ដ៏អស្ចារ្យរបស់ **ព្រះបរមសាស្តា** ពុទ្ធសាសនិកជនយើងដែលកាន់ **ថេរវាទ** ក៏បានប្រារព្ធបុណ្យមួយឈ្មោះហៅថា **មាឃបូជា** (Magha Puja's day; Dharma Respection Festival) ជារៀងរាល់ឆ្នាំនៅថ្ងៃទី ១៥ កើត ខែមាឃ មានប្រពៃណីចាប់តាំងពីថ្ងៃសម័យនោះតរៀងមក។ នៅគ្រាបញ្ចប់របស់អង្គសន្និបាត **ព្រះបរមសាស្តា** ទ្រង់បានប្រកាសតែងតាំង **ព្រះសារីបុត្រ** និង **ព្រះមោគ្គល្លាន** ជាព្រះអគ្គសាវ័កឆ្វេង-ស្តាំរបស់ព្រះអង្គនាពេលនោះផងដែរ។



www.elibraryofcambodia.org

# វគ្គទី៣៨

# អង្គុលីមារ (Angulimala)

នៅសម័យពុទ្ធកាល មានរឿងនិទានស្តីពីបុគ្គលសាហាវព្រៃផ្សៃម្នាក់ឈ្មោះ **អង្គុលីមារ**។ គាត់បានកាប់សម្លាប់មនុស្សមិនរើសមុខ កាត់យកតែម្រាមដៃមកធ្វើជាខ្សែកពាក់លំអរខ្លួន។ អង្គុលីមារដើមឡើយជាកូនប្រុសសេដ្ឋី **អនាថបិណ្ឌិក** នៅស្រុក **សាវត្ថី** ជាមនុស្សស្លូតបូតត្រឹមត្រូវ តែដោយលង់ខ្លួន ចង់ក្លាយជាមនុស្សខ្លាំងពូកែតាមការញុះញង់បំពុលស្មារតីពីជនអប្រិយ៍ ដែលមានបំណងឈ្នានីសគាត់ តែគាត់មិនបានដឹងខ្លួន ជឿទុកចិត្តអមិត្រ ខ្វះការពិចារណា ក៏ក្លាយខ្លួនជាឃាតកកាប់សម្លាប់ប្រជារាស្ត្រប្រុសស្រីគ្មានក្តីមេត្តា ដើម្បីយកម្រាមដៃអោយគ្រប់ ១ ពាន់ នឹងក្លាយជាមនុស្សខ្លាំងពូកែលើសគេ។ **អង្គុលីមារ** មានឈ្មោះដើម **អហឹង្សកុមារ** ពេលដែលកុមារនេះកើតឡើង ឪពុកម្តាយបានរកគ្រូទស្សទាយ៍ពីជោគវាសនានៃកុមារ **អហឹង្សៈ**។ គ្រូហោរបានទស្សទាយ៍ថា កុមារនេះពេលធំឡើងពេញវ័យ នឹងក្លាយជាឃាតកកំណាចឃោរឃៅ ដូច្នេះទើបឪពុកម្តាយដាក់ឈ្មោះអោយកូនថា **អហឹង្សកុមារ** ដើម្បីកាត់បន្ថយភាពកំណាចឃោរឃៅរបស់កូន។ **អង្គុលីមារ** បានសម្លាប់មនុស្សកាត់យកតែម្រាមដៃបានចំនួន ៩៩៩ នៅខ្វះមួយទៀត ក៏មកជួបម្តាយបង្កើត តែគាត់មិនស្គាល់ថាជាអ្នកណាឡើយ ក្តី **ឆោតសោ មោហោ** ធ្វើអោយគាត់វិលវល់តែរឿងកាប់សម្លាប់។ នៅពេលនោះ **ព្រះបរមសាស្តា** ទ្រង់និមន្តមកដល់ទីកន្លែងដែល **អង្គុលីមារ** ប្រុងនឹងប្រហារជីវិតម្តាយខ្លួនឯង ព្រះអង្គក៏ទ្រង់ឃាត់ ហើយប្រាប់អោយគាត់លះបង់

www.elibraryofcambodia.org

អំពើសាហាវនេះចោលចេញ តែ **អង្គុលីមារ** នេះមិនស្តាប់ព្រះអង្គឡើយ ថែមទាំងលើកដាវប្រុងប្រហារព្រះអង្គទៀត ។ ដោយអំណាចបុណ្យបារមីរបស់ព្រះអង្គបុគ្គល **អង្គុលីមារ** មិនអាចធ្វើអ្វីប៉ះពាល់ដល់ព្រះកាយព្រះអង្គបានឡើយ ។ **អង្គុលីមារ** ដេញកាប់ **ព្រះពុទ្ធ** អស់ចិត្តមិនបានសម្រេចឯ **ព្រះពុទ្ធ** ព្រះអង្គខំព្យាយាមសម្តែងធម៌ដាស់តឿន ការវង្វេងទាំងឡាយ


អង្គុលីមារដេញកាប់ព្រះអង្គ
‹ ស្រង់ចេញពី Internet ›

ជរះ ចិត្តឃោរឃៅចេញពីរាងកាយរបស់គាត់ ទីបំផុតការវង្វេងទាំងប៉ុន្មាន ក៏វិនាសបាត់បង់អស់ គាត់បានភ្ញាក់ស្មារតី ដឹងខ្លួនក្លាយជាមនុស្សប្រក្រតីឡើងវិញ គឺស្គាល់ខុសស្គាល់ត្រូវ ស្គាល់បុណ្យស្គាល់បាប និងសោកស្តាយជាខ្លាំង នូវអំពើឃោឃៅរបស់គាត់ ដែលបានសាងកន្លងមក ។

ដើម្បីលប់លាងកំហុសរបស់គាត់ **អង្គុលីមារ** បានលុតជង្គង់ លើកដៃសំពះ **ព្រះពុទ្ធ** សុំព្រះអង្គអោយខ្លួនបានបួសរស់ជ្រកក្រោមម្លប់ព្រះពុទ្ធសាសនាព្រះអង្គ ។ **ព្រះពុទ្ធ** ទ្រង់ក៏អនុញ្ញាតិអោយ **អង្គុលីមារ** បានបួសជាភិក្ខុសិក្សារៀនសូត្រគ្រប់ធម៌ឱវាទ កែខ្លួនជាបុគ្គលល្អ ប្រឹងប្រែងប្រតិបត្តិធម៌វិន័យទាំងយប់ទាំងថ្ងៃ មិន ដែលសំចៃពេលមួយវេលាណាឡើយ ។ ថ្ងៃមួយពេលដែលភិក្ខុ **អង្គុលីមារ** និមន្តបិណ្ឌបាត្រតាមដងផ្លូវនៃក្រុង **សាវត្ថី** ត្រូវប្រជារាស្ត្រប្រុសស្រីគប់ដុំថ្មទៅលើរូបគាត់ជាច្រើនដុំ បណ្តាលអោយមានរហូសជាច្រើន


អង្គុលីមារសុំព្រះអង្គបួស
‹ ស្រង់ចេញពី Internet ›

www.elibraryofcambodia.org

កន្លែង ពេលនោះ **ព្រះសាស្តា** ក៏ទ្រង់និមន្តមកឃាត់ដល់រាស្ត្រប្រុសស្រីទាំងនោះ កុំអោយធ្វើអំពើហិង្សាទាំងឡាយ ដែលពុំគប្បីលើភិក្ខុ **អង្គុលីមារ** ព្រះអង្គទ្រង់មានពុទ្ធដិកាថា: "ម្នាលប្រជារាស្ត្រទាំងឡាយ! ចូរកុំធ្វើបាបដល់រូបគាត់អី! ពេលនោះគាត់ជាអ្នកបួស ជាភិក្ខុក្នុងសាសនា **តថាគត** មិនមែនជាបុគ្គល **អង្គុលីមារ** ដូចកាលពីមុននោះទេ! សព្វថ្ងៃនេះ ភិក្ខុអង្គនេះខិតខំរក្សាសីលសព្វយ៉ាងបានល្អប្រសើរណាស់!"។ ស្តាប់ឱវាទ ដូចនេះប្រជារាស្ត្រប្រុសស្រី ក៏ឈប់មានហិង្សាលើរូបសង្ឃ **អង្គុលីមារ** ទៀត ព្រមទាំងស្វែងយល់គោរពដល់ព្រះសង្ឃនេះវិញ ដូចជាការគោរពព្រះសង្ឃទាំងឡាយដូច្នេះដែរ។ ក្រោយមកភិក្ខុ **អង្គុលីមារ** ក៏បានសម្រេចធម៌ ហើយបានត្រាស់ជា **ព្រះអរហន្ត** ថែមទៀតផង។



សង្ឃអង្គុលីមារបានត្រាស់ដឹងក្លាយជាព្រះអរហន្ត ( ស្រង់ចេញពី Internet )

www.elibraryofcambodia.org

# វគ្គទី៣៩

# ទ្រង់និមន្តចូលមាតុភូមិ

## (Returning of Buddha to Kapilavastu)



ព្រះបាទសុទ្ធោទនៈ និងព្រះនាងបជាបតីមក ចាំងព្រះអង្គចូលវាំង (from Internet)

ការសំដែងព្រះធម៌ និងទិវាចតុរង្គសន្និបាត សង្ឃបានកន្លងផុត បានធ្វើអោយព្រះនាម **ព្រះពុទ្ធ** ជាម្ចាស់ល្បីរន្ទឺគ្រប់ទីកន្លែង ពីមួយទៅមួយ រហូតដល់នគរ **កបិលពស្តុ**(Kapilavastu) ដែលជាមាតុនគររបស់ព្រះអង្គ។ ព្រះរាជាព្រះបាទ **សុទ្ធោទនៈ** ដែលជាព្រះបិតាទ្រង់ជ្រាបថា រាជបុត្រាព្រះអង្គ ទ្រង់បានត្រាស់ជា **ព្រះពុទ្ធ** ហើយ កំពុងតែបំពេញភារកិច្ចផ្សព្វផ្សាយព្រះធម៌គ្រប់ទីកន្លែង និងទ្រង់ជ្រាបថា ទ្រង់កំពុងស្នាក់អាស្រ័យនៅវត្ត **វេឡុវ័ន** ក្នុង ក្រុង **រាជគ្រឹះ**។ ព្រះបិតាទ្រង់នឹករលឹកដល់រាជបុត្រាជាពន់ពេក ដោយពេលវេលាបែកគ្នាបានកន្លងមកជាច្រើនឆ្នាំ ឥឡូវព្រះអង្គទ្រង់យល់ថា រាជបុត្របានសម្រេចព្រះធម៌ដូចបំណង ហើយម្យ៉ាងទៀត ទ្រង់ក៏ចង់ឃើញបុត្រាជា **ព្រះពុទ្ធ** ផងដែរ ក៏មានព្រះតម្រិះ ត្រូវតែនិមន្តព្រះពុទ្ធអោយចូលមកនគរវិញ ទ្រង់បានស្វែងយល់ចាត់អោយមន្ត្រីម្នាក់ឈ្មោះ **កាឡុទាយី** (Kaladayin) ដែលធ្លាប់រត់លេងជាមួយគ្នាកាលពីវ័យកុមារ អោយទៅនិមន្ត **ព្រះពុទ្ធ** ដើម្បីចូលរាជបុរី **កបិលពស្តុ** មាតុកំណើតវិញ។ មន្ត្រី **កាឡុទាយី**

www.elibraryofcambodia.org

ទទួលរាជបញ្ជាពីព្រះរាជា ក៏នាំគ្នីគ្នាជាបរិវារធ្វើដំណើរទៅកាន់នគរ **រាជគ្រឹះ** ភ្លាម ដោយមិនបង្អង់យូរឡើយ ។ ក្បួនដំណើរក៏បានទៅដល់នគរ **រាជគ្រឹះ** ដោយ សុវត្ថិភាព ហើយក៏បានជួបនឹង **ព្រះបរមសាស្តា** ដូចបំណង ។

មន្ត្រី **កាឡុទាយី** ក៏នាំគ្នាចូលទៅគាល់ **ព្រះពុទ្ធ** ដោយផ្ទាល់នៅក្នុងវត្ត **វេឡុវ័ន** ហើយបានទូលព្រះអង្គតាមរាជសេចក្តីថា: "បពិត្រព្រះមហាថេរដ៏មាន បុណ្យ! ព្រះបិតាព្រះអង្គទ្រង់មានព្រះទ័យចង់ឃើញព្រះអង្គជា **ព្រះពុទ្ធគោត្តម** នាពេលព្រះរាជាជាបិតាទ្រង់នៅមានព្រះជន្មនៅឡើយ និងដើម្បីជារាជកិត្តិយស ថ្វាយដល់រាជវង្សផង បានចាត់អោយទូលបង្គំព្រះករុណាមកនិមន្តព្រះអង្គចូល ព្រះនគរ! សូមព្រះមហាថេរប្រទានទូវក្តីសណ្តោសផងចុះព្រះអង្គ!" ។

**ព្រះបរមសាស្តា** ទ្រង់សណ្តាប់ហើយ ក៏យល់ព្រមតាមរាជនិមន្ត ព្រះអង្គ មានពុទ្ធដិកាទៅមន្ត្រី **កាឡុទាយី** វិញ ដោយក្តីសង្ឃឹមថា: "ម្នាល **ទាយី** ដ៏ប្រ ពៃ! អ្នកនៅតែមានភក្តីនឹងមហាក្សត្រដូចកាលវ័យនៅកុមារដដែល! មិនថ្វីទេ **តថាគត** នឹងធ្វើសេចក្តីសង្គ្រោះដល់ញាត្តិជាមិនខាន ចូរអ្នកទៅទូលព្រះបិតាវិញ ចុះ!" ។ មន្ត្រី **កាឡុទាយី** ក៏មានចិត្តត្រេកអរព្រោះនិមន្ត **ព្រះពុទ្ធ** បានដូចបំ ណង គាត់ក៏ថ្វាយបង្គំលា **ព្រះភគវា** ត្រឡប់ចូលនគរវិញ ឯព្រះបរមគ្រូក៏មាន ពុទ្ធដិកាទៅដល់សង្ឃសាវ័កទាំងអស់អោយរៀបចំខ្លួន ដើម្បីនិមន្តទៅកាន់នគរ **កបិលពស្តុ** ទាន់រដូវល្អ អាកាសធាតុអំណោយទាន ។

នៅសាយ័ណ្ហនាគិម្ហូនរដូវ **ព្រះបរមសាស្តា** និងសង្ឃសាវ័កទាំងអស់ក៏ និមន្តមកដល់ក្រុង **កបិលពស្តុ** នាពេលព្រលប់ ព្រះអង្គ និងសាវ័កក៏គង់ស្នាក់នៅ ក្នុងសួនមួយឈ្មោះ **និគ្រោធ** (Nyagradha park) ដែលមហាក្សត្រកសាងឡើង ធ្វើជាបរិស្ថានទុកសម្រាប់គោរពសាសនា ពេលនោះគឺទុកសម្រាប់ **ព្រះពុទ្ធ** និង

www.elibraryofcambodia.org

សាវ័កគង់ស្ងាក់នៅបណ្តោះអាសន្នជំនួសវិត្ត ។ ពេលព្រឹកព្រាងឡើងកាលណា **ព្រះសាស្តា** ទ្រង់ធ្វើកិច្ចជាប្រក្រតី គឺចេញបិណ្ឌបាត្រដោយមានសង្ឃសាវ័កមួយចំនួននិមន្តតាមពីក្រោយទ្រង់ កាត់តាមដងវិថីនានាក្នុងក្រុង **កបិលព័ស្តុ** ឯមហាជនកាលបើបានឃើញជួរសាមណេះសង្ឃនិមន្តដូច្នេះ ក៏នាំគ្នាតាមសម្លឹងមើល ខ្លះទៀតក៏នាំដំណឹងនេះទៅទូលព្រះរាជាក្នុងរាជវាំង ។ ព្រះបាទ **សុទ្ធោទនៈ** កាលបើបានជ្រាប ទ្រង់មានព្រះទ័យសង្វេគដល់បុត្រា ដែលធ្វើដំណើរសុំអាហារពីប្រជារាស្ត្ររបស់ព្រះអង្គបែបនេះ ទ្រង់បានបញ្ជាអោយសេនាអាមាត្យ នាំព្រះអង្គដោយរាជរថទៅកាន់ទីផ្សារដែលមហាជនស្ថិតនៅ ដើម្បីទតដោយផ្ទាល់កន្លែងដែលរាជបុត្រនិមន្តបិណ្ឌបាត្រ ។ នៅពេលព្រះអង្គបានទៅដល់កន្លែងដែល**ព្រះពុទ្ធ** បិណ្ឌបាត្រ ទ្រង់ទតឃើញមហាជន ព្រះអង្គមានសទ្ធាជ្រះថ្លាជឿព្រះពុទ្ធសាសនា បានប្រគេនអាហារ និងបាយពេញបាត្រស្រេចទៅហើយ គាប់ជួនពេលនោះ **ព្រះសាស្តា** ទ្រង់ក្រឡេកឃើញក្បួនសេនាដង្ហែព្រះបិតាមកចំកន្លែងព្រះអង្គ ចំណែកមហាជនជារាស្ត្រកាលបើឃើញក្បួនស្តេច ក៏នាំគ្នាគេចជៀសចេញទៅសងខាងផ្លូវទុកទីធ្លាអោយស្រឡះដើម្បីអោយ **ព្រះពុទ្ធ** និងស្តេចបានជួបគ្នា ។ **ព្រះបាទសុទ្ធោទនៈ** ស្ថិតនៅចំព្រះភក្ត្រ **ព្រះពុទ្ធ** ទ្រង់សម្លឹងរាជបុត្រដោយមិនសប្បាយក្នុងព្រះទ័យទាល់តែសោះ ដោយមានបន្ទូលទៅរកបុត្រាថា: "មើលបុត្រចុះ! បុត្រជាបុត្រមហាក្សត្រ ហេតុម្តេចបានជាមកសុំអាហារពីប្រជារាស្ត្រខ្លួនឯងបែបនេះ! តើអោយបិតាយកមុខទៅទុកឯណា? បុត្ររត់ចេញពីនគរអស់ជាច្រើនឆ្នាំ ពេលត្រឡប់មកវិញបែរជាមកសុំបាយរាស្ត្រ! តើកិត្តិយសរាជវង្សយើងត្រូវអាប់ឱនដល់កម្រិតណា! ឯរឿងស្នងរាជ្យសម្បត្តិ ម្តេចបុត្រមិនគិតគូរសោះអញ្ចឹង!" ។

www.elibraryofcambodia.org



ព្រះអង្គទ្រង់ពន្យល់ព្រះបិតាអំពីការបិណ្ឌបាត( ស្រង់ចេញពីវត្តទឹកថ្លា)

**ព្រះពុទ្ធ** ទ្រង់មានពុទ្ធដិកាដោយព្រះទ័យស្ងប់ស្ងាត់តបទៅបិតាវិញថា: "បពិត្រព្រះបិតាដ៏ចម្រើន! សូមព្រះអង្គខន្តីអភ័យទោសចំពោះទង្វើដែលបុត្រចាកចេញពីនគរ តាមការពិត ការស្វែងរកព្រះធម៌ក្នុងនាមបុព្វជិត ដើម្បីជួយប្រោសសត្វគឺជាទង្វើដ៏មហាសាលមួយ មានតម្លៃជាងរាជសម្បត្តិទៅទៀត! ឥឡូវ **តថាគត** បានសម្រេចព្រះធម៌ដូចបំណង ហើយការប្រតិបត្តិដូចទតឃើញនេះ គឺជាមគ្គផលកុសលបុណ្យដែល **បុព្វបុរសតថាគត** បានអនុវត្តន៍តាំងពីបុរាណមក"។

ពេលនោះព្រះបិតា ក៏ទ្រង់តបវិញថា: "តាំងពីបុរាណមក តើមានស្ដេចសុំទានរាស្ត្រដូចជាបុត្រដែរឬ?"។ **ព្រះសាស្ដា** នៅតែប្រកាន់ព្រះទ័យសន្តិភាពដូចសមុទ្រស្ងប់ដដែល រួចទ្រង់បន្តពុទ្ធដិកាពន្យល់ទៅបិតាវិញថា: "សូមព្រះអង្គទ្រង់ជ្រាបការនិមន្តបិណ្ឌបាត្រនេះ ជាប្រពៃណីនៃ **ព្រះពុទ្ធ** គ្រប់អង្គ ដែលតែងតែប្រតិបត្តិឡើង ដើម្បីគោលបំណងប្រោសមនុស្សគ្រប់រូបអោយកើតមានសទ្ធា! ការមានសទ្ធាជាទានទិព្វប្រោសជីវិតអោយរួចចាកទីក្តីទុក្ខផងទាំងពួង អ្វីដែលព្រះពុទ្ធបុព្វបុរសទ្រង់បានប្រតិបត្តិនោះ ឥឡូវដល់វេន **តថាគត** ក៏ត្រូវប្រតិបត្តិដូច្នេះដែរ!"។ ព្រះបាទ **សុទ្ធោទនៈ** ទ្រង់ស្ដាប់ហេតុផល ដូចនេះហើយព្រះអង្គហាក់មានព្រះទ័យស្រាយកំហឹងបន្តិច ដោយទ្រង់ស្ថិតក្នុងព្រះតម្រិះឃើញព្រះបិតាមហារាជទ្រង់យល់នូវការបកស្រាយរបស់ព្រះអង្គ **ព្រះពុទ្ធ** ក៏ចាប់ផ្ដើមសម្ដែងធម៌

www.elibraryofcambodia.org

ដែលជាធម៌មិមានគោលដៅសំខាន់បន្ថែម ក្នុងការស្រាយកំហឹងព្រះបិតាអោយរសាយចេញអស់ស្រឡះ ។

ចំណែកព្រះបាទ **សុទ្ធោទនះ** ក្រោយពីបានស្តាប់គោលការធម៌សំខាន់ៗ ដែល **ព្រះពុទ្ធ** បានសម្តែងចេញជាច្រើនមក ព្រះអង្គក៏រលត់បាត់អស់កំហឹងទាំងប៉ុន្មានដែលមានពីមុនមក ហើយក៏ស្ថិតនៅក្នុងព្រះតម្រិះទោរទន់ដោយគុណធម៌មកដាក់ក្នុងព្រះទ័យវិញ ដោយមានការគោរពចំពោះពុទ្ធដិកាទាំងឡាយ ។ ព្រះរាជាបានផ្តិព្រះហត្ថាទាំងទ្វេ ទទួលបាត្រពី **ព្រះពុទ្ធ** បុត្រប្រកបដោយឥរិយាបទទន់ភ្លន់ ព្រមទាំងមានបន្ទូលឡើងថា: "បពិត្រព្រះពុទ្ធជាម្ចាស់! ឥឡូវសូមព្រះអង្គព្រមទាំងសាវ័កមេត្តាទទួលសេចក្តីមេត្តាករុណាពីខ្ញុំព្រះករុណា! សូមនិមន្តព្រះអង្គនិងសាវ័កចូលក្នុងវាំង ដើម្បីសុំទទួលការប្រោសដោយព្រះធម៌របស់ព្រះអង្គដល់ញាត្តិទាំងឡាយ ។ **ព្រះបរមសាស្តា** ទ្រង់ញញឹមដោយពុទ្ធដិកាតបថា: "មិនថ្វីទេ! មហារាជ! តថាគតនឹងបំពេញសព្វបែបយ៉ាង តាមការប្រាថ្នារបស់ព្រះញាត្តិវង្ស ចូរចម្រើន! ចូរចម្រើន!" ។ ពពកខ្មៅបានរំកិលផុត ព្រះអាទិត្យបានរះភ្លឺថ្លាលើវេហាស៍ កិច្ចល្អសព្វប្រការត្រឡប់មកកាន់នគរ **កបិលពស្តុ** វិញ **ព្រះបរមសាស្តា** និងសាវ័ក ក៏ទ្រង់និមន្តចូលព្រះបរមរាជវាំង ក្រោមព្រះទ័យរីករាយពីព្រះញាត្តិវង្ស ។

www.elibraryofcambodia.org

# វគ្គទី៤០

# ពិម្ពាពិលាប (Sobbing of Gautama's wife)



ព្រះអង្គសំដែងធម្មទេសនា
ប្រោសព្រះញាតិវង្ស

**ព្រះបាទសុទ្ធោទនៈ** បានបញ្ជាអោយសេនាមន្ត្រីក្នុងវាំង រៀបចំអាសនៈបល្ល័ង្ក សម្រាប់អោយ **ព្រះពុទ្ធ** គង់សម្តែង **ធម្មទេសនា** ក្នុងកាលវេលាដែលទ្រង់ត្រូវបំពេញធម៌ប្រោសព្រះញាតិវង្ស ។ ក្រោយពីចាត់ចែងជាស្ថាពរមក មហារាជ ព្រះញាតិវង្ស សម្តេចគ្រូជាព្រាហ្មណ៍ សេនាមន្ត្រីរាជការប្រជាប្រុសស្រី ព្រះមាតាចិញ្ចឹម **បជាបតី** និងស្រីស្នំក្រមការព្រះនាងបានមកជួបជុំគ្នា រង់ចាំស្តាប់ **ធម៌ទេសនា** លើកលែងតែព្រះនាង **ពិម្ពា** មិនមានវត្តមាននៅទីនោះឡើយ ។ **ព្រះបាទសុទ្ធោទនៈ** ប្រុងចាត់អោយស្រីស្នំទៅយាងព្រះនាងមកដែរ ដើម្បីចូលរួមពិធីស្តាប់ធម្មទេសនា តែ **ព្រះបរមសាស្តា** មានពុទ្ធដិកាថា មិនបាច់យាងព្រះនាងមកទេ ទោះបីជាយាងព្រះនាងមកយ៉ាងណា ក៏ទ្រង់មិនមកដែរ ចាំដល់ពេលព្រះអង្គសម្តែងធម៌នៅទីនេះចប់ ទ្រង់នឹងនិមន្តផ្ទាល់ទៅរកព្រះនាងព្រោះថា: បុព្វេសន្និវាស! ព្រឹត្តការណ៍ថ្ងៃនេះធ្វើអោយព្រះនាងសោកសៅក្នុងហឫទ័យ រហូតដល់ក្ស័យជីវិតមិនខាន ដូច្នេះព្រះអង្គត្រូវតែនិមន្តទៅជួបព្រះនាងដោយផ្ទាល់នៅទីដំណាក់នោះតែម្តង ទើបជាការប្រសើរ ។

ការសម្តែងធម៌ទេសនាដើម្បីប្រោសដល់ព្រះញាតិវង្ស និងមនុស្សម្នាផងទាំងឡាយក្នុងព្រះរាជវាំងបានប្រព្រឹត្តទៅប្រកបដោយសុខសន្តិភាព គ្មានមន្ទិល

www.elibraryofcambodia.org

និងគ្មានអ្វីដែលនាំអោយរំខាន។ អត្ថន័យព្រះធម៌ទេសនានៅពេលនោះ ទ្រង់សម្តែងពី "**មហាធម្មបាលជាតក**" (Guardian of the Dharma Law and the 550 birth stories, concerning the Gautama's previous lives) គឺរៀបរាប់អំពី ៥៥០ បុព្វជាតិដែលព្រះអង្គបានឆ្លងកាត់ នូវសេចក្តីទុក្ខផងទាំងពួងរហូតទីបំផុតទ្រង់បានបំពេញបារមីគ្រប់ប្រការ ហើយបានទទួលអានិសង្ស (លទ្ធផលល្អ) ដល់ជាតិនេះ ទ្រង់បានសម្រេចត្រាស់ជា **ព្រះពុទ្ធ** បានរកឃើញ **អរិយសច្ចៈ** ដែលទ្រង់ត្រាស់ដឹង ក្នុងនោះដែរមាននិទានពន្យល់ពី **អមតធម៌** ដែលមិនចេះសាបសូន្យនៅលើលោក ព្រមទាំងមកស្រាយនូវព្រះធម៌ទាំងឡាយ សម្រាប់រក្សាចិត្តអោយស្ថិតនៅលើផ្លូវ **សច្ចៈធម៌ គុណធម៌** ជាក្បួនច្បាប់ដោយក្តី **មេត្តាករុណា** ហើយនៅចុងបញ្ចប់ ទ្រង់សម្តែងធម៌ទេសនាពី **ភត្តានុមោទនា** (Bhatta anumodana; Saying thank you by a Buddhist monk we he is given food) ស្តីពីការដឹងគុណសព្វប្រការពីសមណៈគ្រប់អង្គ ដែលបានទទួលចំណីអាហារ។ អ្នកបានស្តាប់កាលណោះ បានត្រជាក់កើតសទ្ធាក្នុងចិត្ត ហើយទុកព្រះធម៌ជាទីពឹងពាក់ ដោយសុំខ្លួនជាឧបាសកឧបាសិការបស់ **ព្រះបរមសាស្តា** ជារៀងរហូតមក។

ក្រោយពីសម្តែងធម្មទេសនាសព្វគ្រប់ប្រការ ដល់ ព្រះញាតិវង្សរួចហើយ **ព្រះពុទ្ធ** ទ្រង់ក៏បានយាងនិមន្ត ទៅកាន់រាជដំណាក់ព្រះនាង **ពិម្ពា** នាគ្រានោះ។ ព្រះអង្គ ទ្រង់គង់លើអសនៈដ៏សមរម្យ។ ព្រះនាង **ពិម្ពា** ប្រកបដោយទឹកមុខក្រៀមក្រំបាននាំបុត្រា **រាហុល** ដែលកាលនោះទ្រង់មានព្រះជន្ម ៧ វស្សា បានចេញមកជាមួយមាតាមកថ្វាយបង្គំ **ព្រះបរមសាស្តា** ដោយសេចក្តីគោរពទីករលីកក្រៃលែង ពីទឹកព្រះទ័យរបស់ព្រះនាង **ពិម្ពា**។ **ព្រះពុទ្ធ** ទ្រង់យល់ពីទឹក

www.elibraryofcambodia.org



ព្រះអង្គសម្ដែងធម្មទេសនាប្រោស
ពន្យល់ព្រះនាងពិម្ពា
( ស្រង់ចេញពី Internet )

ព្រះទ័យមាតា **រាហុល** ទ្រង់ក៏សម្ដែងការប្រោសដោយធមិតបរិញថា: "ម្នាល ឧបាសិកាដ៏ប្រពៃ! ចូរកាត់ព្រះទ័យអោយបានជ្រះស្រឡះពីរឿងចំណងមនោសញ្ចេត-នានៅគ្រាអតីតកាល! ពេលនេះតថាគតជាអ្នកបួស មិនដូចបុគ្គលពីមុនឡើយ អ្វីៗចូរឧបាសិកាតាំងស្មារតីក្នុងហឫទ័យ ប្រកបដោយការស្ងប់រំងាប់ ជឿតែលើព្រះធមិជាទីពឹងបានហើយ!" ។

បន្ទាប់មកព្រះអង្គទ្រង់សំដែងធម្មទេសនា "**ចន្ទ កិន្នរីជាតក**" (The legendary story said about the female angel name, Kantak Kennnariya) ទ្រង់សណ្ដាប់ហើយ ធ្វើអោយព្រះនាង **ពិម្ពា** ជក់ព្រះទ័យ រួចចាកពីទុក្ខសោកនឹងចំណង់លោកិយ៍ ហើយត្រឡប់ជាទទួលព្រះទ័យយកព្រះធមិជាទីពឹង ព្រមទាំងសម្រេចព្រះទ័យអនុញ្ញាត្តអោយ **រាហុល** បុត្រា ទ្រង់បួសក្នុងគ្រានោះផងដែរ ។





សម្ដេចព្រះមហាសុមេធាធិបតី **ជួន ណាត ជោតញ្ញាណោ** ព្រះសង្ឃរាជគណៈមហានិកាយ
គ.ស ១៨៨៣ - ១៩៦៩ ព.ស ២៤២៧ - ២៥១៣
ព្រះមហាវិរបណ្ឌិតជាតិកម្ពុជា

www.elibraryofcambodia.org

# វគ្គទី៤១
# ព្រះនន្ទ ព្រះរាហុល និងសក្យអង្គទ្រង់បព្វជា
# (Nanda, Rahula and Sakya princes to become disciples)


រាហុលកុមារត្រូវបានបំបួសដោយព្រះសារីបុត្រ (ស្រង់ចេញពី Internet)

**ព្រះរាហុលកុមារ** ត្រូវបានបំបួសដោយ **ព្រះសារីបុត្រ** ដោយព្រះអង្គនៅវ័យក្មេងពេក ទ្រង់មិនបានទទួលជា **សម្បទាភិក្ខុ** ឡើយ គឺបួសត្រឹមជាសាមណេរ (លោកនេន) ប៉ុណ្ណោះ ហើយនេះជាលើកទីមួយមុនគេបង្អស់ ដែលមានសាមណេរក្នុងព្រះពុទ្ធសាសនា។ បន្ទាប់ពីបំបួស **រាហុល** រួចហើយ ទ្រង់ក៏និមន្តទៅប្រាសាទ **ព្រះនន្ទ** (Nanda) ដែលត្រូវជាអនុជ (បិតាជាមួយ មាតាផ្សេងគ្នា)។ **ព្រះពុទ្ធ** ទ្រង់សម្តែងធម៌ **មង្គលកថា** (Vocation for good fortune) នៅទីនោះ ធ្វើអោយ **ព្រះនន្ទ** មានចិត្តចង់បួសដោយមិនរារែកនៅគ្រានោះ។ ក្រោយពីការសម្រេចនូវ **ធម្មទេសនា** ប្រោសដល់ព្រះញាតិវង្សមួយរយៈកន្លងមក **ព្រះពុទ្ធ** និងអង្គសាវ័កក៏និមន្តចេញពីនគរ **កបិលពស្តុ** ទៅកាន់នគរមួយទៀតឈ្មោះ **សាវត្ថី** (Sravati) ហើយទ្រង់គង់នៅក្នុងវត្ត **ជេតពន្ត** (Jetavana Vihara) ជាកន្លែងដែល **អនាថបិណ្ឌិក** សេដ្ឋី (Anathapindika) បិតារបស់អង្គុលីមារបានកសាងថ្វាយប្រគេនព្រះអង្គ ធ្វើវត្តសម្រាប់អោយព្រះអង្គ និងសាវ័កគង់ស្នាក់អាស្រ័យនៅ (សេដ្ឋី **អនាថបិណ្ឌិក** នេះបានជួប **ព្រះពុទ្ធ** កាលព្រះអង្គគង់នៅនគរ **រាជគ្រឹះ** ក្រោយពេលព្រះអង្គ

www.elibraryofcambodia.org



សេដ្ឋីសាងវត្តថ្វាយព្រះអង្គ
(ស្រង់ចេញពីវត្តសំរោងអណ្តែត)

បានប្រទានការប្រោសអោយដល់ព្រះបាទ **ពិម្ពិសាររាជ** រួចមក)។ ក្នុងសម័យកាលដែល **ព្រះបរមសាស្តា** ទ្រង់គង់ នៅក្នុងវត្ត **ជេតពន្ធ** នោះ **ព្រះនន្ទ** ដែលបានបំបួសជាសាមណេរួច ហើយក៏តាមដង្ហែព្រះអង្គមកដែរ នៅតាមផ្លូវស្រាប់តែ **ព្រះនន្ទ** កើតអផ្សុក បំណងចង់សឹក ដោយហេតុមានចិត្តប្រតិព័ទ្ធលើកល្យាណីស្រីជនបទម្នាក់ ដែលមានសម្ផស្សស្រស់ស្អាត។ ពេលនោះ **ព្រះសាស្តា** ទ្រង់ដឹងរឿង ព្រះអង្គក៏ព្យាយាមលួងលោមពន្យល់សព្វយ៉ាងដល់ **ព្រះនន្ទ** ជាអនុជ ទ្រង់សម្តែងធម៌ប្រតិបត្តិ **ព្រហ្មចរិយធម៌** (Rules of moral conduct) ដល់ **ព្រះនន្ទ** គឺដើម្បីអោយ **ព្រះនន្ទ** ប្រតិបត្តិជាមុនសិន ទើបរៀបការបាន។ **ព្រះនន្ទ** ក៏ធ្វើតាមពុទ្ធដិកា តែក្រោយមកពេលដែល **ព្រះនន្ទ** ចេះធម៌នេះ ស្រាប់តែបាត់ចំណង់ក្តីស្នេហា ឈប់មានការស្រឡាញ់លើនារីរូបនោះទៀត មិនត្រឹមតែប៉ុណ្ណោះ ធ្វើអោយ **ព្រះនន្ទ** ស្អប់ខ្ពើមចំពោះកាមលោកីយ៍ទាំងឡាយផងដែរ។ ចំណែករាជវាំងនៃ **សក្យវង្ស** (សាច់ញាតិ) ក្រោយពីបានដឹងថា **រាហុល** និង **ព្រះនន្ទ** ទ្រង់ព្រះផ្នួស ក៏នាំគ្នាមានរាជបុត្រាជាច្រើនអង្គ ដែលជាព្រះញាតិវង្ស ដូចជា: រាជបុត្រ **ភទ្ទិយៈ** (Bhadrika) **អនុរុទ្ធ** (Anirudha) **ភគុ** (Bhagu) **កម្ពិល** (Kaimpila) និង **ទេវទត្ត** (Devadatta) ទាំងអស់គ្នាមានចិត្តចង់បួស ក៏នាំគ្នាចេញពីនគរទៅរក **ព្រះពុទ្ធ** ហើយក៏សុំបួស ស្នាក់អាស្រ័យនៅជាមួយព្រះអង្គដែរ។ ទាំងអស់គ្នាក៏គោរពស្រលាញ់ និងប្រតិបត្តិនូវព្រះធម៌ជាទីពឹង ហើយបានបួសជាព្រះភិក្ខុសាវ័កដូចចិត្តប្រាថ្នារៀង៧អង្គ។

www.elibraryofcambodia.org



ភទ្ទិយៈ អនុរុទ្ធ ភគុ កម្ពិលៈ ទេវទត្ត បានបួសជាភិក្ខុនៅជាមួយព្រះអង្គ ‹ ស្រង់ចេញពី Internet ›

www.elibraryofcambodia.org

# វគ្គទី៤២

# ព្រះអនុរុទ្ធ និងមហាអានន្ទ

## (Anirudha and Maha Anada)



ព្រះអង្គប្រទានឱវាទដល់ព្រះអនុរុទ្ធ
និងមហាអានន្ទ
(ស្រង់ចេញពីវត្តសំរោងអណ្តែត)

ក្រោយពីបានសិក្សាប្រតិបត្តិព្រះធម៌សព្វបែបយ៉ាងអស់មួយរយៈកាលកន្លងមក **ព្រះអនុរុទ្ធ** បានសម្រេចព្រះធម៌ និងបានត្រាស់ជា **ព្រះអរហន្ត**។ ទ្រង់មានចំណេះល្បីខាងបាលីចម្រើន **វិបស្សនា** (Clear sightendness) ទ្រង់មានប្រាជ្ញាខាងពិធីបុណ្យផ្សេងៗ ដែលតែងប្រារព្ធធ្វើឡើងនៅក្នុងសម័យ **ព្រះពុទ្ធ** គង់នៅ។ ចំណែក **ព្រះអានន្ទ** មានប្រាជ្ញាលើការចងចាំគ្រប់ពុទ្ធដិកា និងព្រះធម៌ដែល **ព្រះពុទ្ធ** បានសម្តែងមកទាំងប៉ុន្មាន។ **ព្រះអានន្ទ** បានក្លាយជាឃ្លាំងផ្ទុករាល់ពុទ្ធឱវាទ និងជាលេខាធិការយ៉ាងជំនាញរបស់ **ព្រះពុទ្ធ** តែ **ព្រះអានន្ទ** ទ្រង់មិនបានត្រាស់ជាព្រះអរហន្តឡើយ ដោយប្រការវៃឆ្លាតរបស់ **ព្រះអានន្ទ** **ព្រះពុទ្ធ** ទ្រង់បានជ្រើសតាំងជាសាវ័កជំនិតរបស់ព្រះអង្គ (Close attendant) នៅជាប់ព្រះអង្គជានិច្ច **ព្រះពុទ្ធ** ទ្រង់ប្រទាននាមដល់ **ព្រះអានន្ទ** ថា "**មហាអានន្ទ**"។ ឯមហាថេរដទៃទៀតនៃ **សក្យវង្ស** ដែលបានបួសជំណាលគ្នា ក៏ទ្រង់សម្រេចជាព្រះអរហន្តគ្រប់ៗអង្គ លើកតែអង្គ **ទេវទត្ត** បានត្រឹមតែបួស មិនបានសម្រេចអ្វីទាំងអស់។ សង្ឃ **ទេវទត្ត** នៅតែមានចិត្តក្រអឺត

www.elibraryofcambodia.org

ក្រទមក្រៃ មិនសូវចេះសម្រប និងចុះញ៉មជាមួយសង្ឃដទៃ ឬក៏មនុស្សម្នាប្រភេទណាឡើយ ម្យ៉ាងទៀត **ទេវទត្ត** តែងមានចិត្តច្រណែននឹង **ព្រះសារីបុត្រ** និង **ព្រះមោគ្គលាន** ដែលគាត់រមែងគិតថា សាវ័កទាំងពីរមិនមែនជារាជវង្សសក្យ បែរបានធ្វើអគ្គសាវ័កឆ្វេងស្តាំ ចិត្តច្រណែននេះមានជាប់ខ្លួន ឯការនិន្ទាឈ្នានិសចេះតែមានជាប់ វាលដាលរហូតដល់ការស្អប់ដល់ **ព្រះពុទ្ធបរមគ្រូ** ទៀតផង។

www.elibraryofcambodia.org

# វគ្គទី៤៣

# ព្រះពុទ្ធបិតា ទ្រង់ប្រឈួន

# (Serious illness of Gautama’s Father)



ព្រះមហាអគ្គសាវ័កទាំង៥អង្គរបស់ព្រះពុទ្ធ

**ព្រះពុទ្ធបរមគ្រូ** ទ្រង់មានព្រះអគ្គសាវ័ក ៥ អង្គយ៉ាងពូកែ ប្រកបដោយប្រាជ្ញាផ្សេងៗដូចជា: ១-**ព្រះសារីបុត្រ** ពូកែខាងផ្លូវលោក ផ្លូវធម៌ ២-**ព្រះមោគ្គលាន** ពូកែខាងវេទមន្តសិលសាស្ត្រ ៣-**ព្រះកស្សប** ពូកែខាងកិច្ចការទូទៅ កែសម្រួល និងជាអគ្គត្រួតពិនិត្យរាល់សំណុំរឿង ដែលទាក់ទងនឹងព្រះពុទ្ធសាសនា ៤-**ព្រះអនុរុទ្ធ** ជំនាញខាងកិច្ចការពិធីបុណ្យផ្សេងៗ ដែលតែងតែប្រារព្ធធ្វើឡើងនៅសម័យ ដែល **ព្រះពុទ្ធ** គង់នៅ ៥-**ព្រះមហាអានន្ទ** ដែលជាសាវ័កជំនិតនៅក្បែរព្រះកាយព្រះអង្គ រាល់ថ្ងៃជាឃ្លាំងផ្ទុករាល់ពុទ្ធដិកា ដែលព្រះអង្គប្រៀនប្រដៅសត្វលោកទាំងឡាយទាំងពួង **មហាអានន្ទ** ចេះចងចាំទាំងអស់ មានពេលខ្លះ **ព្រះពុទ្ធបរមគ្រូ** តែងតែសួរទៅ **មហាអានន្ទ** វិញ ដើម្បីរំលឹកនូវរឿង ដែលទ្រង់បានសម្តែងរួចហើយ ដើម្បីបកស្រាយអោយពុទ្ធបរិស័ទ្ធបានដឹង។ ព្រះមហាថេរទាំង ៥ អង្គ ប្រកបដោយអច្ឆរិយកម្ម បានជួយធ្វើកិច្ចការដ៏មានប្រយោជន៍ជាច្រើនប្រការថ្វាយដល់ **ព្រះពុទ្ធ** ជាម្ចាស់ ធ្វើអោយព្រះអង្គមានកម្លាំងជំនួយយ៉ាងរឹងមាំ មិនយូរប៉ុន្មាន ព្រះពុទ្ធសាសនាបានរីកសាយលើសសាសនាដទៃ ដែលមាននាសម័យនោះ។ **ព្រះបរម**

www.elibraryofcambodia.org

**សាស្តា** និងសង្ឃសាវ័ក ទ្រង់បានបំពេញបេសកម្មនិមន្តប្រោសសត្វត្រាច់ចរគ្រប់ទីកន្លែង ពីនគរមួយទៅនគរមួយ ។

ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងផុត ដែលព្រះអង្គនិមន្តធ្វើដំណើរពីនគរ **កបិលពស្តុ** ទៅកាន់ **សាវត្ថី** ទ្រង់គង់ស្នាក់នៅវត្ត **ជេតពន្ត** ទៅកាន់**នគររាជគ្រឹះ** គង់ស្នាក់នៅវត្ត **វេឡុវ័ន** ទៅកាន់នគរ **វេសាលី** គង់ស្នាក់នៅវត្ត **មហាវ័ន** (Mahavana Monastery) នៅទីនោះទ្រង់ប្រមើមើលនូវញ្ញាណទិព្វ រកឧបនិស្ស័យមនុស្សសត្វលោកទាំងពួង ក៏ស្រាប់តែទ្រង់ជ្រាបនូវហេតុការណ៍ព្រះបិតាប្រឈួន ព្រះអង្គក៏មានពុទ្ធដិកាប្រាប់ដល់សាវ័កទាំង ៥ និងលោកនេន **រាហុល** ព្រមទាំងភិក្ខុសាវ័កជាច្រើនអង្គទៀត អោយរៀបចំខ្លួននិមន្តជាមួយព្រះអង្គ ទៅទតសួរសុខទុក្ខព្រះរោគព្រះបិតានៅនគរ **កបិលពស្តុ** ជាបន្ទាន់នោះដែរ ។ ពេលបាននិមន្តទៅដល់នគរហើយ **ព្រះពុទ្ធ** ទតឃើញព្រះអង្គកំពុងផ្ទុំប្រឈួននៅលើគ្រែ រង់ចាំតែថ្ងៃអស្តង្គត (sunset)។ ព្រះបាទ **សុទ្ធោទនៈ** ពេលបានឃើញ **ព្រះពុទ្ធ** ជាចុងក្រោយនៃព្រះជន្មព្រះអង្គ ស្រាប់តែមានហឫទ័យធូរស្បើយមួយរយៈ តែមិនយូរ ដោយព្រះរាជសុខភាពស្ថិតក្នុងព្រះជន្មចាស់ជរាស្រាប់ផង និងមានព្រះរោគាព្យាធិជាយូរមកហើយ ទ្រង់ក៏សោយទិវង្គតទៅ។ ក្រោយពេលប៉ុន្មានថ្ងៃកន្លងមក កាលព្រះពុទ្ធបិតាទ្រង់សោយទិវង្គតហើយ បានបន្សល់នូវតែការរងទុក្ខសោកស្តាយស្រណោះ អាលោះអាល័យពីក្រុមរាជវង្សានុវង្ស ព្រមទាំងសេនាមន្ត្រី និងប្រជារាស្ត្រប្រុសស្រីប៉ុណ្ណោះ ។



ព្រះអង្គទ្រង់យាងមកទតព្រះបិតាប្រឈួន៖ ស្រង់ចេញពី Internet ។

www.elibraryofcambodia.org

**ព្រះសាស្តា** ទ្រង់ទ្រព្រះសិរសាព្រះបិតាដោយព្រះហស្តផ្ទាល់ ហើយស្រោចទឹក **សុគន្ធវារី** (ទឹកក្រអូប) ហើយលើកព្រះសពដាក់ក្នុងមឈូសរតន៍ ព្រះអង្គទ្រង់ថ្វាយព្រះភ្លើងដោយផ្ទាល់ ។ ពេលបូជាព្រះសពនោះ ព្រះញាតិវង្ស ទាំងអស់ ៦ នគរ បានមកជួបជុំគ្នាគ្មានបាត់មួយអង្គណាឡើយ ។



www.elibraryofcambodia.org

# វគ្គទី៤៤
# ព្រះមាតាចិញ្ចឹមសុំបព្វជា
# (Nursed Maha Prajapati to become nun)



ព្រះនាងបជាបតីសុំព្រះអង្គបួសជាភិក្ខុនី
( ស្រង់ចេញពី Internet )

ក្រោយព្រះបាទ **សុទ្ធោទនៈ** ទ្រង់សោយទីវង្គតទៅ ព្រះជាយាព្រះនាង **បជាបតី** ដែលជាមាតាចិញ្ចឹម **ព្រះពុទ្ធ** បីបាច់ថែរក្សាកាលព្រះអង្គនៅកុមារ ប្រៀបដូចជាបុត្រព្រះនាងបង្កើតនោះ បានដក់ជាប់នូវទុក្ខក្រៀមក្រំក្នុងហប្ញទ័យជាខ្លាំងដោយអត់ពីស្វាមីទៅ ព្រះនាងមានការនឿយណាយក្នុងរឿងលោកីយ៍ ចង់ប្រែហប្ញទ័យ ត្រាច់ចរតាម **ព្រះពុទ្ធ** ជាម្ចាស់ ចង់ស្តាប់ព្រះធម៌ទាំងឡាយ ដែលព្រះអង្គសម្តែង ចង់ប្រតិបត្តិធម៌តាមពុទ្ធឱវាទ ដូច្នេះហើយទើបព្រះនាងនាំស្រីស្នំក្រមការមួយក្រុម ដែលជាភីលៀងជំនិតៗតាមព្រះនាងរាល់ថ្ងៃ ទៅថ្វាយបង្គំ **ព្រះពុទ្ធ** សុំបួសជា **ភិក្ខុនី** (nun) ដើម្បីស្រួលអោយព្រះនាងបាននៅជិតព្រះអង្គ និងបានសិក្សាប្រតិបត្តិធម៌អោយដូចជាភិក្ខុឯទៀត ប៉ុន្តែ **ព្រះពុទ្ធ** ទ្រង់បានបដិសេធ មិនព្រមទទួលអោយបួសឡើយ ជាហេតុធ្វើអោយព្រះនាងមានទុក្ខបន្ថែម គ្មានថ្ងៃស្រាក។ រីឯ **ព្រះបរមសាស្តា** ក្រោយពីបានបញ្ចប់បុណ្យព្រះសពបិតារួចរាល់ហើយ ព្រះអង្គ និងសាវ័កក៏និមន្តចេញពីនគរ **កបិលពស្តុ** ទៅគង់នៅវត្ត **មហាវ័ន** ឯនគរ **វេសាលី** វិញ។

www.elibraryofcambodia.org

ចំណែកព្រះនាង **បជាបតី** ក្រោយពី **ព្រះពុទ្ធ** និមន្តចេញពីនគរ **កបិលពស្តុ**មក ព្រះនាង និងក្រុមភីលៀងជំនិត១មួយក្រុមក៏ជំនុំគ្នាថា: "ទោះបីព្រះនាងមិនបានអនុញ្ញាតការបួសពី **ព្រះពុទ្ធ** ក៏ដោយ ក៏ព្រះនាងត្រូវតែកោរសក់ គ្រងស្បងចីវរដូចភិក្ខុសង្ឃដែរ ដើម្បីបំពេញកត្តកិច្ចជាបុព្វជិតពិត១!"។ -ចំណែកក្រុមភីលៀងក៏មានសំដីតបវិញថា: "ពួកខ្ញុំម្ចាស់ទាំងអស់គ្នា សុខចិត្តកោរសក់ គ្រងស្បង់ចីវរតាមព្រះម៉ែដែរ និងដង្ហែតាមព្រះម៉ែជានិច្ច!"។ កិច្ចជំនុំសម្រេចហើយព្រះនាង និងក្រុមភីលៀងកោរសក់ ក៏នាំគ្នាយាត្រាដោយផ្ទាល់ព្រះបាទទទឹងដីទៅកាន់នគរ **វេសាលី** ដើម្បីគាល់ជួប **ព្រះពុទ្ធ** សារជាថ្មី។ ការធ្វើដំណើររបស់ក្រុមព្រះនាងមានរយៈពេលយូរណាស់ ហើយទ្រង់មានការនឿយហត់ព្រះកាយជាខ្លាំងទំរាំបានទៅដល់វត្ត **មហាវ័ន** កន្លែង **ព្រះពុទ្ធ** គង់នៅ។ កាលបើបានទៅដល់ទីដៅហើយ ក្រុមព្រះនាងមិនហ៊ានចូលទៅក្នុងវត្តភ្លាមទេ ព្រះនាងបាននាំគ្នាសម្រាកនៅក្រោមដើមឈើមួយនៅក្រៅរបងវត្ត គាប់ជួននៅពេលនោះ **អានន្ទ** បាននិមន្តចេញមកក្រៅ ទ្រង់ឃើញព្រះនាងនិងបរិវារនៅក្រៅវត្តជ្រកក្រោមដើមឈើ **អានន្ទ** មានចិត្តខ្លោចផ្សាអាណើតរកអ្វីប្រៀបមិនបាន។ ពេលដែល **អានន្ទ** ឃើញការគ្រងស្បងចីវរ និងកោរសក់របស់ព្រះនាង និងពួកភីលៀងទាំងនោះបញ្ជាក់ថា ក្រុមព្រះនាងគឺចង់បួសខ្លាំងណាស់ ហើយលះបង់ព្រះរាជទ្រព្យ ចាកចេញពីនគរមកដល់ទីនេះ ក៏ព្រោះតែស្មោះព្រះទ័យបព្វជិតនៃម្លប់ព្រះពុទ្ធសាសនាតែបំណងព្រះនាង **ព្រះពុទ្ធ** មិនអនុញ្ញាតឡើយ។ ពេលដែលព្រះនាងឃើញ **អានន្ទ** ចេញមកក្រៅវត្ត ទ្រង់ក៏ស្រក់ទឹកនេត្រាថ្លាយង់ ដោយអំណោរលាយសេចក្តីទុក្ខ ចំណែក **មហាអានន្ទ** ក៏ទ្រង់លួងលោមទៅព្រះនាងវិញ ដើម្បីអោយទ្រង់បានរំសាយពីទុក្ខសោកខ្លះ ដោយមានសង្ឃដិកាថា: "បពិត្រព្រះមាតាដ៏

www.elibraryofcambodia.org



មហាអានន្ទចេញមកឃើញក្រុមព្រះនាងបជាបតី មកដល់មុខវត្ត

ចម្រើន! អាត្មាយល់ច្បាស់ពីបំណងរបស់ញោមហើយ មិនថ្វីទេ! ចាំអាត្មានៅទីនេះសិនចុះ! អាត្មានឹងទៅទូលព្រះដែលមានព្រះភាគអោយទ្រង់ជ្រាប ហើយនឹងជួយទូលព្រះអង្គ សុំអោយញោមទាំងអស់បាននៅទីនេះ!"។

មានសង្ឃដិកាដូច្នេះហើយ **អានន្ទ** ក៏លាព្រះនាងត្រឡប់ទៅក្នុងវត្តវិញ ដើម្បីទូល **ព្រះពុទ្ធ** ប៉ុន្តែមុននឹងចូលទៅដល់ **ព្រះពុទ្ធ អានន្ទ** បានគិតជាស្រេចហើយថា: "បើនឹងទូលព្រះអង្គដោយត្រង់ៗ ពិតជាព្រះអង្គមិនទទួលអោយនារីទាំងឡាយ បួសដូចពួកបុរសឡើយ ដូច្នេះអាត្មាគួរទូលព្រះអង្គតាមមធ្យោបាយដែលអាត្មាគិត ថាជាការល្អប្រសើរជាង!"។ នឹកឃើញវិធីមួយហើយ **អានន្ទ** ចូលទៅដល់ ក៏ទូលទៅព្រះអង្គថា: "សូមក្រាបបង្គំព្រះអង្គ! អាត្មាសូមទូលព្រះអង្គ ព្បិតព្រះមាតា **បជាបតី** និងក្រុមស្រីស្នំរបស់ព្រះនាងបានកោរសក់ គ្រងស្បង់ចីវរដូចភិក្ខុសង្ឃ ហើយធ្វើដំណើរមកដល់ទីនេះ ដោយការតស៊ូព្យាយាមលះបង់រឿងលោកីយ៍ ហើយទ្រង់សម្រេចព្រះទ័យប្រតិបត្តិព្រះធម៌ដូចជា ព្រះភិក្ខុដទៃទៀតដែរ! តើគួរព្រះអង្គអនុញ្ញាតិបានទេ?"។ **ព្រះសាស្តា** ទ្រង់សណ្តាប់ហើយក៏មានពុទ្ធដិកាទៅ **អានន្ទ** វិញថា: "ម្នាល **អានន្ទ!** នារីទាំងឡាយមិនថាតែព្រះនាងជារាជទេពី នោះទេ ទោះជានារីសមញ្ញក៏ដោយ អោយតែព្រមគោរពប្រតិបត្តិខ្ជាប់ខ្ជួនទូវ **គរុ ធម៌ទាំង ៨ ប្រការ** (The eight ways of Dharma Pedagogy) បាននោះ តថាគតនឹងអនុញ្ញាតិអោយបួសជាភិក្ខុនីបាន!"។ បន្ទាប់មក **ព្រះពុទ្ធ** ទ្រង់សម្តែងពន្យល់អំពី **គរុធម៌ ៨ ប្រការ** ប្រាប់

www.elibraryofcambodia.org

ដល់ **អានន្ទ** ជាចុងក្រោយព្រះអង្គ ទ្រង់ មានពុទ្ធដីកាបន្ថែមថា: "បើព្រះនាងអាចរក្សាបានខ្ជាប់នូវ **គរុធម៌** ទាំង ៨ ប្រការ អស់មួយជីវិតហើយនោះ ព្រះនាងនឹងអាចក្លាយខ្លួនជាភិក្ខុនី ក្នុងការប្រព្រឹត្តនូវ **ព្រហ្មចរិយធម៌** ដល់នូវក្តីសម្រេចក្នុង **គុណធម៌** យ៉ាងបរិបូណ៌!"។ **អានន្ទ** បានត្រងត្រាប់ស្តាប់គ្រប់ឱវាទ ហើយចងចាំទុកគ្មានបាត់មួយចន្លោះណាឡើយ ហើយសន្យានឹង **ព្រះពុទ្ធ** ថា នឹងទៅទូលព្រះមាតា **បជាបតី** នូវអ្វីដែលព្រះអង្គបានសម្តែងប្រាប់ដល់ខ្លួន ដើម្បីអោយព្រះនាងទ្រង់ជ្រាប និងប្រតិបត្តិនូវ **គរុធម៌** ទាំង ៨ ប្រការនោះ។

បន្ទាប់មក **អានន្ទ** ក៏រូតរះម្នីម្នាទៅទូលដល់ព្រះនាង **បជាបតី** ដោយសព្វសេចក្តី ព្រះនាងទ្រង់ជ្រាបហើយ ក៏មានសេចក្តីត្រេកអរបន្ទប់អស់ក្តីទុក្ខព្រួយដែលមានពីមុនទាំងប៉ុន្មាន ព្រះនាងទ្រង់មានសុវណ្ណីថ្លែងក្តីអរគុណទៅ **មហាអានន្ទ** វិញថា: "បពិត្រមហា **អានន្ទ** ដ៏ល្បីល្បាញ! ខ្ញុំករុណាសូមអរព្រះគុណដល់ព្រះអង្គ ដែលបានជួយពួកខ្ញុំករុណាបានបួសជាភិក្ខុនីនៅពេលនេះ! ខ្ញុំករុណាប្តេជ្ញានឹងប្រតិបត្តិតាមពុទ្ធដីកា នូវ **គរុធម៌** ទាំង ៨ ប្រការដោយអស់មួយជីវិត! ចំណែកពួកនាងខ្ញុំក៏ដូច្នេះដែរ! ខ្ញុំករុណាធានាថារក្សា **គរុធម៌** ៨ ប្រការដល់ពួកនាងមិនអោយបាត់បង់បានឡើយ!"។ **អានន្ទ** ស្តាប់ហើយពេញចិត្ត រួចក៏និមន្តទៅជួប **ព្រះពុទ្ធ** សារជាថ្មី ដើម្បីបង្គំទូលថ្វាយថា: ព្រះនាងយល់ព្រមគោរពប្រតិបត្តិ **គរុធម៌** ទាំង ៨ ប្រការដោយក្តីហ្មត់ចត់។ **ព្រះពុទ្ធ** ទ្រង់យល់ព្រមសព្វសេចក្តីពេលនោះហើយដែលព្រះនាង **បជាបតី** រាជទេពីនៃនគរ **កបិលពស្តុ** និងស្រីស្នំជំនិតព្រះនាងក៏ក្លាយខ្លួនជា "**បឋមភិក្ខុនី**" ក្នុងព្រះពុទ្ធសាសនាចាប់តាំងពីពេលនោះមក។

www.elibraryofcambodia.org

# វគ្គទី៤៥

# ចិត្តទេវទត្ត មាត់ទេវតា

## (An angel's mouth but an evil heart)
## (Wolf in sheep's clothing)



ទេវទត្តប៉ុងធ្វើឃាតព្រះអង្គ
និងកម្មផលដែលគាត់បានទទួល

ចំណោងជើងខាងលើ ពួកកវីបានអោយឈ្មោះជាប់តាំងពីបុរាណកាលមក គឺបង្ហាញឡើងនូវបុគ្គល ដែលមានគំនិតព្យាបាទ**ព្រះពុទ្ធ** យ៉ាងខ្លាំងក្លានៅក្នុងសម័យពុទ្ធកាល នោះគឺឈ្មោះ **ទេវទត្ត** ។ ក្នុងចំណោមរាជបុត្រ**សក្យវង្ស** ដែលបានបួសជាមួយគ្នា ហើយខំប្រតិបត្តិធម៌យ៉ាងប្រពៃ បានក្លាយខ្លួនជាព្រះសាវ័កជិតៗរបស់ព្រះអង្គមានដូចជា: **ព្រះអានន្ទ ព្រះអនុរុទ្ធ ព្រះភទ្ទិយ: ព្រះភគុ: ព្រះកម្ពិល: ព្រះរាហុល** សុទ្ធតែគោរពស្រឡាញ់ **ព្រះពុទ្ធ** គ្រប់ៗអង្គ មានតែ **ទេវទត្ត** ម្នាក់ប៉ុណ្ណោះ ដែលមិនចេះកោតខ្លាច មានគំនិតប្រកួតប្រជែង ប្រឆាំងជាប់ជានិច្ច ព្រមទាំងមានចិត្តឈ្នានីសព្យាបាទលើ **ព្រះពុទ្ធ**។ ភិក្ខុ **ទេវទត្ត** ជាញាតិជីដូនមួយ និងជាបងថ្លៃ **ព្រះពុទ្ធ** មានមហិច្ឆិតា (embitation) មិនស្កប់ស្កល់ក្នុងការឈ្នានីស **ព្រះពុទ្ធ** បានរកគ្រប់កលល្បិច និងមានពួកជនអាក្រក់មួយចំនួនតូចជួយផង បាននាំបក្សពួកបង្កើតបានឡើងនូវរឿងអមិត្តមួយ គឺកិច្ចបំបែកសង្ឃ ។ ពេលវេលាជាច្រើនក្រោយៗមក ដោយហេតុនៅមិនចុះសម្រុងនឹងសង្ឃដទៃទៀត ភិក្ខុ **ទេវទត្ត** ក៏ចាកចេញពីក្រុមគណៈសង្ឃតែម្នាក់ឯងទៅកាន់ព្រៃ

www.elibraryofcambodia.org

**រាជគ្រឹះ** នៅទីនោះភិក្ខុ **ទេវទត្ត** បានទាក់ទងនឹងរាជបុត្រនាម **អជាតសត្តុ** (Prince Ajatastru) ជាបុត្រស្តេច **ពិម្ពិសារ** អោយជឿទុកចិត្តខ្លួន (**ទេវទត្ត**) រហូតដល់ស្តេច **អជាតសត្តុ** នេះ បានកសាងវត្តមួយអោយគាត់នៅក្នុងក្រុង **រាជគ្រឹះ** នេះដែរ សម្រាប់អោយ **ទេវទត្ត** ស្នាក់នៅធ្វើជាចៅអធិការវត្ត ព្រមទាំងជួយឧបត្ថម្ភគ្រប់បែបយ៉ាងទៀតផង ជាហេតុវឹតតែធ្វើអោយ **ទេវទត្ត** មានកម្លាំង និងអំនួតទ្វេរឡើង ។ ចំណែកព្រះបាទ **ពិម្ពិសារ** ជាបិតា ព្រះអង្គមិនគាំទ្រចំពោះភិក្ខុ **ទេវទត្ត** ដែលមានគំនិតផ្តេសផ្តាសបែបនោះឡើយ ព្រះអង្គទ្រង់ប្រកបដោយទិដ្ឋិ (optimist) គ្រប់ប្រការឯកភាពតាម **ព្រះពុទ្ធ** ទ្រង់មិនចង់អោយមានការបង្កើតឡើងនូវគណៈសង្ឃផ្សេងទៀតទេ ព្រះអង្គតែងតែជួយខាង **ព្រះពុទ្ធ** គ្រប់ប្រការ និងតែងសម្រុះសម្រួលរាជបុត្រនូវសន្តិវិធីផ្សេងៗ តែរាជបុត្រមិនស្តាប់ទ្រង់ឡើយ ។ **ទេវទត្ត** គិតឃើញថា មានតែរាជបុត្រ **អជាតសត្តុ** ដែលមានឥទ្ធិពល អាចជួយគាត់បានក្នុងការសម្រេចបំណងគាត់ប្រឆាំងនឹង **ព្រះពុទ្ធ** ដូច្នេះគាត់ត្រូវធ្វើអោយរាជបុត្រនេះកាន់កាប់អំណាចជាមុនសិន ទើបស្រួលក្នុងការបង្កើតគណៈសង្ឃថ្មី ។ **ទេវទត្ត** បានប្រើគ្រប់វិធីញុះញង់រាជបុត្រ **អជាតសត្តុ** អោយមានចិត្តចង់គ្រងរាជ្យនៅនគរ **រាជគ្រឹះ** នេះតែម្តង ដោយរាជបុត្រនេះចាប់បិតាខ្លួនឯង ឃុំទុកចោលក្នុងប្រាសាទចាស់មួយធ្វើទុក្ខទោស បង្អត់អាហារ មិនគិតគូរ រហូតដល់ទ្រង់ប្រឈួន ហើយក៏សោយទីវង្គតទៅ ។ រយៈពេលដែលដឹងថា រាជបុត្របានកាន់អំណាចទាំងស្រុងហើយ **ទេវទត្ត** បានប្រមូលជនមួយក្រុម ដែលចិត្តជាអ្នកលេង ហើយចេះបាញ់ព្រួញពូកែៗ ដោយជូលជាប្រាក់ច្រើនតម្លឹងដល់ជនទាំងនោះ អោយនាំគ្នាទៅធ្វើគត់ **ព្រះពុទ្ធ** ។ ក្រុមស៊ីឈ្នួលបានព្រមព្រៀងតាមការជួលរបស់ **ទេវទត្ត** ពិតមែន តែពេលពួកទាំងនោះទៅដល់

www.elibraryofcambodia.org

កន្លែង **ព្រះពុទ្ធ** គង់នៅ ឃើញព្រះអង្គគង់ភាវនាធម៌ដោយស្ងប់ស្ងាត់ ប្រកបដោយចរិយាស្រគត់ស្រគំ និងដោយករុណាធម៌គួរជាទីគោរពបូជាពន់ពេកបែបនោះ ហើយបណ្តាលចិត្តពួកក្រុមពិឃាតរារែកចិត្ត មិនអាចសម្រេចបំណងភ្លាមៗបាន ចុងបញ្ចប់ពួកទាំងនោះក៏សម្រេចចិត្តគ្រប់ៗគ្នា មិនត្រូវធ្វើអាក្រក់បៀតបៀនដល់ព្រះអង្គឡើយ រួចក៏នាំគ្នាទៅលុតជង្គង់ថ្វាយបង្គំសារភាពថា ពួកគេបានស៊ីឈ្នួល ប្រុងមកធ្វើបាបដល់ព្រះអង្គដោយប៉ងធ្វើគតតែម្តង ប៉ុន្តែក្រោយពីបានឃើញព្រះអង្គ ទ្រង់ប្រកបដោយធម៌សព្វបែបយ៉ាងដូច្នេះ ធ្វើអោយពួកគាត់លះបង់គំនិតបាបកម្មចោលចេញ ហើយសុំខ្លួនបួសតាមបម្រើព្រះអង្គគ្រប់ៗគ្នា។ **ព្រះពុទ្ធ** ឃើញការភ្ញាក់រលឹករបស់ពួកគាត់បែបនេះ ទ្រង់មានព្រះទ័យសោមនស្សក្រៃលែង ហើយទ្រង់ក៏សម្តែងធម៌បន្ថែម ផ្តល់នូវសេចក្តីរុងរឿង និងគុណធម៌ប្រពៃដល់ពួកទាំងនោះ។ ក្រោយមក **ទេវទត្ត** ដឹងថា ពួកដែលគាត់ជួលទៅធ្វើគត់ **ព្រះពុទ្ធ** បែរជាពួកទាំងនោះទៅចុះចូលនឹងព្រះអង្គទៅវិញ ជាហេតុធ្វើអោយគាត់រឹតតែក្តៅក្រហាយចិត្ត ហើយក៏មានផែនការជាថ្មី ដោយប្តេជ្ញាថា ត្រូវតែធ្វើដោយខ្លួនឯងផ្ទាល់តែម្តង។ គិតឃើញហើយ **ទេវទត្ត** ក៏ឡើងទៅពួនសម្ងំនៅលើ



ទេវទត្តច្រានដុំថ្មដំលាក់ធ្វើបាបព្រះអង្គ (ប្រភពពី Internet)

ចង្កេះភ្នំតូចមួយឈ្មោះ **គិជ្ឈកូដ** (Gidharakuta) ដែលស្ថិតនៅជាប់ផ្លូវដែល **ព្រះពុទ្ធ** និមន្តទៅមកតាមផ្លូវនោះ នៅជិតកន្លែងដែលទ្រង់គង់នៅ។ **ទេវទត្ត** បានតាមដានដឹងពីពេលវេលា ដែល **ព្រះពុទ្ធ** ទ្រង់និមន្តទៅមកបានច្បាស់ហើយ ក៏ត្រៀមខ្លួនពួនសម្ងំនៅទីនោះ អោយតែឃើញ **ព្រះពុទ្ធ** និមន្តមកដល់ នឹងច្រានដុំថ្មធំមួយទម្លាក់ចុះសង្កត់ព្រះអង្គតែ

www.elibraryofcambodia.org

ម្តង។ ពេលវេលាបានមកដល់ **ទេវទត្ត** ក៏អនុវត្តដោយចិត្តហិង្សា ប្រានផ្ទាំងសិលាចុះ តែផ្ទាំងសិលានោះបែរជាបែកជាបំណែកតូចៗ ហើយខ្ចាតចេញអស់ សល់តែកូនដុំដ៏តូច ផ្លាតមកប៉ះព្រះបាទព្រះអង្គបន្តិចបន្តួចប៉ុណ្ណោះ មិនបណ្តាលអោយមានគ្រោះថ្នាក់ធំដុំឡើយ។ ចំណែក **ព្រះពុទ្ធ** និមន្តធ្វើមិនដឹង ហាក់ដូចមិនមានហេតុការណ៍អ្វីកើតឡើងចំពោះព្រះអង្គ ទ្រង់និមន្តចូលវត្តវិញ ហើយបន្ទាប់មកក៏មានគ្រូពេទ្យម្នាក់ឈ្មោះ **ជីវកៈ** (Jivaka) មកពិនិត្យព្យាបាលគ្រាជាសះស្បើយដូចដើមវិញ។

កិច្ចធ្វើឃាតចំពោះ **ព្រះពុទ្ធ** មិនបានសម្រេចម្តងហើយម្តងទៀត តែ **ទេវទត្ត** នៅតែរៀបចំគម្រោងជាថ្មីដើម្បីធ្វើគត់ព្រះអង្គទៀត។ ក្រោយនេះ **ទេវទត្ត** បានលួចទៅលែងដំរីព្រៃមួយដ៏កាចសាហាវដែលអ្នកស្រុកចងទុកដំរីនោះ ឈ្មោះ **នាឡាគិរី** (Nalakiri) ពេលវាបានរួចខ្លួនហើយ វាក៏រត់សំដៅទៅ **ព្រះពុទ្ធ** ដែលទ្រង់កំពុងនិមន្តបិណ្ឌបាត្រជាមួយសាវ័កនៅជាយក្រុង **រាជគ្រឹះ**។ ល្បឿនគុជសាព្រៃមានសន្ទុះដូចព្យុះ តែពេលទៅដល់មុខ **ព្រះបរមសាស្តា** នៃយើង វាបែរជាទុចង៉ក់នៅស្ងៀម ដៀងភ្នែកសម្លឹងទៅព្រះអង្គ ហាក់ដូចជាខ្លាចអំណាចអ្វីមួយភ្លាមនោះដែរ វាបែរជាលុតជង្គង់ចុះ ឱនក្បាលក្រាបដល់ដី ក្នុងន័យគោរពព្រះអង្គទៅវិញ។ ចំណែកឯ **ទេវទត្ត** ដែលលួចលបមើលឃើញហេតុការបែបនោះ ក៏អស់សង្ឃឹមចំពោះការបរាជ័យរបស់ខ្លួនម្តងទៀត តែគំនិតព្យាបាទនៅតែមានដដែល។ ថ្ងៃមួយពេលដែល **ព្រះពុទ្ធ** កំពុងជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ ដើម្បីមកស្តាប់ការសម្តែងធម្មទេសនារបស់ព្រះអង្គ



ទេវទត្តលែងដំរីព្រៃដើម្បីធ្វើឃាតព្រះអង្គ
(ស្រង់ពី Internet)

www.elibraryofcambodia.org

ស្រាប់តែ **ទេវទត្ត** ចូលទៅជួបដោយបញ្ចេញអាកប្បកិរិយាមិនប្រក្រតី បើក លើកឡើងនូវសំណើរដែលគាត់ចង់បាន ឯចំណោមមនុស្សម្នាក៏នាំគ្នាចោលភ្នែក មើលមកគាត់ ហើយចាំស្តាប់ពាក្យសំណើដែលគាត់សុំចំពោះ **ព្រះពុទ្ធ** ថា៖ "**ព្រះពុទ្ធ!** សុំព្រះអង្គបង្កើតនូវធម្មវិន័យអោយបានតឹងរឹងឡើង មិនថាតែភិក្ខុ សង្ឃអង្គណាឡើយ! សូម្បីតែបព្វជិតដែលកាន់សាសនា និកាយផ្សេងៗ ក៏ត្រូវធ្វើ តាមដែរ ហើយឯវិន័យនោះគឺៈ រាល់អ្នកកាន់សាសនាទាំងឡាយ ត្រូវតែកុំស្នាក់ នៅតាមអាស្រម ឬអារាមណាមួយឡើយ! ត្រូវទៅនៅតាមទីវាល ឬក្រោមដើម ឈើព្រៃ មិនត្រូវទទួលចង្ហាន់ដូចប្រភេទសាច់ចំអិនជាដើម! បើល្មើសនឹងត្រូវ បណ្តេញចេញពីភេទជាភិក្ខុ ឬជាបព្វជិតទាំងអស់!"។ ពុទ្ធបរិស័ទដែលនៅជុំវិញរង់ ចាំស្តាប់ពុទ្ធដិកាតបវិញចំពោះសំណើភិក្ខុ **ទេវទត្ត** តើព្រះអង្គទ្រង់មានតម្រិះ យ៉ាងណា?។ ក្រោយពីព្រះអង្គសណ្តាប់នូវសំណើររបស់ **ទេវទត្ត** បែបនេះ ព្រះ អង្គក៏ទ្រង់មានពុទ្ធដិកាឡើងថាៈ "ម្នាលភិក្ខុ **ទេវទត្ត!** សំណើបែបនេះ ពោរពេញ ដោយទុទិដ្ឋិនិយម (pessimism) ខ្លាំងណាស់! **តថាគត** មិនអាចយល់ព្រមបាន ទេ សូម្បីតែភិក្ខុ **ទេវទត្ត** ខ្លួនឯងផ្ទាល់ ក៏មិនអាចទទួលយកបានដែរ! លក្ខណៈ នៃការគង់នៅរាល់ភិក្ខុទាំងឡាយអាចជ្រើសរើសបាន ដោយការពេញចិត្តខ្លួនឯង មិនថាទីណា ឬកន្លែងណាឡើយ! រីឯចង្ហាន់បានមកពីការបិណ្ឌបាត្រ ឬបានមកពី ការប្រគេនជាសាច់ក្តីបន្លែក្តី ភិក្ខុអាចជ្រើសរើសឆាន់បានដោយការចូលចិត្ត!"។ បន្ទាប់មក **ព្រះពុទ្ធ** ទ្រង់សម្តែងពីវិន័យគ្រងស្បង់ចីវរដោយមានពុទ្ធដិកាបន្តថាៈ "គ្រប់ភិក្ខុទាំងឡាយអាចគ្រងស្បង់ចីវរបានគ្រប់យ៉ាង មិនថាជាបន្ទះក្រណាត់បែប ណាឡើយ ទោះបីជារើសពីក្នុងព្រៃ ឬគំនរគរទុកនៅទីមិនគប្បីណាមួយ ឬជា សំពត់បាំងសូលក្តី ក៏អាចគ្រងបានឥតមានទាស់ខុសអ្វីដែរ!"។

www.elibraryofcambodia.org

ការបើកទូលាយសព្វប្រការដល់ភិក្ខុទាំងឡាយយ៉ាងដូច្នេះ ធ្វើអោយចិត្ត **ទេវទត្ត** រឹតតែខ្ទក់ខ្ទាញ់ទ្វេឡើង គំនិតរបស់គាត់ដែលមានបំណងបំបែកសង្ឃមិនបានសម្រេច ហើយមានការអាម៉ាស់មុខនៅចំពោះមហាជន ដែលមកជួបជុំក្នុងទីប្រជុំដ៏ធំរកទីបំផុតគ្មាន។ ដោយបំណងគាត់ចេះតែបរាជ័យ **ទេវទត្ត** ក៏ផ្អាកសកម្មភាពមួយរយៈ។ **ព្រះពុទ្ធ** ក៏ទ្រង់និមន្តទៅគង់នៅវត្ត **វេឡុវ័ន** វិញ ជាមួយសាវ័កជំនិត១ និងភិក្ខុជាច្រើនអង្គទៀត។

**ទេវទត្ត** មិនរៀងចាល ឬខ្វល់ពីការអាម៉ាស់អ្វីឡើយ គាត់នៅតែមានគំនិត និងរកមធ្យោបាយថ្មី១ ដើម្បីសម្រេចនូវការបំបែកសង្ឃរបស់គាត់។ ក្រោយមក គាត់បានប្រមូលសង្ឃមួយចំនួនដែលមានជំនឿលើគាត់ ហើយបង្កើតគណៈសង្ឃថ្មីបាន ដោយរូបគាត់ធ្វើជាប្រធាន ហើយមានច្បាប់វិន័យលើគាត់ជាអ្នកបង្កើតឡើង។ មិនយូរប៉ុន្មានរឿងនេះបានលេចឮដល់ **ព្រះពុទ្ធ** ក្រោយពីព្រះអង្គទ្រង់ជ្រាបពីការបង្កើតឡើងនូវគណៈសង្ឃផ្តេសផ្តាសរបស់ភិក្ខុ **ទេវទត្ត** ហើយមានវិន័យប្រាសចាកសីលធម៌របស់ភិក្ខុសង្ឃ ព្រះអង្គក៏ទ្រង់ចាត់អោយ **ព្រះសារីបុត្រ** ទៅដោះស្រាយចំពោះរឿងហេតុទាំងនេះ ដោយមានពុទ្ធដីកាអោយ **ព្រះសារីបុត្រ** ទ្រង់ព្យាយាមសម្តែងព្រះធម៌ពន្យល់អប់រំដល់ភិក្ខុដែលបានយល់ច្រឡំជឿរឿងអកុសល ដោយ **ទេវទត្ត** អូសទាញទាំងនោះ ត្រឡប់រកផ្លូវល្អត្រឹមត្រូវវិញ **ព្រះសារីបុត្រ** ក៏ទ្រង់និមន្តបំពេញតាមកិច្ចការ តាមឱវាទ **ព្រះពុទ្ធ**។ ពេលដែល **ព្រះសារីបុត្រ** បាននិមន្តទៅដល់វត្តដែល **ទេវទត្ត** ធ្វើជាសង្ក្រាជនោះ ចំពេលវេលាដែល **ទេវទត្ត** កំពុងសឹង (sleeping) យល់ឱកាសល្អ **ព្រះសារីបុត្រ** ក៏និមន្តទៅជួបភិក្ខុទាំងឡាយពេលដែលគ្រប់អង្គកំពុងនៅជុំគ្នា **ព្រះសារីបុត្រ** ក៏សម្តែងធម៌ពន្យល់ណែនាំដោយថេរដីកាថា: "ម្នាលភិក្ខុទាំងឡាយ! ចូរគ្រប់អង្គកុំ

www.elibraryofcambodia.org

ដើរតាមការបំបែកសង្ឃរបស់ **ទេវទត្ត** អោយសោះ គឺជាអំពើពុំគប្បីឡើយ ចូរគ្រប់អង្គទ្រង់ត្រិះរិះពិចារណាអោយបានវែងឆ្ងាយ ការបួសជាសង្ឃមានតែ **ព្រះពុទ្ធ** ជាម្ចាស់មួយអង្គគត់ ដែលយើងត្រូវប្រតិបត្តិគោរពគ្រប់ៗគ្នា! ព្រោះព្រះអង្គជា "**អរិយបុគ្គល**" ដែលទ្រង់ត្រាស់ដឹងពី "**អមតធម៌**" បុគ្គលដទៃទៀតមិនអាចដូចព្រះអង្គបានឡើយ! ចូរសង្ឃគ្រប់អង្គកុំធ្វើអោយមានអកុសលកម្ម (bad action) ដល់ខ្លួនបានអោយសោះ!"។ ភិក្ខុទាំងនោះ ក្រោយពីស្តាប់ និងពិចារណាតាមគន្លងដ៏ត្រឹមត្រូវនៃថេរដិកា ក៏ភ្ញាក់ខ្លួន ហើយនាំគ្នាសម្រេចចិត្តចាកចេញពី **ទេវទត្ត** ដើម្បីនិមន្តតាម **ព្រះសារីបុត្រ** វិលទៅរក **ព្រះពុទ្ធ** ជាម្ចាស់វិញ។ នៅពេលថ្ងៃរសៀលបន្តិច **ទេវទត្ត** ក៏ភ្ញាក់ឡើង ឃើញជុំវិញខ្លួនគាត់មានភាពស្ងាត់ជ្រងំ ប្លែកពីធម្មតា គាត់ក៏ស្ទុះស្ទាចេញមកក្រៅ គ្មានប្រទះឃើញសង្ឃមួយអង្គណាឡើយ ពេលនោះមានអ្នកស្រុកម្នាក់ដើរមក **ទេវទត្ត** ក៏សួរថា: "តើសង្ឃគ្រប់អង្គនៅទីនេះទៅណាបាត់អស់ហើយ?"។ - អ្នកស្រុកម្នាក់នោះបាននិយាយប្រាប់ទៅគាត់វិញថា: "អ៊ូ! ព្រះតេជគុណមិនដឹងទេ! លោកសង្ឃទាំងអស់បាននាំគ្នាទៅតាម **ព្រះសារីបុត្រ** អស់ទៅហើយ!"។ ឮដូច្នេះគាត់ធ្លាក់ថ្លើមក្ដុកដោយទាំងក្ដីក្ដៅក្រហាយមកជាមួយ គាត់ស្ទុះស្ទាចេញដំណើរទាំងអាការៈអស់ទឹកចិត្ត ទៅជួលកម្មករសែងពីរនាក់ អោយសែងគាត់ទៅ ជួប **ព្រះពុទ្ធ** ដើម្បីដោះស្រាយគ្នា។ នៅតាមផ្លូវគាត់រអ៊ូរទាំថា: "ហេតុដូចម្ដេចបានជាមកនាំសង្ឃរបស់គាត់អោយចាកចេញពីគាត់អស់បែបនេះ!"។

ចំណែកនៅកន្លែងគង់របស់ **ព្រះបរមសាស្ដា** មានពុទ្ធបរិស័ទជាច្រើនដែលដឹងថា **ទេវទត្ត** កំពុងធ្វើដំណើរដោយកំហឹង ហើយក៏នាំគ្នារត់មកទូលព្រះអង្គថា: "បពិត្រព្រះគុណម្ចាស់! ឥឡូវនេះ **ទេវទត្ត** កំពុងធ្វើដំណើរដោយហឹង្សាមក

www.elibraryofcambodia.org

វកព្រះអង្គហើយ! សូមទ្រង់មេត្តាគេចព្រះកាយសិនទៅព្រះអង្គ ជៀសវាងការកើតគ្រោះថ្នាក់ដល់ទ្រង់!"។ **ព្រះសាស្តា** ទ្រង់សណ្តាប់ហើយ មិនបានតក់ស្លុតអ្វីបន្តិចឡើយ ព្រះអង្គមានពុទ្ធដិកាតបទៅអ្នកទាំងនោះថា: "ម្នាលពុទ្ធបរិស័ទទាំងឡាយ! ភិក្ខុ **ទេវទត្ត** មិនអាចធ្វើអ្វីអោយ **តថាគត** ដល់នូវគ្រោះថ្នាក់នោះបានទេ! ចូរឧបាសកទាំងអស់កុំមានការបារម្ភអ្វី!"។ មិនយូរប៉ុន្មាន ស្រាប់តែមានអ្នកស្រុកមកប្រាប់ក្រុមពុទ្ធបរិស័ទ ដែលកំពុងតែមានការព្រួយបារម្ភចំពោះព្រះអង្គនោះថា: "ភិក្ខុ **ទេវទត្ត** នោះត្រូវព្រះធរណីស្រូបយកបាត់ទៅហើយ!"។ អ្នកស្រុកនោះបានរៀបរាប់យ៉ាងក្បោះក្បាយទៀតថា: "ពេលភិក្ខុ **ទេវទត្ត** ធ្វើដំណើរមកដល់ពាក់កណ្តាលផ្លូវ គាត់បញ្ជាអោយអ្នកសែងគ្រែស្នែងនោះដាក់គាត់ចុះគ្រាន់តែគាត់ចុះជាន់ដល់ដី ឈានបានប្រមាណពីរបីជំហាន ស្រាប់តែធរណីប្រេះបែកជាពីរ ហើយ ស្រូបយកគាត់ទាំងរស់ទៅតែម្តង[៣៥]!"។

ចាប់តាំងពីថ្ងៃនោះមក ពុទ្ធបរិស័ទទាំងឡាយកើតក្តីរីករាយគ្រប់ៗគ្នា ព្រះអង្គទទួលបាននូវសន្តិភាពក្នុងកិច្ចផ្សព្វផ្សាយ ព្រះធម៌ប្រោសសត្វជាបន្ត លែងមានបុគ្គលណាហ៊ានបៀតបៀនដល់ព្រះអង្គទៀតឡើយ ដោយខ្លាចមានបាបកម្មកើតឡើងដូចជា **ទេវទត្ត**។



ទេវទត្តត្រូវព្រះធរណីស្រូប ( ស្រង់ពី Internet )

---

[៣៥] មានរឿងនិទានខ្លះនិយាយថា ទេវទត្តស្លាប់ដោយជម្ងឺខ្យល់គរ ឯគំនូរតាមវត្តអារាមខ្មែរយើង គឺភាគច្រើនថា ទេវទត្តត្រូវធរណីស្រូប ដូចមានក្នុងសៀវភៅនេះជាដើម។

www.elibraryofcambodia.org

# វគ្គទី៤៦

# ព្រះគុណណូបការៈ

## (The goodness of Gautama Buddha, duration 45 years of his duties)

ពេលវេលាច្រើនរាប់មិនអស់ចេះតែកន្លងផុតទៅឥតឈប់ឈរ **ព្រះពុទ្ធ** ជាម្ចាស់នៃយើងក៏ទ្រង់និមន្តបំពេញភារកិច្ចរបស់ព្រះអង្គឥតឈប់ឈរដែរ។ ព្រះអង្គទ្រង់និមន្តគ្រប់ទីកន្លែងក្នុងផ្ទៃទឹកដីប្រទេសឥណ្ឌា[៣៦] ក្នុងសម័យពុទ្ធកាល ទីនោះមានឈ្មោះនគរធំៗចំនួន ៤ គឺៈ ១-នៅប៉ែកនគរ **រាជគ្រឹះ** មានតំបន់ភ្នំ **គិជ្ឈកូដ គោតមនិគ្រោធ សត្តបណ្ណគុហា** ភ្នំ **វេភារៈ** តំបន់ **កាឡសិលា** ភ្នំ **ឥសីគិលី** វត្ត **វេឡុវ័ន** វត្ត **តបោទារាម បិប្ផលិគុហា**។ល។ ២-នៅប៉ែកនគរ **វេសាលី** មាន ៦ តំបន់ តំបន់ទាំងនេះភាគច្រើនមានឈ្មោះ **ចេតិយ៍** ដូចជាៈ **ឧទេនចេតិយ៍ គោតមចេតិយ៍ សត្តម្ពចេតិយ៍ ពហុបុត្តចេតិយ៍ សារន្ទចេតិយ៍** និង **ចាបាលចេតិយ៍**[៣៧] ។ ៣-នៅប៉ែកនគរ **សាវត្ថី** មានៈ វត្ត **ជេតពន្ត** វត្ត **បុព្វារាម** ភ្នំ **យមកប្បដិហារ**។ល។ និងទី៤-នៅនគរ **កុសិនារា** មានរួមតំបន់ជាច្រើននៅក្នុងនគរនេះ ព្រមទាំងកន្លែងមួយចំនួនទៀតដែលមិនអាចរៀបរាប់អស់។

**ព្រះពុទ្ធ** ជាម្ចាស់ទ្រង់មិនបានគិតពីព្រះកាយ ពីរឿងនឿយហត់ឡើយ ទ្រង់និមន្តដោយព្រះបាទផ្ទាល់នឹងធរណី ពេលខ្លះទ្រង់និមន្តតែអង្គឯងយ៉ាង

---

[36] ឈ្មោះទីកន្លែងទាំងនេះ ដកស្រង់តាមសៀវភៅលោក **ខិម ណារត្ន៍** បោះពុម្ពក្នុងឆ្នាំ១៩៥៤។

[37] ឈ្មោះទីកន្លែងទាំងនេះ ដកស្រង់តាមសៀវភៅលោក **ខិម ណារត្ន៍** បោះពុម្ពក្នុងឆ្នាំ១៩៥៤។

www.elibraryofcambodia.org

កណ្តោចកណ្តែង ពេលខ្លះទៀតក៏ទ្រង់និមន្តជាមួយសាវ័កជំនិត១ ឬភិក្ខុជាច្រើនអង្គ ដោយនិមន្តជាជួរយ៉ាងសមគួរ និងរាបសារជាទីបំផុត។ នៅរៀងរាល់រដូវវស្សា ដែលមានភ្លៀងធ្លាក់មិនអាចនិមន្តបាន ព្រះអង្គតែងគង់រង់ចាំព្រះវស្សានៅតាមវត្តអារាមនានា វត្ត **វេឡុវ័ន** និង **វេតពន្ឋ** ជាកន្លែងដែលព្រះអង្គគង់នៅច្រើនជាងគេ នៅពេលនោះដែរ ក៏តែងតែមានពុទ្ធបរិស័ទជិតឆ្ងាយយកចង្ហាន់ទៅប្រគេនមិនដែលអាក់ខាន។ ពេលចេញវស្សា និងរដូវក្តៅ ព្រះអង្គតែងត្រូវពុទ្ធបរិស័ទ ឬមហាជននិមន្តទៅកាន់លំនៅដ្ឋានរបស់ពួកគេ ហើយរៀបចំប្រគេនចង្ហាន់បានយ៉ាងស័ក្តសម ពេលខ្លះក៏មានប្រជាមហាជននិមន្តព្រះអង្គអោយទៅសម្តែង **ធម្មទេសនា** តាមទីសាធារណៈ និងតំបន់ផ្សេង១ក្នុងភូមិស្រុក ដើម្បីអោយមនុស្សម្នានៅទីនោះបានសណ្តាប់គ្រប់១គ្នា។

ព្រះអង្គមិនដែលអាក់ខានអ្វីដែលមនុស្សលោកយើងត្រូវការ ទ្រង់តែងបំពេញមិនដែលអោយខ្វះចន្លោះឡើយ លើសពីនេះទៀត **ព្រះពុទ្ធបរមគ្រូ** នៃយើង ព្រះអង្គមាន **ពុទ្ធកិច្ច** (work of the Buddha) ជាប្រចាំ ដែលត្រូវអនុវត្តន៍គឺ: **ពេលព្រឹក**: ទ្រង់និមន្តបិណ្ឌបាត្រ **ពេលរសៀល**: ទ្រង់សម្តែងធម្មទេសនាប្រោសសត្វ **ពេលប្រលប់**: ជួបជាមួយមនុស្សសំខាន់១ដូចជាមហាក្សត្រជាដើម ដែលចង់សួរពីបញ្ហាផ្សេង១ ហើយ **ព្រះពុទ្ធ** ទ្រង់ស្រាយបំភ្លឺពីបញ្ហាទាំងនោះបានយ៉ាងច្បាស់លាស់។ ព្រះមហាក្សត្រក៏ទ្រង់មានព្រះទ័យរីករាយ ហើយក៏យាងចូលវាំងវិញដោយគ្មានមន្ទិលសង្ស័យ។ ពេលយប់កាន់តែជ្រៅ ទើបទ្រង់និមន្តចូលផ្ទំ ដែលមានលក្ខណៈប្លែកពីមនុស្សលោកធម្មតាគឺ: ទ្រង់ផ្ទំផ្អៀងដោយបែរមកខាងស្តាំ ព្រះបាទដាក់លើភ្លៅឆ្វេង ព្រះហស្តស្តាំទ្រង់ដាក់ទ្រថ្ពាល់ស្តាំ ទ្រង់គង់លក់ក្នុងថេរៈវេលាល្មមសមគួរក៏ភ្ញាក់តើនឡើង (wake up) ដោយមិនដែល

www.elibraryofcambodia.org

លើសក្នុងកំឡុងពេលយូរឡើយ។ ពេលបច្ចូសម័យ (dawn) ពេលទៀបភ្លឺមុនអារុណរះ ទ្រង់គង់ចម្រើនសមាធិប្រមើលមើលឧបនិស្ស័យ មើលថាតើបុគ្គលណាដែលត្រូវទទួលយកធម៌បាន ព្រះអង្គក៏ទ្រង់និមន្តទៅដោយផ្ទាល់ទៅរកអ្នកនោះ ហើយសម្តែងធម៌ប្រោសដល់អ្នកនោះនៅថ្ងៃនោះតែម្តង មិនទុកពេលវេលាកន្លងទៅឥតប្រយោជន៍ទេ។

ចាប់ពីថ្ងៃ **ព្រះពុទ្ធបរមគ្រូ** ដែលព្រះអង្គបានត្រាស់ដឹង **ពោធិញ្ញាណ** ក្នុងព្រះជន្ម ៣៥ វស្សាមក ទ្រង់បានធ្វើកិច្ចការយ៉ាងមានប្រយោជន៍ជាច្រើនលើសលប់ដល់មនុស្សលោកយើង ទ្រង់បានផ្តល់នូវការប្រៀនប្រដៅនូវអំពើល្អដាក់ជាប់ខ្លួន សន្សំកុសល ធ្វើទានដើម្បី **មគ្គផល** បច្ចុប្បន្នក៏ដូចអនាគត។ ទ្រង់កែលំអរវាល់អំពើខុសឆ្គាំងឆ្គង ឬហេតុមិនគប្បីនៃជនទាំងឡាយណាដែលបានប្រព្រឹត្តអោយបែរត្រឡប់កាយចិត្តប្រព្រឹត្តល្អត្រឹមត្រូវជំនួសវិញ។ ទ្រង់បានដាស់តឿនរាល់បុគ្គលទាំងឡាយអោយចេះមានចិត្តតស៊ូក្នុងជីវិត ដោយសង្គ្រោះខ្លួនឯងដើម្បីយកឈ្នះឧបសគ្គ ឬគ្រោះភ័យដែលជួបប្រទះ ឬប្រឈមមុខចំពោះហេតុការណ៍ណាមួយ ដែលបណ្តាលអោយមានគ្រោះថ្នាក់ដល់ខ្លួន។ ទ្រង់បានបង្ហាញនូវមាគ៌ាអប់រំដ៏ល្អប្រពៃជាច្រើនទៀតចំពោះសាវ័កព្រះអង្គ និងអង្គភិក្ខុទាំងអស់ ទ្រង់បានអោយឱវាទល្អៗដើម្បីរក្សាចិត្ត ក្នុងការគោរពប្រតិបត្តិធម្មវិន័យដោយក្តីមេត្តា (compassion) ករុណា (grace) កាន់ចិត្តរក្សាសិលដោយខន្តី (tolerance) សច្ចៈធម៌ និងផ្លូវព្រះនិព្វាន ព្រះអង្គបានធ្វើកិច្ចការដល់មនុស្សលោកចំនួន ៤៥ ឆ្នាំ រហូតដល់ព្រះអង្គមានព្រះជន្ម ៨០ វស្សា។

ក្នុងកំឡុងពេល ៤៥ ឆ្នាំ **ព្រះពុទ្ធ** ជាម្ចាស់ទ្រង់មានកិច្ចការយ៉ាងលំបាកក្រៃលែង ដែលមិនមានមនុស្សណាអាចធ្វើដូចជាព្រះអង្គបានឡើយ ដើម្បីសម្រេចព្រះ

www.elibraryofcambodia.org

ធម៌របស់ព្រះអង្គអោយជ្រួតជ្រាបដល់ចិត្តមនុស្សទូទាំងពិភពលោក ទោះបីជាព្រះអង្គស្ថិតក្នុងព្រះជន្ម ៨០ វស្សាទៅហើយក្តី ក៏ទ្រង់នៅតែតស៊ូ និមន្តក្នុងដំណើរប្រោសសត្វរហូតដល់ទីកំណត់នៃជីវិតព្រះអង្គ។ **ព្រះបរមសាស្តា** ទ្រង់ដឹងថាព្រះកាយព្រះអង្គត្រូវដល់កំណត់កាលទ្រុតទ្រោម ចុះទន់ខ្សោយទៅតាមព្រះធម៌ **អនិច្ចំ** (uncertain) **អនត្តា** (non-self) ហើយមិនអាចគង់ព្រះជន្មលើលោកនេះបានយូរទៀតទេ ដូច្នេះព្រះអង្គក៏ខំនិមន្តចាកចេញពីក្រុង **រាជគ្រឹះ** ទៅកាន់ទីកន្លែងមួយដែលព្រះអង្គទ្រង់តម្រិះថាជាកន្លែងស័ក្តសម នឹងត្រូវចូលព្រះនិព្វានសម្រាប់ព្រះអង្គ តើកន្លែងណាដែលទ្រង់ត្រូវជ្រើសរើសយកទី **ព្រះនិព្វាន** នោះ?

(សូមតាមដានបន្ត)។

www.elibraryofcambodia.org

# វគ្គទី៤៧

# ជាក់ព្រះជន្មសង្ខា

## (Limit of Gautama Buddha's life)



(ស្រង់ពីវត្តទឹកថ្លា ក្រុងភ្នំពេញ ប្រទេសកម្ពុជា)

**ព្រះពុទ្ធ** ទ្រង់ចម្រើនសមាធិប្រមើលមើលដឹងពីទីកន្លែង ដែលជាទិសដៅរបស់ព្រះអង្គ តែទ្រង់មិនទាន់អោយ **មហាអានន្ទ** ឬភិក្ខុដ៏ទៃទៀតដឹងឡើយ ព្រះអង្គគ្រាន់តែត្រាស់បង្គាប់អោយ **មហាអានន្ទ** និងភិក្ខុសង្ឃដែលនៅជាមួយរៀបចំចេញដំណើរប៉ុណ្ណោះ។ និមន្តចាកចេញពីនគរ **រាជគ្រឹះ** ឆ្ពោះទៅកាន់ភាគខាងជើងភ្នំ **ហេមាល័យ** (Himalayas) ដោយមាន **អានន្ទ** និងភិក្ខុជាច្រើនទៅជាមួយផង។

នៅភាគខាងជើងនោះ ជាទឹកដីធំធេងនៃនគរពីរគឺ **វេសាលី** (Vashali) និងនគរ **កុសិនារា** (Kushinagara) ការធ្វើដំណើរមានរយៈពេលយូរណាស់បាន ពាក់កណ្តាល ក្រុមព្រះអង្គក៏បានចូលដល់ភូមិមួយស្ថិតក្នុងស្រុក **វេឡុវ័ន** ក៏ចូលដល់រដូវវស្សាដោយរដូវនេះសើមផ្ទៃដី ក្រុមព្រះអង្គមិនអាចនិមន្តបាន ព្រះអង្គក៏មានពុទ្ធដីកាបង្គាប់ដល់ភិក្ខុដែលរួមដំណើរថាៈ "ម្នាលភិក្ខុទាំងឡាយ! ឥឡូវនេះដល់ពេលរដូវចូលវស្សាហើយ គ្រប់ៗគ្នាគប្បីត្រូវសម្រាកមួយកន្លែង គង់ចាំព្រះវស្សានៅទីណាស្រេចតែចិត្តចុះ! ចំណែក **តថាគត** និង **អានន្ទ** សម្រេចថាគង់ចាំព្រះវស្សានៅភូមិតូចខាងមុខនេះហើយ!"។ ស្តាប់ពុទ្ធដីកាហើយ ភិក្ខុទាំង

www.elibraryofcambodia.org

ឡាយក៏ថ្វាយបង្គំលាព្រះអង្គ រួចបែកគ្នាទៅរកកន្លែងគង់ រង់ចាំវស្សារៀងៗអង្គ ចំណែកឯ **ព្រះពុទ្ធ** និង **អានន្ទ** ក៏គង់ចាំវស្សានៅក្នុងសំណាក់មួយ ដែលទ្រង់ទ្រាយដូចជាឧបដ្ឋានសាលាស្ថិតនៅក្នុងភូមិនោះ។ ក្នុងកំឡុងពេលដែលព្រះអង្គគង់ចាំព្រះវស្សានៅទីនោះ ព្រះអង្គទ្រង់ប្រឈួនធ្ងន់ តែទ្រង់ខំតាំងស្មារតីទប់ **សតិសម្បជញ្ញៈ** (memory and conscience) ដើម្បីទប់ទល់ទៅនឹងសេចក្តីវេទនាទាំងឡាយ ទុក្ខនៃជំងឺទាំងនោះ ហាក់ដូចជាមិនអាចគ្របសង្កត់លើព្រះអង្គបានឡើយ ព្រះអង្គខំតាំងភាវនាធម៌ "**ឥទ្ធិពលបាទធម៌**" (Greatness saturation of the Dharma) មកជាគ្រឿងបន្ទាបបន្ទប់កុំអោយជម្ងឺរាលដាលបាន។ រយៈពេលមិនយូរប៉ុន្មាន ព្រះអង្គក៏ទ្រង់ជាសះស្បើយបន្តិចម្តងៗ រហូតបានជាស្រឡះពីអាការៈរោគទាំងឡាយនោះ។ រសៀលថ្ងៃមួយ ពេលព្រះអង្គកំពុងប្រថាប់នៅរបៀងយ៉នៃសាលាសំណាក់នោះ (porch of Sala) **មហាអានន្ទ** ក៏ ចូលទៅក្រាបបង្គំព្រះអង្គដោយមានថេរដិកាឡើងទាំងអំណោរថាៈ "ព្រះគ្រូជាម្ចាស់! ខ្ញុំករុណាត្រេកអរណាស់ កាលបើឃើញព្រះសុខភាពព្រះអង្គបានល្អប្រសើរដូចដើមវិញដូច្នេះ! នេះគឺអាស្រ័យដោយព្រះចិន្តាអត់ធន់ដ៏អស្ចារ្យរបស់ព្រះអង្គ ដែលទ្រង់បានធ្វើអោយជម្ងឺព្យាធិទាំងឡាយជៀសចាកឆ្ងាយ ចំពោះខ្ញុំករុណា ដែលមិនទាន់បានត្រាស់ដឹងនូវធម៌អ្វីសោះនោះ ដោយហេតុខ្ញុំករុណានៅតែនឹកមមៃពីក្តីបារម្ភផងទាំងឡាយ និងព្រះសុខភាពព្រះអង្គមួយរយៈពេលដែលទ្រង់ប្រឈួន ឥឡូវទោះបីព្រះអង្គបានជាសះស្បើយក៏ដោយ ក៏ចិត្តខ្ញុំករុណានៅតែមានគំនិតគិតឃើញថា បើព្រះអង្គមិនទាន់ បានបង្រៀនព្រះធម៌សព្វគ្រប់ដល់ភិក្ខុ



មហាអានន្ទមានថេរដិកាពិភាក្សា
ជាមួយព្រះអង្គ
(ស្រង់ពីវត្តសំរោងអណ្តែត)

www.elibraryofcambodia.org

ទាំងឡាយទេនោះ ភិក្ខុទាំងឡាយច្បាស់ជាមិនបានរឹងមាំក្នុងការប្រតិបត្តិនូវធម៌ដែលទ្រង់បានបង្រៀនរួចហើយនោះទេ!"។ **ព្រះពុទ្ធបរមគ្រូ** ទ្រង់តបទៅ **មហាអានន្ទ** វិញ ទ្រង់បានសម្ដែងនូវអ្វីដែល **មហាអានន្ទ** មិនទាន់មានការជ្រះស្រឡះក្នុងចិត្ត ព្រះអង្គមានពុទ្ធដីកាឡើងថា: "ម្នាល **អានន្ទ** អ្នកមិនត្រូវនៅគិតបែបនេះទៀតទេ! ភិក្ខុទាំងឡាយបានទទួលការប្រៀនប្រដៅសព្វយ៉ាងទាំង **ធម៌អប់រំចិត្ត** ក៏ដូចជា **ធម៌វិន័យ** ជាច្រើន មិនមានអ្វីនៅខ្វះចន្លោះឡើយ! តថាគតមានសង្ឃឹមយ៉ាងមុតមាំថា ការប្រតិបត្តិរបស់ភិក្ខុទាំងឡាយ នឹងបានល្អប្រសើរជាក់ជាមិនខាន! ម្នាល **អានន្ទ**! ឥឡូវនោះតថាគតមានព្រះជន្ម ៨០ វស្សាទៅហើយ ប្រៀបដូចជារទេះដែលចាស់ទ្រុតទ្រោម ទប់ទល់បានដោយសារតែឫស្សី មិនមានអ្វីនៅរឹងមាំទៀតឡើយ! ដូច្នេះហើយភិក្ខុទាំងឡាយ និងបុគ្គលទាំងឡាយ ត្រូវទីពឹងលើខ្លួនឯង! ការទីពឹងលើខ្លួនឯង ជាការប្រសើរជាងគប្បីទីពឹងអ្នកដទៃ ចំណែកការពឹងលើព្រះធម៌ជាដើមទុនចងចិត្ត អោយមានសេចក្តីជឿជាក់លើអ្វីដែលជាការតស៊ូរបស់ខ្លួនឯងប៉ុណ្ណោះ!"។

ការសាសងត្រូវបញ្ចប់ **មហាអានន្ទ** យល់ច្បាស់ ពេលព្រះអង្គមានពុទ្ធដីកាយ៉ាយប៉ាប់ទាំងនេះ លែងមមៃនឹកគិតក្នុងចិត្តទៀត ហើយចិត្ត **អានន្ទ** ក៏ប្រែជាគិតវិញថា អ្វីដែលព្រះអង្គបានបង្រៀន ពិតជាពង្រឹងដល់ផ្លូវចិត្តរបស់បុគ្គលគ្រប់រូប មិនថាអ្នកណាជាអ្នកណាឡើយ គឺឈានដល់ក្តីសម្រេចដោយខ្លួនឯងជាក់ជាប្រាកដ។ ក្រោយមួយសប្តាហ៍កន្លងមក ព្រះអង្គក៏ទ្រង់ស្រឡះព្រះកាយមែនទែន ទ្រង់ក៏និមន្តចេញបិណ្ឌបាត្រជាមួយ **អានន្ទ** ដូចប្រក្រតី។ ព្រះអង្គ និង **អានន្ទ** បាននិមន្តទៅដល់តំបន់ **បាវាលចេតិយ៍** (Pava Stupa) នៅជិតក្រុង **វេសាលី** ទ្រង់ក៏គង់សម្រាកនៅទីនោះ **អានន្ទ** បានរៀបចំក្រាលកម្រាល សម្រាប់ព្រះអង្គ

www.elibraryofcambodia.org



ព្រះអង្គកំពុងធ្វើសមាធិភាវនាធម៌ ៤ យ៉ាង
(ស្រង់ពី Internet)

គង់នៅលើផ្ទាំងថ្មមួយផ្ទាំងក្រោមដើមឈើដ៏ត្រឈឹងត្រឈៃមួយ។ កាលបើទ្រង់បានសម្រាក ព្រះកាយហើយ ព្រះអង្គក៏គង់ធ្វើសមាធិភាវនាធម៌ ៤ យ៉ាងគឺ: **ឆន្ទៈ វិរិយ ចិត្តៈ** និង **វិមំសា** ឆ្លងផុតធម៌ទាំង ៤ ក៏ទ្រង់ប្រមើមើលពីការចូល **បរិនិព្វាន** របស់ព្រះអង្គម្តងវិញ។ កាលបើទ្រង់ធ្វើសមាធិម្តងៗ ព្រះអង្គតែងទតឃើញនូវបាតុភូតផ្សេងៗ ដែលបង្ហាញអោយដឹងថា នឹងកើតឡើង ដូចជានៅត្រង់វគ្គនេះ ពេលព្រះអង្គកំពុងធ្វើកម្មដ្ឋានភាវនានូវធម៌ទាំង ៤ នោះមក ទ្រង់ក៏ទតឃើញមាន **មារ** ដែលចេះតែតាមព្យាយាមជាយូរមកហើយ ចង់អោយព្រះអង្គចូល **ព្រះនិព្វាន** បាននិមិត្តកាយចេញមកក្រាបទូលតឿន **ព្រះសាស្តា** ថា: "ព្រះអង្គ! ល្មមដល់ពេលចូល **និព្វាន** ហើយ កុំនៅយូរពេក"។ **ព្រះបរមសាស្តា** ទ្រង់មានពុទ្ធដីកាតបទៅ **មារ** នោះវិញថា: "ម្នាល **មារ!** ចូរអ្នកកុំខ្វល់ខ្វាយពេក! ការ **បរិនិព្វាន** របស់ តថាគតមិនយូរទេ! នៅសល់តែ ៣ ខែទៀត **តថាគត** នឹងធ្វើ **បរិនិព្វាន** ហើយ!"។

ការបើស្តាប់ឮដូច្នេះហើយ **មារ** ចិត្តបាបក៏អស់ចិត្ត ហើយក៏រលាយទៅវិញបាត់ ក្នុងនិមិត្តការប្រមើមើលរបស់ព្រះអង្គ។ ពេលនោះ **អានន្ទ** នៅជិតនោះដែរហាក់បានឮសំលេងខ្យល់បក់រសាត់កាត់ពីមុខ ទ្រង់ហាក់ឆ្ងល់ក៏ចូលទៅទូលសួរព្រះបរមគ្រូថា: "បពិត្រព្រះអង្គ! អម្បាញ់មិញ ខ្ញុំករុណាហាក់ឮខ្យល់ចំលែក បក់មកកាត់ពីមុខខ្ញុំករុណា តើជាខ្យល់អ្វីទៅព្រះអង្គ?"។ ព្រះអង្គទ្រង់មានពុទ្ធដីកាប្រាប់ទៅ **អានន្ទ** វិញថា: "មែនហើយ **អានន្ទ!** ខ្យល់ដែលបកកាត់ពីមុខអ្នកនេះ ពិត

www.elibraryofcambodia.org

ជានិមិត្តសញ្ញាដែលមកប្រាប់ថា **តថាគត** នឹងចូល **ព្រះនិព្វាន** នៅ ៣ ខែក្រោ-យនេះហើយ គឺនៅថ្ងៃពេញបូណ៌មីនាខែពិសាខខាងមុខនោះហើយ!"។ **មហាអានន្ទ** ឮហើយទ្រង់កើតទុក្ខរកអ្វីប្រៀបពុំបាន ហើយក៏មានថេរដិកាទាំងទឹកនេត្រាទៅព្រះបរមគ្រូវិញថា: "ឱ! ព្រះបរមគ្រូជាម្ចាស់! សូមព្រះអង្គកុំទាន់អាលចូល **បរិនិព្វាន** អី! សូមទ្រង់មេត្តានៅគង់ព្រះជន្មបន្តទៀត ដើម្បីជួយមនុស្សសត្វទាំងឡាយតទៅទៀតព្រះអង្គ!"។ **ព្រះពុទ្ធ** ទ្រង់ទតនូវភាពសោកសង្រេងរបស់ **អានន្ទ** ចំពោះព្រះភក្ត្រ ទ្រង់ក៏មានការរំជើបរំជួលក្នុងព្រះទ័យដែរ តែព្រះអង្គខំមានពុទ្ធដិកាលួងលោមចិត្ត **អានន្ទ** កាត់បន្ថយការទុក្ខសោកខ្លះរបស់សាវ័កជំនិតនេះដោយពុទ្ធដិកាថា: "ម្នាល **អានន្ទ**! អ្នកមិនត្រូវមានទុក្ខព្រួយទេ! ការស្លាប់រស់នៅលើវាលវដ្តសង្សារនេះជារឿងធម្មតា **តថាគត** បានកាត់ផ្តាច់កម្មផលលោកីយ៍អស់ហើយ! ការសម្រេចចូលបរិនិព្វានរបស់ **តថាគត** នៅពេល ៣ ខែខាងមុខនេះ ជាការបញ្ជាក់ប្រាប់ថា "សេចក្តីស្លាប់ជាច្បាប់ធម្មជាតិដ៏ធំ ដែលមិនអាចជៀសរួចបាន! ហើយក៏គ្មានអ្វីអាចស្ថិតស្ថេរបានរហូតដែរ! **ម្នាល អានន្ទ**! សាវ័កដ៏ប្រសើរ **តថាគត** ពេញចិត្តនឹងកិច្ចប្រតិបត្តិរបស់អ្នកណាស់! តែពេលវេលាមិនពន្យាអោយលើសពី ៣ ខែទៀតឡើយ ចូរអ្នកហៅភិក្ខុទាំងឡាយអោយមកជួបជុំគ្នានៅទីនេះ តថាគតនឹងមានឱវាទផ្តាំផ្ញើជាច្រើនទៀត!"។ **មហាអានន្ទ** ក៏ធ្វើតាមពុទ្ធដិកា ហៅអស់ភិក្ខុទាំងឡាយដែលមានក្នុងតំបន់នេះ អោយមកជួបជុំគ្នានៅព្រៃ **មហាវ័ន** (Maha-vana) ទីកន្លែងដែលព្រះអង្គគង់នៅ។


ភិក្ខុទាំងឡាយជួបជុំជាមួយព្រះអង្គនៅព្រៃមហាវ័ន
‹ស្រង់ពី Internet›

www.elibraryofcambodia.org

# វគ្គទី៤៨

# ពុទ្ធឱវាទសំខាន់ៗដល់ភិក្ខុសង្ឃ

# (Important instruction of Gautama Buddha for the Buddhist Monks)



ព្រះអង្គទ្រង់សំដែងធម្មទេសនាដល់ភិក្ខុទាំងឡាយនៅព្រៃមហាវ័ន
( ស្រង់ពី Internet )

**មហាអានន្ទ** បានចាត់ចែងហៅភិក្ខុទាំងអស់ដែលគង់នៅជិតៗក្រុង **វេសាលី** ទាំងប៉ុន្មាន ខ្លះនៅតាមភូមិស្រុកតូចៗ ដែលស្ថិតនៅជុំវិញក្រុង បានមកជួបជុំគ្នានៅព្រៃ **មហាវ័ន**។ នៅទីនោះ ព្រះបរមគ្រូទ្រង់គង់ក្រោមដើមឈើធំមួយ តាំងពីថ្ងៃរហូតទល់យប់ កាលបើភិក្ខុទាំងអស់បានមកជួបជុំគ្នាហើយ ព្រះអង្គក៏ទ្រង់សម្តែងធម៌ ៣ យ៉ាងគឺ ១-**ទេសិតធម៌**(Dharma that guides human into becoming angels) ២-**ពោធិបក្ខិយធម៌** (Dharma that guides to enlightenment; usually referred to as the 37 qualities or items contributing to Bodhi.) ៣-**អប្បមាទធម៌** (Dharma that guides to consciousness) ដែលបង្ហាញអោយភិក្ខុនៅទីនោះ ដឹងពីការគោរពប្រតិបត្តិអោយបានត្រឹមត្រូវ នូវគោលបទធម៌វិន័យដែលព្រះអង្គបានបង្ហាត់បង្ហាញរួចមកហើយ។ ក្នុងអត្ថន័យនៃព្រះធម៌ពេលនោះព្រះអង្គបានសម្តែងថា: "ភិក្ខុទាំងឡាយត្រូវគោរពប្រតិបត្តិធម៌វិន័យអោយបានល្អប្រសើរ ជាគំរូដល់មហាជន និងបង្ហាញបន្តដល់មនុស្សលោកទាំងពួងអោយគោរពប្រតិបត្តិតាមគំរូល្អនេះដូចខ្លួនដែរ ការអនុវត្តណែនាំមនុស្សទាំងពួង

www.elibraryofcambodia.org

អោយធ្វើដូចខ្លួនបាន នោះអាស្រ័យត្រូវធ្វើកិច្ចសន្តិវិធី (peaceful mothod) វក្សា អធ្យាក្រិតភាព ការប្រកាន់ភាពបរិសុទ្ធត្រឹមត្រូវ និងគតិយុត្តិធម៌នោះ ទើបពិភព លោកបានសុខសន្តិភាព ត្រូវញ៉ាំងប្រយោជន៍ខ្លួន រួមនិងប្រយោជន៍អ្នកដទៃអោយ បរិបូរណ៍ ចូរគ្រប់គ្រងផ្លូវចិត្តរបស់ខ្លួនចូរជៀសវាងកុំអោយមានក្តីប្រមាថផងទាំង ឡាយទាំងពួង នោះសេចក្តីសុខទាំងប៉ុន្មាន សេចក្តីចម្រើនទាំងឡាយនឹងបានជា ប្រាកដ ហើយសេចក្តីទុក្ខនឹងមិនមានកាលវិលវល់កើត ស្លាប់នៅលើវាលវដ្តសង្សារ នោះទៀតដែរ" ។

ភិក្ខុទាំងឡាយដែលនៅទីនោះ ខិតខំត្រងត្រាប់ស្តាប់ពុទ្ធឱវាទទាំងប៉ុន្មាន ដោយយកចិត្តទុកដាក់ជាទីបំផុត គ្រប់ៗអង្គបានប្តេជ្ញាក្នុងចិត្ត ត្រូវតែខិតខំសិក្សា រក្សាការប្រតិបត្តិតាមពុទ្ធដីកា មិនអោយខ្វះចន្លោះឡើយ លើសពីនេះទៅទៀត គ្រប់ៗអង្គក៏ដឹងច្បាស់ថា ពេលវេលានេះប្រហែលជាដំបូន្មានចុងក្រោយរបស់ ព្រះអង្គហើយ ព្រោះនៅតែ ៣ ខែទៀត ទ្រង់នឹងចូល **បរិនិព្វាន** ដូច្នេះព្រះអង្គ ត្រូវប្រឹងប្រែងសម្តែងធម៌ឱវាទសំខាន់ៗដល់ភិក្ខុសង្ឃរបស់ព្រះអង្គ ដើម្បីអោយ បានក្លាយខ្លួនជាបុគ្គលល្អពិសិទ្ធសម្រាប់សាសនាព្រះអង្គ។ ទ្រង់ខំសម្តែងពុទ្ធឱវាទ លុះត្រាយប់យន់រាត្រីទើបបញ្ចប់ ។

www.elibraryofcambodia.org

# វគ្គទី៤៩

# ក្រុងវេសាលីចុងក្រោយ

# (A final look at the the city of Vashali)



ព្រះអង្គនិមន្តមកដល់ក្រុងវេសាលី ( ស្រង់ចេញពី Sakyamuni Buddha )

ព្រះអាទិត្យផ្ដើមបំភ្លឺពិភពលោកជាថ្មី **ព្រះពុទ្ធបរមគ្រូ** និង **មហាអានន្ទ** ជំនិតក៏ផ្ដើមរៀបចំចាកចេញពីអាស្រម ដែលទ្រង់គង់នៅដើម្បីនិមន្តបិណ្ឌបាត្រជាប្រក្រតី ទ្រង់ក៏បាននិមន្តដល់ក្រុង **វេសាលី** ។ ព្រះអង្គទ្រង់ឈប់នៅទីនោះមួយសន្ទុះទ្រង់ទតទៅទីក្រុងចុងក្រោយនៃដំណើររបស់ព្រះអង្គ ។ ព្រះអង្គទ្រង់មានពុទ្ធដីកាទាំង ព្រះភ័ក្ត្រទតទៅកាន់ទីក្រុងដោយបន្ទូលថា: "ម្នាល! សាវ័ក **អានន្ទ** ពេលនេះតថាគតបានឃើញទីក្រុង **វេសាលី** នេះជាចុងក្រោយហើយ! តំណេតទៅទីក្រុងនេះបានត្រឹមតែមានឈ្មោះជាមួយ **តថាគត** ប៉ុណ្ណោះ! បន្ទាប់ពីនេះ យើងត្រូវនិមន្តទៅស្រុក **ភណ្ឌគ្រាម** (Bhanda Khrama) ទៀត!" ។ ទ្រង់និមន្តពី **ភណ្ឌគ្រាម** បានទៅដល់ស្រុក ៣ ទៀតគឺ **ហត្ថី** (Hartthi Khrama) **អម្ពគ្រាម** (Amba Khrama) និង **ជម្ពូគ្រាម** (Jambu Khrama) នៅស្រុកទាំងនេះ **ព្រះពុទ្ធ** ជាម្ចាស់ទ្រង់សម្ដែងធម៌ **សីល សមាធិ បញ្ញា** និង **វិមុត្តិ** ដែលជា **អរិយធម៌** ដល់ភិក្ខុទាំងឡាយ និងអ្នកស្រុកដែលរស់នៅទីនោះ ។

www.elibraryofcambodia.org

បន្ទាប់មកព្រះអង្គ និង **អានន្ទ** បាននិមន្តទៅដល់នគរ **ភោគៈ** (Bhoga) ទ្រង់ក៏ប្រថាប់នៅតំបន់មួយឈ្មោះ **អានន្ទចេតិយ** (Anada Stupa)។ នៅអែរនោះដែរ ព្រះអង្គក៏ខំសម្តែងធម្មទេសនា **មហាបទេស** ៤ យ៉ាងនៃព្រះសូត្រ ដើម្បីប្រៀនប្រដៅដល់ភិក្ខុសង្ឃទាំងឡាយ អោយដឹងច្បាស់ពី **ផ្លូវធម៌ គោលធម៌** ដែលជាការអប់រំយ៉ាងសំខាន់ៗ និងមានសារៈប្រយោជន៍ ព្រមទាំងសម្តែងពី **ត្រៃសិក្ខា** ជាច្រើនទៀត។

www.elibraryofcambodia.org

# វគ្គទី៥០

# ព្រះសាស្តាទ្រង់ប្រឈួនជាទម្ងន់

## (Gautama Buddha was in serious ill while traveling to Kushinagara)



ព្រះអង្គទ្រង់ប្រឈួន ( ស្រង់ចេញពីវត្ត ទឹកថ្លា ក្រុងភ្នំពេញ ប្រទេសកម្ពុជា)

ក្រោយពីទូន្មានប្រៀបប្រដៅសព្វគ្រប់ប្រការក្នុងស្រុកជាច្រើនហើយ **ព្រះមុនីសាស្តា** និង **មហាអានន្ទថេរ** ក៏ទ្រង់និមន្តបន្ត គឺទិសដៅនគរ **កុសិនារា** (Kushinagara) បន្ទាប់មកទ្រង់និមន្តទៅដល់ជាយក្រុង **បាវា** (City of Pava) ទ្រង់ឈប់សម្រាកព្រះកាយនៅចំការស្វាយមួយរបស់នាយ **ចុន្ទ**(Chunda)។ នាយ **ចុន្ទ** ក៏នាំក្រុមគ្រួសារទៅក្រាបថ្វាយបង្គំព្រះអង្គដែលទ្រង់និមន្តមកដល់ចំការរបស់ខ្លួន។ នៅទីនោះ **ព្រះមុនីសាស្តា** ទ្រង់សម្តែង **ធម្មកថា** ដល់ក្រុមគ្រួសារនាយ **ចុន្ទ** ធ្វើអោយគ្រួសារគាត់មានជំនឿជឿជាក់លើព្រះធម៌ព្រះអង្គគួរជាទីពឹងពាក់។ នាយ **ចុន្ទ** មានចិត្តសទ្ធាបាននិមន្តព្រះអង្គ និង **អានន្ទ** សាវ័កអោយទៅទទួលចង្ហាន់នៅផ្ទះគាត់ វេលាព្រឹកស្អែក ព្រះបរមគ្រូក៏អារាធនាតាមការនិមន្តរបស់គ្រួសារនាយ **ចុន្ទ**។ នៅរាត្រីនោះ គ្រួសារនាយ **ចុន្ទ** បានរៀបចំផ្ទះសំបែង គ្រឿងប្រដាប់ប្រដា និងចង្ហាន់ត្រៀមទុកទទួល **ព្រះសាស្តា**។

ព្រឹកឡើងព្រះអង្គក៏រៀបចំនិមន្តទៅផ្ទះគ្រួសារនាយ **ចុន្ទ** តាមពុទ្ធដិកាពីម្សិល។ នៅពេលវេលាជិតដល់ពេលត្រូវឆាន់ ព្រះអង្គគង់នៅទីសមរម្យ ដែលក្រុម

www.elibraryofcambodia.org

គ្រួសារនាយ **ចុន្ទ** បានរៀបចំទុកថ្វាយ ។ ព្រះអង្គទ្រង់ឆាន់ម្ហូបម្យ៉ាងដែលចំអិនដោយផ្សិតមួយប្រភេទ ដែលដុះចេញពីដើមច័ន្ទក្រឹស្នា ។ ពេលបានឆាន់រួច ស្រាប់តែព្រះអង្គមានអាការៈរោគចាស់លាប់ឡើងវិញ មានសភាពធ្ងន់ធ្ងរជាងពេលមុនទៀត ដោយមានធ្លាក់លោហិតមកផង ទ្រង់មានព្រះកាយឈឺចាប់ និងអស់កម្លាំងជាខ្លាំង ។ **អានន្ទ** ឃើញដូច្នេះទ្រង់ព្រួយបារម្ភជាអនេក បានទូលសួរទៅ **ព្រះពុទ្ធ** ថាៈ "បពិត្រព្រះគុណម្ចាស់! សូមព្រះអង្គកុំអាលនិមន្តទៅមុខទៀតអី! ទ្រង់គប្បីនៅសម្រាកព្រះកាយព្យាបាលសិនទៅព្រះអង្គ!" ។ **ព្រះបរមសាស្តា** ទ្រង់បានតាំងស្មារតីយ៉ាងមាំ ហើយមានពុទ្ធដីកាតបទៅ **អានន្ទ** វិញថាៈ "ម្នាល **អានន្ទ!** តថាគតមិនអីទេ! អ្នកកុំព្រួយបារម្ភអី! យើងត្រូវតែបន្តដំណើរទៅមុខទៀត យ៉ាងណាក៏ដោយត្រូវតែទៅដល់នគរ **កុសិនារា** តាមក្តីប្រាថ្នារបស់ **តថាគត!**" ។ ដូចព្រះអង្គមានពុទ្ធដីកា ទោះបីមានព្រះកាយឈឺចាប់យ៉ាងណាក៏ដោយ ក៏ទ្រង់អត់ធ្មត់ តស៊ូធ្វើដំណើរចាកចេញពីស្រុកនេះ ឆ្ពោះទៅកាន់ទិសដៅនគរ **កុសិនារា** ។

www.elibraryofcambodia.org

# វគ្គទី៥១

# បុក្កុសរាជទាយាទ (Prince Pukusa)



មហាអានន្ទដងទឹកស្ទឹងថ្វាយព្រះអង្គ
( ស្រង់ចេញពីវត្តសំរោងអណ្តែត )

សែនសង្វេគដល់អង្គ **ព្រះសាស្តា** និង **មហាអានន្ទ** សាវ័ក ទ្រង់ខំតស៊ូនិមន្តបន្តបន្តិចម្តងៗ ទាំងទុក្ខព្រាំព្រា តែទឹកព្រះទ័យបានពុះពារក្រៃគ្មានអ្វីប្រៀបបានឡើយ ទ្រង់ប្តេជ្ញាត្រូវតែទៅអោយដល់គោលដៅ ។ មកដល់ពាក់កណ្តាលផ្លូវដោយព្រះកាយហត់ឡើយ ទ្រង់ក៏ចូលទៅសម្រាកក្រោមដើមឈើមួយ ទ្រង់បង្គាប់អោយ **អានន្ទ** ទៅដងទឹកអោយព្រះអង្គសោយនៅស្ទឹង **កក្កុត្ថា** (Kakutta river) ដែលស្ថិតនៅក្បែរនោះ ពេលនោះ **អានន្ទ** ទ្រង់ថេរ-ដិកាទូលទៅព្រះអង្គថា: "ស្ទឹងនេះមានសភាពល្អក់ ដោយហេតុថាមានក្រុមរទេះទើបបរកាត់ទីនេះ! មិនគួរព្រះអង្គសោយបានឡើយ!" ។ ព្រះបរមគ្រូទ្រង់មានពុទ្ធដិកាតបវិញថា: "មិនអីទេ! ទៅដងចុះ!" ។ **អានន្ទ** ទាល់តម្រិះ ក៏សម្រេចចិត្តទៅដងទឹកក្នុងស្ទឹងនោះថ្វាយព្រះអង្គ ប៉ុន្តែពេល **អានន្ទ** ទៅដល់ទីទឹកស្ទឹង ក៏ស្រាប់តែទឹកស្ទឹងប្រែក្លាយទៅជាថ្លាយង់យល់ដល់បាតដី **អានន្ទ** មានចិត្តសប្បាយក៏ម្នីម្នាដងមកថ្វាយព្រះអង្គ។ សម័យកាលនោះមានរាជបុត្រស្តេចមួយអង្គ ព្រះនាម **បុក្កុស** (prince Pukusa) ជាសិស្ស **អាឡារតាបស** បានចេញពីនគរ **កុសិនារា** ដើម្បីធ្វើដំណើរទៅកាន់នគរ **បាវា** ជួនក៏បានជួបនិង **ព្រះសាស្តា** ទ្រង់គង់ក្រោមដើមព្រឹក្សរាជទាយាទ **បុក្កុស** ក៏ចូលទៅថ្វាយបង្គំព្រះអង្គ ។

www.elibraryofcambodia.org

**ព្រះពុទ្ធ** ជាម្ចាស់ទ្រង់ទតរាជបុត្រ សមប្រកបដោយលក្ខណៈទសពិធរាជធម៌ ព្រះអង្គក៏សម្តែង **សន្តិវិហារធម៌** ដល់រាជបុត្រា **បុក្កុស** ដើម្បីអោយព្រះអង្គយល់ការប្រកបដោយសន្តិភាព ជាលទ្ធផលល្អប្រសើរដល់រាជនគរ និងប្រជារាស្ត្រស្ថិតនៅដោយក្តីសុខសាន្ត។ រាជបុត្រា **បុក្កុស** ក្រោយពីស្តាប់ព្រះធម៌របស់ព្រះបរមគ្រូ ក៏មានព្រះទ័យជឿជាក់ស្មោះស្ម័គ្រលើព្រះធម៌ និងសាសនាព្រះអង្គអស់ពីដួងចិត្ត ហើយប្តេជ្ញាថានឹងគោរពប្រតិបត្តិតាមឱវាទដោយគ្មានការរារែកអ្វីក្នុងព្រះទ័យឡើយ។

រាជទាយាទ **បុក្កុស** បានប្រគេនក្រណាត់ពណ៌មាសពីរដុំដល់ **ព្រះពុទ្ធ** ជាម្ចាស់ តែព្រះអង្គទទួលយកតែមួយដុំ ឯមួយដុំទៀត ទ្រង់មានពុទ្ធដីកាត្រាស់អោយបុត្រាប្រគល់ទៅ **អានន្ទថេរ** វិញ។ រាជទាយាទ **បុក្កុស** ក៏ទ្រង់ធ្វើតាមពុទ្ធដីកា បន្ទាប់មកព្រះរាជបុត្រ **បុក្កុស** ក៏ថ្វាយបង្គំលា **ព្រះបរមសាស្តា** និង **មហាអានន្ទ** ចាកចេញទៅ។ ចំណែក **ព្រះបរមសាស្តា** និង **មហាអានន្ទថេរ** ក៏ទ្រង់និមន្តបន្តដំណើរទៅមុខទៀត។



ព្រះរាជបុត្របុកុសបានជួបព្រះអង្គ ‹ ស្រង់ចេញពីវត្តទឹកថ្លា ›

www.elibraryofcambodia.org

# វគ្គទី៥២

# អានន្ទវិយោគ (Sobbing of Ananda)

ជាច្រើនថ្ងៃក្រោយមក **ព្រះពុទ្ធ** និង **អានន្ទ** សាវ័ក ក៏បានមកដល់កូនស្ទឹងតូចមួយឈ្មោះ **ហិរញ្ញវតី** (Hiranyavati river) គឺជាព្រះប្រទល់នគរ **បាវា** និងនគរ **កុសិនារា**។ ស្ទឹង **ហិរញ្ញវតី** ជាកូនស្ទឹងតូចមួយ ហើយមានទឹករាក់អាចដើរឆ្លងទៅមកបាន ព្រះអង្គ និង **អានន្ទ** ក៏នាំគ្នានិមន្តឆ្លងកាត់កូនស្ទឹងទឹករាក់នោះទៅកាន់ត្រើយម្ខាង ដែលជាទឹកដីនគរ **កុសិនារា**។ ឆ្លងស្ទឹងតូចនោះហើយ ព្រះអង្គក៏និមន្តទៅដល់ព្រៃ **សាលវ័ន** (Salavana) ទីនោះជាកន្លែងរមណីដ្ឋានមួយដែលពួកស្ដេច និងត្រកូលក្សត្រតែងនាំគ្នាមកលេងកំសាន្ត ស្ថិតនៅជាយក្រុងនៃនគរ **កុសិនារា**។

ដោយព្រះកាយនឿយហត់ពន់ពេក ក្នុងការធ្វើដំណើរជាច្រើនថ្ងៃ ម្យ៉ាងព្រះអង្គមានជំងឺស្រាប់ផង ព្រះអង្គត្រូវតែសម្រាកក្នុងព្រៃ **សាលវ័ន** នេះ។ ទ្រង់ទតទិដ្ឋភាពព្រៃជុំវិញមួយភ្លែត ក៏ប្រទះឃើញដើមរាំងភ្នំមួយគូ ក៏ទ្រង់ត្រាស់បង្គាប់ទៅ **អានន្ទ** ថា: "ម្នាល **អានន្ទ**! ពេលនេះ **តថាគត** អស់កម្លាំងខ្លាំងណាស់! មិនអាចបន្តដំណើរទៅមុខទៀតបានទេ ចូរអ្នករៀបចំកន្លែងនៅចន្លោះក្រោមដើមរាំងទាំងពីរនោះ អោយ **តថាគត** សម្រាក!"។ **អានន្ទ** ម្ទីម្ទារៀបចំគ្រែ ហើយយកសំពត់សង្ឃាដីរបស់ព្រះអង្គក្រាលពីលើគ្រែ ដោយដាក់ក្បាលដំណេកទៅទិសខាងជើងស្ថិតនៅចន្លោះដើមរាំងទាំងពីរ។

www.elibraryofcambodia.org


មហាអានន្ទវិយោគ

**ព្រះពុទ្ធបរមគ្រូ** ទ្រង់ផ្ទុំផ្ទៀងព្រះកេស ទៅស្តាំដោយយកព្រះហត្ថស្តាំទ្រពីក្រោម ឯព្រះហត្ថឆ្វេងដាក់សណ្តូកលើព្រះបាទឆ្វេង ដែលគងលើព្រះបាទស្តាំ។ ព្រះអង្គទ្រង់ផ្ទុំពុំបានលក់ឡើយ គ្រាន់តែសម្រាក ខ្លះសំរួលការធូរស្បើយពីការនឿយហត់ប៉ុណ្ណោះ ចំណែកព្រះទ័យព្រះអង្គពោរពេញទៅដោយភាពស្ងប់ស្ងាត់ មិនមានភាពរវើយរវាយអ្វីបន្តិចឡើយ ។ឃើញព្រះបរមគ្រូទ្រង់ផ្ទុំដោយស្ងៀមស្ងាត់ **អានន្ទ** ក៏និមន្តលបៗ ខ្លាចប៉ះពាល់ធ្វើអោយព្រះអង្គភ្ញាក់ ចាកចេញពីទីនោះ ហើយនិមន្តចូលព្រៃមួយក្បែរនោះ ហើយទួញយំតែអង្គឯង។ **អានន្ទ** ទ្រង់មានទឹកភ្នែកហូររហាម ពោលតិចៗទាំងខ្សឹកខ្សួលថា: "ឱ! វាសនាអាត្មាអញអើយ! មិនទាន់បានត្រាស់ជា **ព្រះអរហន្ត** នៅឡើយឥឡូវ **ព្រះបរមគ្រូជាម្ចាស់** ព្រះអង្គនឹងត្រូវចូល **បរិនិព្វាន** រលត់ខន្ធចោលអាត្មាអញទៀត! តើអោយអាត្មាអញទៅពឹងលើអ្វី?"។ គួរសង្វេគ **មហានន្ទសាវ័ក** ទ្រង់ទួញសោកឥតស្រាកស្រាន្ត ព្រោះតែព្រួយខ្លាចបាត់បង់ព្រះបរមគ្រូជាទីសក្ការៈគោរពស្មើជីវិត ធ្វើអោយ **មហាអានន្ទ** នៅតែបន្តទុក្ខសោកក្នុងទ្រូង ព្រៃតែអង្គឯង គ្មានអ្នកណាអាចជួយរំលែកទុក្ខព្រួយពីព្រះអង្គបានឡើយ ។

ក្រោយមកដំណឹង **ព្រះពុទ្ធ** និមន្តមកដល់ព្រៃ **សាលវ័ន** ហើយទ្រង់កំពុងមានជំងឺទៀតផងនោះ បណ្តាលអោយភិក្ខុទាំងឡាយនៅក្នុងតំបន់ ក៏នាំគ្នាគ្រប់អង្គនិមន្តមកមើល **ព្រះបរមសាស្តា** នៅចន្លោះដើមរុក្ខាទាំងទ្វេ។ ខណៈដែល **ព្រះពុទ្ធ** ទ្រង់ដឹងព្រះកាយ ហើយបើកព្រះនេត្រឡើងទតឃើញបណ្តាភិក្ខុទាំងឡាយនៅជុំវិញព្រះអង្គ បាត់តែ **អានន្ទ** មិនឃើញ ក៏ទ្រង់ត្រាស់សួរទៅភិក្ខុនៅ

www.elibraryofcambodia.org

ក្បែរនោះថា: "ម្នាលភិក្ខុ! ចុះ **អានន្ទ** ទៅណាហើយ ម្តេចបានជាមិនឃើញនៅទីនេះ?" ភិក្ខុនៅជិតព្រះអង្គក៏ទូលថ្វាយតបទៅវិញថា: "បពិត្រព្រះបរមគ្រូជាម្ចាស់! **មហាអានន្ទ** ទ្រង់គង់នៅក្នុងព្រៃឯណោះ! កំពុងមានទុក្ខទួញសោកឥតឧបមា ដោយទ្រង់គិតថាព្រះគុរម្ចាស់ **បរិនិព្វាន** ទៅ លោកគ្មានអ្វីប្រតិបត្តិ និងជាទីពឹងទៀត!"។ **ព្រះពុទ្ធ** ជាម្ចាស់ទ្រង់សណ្តាប់ហើយ ព្រះអង្គទ្រង់ដឹងពីទុក្ខព្រួយរបស់ **អានន្ទសាវ័ក** ទ្រង់ត្រាស់បង្គាប់ដល់ភិក្ខុគង់នៅក្បែរ អោយទៅហៅ **អានន្ទ** ដើម្បីព្រះអង្គប្រើទឹកព្រះទ័យលួងលោមផ្អែកផ្លូវចិត្តដល់រូប **អានន្ទ** វិញ។ ភិក្ខុនៅក្បែរនោះក៏ក្រាបបង្គំលាព្រះអង្គទៅហៅ **អានន្ទ** ដែលកំពុងទុក្ខសោកនៅក្នុងព្រៃមួយអង្គឯង។ ភិក្ខុមកដល់ក៏ប្រាប់ទៅ **អានន្ទ** តាមពុទ្ធដីកា **អានន្ទ** ដឹងហើយកាលណោ ក៏មីម្នាជូតទឹកភ្នែកយ៉ាងស្អាតហើយត្រឡប់ចូលគាល់ **ព្រះបរមសាស្តា** វិញ។



មហាអានន្ទចូលគាល់ព្រះអង្គ ‹ ស្រង់ចេញពីស.ភ Sakyamuni Buddha ›

www.elibraryofcambodia.org

# វគ្គទី៥៣

# អានន្ទត្រូវបានលើកសរសើរ

## (Gautama praised Ananda)



ព្រះអង្គសរសើរដល់មហាអានន្ទ
(ស្រង់ចេញពីវត្តសំរោងអំហ្គេត)

លំដាប់ពេលដែល **មហាអានន្ទ** បានមកជួប **ព្រះសាស្តា** ហើយព្រះអង្គទ្រង់មានព្រះភាគលើកសរសើរឡើងដល់ព្រះ **អានន្ទ** នៅចំពោះមុខភិក្ខុសង្ឃទាំងឡាយ ដែលនៅជុំវិញព្រះអង្គដោយមានពុទ្ធដិកាថា: "ម្នាលភិក្ខុទាំងឡាយដឹងទេ! តាំងពីបុរាណកាលមក **ព្រះពុទ្ធ** គ្រប់អង្គ តែងមាន **ឧបដ្ឋាក** (attend-ant) ដ៏គាប់ប្រសើរនៅក្បែរព្រះកាយគ្រប់ៗអង្គ ប៉ុន្តែ **ឧបដ្ឋាក** ទាំងនោះមិនល្អស្មើនឹង **អានន្ទ** ដែលជាឧបដ្ឋាករបស់ **តថាគត** នាពេលនេះឡើយ **អានន្ទ** ជាអ្នកជំនិត នៅបំរើជាប់ **តថាគត** បានល្អឥតខ្ចោះ **អានន្ទ** ពោរពេញដោយលក្ខណៈសម្បត្តិល្អប្រពៃ ប្រាជ្ញាវៀងវៃដែល **តថាគត** មិនដែលជួបប្រទះទាល់តែសោះ! **អានន្ទ** បានធ្វើរបៀបរៀបចំតម្រូវតាមពេលវេលាសមរម្យ ដើម្បីអោយពុទ្ធបរិស័ទទាំងឡាយ ដែលប្រាថ្នាចង់ជួប **តថាគត** អោយបានជួបយ៉ាងល្អប្រសើរ ជានិច្ចកាល **អានន្ទ** ចេះធ្វើបដិសណ្ឋារកិច្ចគ្រប់យ៉ាង ដើម្បីទទួលរាក់ទាក់ភ្ញៀវទាំងឡាយ ធ្វើអោយពួកគេមានចិត្តរីករាយ **អានន្ទ** សម្តែងធម៌ធ្វើអោយពួកបរិស័ទចាប់អារម្មណ៍លើធម៌ដែល **អានន្ទ**

www.elibraryofcambodia.org

សម្តែងជាពន់ពេកណាស់ ពួកគេមិនចេះធុញទ្រាន់អ្វីសោះឡើយ! គ្រប់ពេលវេលា **អានន្ទ** ជាឧបដ្ឋាកដ៏ល្អអស្ចារ្យរបស់ **តថាគត!**"។

**អានន្ទ** ត្រង់ត្រាប់ស្តាប់ពុទ្ធដិកាសរសើរដល់ខ្លួនហើយ គួរតែមានព្រះទ័យត្រេកអរ តែមិនដូច្នេះឡើយ **អានន្ទ** ពេលនោះទ្រង់មិនមានអារម្មណ៍ចំពោះការសរសើរពី **ព្រះពុទ្ធ** ដោយក្នុងព្រះទ័យនៅដក់ជាប់ក្តីទុក្ខព្រួយបារម្ភជាប់ជានិច្ច ដោយគិតថា **ព្រះពុទ្ធបរមគ្រូ** នៃខ្លួននឹងត្រូវចូល **បរិនិព្វាន** ចោលព្រះអង្គ **អានន្ទ** ទប់អារម្មណ៍បានស្រួលបួលពីទុក្ខព្រួយមួយឡែក ហើយសម្រួលក្រាបបង្គំទូលទៅ **ព្រះបរមសាស្តា** វិញថាៈ "បពិត្រព្រះអង្គដ៏មានគុណ! សូមទ្រង់កុំទាន់ចូល **បរិនិព្វាន** នៅទីនេះធ្វើអ្វី! ត្បិតទីនេះជាទីព្រៃមិនសមរម្យទាល់តែសោះ សូមព្រះអង្គជ្រើសរើសយករាជធានីណាមួយ ដូចជាក្រុង **រាជគ្រឹះ** ក្រុង **សាវត្ថី** ឬរាជធានីណាដ៏ទៃទៀត ដែលមានច្រើនដោយសាវ័កព្រះអង្គដែលជាអរហន្ត ឬក៏អស់លោកមន្ត្រី សេនាបត្តី ឬអង្គព្រះមហាក្សត្រជាដើម ដែលពោរពេញដោយអំណាច និងធនធានច្រើន ពួកគេអាចនឹងអាចចាត់ចែងសព្វយ៉ាងដល់ព្រះសពព្រះអង្គបានយ៉ាងស័ក្តសមទៅនិងព្រះកិត្តិយសរបស់គុណម្ចាស់!"។

**ព្រះពុទ្ធ** ទ្រង់យល់ពីបំណងល្អរបស់របស់ **អានន្ទ** ដែលចង់អោយព្រះអង្គជ្រើសរើសទីកន្លែងសមរម្យនឹងព្រះអង្គ ដើម្បីចូល **ព្រះនិព្វាន** ប៉ុន្តែទ្រង់ដឹងរួចទៅហើយថា ទីណាកន្លែងណាដែលព្រះអង្គត្រូវជ្រើសរើសទុកជាមុនសម្រាប់ទ្រង់នោះ គឺជាទីព្រៃទឹកដីនគរ **កុសិនារា** នេះឯង។ ព្រះអង្គទ្រង់មានពុទ្ធដិកាពន្យល់ប្រាប់ទៅ **អានន្ទ** វិញថាៈ "ម្នាល **អានន្ទ!** ទីនេះហើយដែលជាកន្លែងស័ក្តសមសម្រាប់ **តថាគត** ចូល **បរិនិព្វាន** នោះ! អ្នកមិនដឹងទេ! ទីនេះកាលពីយូរលង់ណាស់មក ហើយជារាជធានីរុងរឿងមួយ ដែលគ្រប់គ្រងដោយមហាក្សត្រា

www.elibraryofcambodia.org

ធិរាជមួយព្រះអង្គ ព្រះនាម **មហាសុទស្សន** (Mahashuthana) ជាស្តេចចក្រពត្តិ មានទីនគរចំណុះជាច្រើន ជាទីសំបូរស្តុកស្តម្ភណាស់! ម្នាល **អានន្ទ** ចូរអ្នកកុំពិបាកចិត្តថ្វី! **តថាគត** បានប្រាប់អស់ហើយ រាល់សង្ខារទាំងឡាយមិនមានអ្វីជាការទៀងទាត់ឡើយ តែងត្រូវអន្តរាយទៅវិញជាធម្មតា! ឥឡូវនេះចូរអ្នកទៅកាន់ក្រុង **កុសិនារា** ថ្វាយដំណឹងដល់ព្រះរាជា និងអស់ប្រជានុរាស្ត្រទូទៅនៅថ្ងៃនេះតែម្តង! ព្រោះនៅវេលាជិតភ្លឺព្រឹកស្អែកមុនពេលអារុណរះ **តថាគត** និងចូល **បរិនិព្វាន** ហើយ! ប្រសិនអ្នកទាំងឡាយនោះចង់ឃើញ **តថាគត** ពេលចុងក្រោយ អោយពួកគេមកមើលចុះ!" ។

ដឹងពុទ្ធដិកាដូច្នេះហើយ **អានន្ទ** និងភិក្ខុជាច្រើនអង្គ ក៏នាំគ្នានិមន្តទៅកាន់ក្រុង **កុសិនារា** ដើម្បីថ្វាយដំណឹងដល់ស្តេច **មល្លះ** (King Malla) និងរាជទាយាទ ទាំងរាជបុត្រា រាជសិណើសាទាំងអស់បានជ្រាបហើយ ក៏មានទុក្ខព្រួយអាឡោះអាល័យជាខ្លាំង ចំណែកប្រជានុរាស្ត្រក្នុងនគរក៏មានទុក្ខទួញសោកស្រណោះ **ព្រះបរមសាស្តា** គ្រប់ៗគ្នា ខ្លះយំខ្សឹបខ្សួលរៀបរាប់ថា: "ឱ **ព្រះបរមគ្រូ** ជាម្ចាស់នៃយើងអើយ! មិនគួរព្រះអង្គឆាប់ចូល **បរិនិព្វាន** យ៉ាងនេះសោះ! ពេលអស់ពីព្រះអង្គទៅ ក្នុងលោកយើងនេះហាក់បីដូចជាចង្កៀងគ្មានពន្លឺយ៉ាងដូច្នេះដែរ!" ។ ហេតុដូចនេះហើយមហាជនទាំងនោះ ក៏នាំគ្នាប្រូតរះធ្វើដំណើរទៅកាន់ព្រៃ **សាលវ័ន** ទីកន្លែងដែល **ព្រះបរមសាស្តា** ទ្រង់គង់ចូល **បរិនិព្វាន** ។ គ្រប់ៗគ្នាមានបំណងចង់ឃើញព្រះអង្គមុនថ្ងៃរះ និងអោយទាន់ពេលវេលាចុងក្រោយរបស់ព្រះអង្គផងដែរ ។

www.elibraryofcambodia.org

# វគ្គទី៥៤
# សុភទ្ទបច្ឆិមភិក្ខុ
## (Subhadra last a Bhikkhu)

បណ្តាមហាជននាំគ្នាទៅមើល **ព្រះអង្គសាស្តា** មហាវិយោគវិជ្ជលអស់ស្ថានទេវលោក មានភាពអ៊ូអរហូរហែរមិនដាច់។ កាលបានឃើញព្រះអង្គហើយទាំងអស់គ្នាក៏មានបំណងមិនចង់ឃ្លាតឆ្ងាយពីព្រះអង្គទាល់តែសោះ ចេះតែនៅស្រណោះព្រះអង្គគ្រប់ៗគ្នា។ ពេលនោះស្រាប់តែមានយុវជនម្នាក់ឈ្មោះ **សុភទ្ទ** (Subhdra) ដែលបានធ្វើដំណើរពីស្រុកឆ្ងាយ បានចូលមកដល់ក្រុង **កុសិនារា** ហើយបានឮដំណើងថា **ព្រះពុទ្ធ** ជិតចូល **និព្វាន** ក៏ម្នីម្នាទៅរកព្រះអង្គភ្លាម ក្នុងបំណងចង់ចូលសុំសួរនូវបញ្ហាមួយចំនួន ដែលខ្លួនមានជាយូរមកហើយ ព្រោះគាត់តែងគិតឃើញថា បញ្ហាដែលជាចម្ងល់សម្រាប់ខ្លួនគាត់នេះ គឺមានតែ **ព្រះពុទ្ធ** ទេទើបអាចបកស្រាយបំភ្លឺបាន ដូច្នេះគឺមានតែគាត់ប្រឹងប្រែងស្ទាត់ទៅរកព្រះអង្គដើម្បីជួយដោះចម្ងល់របស់គាត់។

ពេលបានទៅដល់ព្រៃ **សាលវ័ន** ភ្លាម **សុភទ្ទ** មិនបានទៅជួប **ព្រះពុទ្ធ** ដូចបំណងភ្លាមនោះទេ ដោយ **មហាអានន្ទ** បានឃាត់នៅខាងក្រៅដោយប្រាប់គាត់ថា **ព្រះពុទ្ធ** ទ្រង់កំពុងប្រឈួន ហើយទ្រង់អស់កម្លាំងខ្លាំងណាស់ មិនអាចអោយអ្នកណាទៅរំខានព្រះអង្គដោយប្រការណាមួយឡើយ ប៉ុន្តែ **សុភទ្ទ** នៅតែទទូចសុំហើយសុំទៀត សុំអោយ **ព្រះពុទ្ធ** ឆ្លើយបំភ្លឺនូវបញ្ហារបស់គាត់មុនទ្រង់ចូល **បរិនិព្វាន**។ ចំណែកឯ **អានន្ទ** នៅតែមិនព្រមអនុញ្ញាត្តិអោយគាត់ចូលជ

www.elibraryofcambodia.org


សុភទ្ទសួរសំនួរដល់ព្រះអង្គ

ដែល ។ ការជជែកគ្នាចុះឡើង **ព្រះពុទ្ធ** បានឮសំដីអ្នកទាំងពីរ ម្នាក់សុំម្នាក់ឃាត់ ព្រះអង្គក៏អនុញ្ញាតិអោយ **សុភទ្ទ** ចូលជួបដោយទ្រង់ដឹងពីបំណងរបស់គាត់សព្វប្រការ ។ **ព្រះបរមគ្រូ** ទ្រង់ត្រាស់ទៅ **អានន្ទ** ថា: "ម្នាល **អានន្ទ**! ចូរអ្នកអោយគាត់ចូលមកចុះ ព្រោះគាត់មានបំណងចង់ជួប **តថាគត** ហើយ ត្រូវតែបំពេញបំណងអោយគាត់! ការដោះស្រាយបញ្ហារបស់គាត់ មិនមានអ្វីប៉ះពាល់ដល់សុខភាព **តថាគត** ឡើយ!"។ ឮពុទ្ធដិកាដូច្នេះ **អានន្ទ** ក៏អនុញ្ញាតិអោយ **សុភទ្ទ** ចូលជួបព្រះអង្គ ។ **សុភទ្ទ** ក៏ចូលទៅថ្វាយបង្គំ **ព្រះពុទ្ធ** ទូលថ្វាយពីសំនួរដែលខ្លួនគាត់ចង់ដឹងថា: "ខ្ញុំករុណា **សុភទ្ទ** សុំទូលសួរ **ព្រះពុទ្ធ** ជាម្ចាស់ថា: **គ្រូគណៈចារ្យ** ធំទាំង ៦ នោះបានត្រាស់ដឹងតាម **បដិបញ្ញា** របស់ព្រះអង្គឬទេ?"។ **ព្រះពុទ្ធ** ជាម្ចាស់ទ្រង់ត្រាស់ដឹងថា **សុភទ្ទ** មានជំនឿផ្សេងស្ថិតនៅក្នុងផ្នត់គំនិតរបស់គាត់ ។ ព្រះអង្គទ្រង់មានពុទ្ធដិកាថា: "ការត្រាស់ដឹងរបស់ **គណៈចារ្យ** ទាំងឡាយ គឺស្ថិតនៅលើការយល់ច្បាស់ខ្លួនឯង នូវព្រះធម៌ និងការអប់រំចិត្តនូវសច្ចៈធម៌ នោះហើយក៏ដូចជាការសម្រេច **បដិបញ្ញា** របស់ **តថាគត** ដែរ!"។ ក៏ត្រាស់ប្រៀនប្រដៅដោយ **មគ្គៈ** (Maga; right path to Sanetiy) មានអង្គ ៨ យ៉ាងជាតួអង្គដ៏ប្រសើរប្រាសចាកសត្រូវអោយក្លាយជាបុគ្គលយល់ច្បាស់នូវគន្លងធម៌ ហើយចង់ក្លាយខ្លួនជា **សមណៈ** ។ **សុភទ្ទ** ក្រោយពីបានស្តាប់ដំបូន្មាននៃអង្គទាំង ៨ យ៉ាង ហើយក៏កើតចិត្តជ្រះថ្លាជឿជាក់ក្នុងផ្លូវព្រះពុទ្ធសាសនា ក៏ក្រាបបង្គំសុំបួសជាភិក្ខុ ។

www.elibraryofcambodia.org

**ព្រះពុទ្ធបរមគ្រូ** ទ្រង់ក៏អនុញ្ញាត្តិ ហើយត្រាស់អោយ **អានន្ទ** កោរសក់អោយគាត់ រួចព្រះអង្គក៏បំបួសគាត់ក្នុងពេលនោះភ្លាម អោយសមតាមបំណងរបស់គាត់។ **សុភទ្ទ** ក៏បានក្លាយជា **បច្ឆិមភិក្ខុ** ចុងក្រោយគេបង្អស់ក្នុងព្រះពុទ្ធសាសនា ដែលព្រះបរមគ្រូទ្រង់ជាអ្នកប្រោសបំបួស។ ចំណុចនេះហើយដែលក្នុងពុទ្ធប្រវត្តិបាននិទានថា **បឋមភិក្ខុ** (the first Bhikku Kaundinya) ដែលបំបួសមុនគេក្នុងព្រះពុទ្ធសាសនាគឺ ព្រះភិក្ខុ **កោណ្ឌញ្ញ** នៅព្រៃ **មិគទាយវ័ន** ជិតក្រុង **ពារាណសី** ចំណែក **បច្ឆិមភិក្ខុ** (the last Bhikku Saubbadra) ដែលបំបួសចុងក្រោយគេបង្អស់ គឺព្រះភិក្ខុ **សុភទ្ទ** នៅព្រៃ **សាលវ័ន** ជិតក្រុង **កុសិនារា**។ **សុភទ្ទភិក្ខុ** ខិតខំសិក្សាព្យាយាមប្រតិបត្តិធម៌តាមពុទ្ធឱវាទ មិនយូរប៉ុន្មានព្រះអង្គក៏បានសម្រេចជាព្រះអរហន្ត។



ព្រះអង្គ និងសុភទ្ទ ដែលជាភិក្ខុចុងក្រោយក្នុងព្រះពុទ្ធសាសនា

www.elibraryofcambodia.org

# ទិវាទី៥៥

# ទ្រង់សម្រេចបរិនិព្វាន

# (To achieve Nirvana)



ព្រះអង្គចូលបរិនិព្វាន ( ស្រង់ចេញពី វត្តទឹកថ្លា ក្រុងភ្នំពេញ ប្រទេសកម្ពុជា)

កាលវេលាចេះតែរំកិលទៅមុខ ពេលរំលងអាធ្រាតទៅហើយ **ព្រះបរមសាស្តា** នៅតែមានមហាករុណាធមិ ហើយទ្រង់ឈ្វេងយល់ថា នេះជានាទីចុងក្រោយ របស់ព្រះអង្គហើយ ទើបព្រះអង្គប្រឹងប្រែងផ្តល់ឱវាទ និងត្រាស់ដិកាប្រាប់អស់ភិក្ខុថាៈ "ម្នាលភិក្ខុទាំងឡាយដែលនៅទីនេះ! តើមានភិក្ខុអង្គណានៅមិនទាន់យល់ច្បាស់ ឬមានការសង្ស័យដោយប្រការណាមួយអំពី **ព្រះរតនៈត្រ័យ** ទៀតនោះ អ្នកអាចសាកសួរ **តថាគត** បាននៅពេលចុងក្រោយនេះ!"។ ប៉ុន្តែស្ងាត់ឈឹង មិនមានភិក្ខុអង្គណាមានសំនួរអ្វីឡើយ ព្រោះគ្រប់អង្គភាគច្រើនជា **ព្រះអរហន្ត** ទ្រង់យល់ច្បាស់ពី **ព្រះរតនៈត្រ័យ** មានៈ **ព្រះពុទ្ធរតនៈ ធម៌រតនៈ** និង **សង្ឃរតនៈ** ដោយហេតុនេះទើបគ្មានភិក្ខុអង្គណាមានសំនួរដល់ព្រះអង្គ។ ព្រះបរមគ្រូទ្រង់អស់ព្រះទ័យ លែងអាល័យរាល់អ្វីៗ ដែលទ្រង់ខំតស៊ូអស់រយៈពេល ៤៥ ឆ្នាំ បានត្រូវសម្រេចជាស្ថាពរ ហើយទ្រង់នឹងយាងចូល **បរិនិព្វាន** ដោយស្ងប់ព្រះទ័យ តែនៅនាទីចុងក្រោយបង្អស់ទ្រង់ខំត្រាស់ពុទ្ធដិកាបន្តិចទៀតថាៈ "ម្នាលភិក្ខុទាំងឡាយ! តថាគតជិតដល់ពេលវេលាហើយ នេះជាពាក្យចុងក្រោយ ចូរចាំថា សង្ខារធម៌ទាំងឡាយមិនទៀងទាត់ឡើយ តែងបែកធ្លាយទៅវិញជាធម្មតា ចូរជៀសអោយបានទូវក្តីប្រមាថផងទាំងពួង!"។

www.elibraryofcambodia.org

បន្ទាប់មកព្រះអង្គមិនមានពុទ្ធដីការអ្វីទៀតឡើយ ទ្រង់ដឹកលំព្រះទ័យក្នុងសមាធិឡើងដល់ឈានទី ៥ រួចចុះមកឈានទី ៤ វិញ ចេញពីឈានទី ៤ នេះ ខន្ធទាំង៥ (The five components) ក៏ចាកចេញផុត (លែងមានចំណងវិលវល់កើតស្លាប់ទៀតឡើយ)។ ព្រះអង្គទ្រង់ចូល **បរិនិព្វាន** លែងមានការវិលវល់កើតស្លាប់នៅលើវាលវដ្តសង្សារទាំងលោកនេះ និងលោកដទៃទៀតឡើយ នៅពេលនោះគឺថ្ងៃអង្គារ ១៥ កើត ខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក វេលាទៀបភ្លឺ ទ្រង់រលត់ខន្ធចូលកាន់ **ព្រះមហាបរិនិព្វាន** ក្នុងព្រះជន្ម ៨០ វស្សានៅក្រោមដើមព្រឹក្សាទាំងគូ ជិតរាជធានីនគរ **កុសិនារា**។ ចង្កៀងភ្លឺថ្លាត្រូវរលត់បាត់ចាប់ពីពេលនោះ ប៉ុន្តែប្រទីបនៃព្រះធម៌ដែល **ពុទ្ធោវាទ** បានបន្សល់ទុកនៅតែភ្លឺចិញ្ចាចគ្មានថ្ងៃរលត់គឺស្ថិតនៅជាអមតៈ។ **ព្រះធម៌** ជាមាគ៌ាយ៉ាងភ្លឺថ្លាហាក់បីដូចជា **ព្រះសម្មាសម្ពុទ្ធ** ព្រះអង្គគង់ប្រថាប់នៅដូច្នេះដែរ។ មានតែព្រះធម៌នេះហើយដែលលប់បំបាត់ជីវិតសោកសៅនៃកម្មលោកីយ៍ផងទាំងឡាយបាន ហើយថែមទាំងផ្តល់ជាមេរៀនល្អៗសម្រាប់ជីវិតរស់នៅ ក៏ដូចជាខ្សែជីវិត **អនត្តា** ដែលវិលវល់ឈឺ ចាស់កើតស្លាប់នាវាលវដ្តសង្សារយើងនេះ។



ព្រះអង្គទ្រង់សំរេចបាននូវព្រះនិព្វានហើយ (ស្រង់ចេញពី Internet)

www.elibraryofcambodia.org

# វគ្គទី៥៦
# ពិធីថ្វាយព្រះភ្លើង (Cremation ceremony)



ព្រះពុទ្ធបរមសពត្រូវបានគេដាក់ដឹកល់ក្នុងមឈូសមាស

កាលព្រះបរមគ្រូទ្រង់ **បរិនិព្វាន** ទៅហើយ ពេលរាត្រីស្ថិតនៅឡើយមិនទាន់ភ្លឺស្វាង ខណៈនោះ **ព្រះអនុរុទ្ធ** និង **មហាអានន្ទ** ក៏សំដែងធម៌តាមកាលដ៏សមគួរល្មម ដល់ពេលអស់បរិស័ទមកដល់គ្រប់គ្នា។ ដល់ថ្ងៃរះច្បាស់ពន្លឺ **ព្រះអនុរុទ្ធ** ក៏ចាត់ចែងអោយ **អានន្ទ** ទៅថ្វាយដំណឹង **ព្រះពុទ្ធ** បរិនិព្វានដល់ព្រះរាជានគរ **កុសិនារា**។ ព្រះមហាក្សត្រ **មល្លៈ** ទ្រង់សណ្ដាប់កាលណា ក៏កើតចិន្តាសោកសៅអស់ទាំងផៅញាតិវង្សព្រះអង្គ។ បន្ទាប់មកព្រះរាជា និងអស់មន្ត្រីព្រមទាំងព្រះញាត្តិ ក៏រៀបចំយាងទៅកាន់ព្រៃ **សាលវ័ន** ដើម្បីចាត់ចែងធ្វើពិធីសក្ការៈថ្វាយព្រះភ្លើងដល់ **ព្រះពុទ្ធសរិរៈ**។ ក្សត្រទាំង ៨ អង្គ ដែលជារាជក្សិណសាជាប្រធានកម្មវិធី បានចាត់ចែងធ្វើពិធីបុណ្យថ្វាយព្រះភ្លើង **ព្រះសរិរៈ** ទ្រង់ដំកល់ក្នុងមឈូសមាស។

ពិធីបុណ្យបានប្រព្រឹត្តទៅអស់ ៦ ថ្ងៃ ៦ យប់ ដោយមានភ្លេងប្រគំ កម្រងផ្កាក្រអូបឈ្មុយឈ្ងុបសព្វគន្ធពិដោរ។ លុះដល់ថ្ងៃទី ៧ ត្រូវរំកិលព្រះ **បរមសរិរៈ** ដង្ហែរចេញទៅទិសខាងត្បូង ដើម្បីបូជាខាងត្បូងព្រះបរមរាជវាំង ប៉ុន្តែខណៈដែលរំកិល **ព្រះសរិរៈ** មឈូសមាសមិនកំរើកសោះ ហេតុយ៉ាងនេះក្សត្រទាំង ៨ អង្គ

www.elibraryofcambodia.org

ក៏ទូលសួរទៅ **ព្រះអនុរុទ្ធ** ដែលជាអ្នកជំនាញខាងពិធីការថា: "បពិត្រព្រះមហាថេរ **អនុរុទ្ធ!** ហេតុដូចម្តេចបានជារំកិល **ព្រះបរមសរីរៈ** មិនបានដូច្នេះ? តើមានទាស់អ្វីមែនទេព្រះអង្គ?" ។ **ព្រះអនុរុទ្ធ** ទ្រង់រំពឹងគិតថាខុសពីបំណងទេវតាដែលក្បួនដង្ហែទៅទិសខាងត្បូងនោះ ទើបព្រះអង្គមានថេរដិកាថា: "ចូរគ្រប់ព្រះអង្គចាត់ចែងអោយដង្ហែ **ព្រះបរមសរីរៈ** ទៅទិសខាងជើងវិញដោយឆ្លងកាត់កណ្តាលក្រុងឆ្ពោះទៅកាន់ទិសខាងកើត ដើម្បីថ្វាយព្រះភ្លើងនៅ **មកុដពន្ធចេតិយ** របស់ព្រះរាជា **មល្លៈ** ដែលស្ថិតនៅទិសខាងកើតរាជធានី!" ។ ក្សត្រទាំង ៨ អង្គក៏ចាត់ចែងក្បួនដង្ហែប្រព្រឹត្តតាមថេរដិកា **ព្រះអនុរុទ្ធ** ។ ដល់ទីស្ថាន **មកុដពន្ធចេតិយ** ហើយក្សត្រ ៤ អង្គជាប្រមុខ ដែលជាអ្នកអោយភ្លើង បានកាន់ភ្លើងចេញមកពីទិសទាំង ៤ ដើម្បីថ្វាយព្រះភ្លើង ។ ខណៈដែលក្សត្រទាំង ៤ កំពុងថ្វាយព្រះភ្លើង ភ្លើងដុតមិនឆេះទាល់តែសោះ គ្រប់អង្គក៏សួរទៅ **ព្រះអនុរុទ្ធ** ។ **ព្រះអនុរុទ្ធ** ទ្រង់មានថេរដិកាថា: "នេះគឺទេវតាមានបំណងចង់អោយ **ព្រះមហាកស្សបត្ថេរ** ដែលទ្រង់កំពុងតែនិមន្តមកនេះ ដើម្បីទាន់ថ្វាយបង្គំព្រះសពជាមុនសិន ទើបអាចថ្វាយព្រះភ្លើងបាន ។

**រាជមល្លៈ** ទាំង ៤ អង្គ ក៏ផ្អាកថ្វាយព្រះភ្លើងសិន ដោយរង់ចាំព្រះមហា **កស្សប** មកដល់ ។ ចំណែកព្រះមហាក្សត្រ **កស្សប** ដែលនៅរដ្ឋ **ឧរុវេល** ក្រោយពីបានដំណើងថា **ព្រះពុទ្ធបរមគ្រូ** ទ្រង់ចូល **បរិនិព្វាន** ក៏នាំភិក្ខុជាបរិវារប្រាំរយអង្គចាកចេញ ហើយខំប្រឹងរូតរះនិមន្តបានមកដល់ក្រុង **ឆាទា** ព្រះអង្គបានដឹងថាពិធីបុណ្យ ៧ ថ្ងៃរបស់ព្រះបរមសពបានកន្លងផុតទៅហើយ ។ មិនយូរប៉ុន្មានព្រះមហា **កស្សប** និងភិក្ខុបរិវារ ក៏និមន្តមកដល់កន្លែងថ្វាយព្រះភ្លើង ។ព្រះមហា **កស្សប** និងអង្គជំនិត៧ បាននិមន្តប្រទក្សិណ ៣ ជុំទីថ្វាយព្រះភ្លើង ពេលនោះ

www.elibraryofcambodia.org

ស្រាប់តែមានហេតុអស្ចារ្យ ដោយព្រះបាទទាំងទ្វេរបស់ព្រះមហាបរមសព ក៏លៀនចេញមកក្រៅពីមឈូសមាស ដោយទេវានុភាពអោយ **ព្រះកស្សប** និងភិក្ខុសង្ឃជាពលថ្វាយបង្គំ។ រួចរាល់កាលណោជើងថ្កល់នោះ ក៏ស្រាប់តែមានភ្លើងឆេះឡើងបូជាព្រះបរមសព។ ក្រោយមក **ព្រះសរិរៈ** ទាំងប៉ុន្មានក៏ឆេះអស់ នៅសល់តែ **ព្រះអដ្ឋិធាតុ** ប៉ុណ្ណោះ។

ព្រះរាជា **មល្លះ** ក៏ចាត់ចែងរើសព្រះធាតុ ហើយនិមន្ត **ព្រះសារីរិក** ធាតុទៅដំកល់ទុកក្នុងវិមានមួយនាព្រះរាជវាំង **កុសិនារា** ដោយមានរាជយោធានៅការពាររក្សាយ៉ាងហ្មត់ចត់ ដើម្បីជៀសវាងមានក្សត្រនគរផ្សេងៗ ចូលមកដណ្តើមយក បន្ទាប់មកក៏មានធ្វើពិធីបុណ្យដំកល់ **ព្រះសារីរិក** ធាតុក្នុងវិមានរាជវាំងអស់រយៈពេល ៧ ថ្ងៃ។



ព្រះមហាកស្សបថ្វាយបង្គំព្រះបាទដែលលានចេញមកក្រៅមឈូស

www.elibraryofcambodia.org

# វគ្គទី៥៧

# ចែកព្រះសារីរិកធាតុ

## (To divide the Buddha's bone)



បន្ទាប់មកដំណឹងបរិនិព្វានរបស់ **ព្រះបរមសាស្តា** បានលេចឮដល់គ្រប់នគរ។ បានដឹងហើយនគរមួយចំនួនដូចជា **នគររាជគ្រឹះ** មានស្តេច **អជាតសត្តុរាជ** ស្តេច **លិច្ឆវី** ក្រុង **វេសាលី** ស្តេច **សក្យ**ក្សត្រ ក្រុង **កបិលពស្តុ** ស្តេច **ថូលិក្សត្រ** ក្រុង **អល្លកប្ប** ស្តេច **កោឡិយ** ក្សត្រ ក្រុង **រាមគ្រាម** មហាព្រាហ្មណ៍នៅដែន **វេដ្ឋទិបកៈ** និងពួកក្សត្រនៅក្រុង **បាវា** ក៏បាននាំគ្នាបញ្ជូនរាជទូតរៀងៗខ្លួន ដើម្បីសុំចែករំលែក **ព្រះសារីរិកធាតុ** ទុកជាទីសក្ការៈប្រចាំនគរតែស្តេច **មល្លៈ** មិនបានចែករំលែកអោយដោយងាយៗឡើយ ដោយព្រះអង្គសំអាងថា **ព្រះពុទ្ធ** ទ្រង់ **បរិនិព្វាន** ក្នុងទឹកដីនគរព្រះអង្គ ដូច្នេះកើតមានការជជែកវែកញែកស្ទើរតែកើតសង្គ្រាមនឹងគ្នា តែក្រោយមកមានមហាព្រាហ្មណ៍ម្នាក់ឈ្មោះ **ទោណៈ** ព្រាហ្មណ៍ដែលជាអ្នកវៃឆ្លាតជាង គេក្នុងក្រុង **កុសិនារា** បានគិតឃើញថា បើមិនរកវិធីសម្របសម្រួលទេ នឹងកើតមានសង្គ្រាមជាក់ជាមិនខាន ទើប **ទោណៈ** ព្រាហ្មណ៍ ធ្វើជាអ្នកចំណែក ហើយប្រើសម្តីផ្អែមពិរោះ មកបកស្រាយសមហេតុផលក្នុងផ្លូវសាមគ្គីបណ្តាលអោយរាជទូតគ្រប់នគរទាំងនោះស្តាប់បាន ដោយទទួលយកក្នុងចំណែកជា ៨ ផ្នែក មួយនគរមួយចំណែក។ កាលណោះស្តេច **មោរិយៈ** ក្សត្រក្រុង

www.elibraryofcambodia.org

**មិច្ឆលិវិល** បានជ្រាបដំណឹងក្រោយគេ ក៏បញ្ជូនរាជទូតមកដែរ តែគេចែកគ្នាអស់ទៅហើយ ទើបស្តេច **មល្លះ** ម្ចាស់ទីកន្លែងសម្រេចប្រគល់ **ធ្យូង** ដែលសេសសល់កន្លែងបូជាអោយទៅនគរនេះចុងក្រោយគេ។

ក្រោយពីនគរទាំង ៨ បានចំណែកព្រះសារីរិកធាតុរៀង១នគរហើយ ក៏យកទៅបញ្ចុះក្នុងស្តូបប្រចាំនគររៀង១ខ្លួន ទុកធ្វើជាទីសក្ការៈគោរពបូជាតរៀងមក។ ស្តូបដំកល់ត្រូវបានកសាងឡើងចំនួន ១០ នគរ ស្តូបដំកល់ **ព្រះសារីរិកធាតុ** មាន ៨ នគរ។ ស្តូបដំកល់ **ធ្យូង** ដែលយកពីកន្លែងបូជានៅនគរមួយ។ ស្តូបដំកល់ **ព្រះតុម្ពះ** (រង្វាល់ចំណែកពេលចែកគ្នា) នៅនគរមួយ។

(ចប់ប្រវត្តិព្រះបរមសាស្តាមហាបុរសនៃយើង)

www.elibraryofcambodia.org

សិក្សាស្វែងយល់:

# ជំពូក ៣

## វគ្គទី១

## អំពីប្រភេទចេតិយនៃព្រះបរមគ្រូនៃយើង[៣៨]

ពុទ្ធសករាជត្រូវបានចាប់រាប់ពីថ្ងៃព្រះអង្គចូល **ព្រះបរិនិព្វាន** មកទាល់សព្វថ្ងៃ មានអាយុជាង ២៥៥៤ ឆ្នាំហើយ (គិតមកពីដល់ខែមេសា ឆ្នាំ២០១០នេះ)។ ក្នុងកំឡុងពេលនគរទាំង ១០ បានទទួល **ព្រះសារីរិកធាតុ** រៀងៗខ្លួនហើយ ពុទ្ធសាសនិកជនក៏ចាប់ផ្តើមមតិកសាងចេតិយព្រះពុទ្ធអង្គឡើង ដើម្បីជានិមិត្តរូបឱ្យទិសដឹងគុណចំពោះព្រះអង្គ និងធ្វើជាកន្លែងសក្ការៈគោរពបូជា ឯចេតិយដែលបានធ្វើនោះមានលក្ខណៈ ៤ ប្រភេទ ដូចខាងក្រោមនោះ:

-**ប្រភេទទី១: ធាតុចេតិយ** ជាចេតិយដែលបានបញ្ចុះព្រះសារីរិកធាតុ។

-**ប្រភេទទី២: ចន្ទាន់ចេតិយ** ជាចេតិយសម្រាប់បញ្ចុះបាត្រ ចីវរ ធម្មក្រក និងបរិក្ខារផ្សេងៗ ឯគ្រឿងប្រើប្រាស់ដូចជាសេនាសនៈ មានគ្រែ កុដិ វិហារ គុម្ពស្តូក (របស់វាល់ចែក **សារីរិកធាតុ** ព្រះអង្គ) និងអង្គារស្តូប (ធ្យូងដែលបូជាព្រះបរមសព) ក៏បញ្ចុះក្នុងប្រភេទចេតិយនេះដែរ។

---

[៣៨] តាមសៀវភៅលោក **ខិម ណសាត្រី** បោះពុម្ពឆ្នាំ ១៩៥៤។

www.elibraryofcambodia.org

**-ប្រភេទទី៣: ធម្មចេតិយ** ជាចេតិយដែលពុទ្ធសាសនិកយើងកសាងឡើង នៅសម័យក្រោយៗមកទៀត គឺទុកឧទ្ទិសដល់ **ព្រះពុទ្ធបរមគ្រូ** ថ្លែងពីសេចក្ដីជ្រះថ្លារបស់ខ្លួនចំពោះព្រះអង្គ។ ពុទ្ធសាសនិកជនយើងបានកសាងជាសាស្ត្រាស្លឹករឹត ដែលនិទានពីរឿង **ព្រះពុទ្ធជាម្ចាស់** ហើយដែលមិនមាន **សារីរិកធាតុ** ឬសំភារៈប្រើប្រាស់របស់ព្រះអង្គ ក៏យកមាសប្រាក់ សំរិទ្ធិ ចារឆ្លាក់ជំនួស ហើយបញ្ចុះក្នុង **ធម្មចេតិយ** នេះ។

**-ប្រភេទទី៤: ឧទ្ទេសិកចេតិយ** ត្រូវបានគេកសាងឡើងក្រោយៗមកទៀត ប្រមាណជាក្នុងសតវត្សទី ៣ ក្នុងរាជ្យព្រះបាទ **អសោក** (Asoka) ព្រោះក្នុងរាជ្យព្រះអង្គ ទ្រង់បានកសាងសមិទ្ធិផលជាច្រើនសម្រាប់ព្រះពុទ្ធសាសនា។ **ឧទ្ទេសិកចេតិយ** នេះគឺបញ្ចុះរូបព្រះបដិមាករដែលធ្វើពីលោហៈធាតុមាន មាសប្រាក់ សំរិទ្ធិ ឥដ្ឋ ឈើពិសេសៗមាន ឈើខ្លឹមច័ន្ទ ក្រឹស្នាជាដើម ដែលពុទ្ធសាសនិកមានសទ្ធាជ្រះថ្លា កសាងឡើងជាតំណាងព្រះពុទ្ធរូប កាលព្រះបរមគ្រូទ្រង់គង់នៅ ដើម្បីទុកជាទីសក្ការៈគោរពបូជាតរៀងៗមក។

www.elibraryofcambodia.org

# វគ្គទី២
# អំពីការប្រព្រឹត្តព្រះធម៌វិន័យ
# (Buddhist council to discuse and verify the accuracy of the Dharma)

កាលក្រោយបន្ទាប់ពី **ព្រះពុទ្ធបរមគ្រូ** ទ្រង់ **បរិនិព្វាន** ហើយ ព្រះសង្ឃសាវ័កទាំងឡាយបានខំទ្រទ្រង់ និងផ្សព្វផ្សាយជាបន្តបន្ទាប់ពីសម័យមួយមកទល់សម័យមួយ ដោយធ្វើកិច្ច **សង្គាយនា** Buddhist monks convention (religious convention) ចងក្រងរៀបរៀងអំពីព្រះធម៌វិន័យជាហូរហែរ ដោយខ្សែកខ្ញុំព្រះករុណាខ្ញុំបាទសូមលើកយកតែ **សង្គាយនា** ធំៗទាំង **៥** គឺមានបរិយាយដូចតទៅនេះ:

១- **បឋមសង្គាយនា:** (First review of a text)

ក្រោយ **ព្រះពុទ្ធបរមគ្រូ** ទ្រង់ **បរិនិព្វាន** បានជាង ៣ ខែ ព្រះមហា**កស្សបត្ថេរ** ដែលព្រះអង្គទ្រង់ជំនាញខាងកិច្ចកែសម្រួល និងត្រួតពិនិត្យ បានប្រមូលសំណុំរឿងទាំងឡាយបានធ្វើ **បឋមសង្គាយនា** ជាមួយភិក្ខុសង្ឃចំនួន**៥០០** អង្គ នៅក្រុង **រាជគ្រឹះ** ដែលមានស្តេច **អជាតសត្រូវ** ជារាជឧបត្ថម្ភ។ **កិច្ចសង្គាយនា** ជាលើកដំបូងនេះត្រូវបានលើកឡើងនូវរឿងភិក្ខុ **សុភទ្ទ** មកចោទសួរ និងដោះស្រាយលើកិច្ចប្រតិបត្តិធម៌វិន័យ មានក្តីពាក់ព័ន្ធជាច្រើន មានរយៈពេល ៧ ខែទើបសម្រេច។

www.elibraryofcambodia.org

២- **ទុតិយសង្គាយនា:** (Second review of a text of the Buddhist Scripture)

ក្រោយ **ព្រះពុទ្ធបរមគ្រូ** ទ្រង់បរិនិព្វានជាង ១០០ ឆ្នាំ ព្រះមហា **យសកាកណ្ឌបុត្រ** ជាមហាថេរដែលសង្វាតស្រាវជ្រាវធម៌វិន័យ បានប្រមូលសំណុំរឿងទាំងឡាយ ហើយធ្វើ **ទុតិយសង្គាយនា** ជាមួយភិក្ខុសង្ឃ **៧00** អង្គ នៅ **វាលុការាម** ក្រុង **វេសាលី** ដែលមានស្ដេច **កាលាសោក** ជារាជឧបត្ថម្ភ។ កិច្ចសង្គាយនាលើកទី ២ នេះ ត្រូវបានលើកឡើងពីហេតុផលរឿងភិក្ខុ **វជ្ជីបុត្ត** ដែលមាន ១០ ប្រការ បានធ្វើធម៌វិន័យយកមកចោទសួរ និងដោះស្រាយ មានរយៈពេល ៨ ខែទើបសម្រាប់។

៣- **តតិយសង្គាយនា:** (Third review of a text of the Buddhist Scripture)

ក្រោយ **ព្រះពុទ្ធបរមគ្រូ** ទ្រង់បរិនិព្វានជាង ២៣៤ ឆ្នាំ ព្រះមហា **មោគ្គលីបុត្តតិស្ស** ជាមហាថេរដែលសង្វាតយកព្រះទ័យទុកដាក់ស្រាវជ្រាវធម៌វិន័យ បានប្រមូលសំណុំរឿងទាំងឡាយហើយធ្វើ **តតិយសង្គាយនា** ជាមួយភិក្ខុសង្ឃ **១000** អង្គ នៅ **អសោការាម** ក្រុង **បាតលី** ដែលមានស្ដេច **អសោករាជ** ជារាជឧបត្ថម្ភ។ កិច្ចសង្គាយនាលើកទី ៣ នេះ ត្រូវបានលើកឡើងពីហេតុផលរឿងភិក្ខុ **តិរ្ថិយ៍បួម** បានចូលបួសក្នុងមជ្ឈមណ្ឌលសង្ឃ ហើយបានប្រព្រឹត្តក្នុងធម៌វិន័យ យកមកដោះស្រាយបន្ថែមក្រិត្យវិន័យ មានរយៈពេល ៩ ខែ ទើបសម្រេច។

www.elibraryofcambodia.org

៤- **ចតុត្ថសង្គាយនា:** Fourth review of a text of the Buddhist Scripture

តំណតមកក្រោយ **ព្រះពុទ្ធបរមគ្រូ** ទ្រង់បរិនិព្វានជាង ២៣៦ ឆ្នាំ ព្រះមហា **មហិន្ទ** ជាមហាត្ថេរដែលខំប្រឹងស្រាវជ្រាវធម៌វិន័យ ក៏បានបន្ត ២ ឆ្នាំទៀត បានប្រមូលសំណុំរឿងឡើងវិញ ហើយធ្វើ **ចតុសង្គាយនា** ជាមួយភិក្ខុសង្ឃ ៨000អង្គ នៅ **ថូបារាម** ក្រុង **អនុរាធបុរី** ដែនដី **លង្កាទ្វីប** ដែលមានស្តេច **ទេវានម្បិយតិស្ស:** ជារាជឧបត្ថម្ភ។ កិច្ចសង្គាយនាលើកទី ៤ នេះ ត្រូវបានលើកឡើងពីហេតុផលដែលកសាងប្រតិស្ឋានព្រះពុទ្ធសាសនា ក្នុងទឹកដី **លង្កាទ្វីប** ទៅដល់ដែនដីនគរផ្សេងៗទៀត ឯក្រិត្យធម្មវិន័យត្រូវបកស្រាយ និងចោទសួរ ធ្វើការកែទម្រង់អោយកាន់តែមានភាពសុក្រិត្តទ្វេឡើង ដោយចំណាយអស់រយៈពេល ១០ ខែទើបសម្រេច។

៥- **បញ្ចមសង្គាយនា:** Fifth review of a text of the Buddhist Scripture

បន្ទាប់ពីនោះក្រោយ **ព្រះពុទ្ធបរមគ្រូ** ទ្រង់បរិនិព្វានជាង ៤៥0 ឆ្នាំ ព្រះមហា **ព្រះពុទ្ធទត្ត** ជាព្រះមហាត្ថេរ ដែលសង្វាតព្យាយាមរឿងធម៌វិន័យ ព្រះអង្គខំសិក្សាកែលំអក្រិត្យវិន័យ ដើម្បីអោយកាន់តែពិសិដ្ឋក្នុងកិច្ចប្រតិបត្តិ ព្រះអង្គបានប្រមូលសំណុំរឿងទាំងឡាយ ហើយធ្វើ **បញ្ចមសង្គាយនា** ជាមួយភិក្ខុសង្ឃ **១000** អង្គនៅ **អាលោកលេណស្ថាន** ក្រុង **មះលំយ** ក្នុងទឹកដី **លង្កាទ្វីប** ដោយមានស្តេច **វដ្តគាមណីអភយះ** ជារាជឧបត្ថម្ភ។កិច្ចសង្គាយនាលើកទី ៥ នេះ ត្រូវបានលើកឡើងពីហេតុផលថា កុលបុត្រត្រូវតាំងសតិបញ្ញាអោយនឹងនរ លះបង់មន្ទិល ទទ្រង់ព្រះធម្មវិន័យ ក្នុងក្តីសង្ឃឹមតែមួយក្នុង

www.elibraryofcambodia.org

ពុទ្ធសាសនា **ព្រះពុទ្ធឧត្តមគ្គោ** ទ្រង់កាត់បន្ថយក្រិត្យខ្លះ តែបង្កើនភាពល្អច្រើនទៀត ដើម្បីអោយកុលបុត្រត្រូវទទួលយកបាន និងសង្វាតប្រតិបត្តិព្រះធម៌ ដែលជាទីពឹងពាក់ស្នាក់អាស្រ័យ ។ សង្គាយនានេះត្រូវបានចំណាយអស់កាលវេលារយៈពេលមួយឆ្នាំ ទើបបានចប់សម្រាប់ជាស្ថាពរ ។

www.elibraryofcambodia.org

# វគ្គទី៣

# ព្រះធម៌ជាទស្សនៈវិជ្ជា?

# (Is Dharma a Philosophy?)

ដូចដែលព្រះតេជគុណ ព្រះថេរាព្រះថេរៈ អស់លោកអ្នកអាន បានជ្រាបរួចហើយ នៅសម័យពុទ្ធកាល ដែលព្រះបរមគ្រូទ្រង់គង់នៅ **ព្រះធម៌** ដែលព្រះអង្គសម្តែងប្រោសបុគ្គលទាំងឡាយ ( មនុស្សសត្វ) កាលនោះមិនទាន់មានចារឹកអក្សរអ្វីឡើយ ។ លុះក្រោយព្រះអង្គ **បរិនិព្វាន** ច្រើនរយឆ្នាំមក ទើបមានព្រះសង្ឃសាវ័កទាំងឡាយបានធ្វើ **សង្គាយនា** ចងក្រងជាពុទ្ធវចនៈឡើងជាបន្តបន្ទាប់ពីតំណមួយទល់តំណមួយរហូតដល់សព្វថ្ងៃ ។ រីឯកំណើតពុទ្ធវចនៈដែលមានជាលាយលក្ខណ៍អក្សរបាន ហើយធ្វើឡើងនៅកោះ **សិរីលង្កា** ដែលមានកិច្ចសង្គាយនាយ៉ាងធំបញ្ចប់នៅទីនោះ ប៉ុន្តែក៏សុំជម្រាបដែរថា រាល់ការចងក្រងនៃពុទ្ធវចនៈទាំងនោះ ដែលយើងហៅថា **ឧត្តមសង្គីតិ** ច្រើនជាបាលី (Bali) តែក្រោយមកក៏បានបកប្រែជាខេមរៈភាសានៅឆ្នាំ ១៩២៩ ។ ចំណែកឯ **ថេរវាទ** ដែលជាវិន័យសិក្ខា គឺមាននៅក្នុងគម្ពីរ **ព្រះត្រៃបិតក** ។

ចំពោះ **ថេរវាទ** នេះបើតាមឯកសារប្រវត្តិសាស្ត្រខ្មែរ ថាបានចូលនគរខ្មែរតាំងពីសម័យនគរភ្នំក្នុងគ.ស. ៥០៣ ព.ស. ១០៤៦ ។ ឯកសារទាំងនោះគឺស្ថិតនៅ **វ៉ូកាញ់** ខេត្ត **ញ៉ាត្រាង** ដីកម្ពុជាក្រោមសព្វថ្ងៃ ។ ក្នុងរាជស្តេច **កៅណ្ឌិន្យជ័យវរ្ម័ន** ព្រះអង្គបានបញ្ជូនព្រះភិក្ខុខ្មែរពីរអង្គព្រះនាម **សង្ឃបាល** និង **មន្ទ្រសេន** ដែលមានជំនាញខាងគម្ពីរ **ត្រៃបិតក** និងចេះភាសាបរទេសផង អោយ

www.elibraryofcambodia.org

ទៅប្រែគម្ពីរនៅនគរចិន តាមការអញ្ជើញរបស់ស្តេចចិនព្រះនាម **ឡូ** ( ក្នុងរាជវង្ស លាង) ការប្រែមានរយៈពេល ១៦ ឆ្នាំទើបចប់។ ព្រះនាមមហាថេរខ្មែរបាន សរសេរទុកក្នុងគម្ពីរ **ព្រះត្រៃបិតក** ចិនទល់សព្វថ្ងៃ។

នៅឆ្នាំ ១៩៥៦ អធិបតីសមាគមចិនបានប្រគល់ច្បាប់ចម្លងនៃគម្ពីរនោះដល់ ព្រះបាទ **សីហនុ** ព្រះប្រមុខរដ្ឋខ្មែរ ទុកជាចំណងមេត្រីភាពខ្មែរ-ចិន គិតទល់ ឥឡូវឆ្នាំ ២០១០ ច្បាប់ចម្លងនេះមានរយៈអាយុ ៥៤ ឆ្នាំហើយ។ នៅសម័យមាន អ្នកប្រាជ្ញកើត ពួកគេបានធ្វើការវិភាគដោយទស្សនៈរៀង១ខ្លួនថា: "ព្រះធម៌ដែល នៅក្នុងពុទ្ធសាសនានោះ គឺជាទស្សនៈវិជ្ជា" ដែលបង្រៀនអប់រំផ្លូវចិត្ត ដើម្បី ស្រោចស្រង់អោយរួចពីទង្វើខុសឆ្គងទាំងឡាយ មានជាអាទិ៍គឺអំពើបាប និងអំពើ ប្រាសចាកពីសីលធម៌ទាំងឡាយ ថែមពីនេះទៅទៀត ព្រះធម៌គឺសំដៅសេចក្តីទុក្ខ បានបង្ហាញពីទស្សនៈ នៃអ្នកប្រាជ្ញមួយចំនួនដូចខាងក្រោមនេះ:

- អ្នកប្រាជ្ញលោក Sochopenhauer បានអោយទស្សនៈថា"**សេចក្តីទុក្ខ ជាសច្ចៈធម៌**" (Suffering is Truth) ហើយគំនិតនេះ បានក្លាយជាទស្សនៈវិជ្ជា នាបស្ចិមប្រទេសទាល់សព្វថ្ងៃ។

- លោក Spinoza បានមានទស្សនៈថា សភាវធម៌នេះ មិនទាន់ប្រាកដ និយមនៅឡើយ ព្រោះថាវាអាចប្រែប្រួលតាមធម្មជាតិបាន មានន័យថា ទស្សនៈ អ្នកប្រាជ្ញ Spinoze ចង់បង្ហាញថា: "**សេចក្តីទុក្ខ** នេះ មនុស្សអាចយកឈ្នះបាន បើរកឃើញវិជ្ជាជាធម៌នៅស្ថិតស្ថេរចេរកាលបាននោះ"។

- លោក Berkley មានទស្សនៈថា "អ្វីដែលជាគ្រាប់បែកញែកពុំបាននេះ គ្រាន់តែជាការប្រឌិតទុកខាង **បរមត្ថវិជ្ជា** (Metaphysics) ប៉ុណ្ណោះ"។

www.elibraryofcambodia.org

- លោកសាស្ត្រាចារ្យ Hume បែរជានិយាយថា ក្រោយការរំកែញែកផ្លូវចិត្ត មានតែវិញ្ញាណទេ ដែលអាចហូរចូលក្នុងផ្លូវចិត្តបាន (Only soul able to enter into the heart) ។

- លោក Bergson មានទស្សនៈថា "**សភាវធម៌នេះជាច្បាប់នៃការប្រែប្រួល**" ។

- លោកសាស្ត្រាចារ្យ James គូសបញ្ជាក់ថា "សេចក្ដីទុក្ខដែលមានក្នុងព្រះធម៌សម្ដែងនេះអាចអោយយើងយល់ថា គឺជាចំណុចស្ថិតក្នុងចិត្ត បើចិត្តចង់បំបាត់ ឬយកឈ្នះអាចធ្វើបានដោយងាយ តែបើចុះចាញ់នោះនឹងកើតសេចក្ដីទុក្ខ" ។

ទស្សនៈនៃក្រុមអ្នកប្រាជ្ញទាំងនេះ **ព្រះពុទ្ធបរមគ្រូ** ទ្រង់បាន **ទេសនា** ប្រោសសត្វលោកប្រមាណជាង ២៥៤៧ ដង រួចមកហើយនៅតាមដងគង្គាស្ថាននាទីកដីឥណ្ឌា ដោយព្រះអង្គតែងបានទេសនាប្រាប់ថានេះជា:

**អនិច្ចំ** (perishable) **ទុក្ខំ** (Suffering) **អនត្តា** (non-self Souless)

នៅលើវាលវដ្តសង្សារ ជីវិតជួបទុក្ខ សេចក្ដីសុខមិនទៀង ខ្លួនមិនមានវិញ្ញាណហើយៈ

- **អនិច្ចធម៌:** ធម៌ប្រែប្រួលតែមួយភ្លែត
- **ទុក្ខធម៌:** ធម៌ដែលទ្រាំនូវក្ដីលំបាក
- **អនត្តាធម៌:** ធម៌ដែលមិនមែនជារបស់ខ្លួន

ដូច្នេះទើប **ព្រះពុទ្ធបរមគ្រូ** ទ្រង់សម្ដែងធម៌ណា ដែលដឹកនាំសត្វលោកទៅកាន់ទីបំផុតទុក្ខគឺ **អមតមហានិព្វាន** ប៉ុណ្ណោះ ។ យោងតាមអត្ថបទខាងលើព្រះបរមគ្រូ ទ្រង់ពន្យល់ប្រៀនប្រដៅក្នុងន័យពីរៈ

www.elibraryofcambodia.org

**១- ធម៌ជាផ្លូវត្រូវប្រតិបត្តិ**

**២- ធម៌មិនមែនជាផ្លូវត្រូវប្រតិបត្តិ**

ព្រះធម៌ដែល **ព្រះពុទ្ធ** ទ្រង់សម្តែងប្រៀនប្រដៅសត្វលោកទាំងឡាយ មិនមែនជាធម៌ដែលនាំអោយភ័យខ្លាច និងមិនមែនជាទ្រឹស្តីទស្សនៈវិជ្ជាបែបថ្មីអ្វីឡើយ ព្រះអង្គគ្រាន់តែសម្តែងបង្ហាញពីអ្វីដែលជាសភាវពិត បានជួបហើយត្រូវបាត់បង់ទៅវិញ ឧទាហរណ៍ៈ ដូចជា **សង្ខារធម៌** ដែលទ្រង់ត្រាស់ចុងក្រោយពេលព្រះអង្គជិតចូល **បរិនិព្វាន** (សង្ខារមិនទៀងតែងបែកធ្លាយទៅវិញជាធម្មតា) ជាការពិតវាជាសភាវៈ ដែលធម្មជាតិបានពាក់តែងរូបកាយរបស់មនុស្សអោយមានជីវិតរស់នៅ តែពេលក្រោយក៏ត្រូវចាកចេញទៅវិញគឺ **សេចក្តីស្លាប់** ។ដូច្នេះទើបព្រះអង្គចង់អោយមនុស្សសត្វទាំងឡាយ មានសេចក្តីល្អក្នុងខ្លួន **ចិត្តព្យាបាទ មិនត្រូវមានខ្មៅ ចិត្តករុណាការពារត្រូវមានជានិច្ច** (Have no malice in mind but have to mind defence) ។ ពុទ្ធឱវាទពេលដែលព្រះអង្គនៅមានជីវិតរស់នៅ ព្រះអង្គមិនចង់អោយមនុស្សសត្វផុងខ្លួន លង់ក្នុងក្តីមិនល្អដែលនាំអោយជីវិតជួបការហ្មងសៅ ឬសំណល់កម្មផល បន្សល់នូវការក្រៀមក្រំវាយដំផ្លូវចិត្ត សម្រាប់រូបកាយផ្ទាល់ខ្លួន ឬរូបបុគ្គលដទៃអោយនៅតែអាឡោះអាល័យ ឬចងរាល់អនុស្សាវរីយ៍ទាំងឡាយប្រៀបដូចរឿងមួយនៅក្នុងគម្ពីរ**សុត្តន្តបិដក** ស្តីអំពីបុគ្គល **អង្គុលីមារ** (វគ្គទី ៣៨) ជាឃាតកយ៉ាងសាហាវ កាប់សម្លាប់ជីវិតអស់រាប់រយនាក់ (៩៩៩ នាក់) នៅសល់តែមួយ ត្រូវគ្រប់មួយពាន់ **អង្គុលីមារ** មកជួបម្តាយបង្កើត ពេលខ្លួនកំពុងទោសោ មោហោ **អង្គុលីមារ** បុគ្គលមិនយល់ អ្វីជាអ្នកមានគុណឡើយ កាលនោះ **អង្គុលីមារ** បានជួប **ព្រះសម្មាសម្ពុទ្ធ** ព្រះបរមគ្រូទ្រង់សម្តែងធម៌ប្រោសគាត់ ដោយទូន្មាននូវធម៌

www.elibraryofcambodia.org

ពន្យារបន្ទូវអំពើហិង្សា ចេញអស់ពីខ្លួន **អង្គុលីមារ** យល់កំហុសខុសឆ្គងឥតពហេនាពីមុន ក្រោយពីស្ដាប់ព្រះធម៌គាត់បានជ្រួតជ្រាប ហើយប្ដេជ្ញាចិត្តបួសជាភិក្ខុជ្រកកោនក្រោមម្លប់ព្រះពុទ្ធសាសនា រៀនសូត្រ និងប្រតិបត្តិធម៌គ្រប់យ៉ាងរហូតបានក្លាយជា **ព្រះអរហន្ត** នៅគ្រាក្រោយមក ។

លើសពីនេះទៅទៀត ព្រះធម៌ដែល **ព្រះពុទ្ធបរមគ្រូ** ទ្រង់ប្រៀនប្រដៅដល់សព្វសត្វលោកនោះ មានចំណុចជាលក្ខណៈសភាវៈប្រជាធិបតេយ្យ សេរីភាព និងសេចក្ដីព្យាយាម ។ ព្រះអង្គបានបើកសិទ្ធិអោយពុទ្ធសាសនិករបស់ព្រះអង្គមានសិទ្ធិក្នុងការពិចារណាតាមហេតុផលលើជំនឿរបស់ខ្លួន មិនបណ្ដោយអោយមានជំនឿបែបមិនសមហេតុផលនោះឡើយ ។ **បែបប្រជាធិបតេយ្យ** ព្រះអង្គបានផ្សព្វផ្សាយគ្រប់គណៈនិកាយសាសនាផ្សេងៗ អោយចង **សម្ព័ន្ធភាព** គ្នានិងគ្នា ជៀសវៀងការប្រកាន់ដោយទស្សនៈផ្សេងៗ ឬសាសនាបែបនេះបែបនោះទេ ។ ព្រះបរមគ្រូព្យាយាមបង្កើតកម្លាំងចិត្ត អោយប្រសព្វមុខក្នុងសន្តិភាព ជៀសវាងការបង្កសង្គ្រាម រក្សាផ្គត់ចិត្តគំនិតអោយស្របគ្នា មានភាពស្មើគ្នា ជាសាមគ្គីភាព **ផ្នែកសេចក្ដីព្យាយាមៈ** ព្រះអង្គបានទូន្មានប្រៀនប្រដៅអស់បុគ្គល អោយរក្សាសេចក្ដីព្យាយាមរាល់បញ្ហាចំពោះមុខ ដែលជាឧបសគ្គផងទាំងឡាយ មិនយូរមិនឆាប់សេចក្ដីព្យាយាមនោះ នឹងឈានដល់ក្ដីសម្រាប់ និងមានជោគជ័យ ។ ពិសេសឱវាទប្រពៃៗដូចតួយ៉ាង **សីល៥** ប្រកាន់សេចក្ដីល្អៗគ្រប់ផ្លូវ **ព្រហ្មវិហារធម៌ ៤ ប្រការ** ប្រកាន់នូវក្ដីមេត្តា ចំណែក **ទសពិធរាជធម៌** សំដៅអោយ **អ្នកគ្រប់គ្រង**ប្រទេសជាតិ ស្រឡាញ់ជាតិប្រជាដោយស្មោះត្រង់ ទាំងអស់នេះសុទ្ធតែជា **ទ្រឹស្ដី**នៃ **គុណធម៌** ដ៏ល្អបវរមហាប្រសើរសម្រាប់ផ្លូវដើរនៃជីវិតយើងគ្រប់ៗគ្នា ។

www.elibraryofcambodia.org

ព្រះអង្គសម្ដែង **ព្រះធម្មទេសនា** ស្រោយស្រង់សេចក្ដីទន់ខ្សោយទាំងឡាយ អោយមានភាពរឹងមាំក្លាហានចេះលះបង់ និងចេះធ្វើអ្វីៗដើម្បីខ្លួនឯងដោយមិនពឹងលើអ្នកដទៃ ប៉ុន្តែគំនិតជាទានស្ថិតនៅជានិរន្តរ៍ ព្រោះថាចិត្តជាទានជាគ្រឿងដ៏ក្រអូបសាយ ភ្លឺឆ្វាយដូចកាំរស្មី គ្មានអ្វីហួងសៅនៅពេលដែលយើងបានសម្រាប់ធ្វើបុណ្យទានជាកុសល ទទួលអនិសង្សដ៏ប្រពៃថ្លៃថ្លាសម្រាប់ជីវិតយើងគ្រប់ៗរូប ។



មហាចេតិយ៍នៅភ្នំ Sanchi នៅរដ្ឋ Madhya Pradesh, India

www.elibraryofcambodia.org




www.elibraryofcambodia.org

# ជីវប្រវត្តិសង្ខេប
# អ្នកនិពន្ធ ប៊ុន ណារ័ត្ន

លោក **ប៊ុន ណារ័ត្ន** កើតថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៥២ នៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ប្រទេសកម្ពុជា។ កិរិតវប្បធម៌ៈ បានបញ្ចប់ការសិក្សាមធ្យមសិក្សាភាគទី ២ នៅឆ្នាំ១៩៧២ នៅវិទ្យាល័យទួលស្វាយព្រៃ ក្រុងភ្នំពេញ ប្រទេសកម្ពុជា។

ឆ្នាំ ១៩៧២ ដល់ ១៩៧៥ ធ្វើជាអ្នកនិពន្ធកាសែត និងអ្នកគូរគំនូរថ្លុក (cartoon)

ឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ធ្វើស្រែ

ឆ្នាំ ១៩៧៩ ដល់ ១៩៨១ រត់ពន្ធ។

ឆ្នាំ ១៩៨១ ដល់ ១៩៨៤ ធ្វើជាគ្រូបង្រៀនភាសាអង់គ្លេស

ឆ្នាំ ១៩៨៤ ដល់ ១៩៩៥ ធ្វើជាអ្នកត្រួតពិនិត្យទំនិញ នៅកំពង់ផែក្រុងភ្នំពេញ (cargo supervisor)

ឆ្នាំ ១៩៩៥ ធ្វើជាងផាត់ពណ៌នៅវត្ត Stockton,Califonia សហរដ្ឋអាមេរិក

ឆ្នាំ ១៩៩៦ ចូលរួមការងារសមាគមខ្មែរ ព្រះពុទ្ធសាសនា នៅតំបន់នូអ៊ីងគ្លិន (New England) ជាអ្នកនិពន្ធកាសែតពោធិព្រឹក្ស ប្រចាំទំព័រសិក្សាស្រាវជ្រាវ ឆ្នាំ ២០០០ ដល់ ២០១០នេះ។

www.elibraryofcambodia.org

# ស្នាដៃនិពន្ធ

| | | |
|---|---|---|
| ១. រឿង ជនអាវ៉ាសែ | ប្រលោមលោក | ឆ្នាំ ១៩៧៣ |
| ២. ត្រីយអាថិអាកំបាំង | ប្រលោមលោក | ឆ្នាំ ១៩៧៣ |
| ៣. ទឹកដីនៃភ្លើងសង្គ្រាម | ប្រលោមលោក | ឆ្នាំ ១៩៧៣ |
| ៤. អ្នកប្រដល់១៣ស្រុក | ភាពយន្ត | ឆ្នាំ ១៩៧៤ |
| ៥. ឈាមវង្វេងផ្ទៃ | ភាពយន្ត | ឆ្នាំ ១៩៨៦ |
| ៦. ព្យុះចិត្តភក្តីស្រីកូនក្លោះ | ភាពយន្ត | ឆ្នាំ ១៩៨៦ |
| ៧. រលកដួងចិត្ត | ភាពយន្ត | ឆ្នាំ ១៩៨៦ |
| ៨. បេះដូងសំងាត់ | ប្រលោមលោករូបភាពភាគ | ឆ្នាំ ១៩៨៩ |
| ៩. ផាត់សមុទ្រ | ប្រលោមលោករូបភាព | ឆ្នាំ ១៩៨៩ |
| ១០. ព្រះម៉ែមានគុណ | ប្រលោមលោក | ឆ្នាំ ២០០០ |
| ១១. ក្រឡាហោមគង់ | ប្រលោមលោក | ឆ្នាំ ២០០១ |
| ១២. បាយ័នទូញយំ | ប្រលោមលោក | ឆ្នាំ ២០០១ |
| ១៣. ទស្សនះវិជ្ជា | ឯកសារ | ឆ្នាំ ២០០២ |
| ១៤. ដែនដីកលិយុគទ្រឿងមិុញយ៉ាង | ប្រលោមលោក | ឆ្នាំ ២០០២ |
| ១៥. ស្វែងយល់ប្រវត្តិសាស្ត្រខ្មែរ | ឯកសារ | ឆ្នាំ ២០០៣ |
| ១៦. បិសាចខ្លាចខ្មោច | ភាពយន្ត | ឆ្នាំ ២០០៥ |
| ១៧. អ្នកលេងស្នងតាន់ | ភាពយន្ត | ឆ្នាំ ២០០៥ |
| ១៨. តាស្បង់ | ភាពយន្ត | ឆ្នាំ ២០០៥ |
| ១៩. សមុទ្រស្ងប់ | ភាពយន្ត | ឆ្នាំ ២០០៥ |

www.elibraryofcambodia.org

| | | |
|---|---|---|
| ២០. ផ្ការីកខុសរដូវ | ភាពយន្ត | ឆ្នាំ ២០០៥ |
| ២១. ក្រីមចូលក្រុងកុងនាយកុយ | ភាពយន្ត | ឆ្នាំ ២០០៥ |
| ២២. ដាវសិល៍សិស្សតសី | ប្រលោមលោករូបភាពភាគ | ឆ្នាំ ២០០៥ |
| ២៣. មហាបុរសខ្មែរ | ប្រលោមលោក | ឆ្នាំ ២០០៥ |
| ២៤. បុប្ផាស្នេហ៍ធីតាបិសាច | ប្រលោមលោករូបភាពភាគ | ឆ្នាំ ២០០៥ |
| ២៥. ចៅវង្សាឧបុលវាណ្ណាទេវី | ប្រលោមលោករូបភាពភាគ | ឆ្នាំ ២០០៥ |
| ២៦. ម្ចាស់វិមានលោហិត | ប្រលោមលោករូបភាពភាគ | ឆ្នាំ ២០០៦ |
| ២៧. បុប្ផាអាថ៌កំបាំង | ប្រលោមលោករូបភាពភាគ | ឆ្នាំ ២០០៦ |
| **២៨. ព្រះសាស្តា** | **ឯកសារ** | **ឆ្នាំ ២០០៧** |
| ២៩. វប្បធម៌ ( អរិយធម៌ជនជាតិខ្មែរ ) | ឯកសារ | ឆ្នាំ ២០០៩ |



www.elibraryofcambodia.org

យើងខ្ញុំជាកូន ជ្រា ស៊ីផាត និង ជ្រា សុនដាវី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ លោកឪពុក ជា គ្រី និង អ្នកម្តាយ កៅ ប៊ុក

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ គីម វាសនា

កក្កដា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ចៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org



ថ្ងៃដែលព្រះអង្គទ្រង់យាងចូលព្រះបរិនិព្វាន ក្នុងព្រះជន្ម ៨០ ព្រះវស្សា ចង្កៀងភ្លឺថ្លា ត្រូវបានរលត់បាត់នៅពេលនោះ តែប្រទីបនៃព្រះធម៌របស់ព្រះអង្គនៅតែបន្សល់ទុកពន្លឺចិញ្ចាច គ្មានថ្ងៃរលត់ គឺស្ថិតនៅជាអមតៈ ។

$ 3,30


**គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ**

អាស័យដ្ឋាន : ផ្ទះលេខ ១៤៣E₀ ផ្លូវខេមរភូមិន្ទ (St. 130) ភ្នំពេញ

9789995021368


www.elibraryofcambodia.org